

នៅពេលដែលពិភពលោកកំពុងតែជាប់រវល់ខ្លាំងនៅក្នុងដំណាក់កាលចុងក្រោយនៃសង្គ្រាមត្រជាក់ កម្ពុជាកំពុងតែស្វែងរកមាគ៌ាសេដ្ឋកិច្ចផ្ទាល់ខ្លួនមួយដើម្បីស្តារជីវភាពប្រជាជនឡើងវិញក្រោយពេលប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនបានដួលរលំក្នុងរបបខ្មែរក្រហម។

នៅក្នុងសៀវភៅនេះ បណ្ឌិត ហង់ជួន ណារ៉ុន បានបង្ហាញកំណែទម្រង់គោលនយោបាយក្នុង និងក្រៅប្រទេសរបស់រដ្ឋាភិបាលដែលមានគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងនោះសកម្មភាពសំខាន់ៗផ្តល់អាទិភាពលើផ្នែកវិនិយោគខាងវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការអភិវឌ្ឍធនធានមនុស្ស។

ISBN: 978 99243 40 20 1

បណ្ឌិត ហង់ជួន ណារ៉ុន

គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស
នៃប្រទេសកម្ពុជា នាសម័យទំនើប

# គោលនយោបាយទំនាក់ទំនង
# សេដ្ឋកិច្ចក្រៅប្រទេស
# នៃប្រទេសកម្ពុជា នាសម័យទំនើប

## នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា
## (ទសវត្សរ៍ឆ្នាំ១៩៨០)



## ដោយ បណ្ឌិត ហង់ជួន ណារ៉ុន

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
Sipar
២០១៧

រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការSipar

© ហង់ជួន ណារ៉ុន

រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅកម្ពុជាដោយរោងពុម្ព អេស អេច

# គោលនយោបាយទំនាក់ទំនង
# សេដ្ឋកិច្ចក្រៅប្រទេស
# នៃប្រទេសកម្ពុជា នាសម័យទំនើប

## នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា
## (ទសវត្សរ៍ឆ្នាំ១៩៨០)

ដោយ បណ្ឌិត **ហង់ជួន ណារ៉ុន**

២០១៧

# មាតិកា

សេចក្តីផ្តើម ........................................................................ ៧

## ជំពូក ១
## លក្ខខណ្ឌចម្បង និងកត្តាជាមូលដ្ឋាន នៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា

**១.១ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងស្ថានភាពរបស់កម្ពុជា ក្នុងបរិបទនៃការបែងចែកពលកម្មអន្តរជាតិ** ...................................... ៩

១.១.១ ស្ថានភាពទូទៅ និងការប្រៀបធៀប រចនាសម្ព័ន្ធសេដ្ឋកិច្ច........................................................... ៩

១.១.២ ស្ថានភាពវិស័យកសិកម្មឆ្នាំ ១៩៨០ ដល់ ១៩៨៩..... ១៣

១.១.២.១ ដំណាំស្រូវ........................................... ១៤

១.១.២.២ ដំណាំកៅស៊ូ........................................ ១៨

១.១.៣ ការប្រើប្រាស់កម្លាំងអូសទាញក្នុងវិស័យកសិកម្ម...... ២១

១.១.៣.១ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម............... ២១

១.១.៣.២ ការប្រើប្រាស់សត្វពាហនៈ ......................... ២២

១.១.៤ ការប្រើប្រាស់ធនធានដីធ្លី........................................ ២៣

១.១.៥ វិស័យឧស្សាហកម្ម................................................ ២៩

១.១.៥.១ ឧស្សាហកម្មអគ្គិសនី ............................. ៣១

១.១.៥.២ ឧស្សាហកម្មគីមី..................................... ៣៤

១.១.៥.៣ ឧស្សាហកម្មចំណីអាហារ......................... ៣៥

១.១.៥.៤ រោងចក្រវាយនភណ្ឌ .............................. ៣៥

១.១.៥.៥ ឧស្សាហកម្មសំណង់.............................. ៣៦

១.១.៥.៦ រោងចក្រឧស្សាហកម្មផ្សេងៗទៀត ............ ៣៦

១.១.៦ វិស័យពាណិជ្ជកម្មក្រៅប្រទេស ..................................... ៣៨
១.១.៦.១ ស្ថានភាពជញ្ជីងពាណិជ្ជកម្មអន្តរជាតិ........ ៣៩
១.១.៦.២ ការនាំចេញ ..................................... ៤០
១.១.៦.៣ ការនាំចូល ..................................... ៤៤
១.១.៧ សន្និដ្ឋាន ..................................... ៤៧

**១.២ របនាសម្ព័ន្ធនៃសេដ្ឋកិច្ច-សង្គមរបស់ប្រទេសកម្ពុជា ................. ៤៨**
១.២.១ ការសិក្សាលើទ្រឹស្តីជាមូលដ្ឋានជុំវិញសណ្ឋាន
នៃសេដ្ឋកិច្ច-សង្គម..................................... ៤៨
១.២.២ លក្ខណៈពិសេសនៃសណ្ឋានសេដ្ឋកិច្ចកម្ពុជា
និងបទពិសោធន៍ចុងទសវត្សរ៍ឆ្នាំ១៩៨០..................................... ៥៨
១.២.៣ ការវិនិយោគជាមួយនឹងដំណើរការឆ្ពោះទៅរក
មូលធននិយម..................................... ៦៤
១.២.៤ សេចក្តីសន្និដ្ឋាន..................................... ៦៦

**១.៣ តួនាទីរដ្ឋ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅប្រទេសកម្ពុជា.... ៦៨**
១.៣.១ អត្ថន័យរបស់រដ្ឋ សម្រាប់បណ្តាប្រទេស
កំពុងអភិវឌ្ឍ ..................................... ៦៨
១.៣.២ តួនាទីបក្ស និងរដ្ឋចំពោះគោលនយោបាយ
សេដ្ឋកិច្ចក្រៅប្រទេស ..................................... ៧៤
១.៣.៣ ស្ថាប័ន និងនីតិវិធីលើគោលនយោបាយ
សេដ្ឋកិច្ចក្រៅប្រទេស ..................................... ៨០

**១.៤ សេចក្តីសន្និដ្ឋាន..................................... ៨៤**


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក២

## គោលបំណង និងមធ្យោបាយនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស


**២.១ ទិសដៅជាមូលដ្ឋាននៃយុទ្ធសាស្ត្រសេដ្ឋកិច្ចក្រៅប្រទេស នាទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០** ........................ ៨៧

២.១.១ ប្រភេទក្រុមសាមគ្គីបង្កបង្កើនផល និងការបែងចែកពលកម្ម .................................................... ៩១

២.១.២ ឯកជនភាវូបនីយកម្ម និងទ្រឹស្តីអភិវឌ្ឍសេដ្ឋកិច្ច ......១០០

២.១.៣ ដំណើរស្តារឡើងវិញនូវវិស័យឧស្សាហូបនីយកម្ម..... ១០៦

២.១.៤ ឧបសគ្គ និងកំណែទម្រង់វិស័យឧស្សាហកម្ម ទៅរកសេរីភាវូបនីយកម្ម.................................................. ១១១

២.១.៥ ការចាប់ផ្តើមទីផ្សារហិរញ្ញវត្ថុ (ធនាគាររដ្ឋ និងឯកជន)................................................... ១១៥

**២.២ ទិសដៅជាមូលដ្ឋាននៃគោលនយោបាយសេដ្ឋកិច្ច ក្រៅប្រទេសរបស់ប្រទេសកម្ពុជានាសម័យទំនើប**........................ ១១៨

២.២.១ ទំនាក់ទំនងរវាងសេដ្ឋកិច្ច និងនយោបាយ............. ១២០

២.២.២ សម្ពាធនយោបាយអន្តរជាតិលើសេដ្ឋកិច្ចកម្ពុជា..... ១២៥

២.២.៣ ការរឹតចំណងទំនាក់ទំនងសេដ្ឋកិច្ច ជាមួយប្លុកសង្គមនិយម .................................................. ១៣០

**២.៣ ការវិវត្តនៃនយោបាយពាណិជ្ជកម្មក្រៅប្រទេស**................. ១៤០

២.៣.១ ការកំណត់គោលនយោបាយអត្រាពន្ធចម្រុះ ........ ១៤២

២.៣.២ ការបង្កើតរបាំងសេដ្ឋកិច្ច និងនយោបាយគាំពារ... ១៤៧

២.៣.៣ ការកំណត់នយោបាយរូបិយប័ណ្ណ និងឥណទាន.... ១៥៨

**២.៤ គោលនយោបាយលើវិស័យទំនាក់ទំនងមូលធនបរទេស**... ១៦៩




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៣

## ទិសដៅចម្បងនៃទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃកម្ពុជា

***៣.១ ទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា ជាមួយស.ស.ស.ស និងជាមួយប្រទេសអឺរ៉ុបខាងកើត ................ ១៧៩***

*៣.១.១ អតុល្យភាពពាណិជ្ជកម្ម និងវិធានការកាត់បន្ថយអតុល្យភាព ...................................................... ១៨៦*

*៣.១.២ កិច្ចសហប្រតិបត្តិការវិស័យបច្ចេកទេស និងវិទ្យាសាស្ត្រ ................................................................ ១៩៨*

*៣.១.៣ កិច្ចសហប្រតិបត្តិការឥណទាន និងបញ្ហាបំណុលក្រៅប្រទេស .......................................... ២០២*

***៣.២ ស្ថានភាព និងចក្ខុវិស័យជុំវិញការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសជាមួយប្រទេសតតិយលោក និងប្រទេសមូលធននិយមលូតលាស់ ................................... ២០៨***

***សេចក្តីសន្និដ្ឋានរួម ....................................................................... ២២៧***

***បណ្ឌិត ហង់ជួន ណារ៉ុន ............................................................ ២៣៣***

***ស្នាដៃរបស់អ្នកនិពន្ធ ................................................................... ២៣៥***



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្ដីផ្ដើម

សៀវភៅ«គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើប»នេះ គឺជានិក្ខេបបទដែលខ្ញុំបានរៀបរៀងឡើង ដើម្បីទទួលបានសញ្ញាបត្របណ្ឌិតសេដ្ឋកិច្ច នៅវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិទីក្រុងមូស្គូ នៅឆ្នាំ១៩៩១។ ខ្ញុំយល់ឃើញថា ប្រធានបទនេះនៅតែមានសារៈសំខាន់នាពេលបច្ចុប្បន្ន ដើម្បីយល់ដឹងពីទំនាក់ទំនងរវាងគោល-នយោបាយក្រៅប្រទេស ជាពិសេសគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស និងគោលនយោបាយក្នុងប្រទេស ជាពិសេសគោលនយោបាយសេដ្ឋកិច្ច។ នៅពេលដែលសម្ដេចតេជោ ហ៊ុន សែន ដែលពេលនោះសម្ដេចជានាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់ផ្ដើមចរចាជាមួយសម្ដេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលជាប្រមុខនៃរដ្ឋាភិបាលកម្ពុជាត្រីភាគី សម្ដេចតេជោបានចាប់ផ្ដើមធ្វើកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយក្នុងគោលដៅធ្វើទំនើបកម្មនៅកម្ពុជាផង និងដើម្បីបង្កើតឡើងនូវលក្ខខណ្ឌសមស្រប ដើម្បីការបង្រួបបង្រួមជាតិកម្ពុជាដែលហែកហួរគ្នានិងបាក់បែកគ្នាអស់ជាងបីទសវត្សរ៍ ដោយសារការជ្រៀតជ្រែកផ្ទៃក្នុងរបស់ប្រទេសមហាអំណាច ដើម្បីការពង្រីកឥទ្ធិពលរបស់គេនៅឧបទ្វីបឥណ្ឌូចិន។ កំណែទម្រង់គោលនយោបាយក្នុងប្រទេសបានធ្វើឱ្យមានកំណែទម្រង់គោល-នយោបាយទំនាក់ទំនងក្រៅប្រទេសរបស់កម្ពុជា។

សៀវភៅនេះមានបំណងពិនិត្យមើលជាទូទៅលើការតស៊ូរបស់កម្ពុជាក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ដោយពិនិត្យឡើងវិញនូវកំណែទម្រង់គោលនយោបាយក្នុងប្រទេសដែលមានគោលដៅលើកកម្ពស់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ហើយរដ្ឋកម្ពុជាដែលចាប់បដិសន្ធិឡើងពីកំណែទម្រង់នេះបានផ្ដល់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាទិភាពផ្នែកវិនិយោគខាងវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ការអភិវឌ្ឍធនធានមនុស្ស។

ខ្ញុំសូមថ្លែងអំណរគុណបណ្ឌិត ឈុន ពហុ ដែលបានបកប្រែនិក្ខេបបទនេះពីភាសារុស្ស៊ីមកជាភាសាខ្មែរ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះជួយដល់យុវជនជំនាន់ក្រោយយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជា ដើម្បីធ្វើយ៉ាងណាជួយកសាងជាតិឱ្យបានរុងរឿងដូចអារ្យប្រទេស ជាពិសេសធានាបានសន្តិភាព និងវិបុលភាពក្នុងសង្គមពុទ្ធិ។

**ហ៊ុនសែន ណារ៉ុន**

ភ្នំពេញ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក១
# លក្ខណៈចម្បង និងកត្តាជាមូលដ្ឋាន នៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស របស់កម្ពុជា

## ១.១ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងស្ថានភាពរបស់កម្ពុជា ក្នុងបរិបទនៃការបែងចែកពលកម្មអន្តរជាតិ

### ១.១.១ ស្ថានភាពទូទៅ និងការប្រៀបធៀបរចនាសម្ព័ន្ធសេដ្ឋកិច្ច

*តាមការស្រាវជ្រាវបង្ហាញថា ប្រទេសកម្ពុជាជាប្រទេសកសិកម្ម។ សេដ្ឋកិច្ចរបស់ប្រទេសនេះបានពឹងអាស្រ័យលើមូលដ្ឋានផលិតកម្មកសិកម្ម និងមានពលរដ្ឋសកម្មប្រមាណ៨១%ដែលប្រកបរបរកសិកម្ម។ ស្របជាមួយគ្នានេះ ទំហំចំណែកវិស័យកសិកម្មបានគ្របដណ្តប់រហូតដល់៤០,៩៤% នៃផ.ស.ស (GDP) នេះបើយោងតាមទិន្នន័យឆ្នាំ១៩៧០។*

*នាសម័យអាណានិគមនិយម ដោយសារតែបញ្ហាវិសមភាពនៃការបែងចែកពលកម្មអន្តរជាតិរវាងប្រទេសកម្ពុជា និងបារាំងទើបប្រទេសកម្ពុជាក្លាយជាប្រទេសផ្គត់ផ្គង់វត្ថុធាតុដើម សម្រាប់ប្រទេសម្ចាស់អាណានិគម និងជាមូលដ្ឋាននៃការវិនិយោគ បម្រើឱ្យសេដ្ឋកិច្ចរបស់ប្រទេសបារាំង។ គួរបញ្ជាក់ដែរថា ក្រោមគោលនយោបាយសេដ្ឋកិច្ច និងយុទ្ធសាស្ត្រគ្រប់គ្រងរបស់ម្ចាស់អាណានិគម ប្រទេសកម្ពុជាត្រូវបានតម្រង់ទិសទៅរកការស្ដាបនាឡើងនូវទម្រង់សេដ្ឋកិច្ចកសិកម្មបែបឯកវប្បកម្ម ដោយគ្រាន់តែតម្រូវឱ្យដាំដុះដំណាំកសិ-ឧស្សាហកម្មតែ២ ឬ៣មុខប៉ុណ្ណោះ សម្រាប់បម្រើឱ្យការ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាំចេញ។

បន្ទាប់ពីទទួលបានឯករាជ្យនាឆ្នាំ១៩៥៤ ប្រទេសកម្ពុជាចាប់ផ្ដើមរៀបចំមាគ៌ានយោបាយអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ខ្លួន។ នៅសម័យកាលនោះ ប្រទេសកម្ពុជាបានស្ថាបនារោងចក្រសហគ្រាសយ៉ាងច្រើនសន្ធឹកសន្ធាប់ និងបានផលិតផលិតផលឧស្សាហកម្មរហូតឈានដល់ការកាត់បន្ថយការនាំចូលមុខទំនិញជាច្រើនប្រភេទដែលធ្លាប់នាំចូលពីបរទេស។ ក្នុងស្ថានភាពនេះ ទើបនៅចុងទសវត្សរ៍ទី៦០ ប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់សេដ្ឋកិច្ចលេខ៣នៅក្នុងតំបន់អាស៊ាន(បន្ទាប់ពីប្រទេសសិង្ហបុរី និងហ្វីលីពីន)ទាក់ទងនឹងការវាស់វែងអំពីផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ(GDP per Capita)។ ជាងនេះទៀត ផ្អែកលើការវិភាគអំពីទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ យើងពិនិត្យឃើញថា ប្រទេសកម្ពុជា និងថៃ នៅសម័យកាលនោះ គឺមានកម្រិតសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ហើយនៅក្នុងវិស័យខ្លះទៀត ប្រទេសកម្ពុជាយើងហាក់ដូចជាមានប្រៀបជាងប្រទេសថៃទៀតផង ដូចជានៅចន្លោះឆ្នាំ១៩៦១ដល់ឆ្នាំ១៩៧០ កំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យផលិតកម្មកសិកម្មសម្រាប់ពលរដ្ឋម្នាក់ៗមានកម្រិតខ្ពស់ជាងប្រទេសថៃ២ដង(ពោលគឺ០,៨%ទល់នឹង០,៤%)។

ប៉ុន្តែនៅចុងទសវត្សរ៍ទី៦០ ជាអកុសល ប្រទេសកម្ពុជាយើងបានចាប់ផ្ដើមមានការរំជើបរំជួលផ្នែកនយោបាយ និងសង្គមដែលវិបត្តិនេះបានឈានទៅដល់ការធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ។ ក្រោយរដ្ឋប្រហារ សង្គ្រាមស៊ីវិលក៏បានផ្ទុះឡើងយ៉ាងឆាប់រហ័សដែលស្ថានការណ៍ដ៏អាក្រក់នេះបានបង្អាក់ដំណើរដល់ការរីកលូតលាស់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

សង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ដល់១៩៧៥ និងស្ថានការណ៍ប្រទេសជាតិឆ្នាំ១៩៧៥ដល់១៩៧៩ ក្រោមការដឹកនាំរបស់ពួកប៉ុល ពត បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ប៉ុន្តែចាប់តាំងពី

ថ្ងៃដំបូងបន្ទាប់ពីទទួលបានជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានចាប់ផ្តើមព្យាបាលស្លាកស្នាមរបួសដែលបន្សល់ទុកដោយរបបប៉ុល ពត ឡើងវិញ។ ក្នុងស្ថានភាពនេះ យើងឃើញថា ដំណើរការនៃការស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសកម្ពុជាបានធ្វើឡើងយ៉ាងលំបាកលំបិនបំផុត ព្រោះថា របបប៉ុល ពត បានបំផ្លិចបំផ្លាញដល់ឫសគល់នៃរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមរបស់ប្រទេសកម្ពុជាទាំងមូល និងបានកម្ទេចចោលរាល់សមិទ្ធផល និងលក្ខខណ្ឌសេដ្ឋកិច្ចរបស់ប្រជាជនខ្មែរ។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាសម័យកាលនោះដុនដាបបំផុត ដែលមិនធ្លាប់មានពីមុនមក ជាពិសេសការខូចខាតទាំងអស់នេះ បានប៉ះពាល់ដល់គ្រប់វិស័យសេដ្ឋកិច្ចជាតិ ក្នុងនោះមានវិស័យឧស្សាហកម្ម ការដឹកជញ្ជូន និងទូរគមនាគមន៍ ហើយបញ្ហាធ្ងន់ធ្ងរបំផុតនោះគឺប៉ះពាល់ដល់វិស័យកសិកម្មតែម្តង។ យ៉ាងណាមិញ ការបង្កើត«សហករណ៍»ដែលគ្មានទំនាក់-ទំនងដោះដូររវាងរូបិយវត្ថុ និងទំនិញនៅទូទាំងប្រទេស ហើយប្រជាជនគ្មានសិទ្ធិទាល់តែសោះក្នុងការប្រើប្រាស់ទ្រព្យធនជាកម្មសិទ្ធិ( ផលិតផលកសិកម្ម)ដែលផលិតចេញពីញើសឈាម និងកម្លាំងពលកម្មផ្ទាល់ខ្លួននោះបានធ្វើឱ្យកើតមានគ្រោះទុរភិក្សនៅទូទាំងប្រទេស។ សម័យនោះ នៅតំបន់ជនបទស្រែចម្ការបានជួបប្រទះកង្វះខាតពូជស្រូវ កម្លាំងអូសទាញ ឧបករណ៍កសិកម្ម ធនធានមនុស្សដែលមានជំនាញ ព្រមទាំងបញ្ហាផ្សេងៗជាច្រើនទៀត។ ដូច្នេះ ការស្តារស្ថានការណ៍សេដ្ឋកិច្ចឡើងវិញរបស់ប្រទេសកម្ពុជាក្រោយសម័យកាលនៃរបបខ្មែរក្រហម ពិតជាបានជួបប្រទះនូវសភាពស្មុគស្មាញយ៉ាងខ្លាំងក្លា។

នៅទសវត្សរ៍ទី៨០ ផលិតផលក្នុងស្រុកសរុប( ផ.ស.ស)នៅកម្ពុជាស្ថិតក្នុងកម្រិតក្រីក្រ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ បើធៀបទៅនឹងបណ្តាប្រទេសក្រីក្របំផុតនៅលើពិភពលោក ប្រទេសកម្ពុជាមានលក្ខណៈប្រសើរជាង ព្រោះថា ប្រទេសកម្ពុជាមិនត្រូវបានគេរាប់បញ្ចូលទៅក្នុង

ចំណោមប្រទេសដែលក្រីក្របំផុតដែលជាសមាជិករបស់អង្គការសហប្រជា-ជាតិនោះទេ។ ទោះបីជាក្នុងចំណាត់ប្រភេទ៣យ៉ាងនៃភាពក្រីក្រ ប្រទេសកម្ពុជាបានឆ្លើយតបរហូតដល់២លក្ខណៈវិនិច្ឆ័យ។ ជាក់ស្តែង សម្រាប់ប្រទេសកម្ពុជា យើងពិនិត្យឃើញថា មនុស្សពេញវ័យដែលចេះអក្សរ មានកម្រិតខ្ពស់ជាង៧០% ក៏ប៉ុន្តែ ប្រជាជនសកម្មប្រមាណ៨១%ប្រកបរបរកសិកម្មដែលមានកម្រិតខ្ពស់ជាងបណ្តាប្រទេសកំពុងអភិវឌ្ឍរហូតដល់ទៅ៣៩%ឯណោះ។ ក្នុងន័យនេះ បង្ហាញថា សមត្ថភាពផលិតកម្មកសិកម្មនៃប្រទេសកម្ពុជាយើងនាសម័យនោះ មានលក្ខណៈទន់ខ្សោយនៅឡើយ ព្រោះយើងបានប្រើប្រាស់កម្លាំងពលកម្មច្រើនក្នុងវិស័យកសិកម្មនេះ។ ចំពោះវិស័យឧស្សាហកម្មវិញ ទំហំចំណែករបស់វាស្មើនឹង១៦,៨%នៃផ.ស.ស និងមានប្រជាជនសកម្មបានចូលរួមបម្រើការងារក្នុងវិស័យនេះប្រមាណតែ១,៦%ប៉ុណ្ណោះ មានន័យថា មានកម្រិត២ដងទាបជាងប្រទេសកំពុងអភិវឌ្ឍសេដ្ឋកិច្ចដូចគ្នា។ ក្នុងស្ថានភាពបែបនេះ យើងអាចធ្វើការវាយតម្លៃបានថា ប្រទេសកម្ពុជានាដំណាក់កាលនោះស្ថិតក្នុងលំដាប់នៃការចាប់ផ្តើមឡើងនូវឧស្សាហូបនីយកម្មតែប៉ុណ្ណោះ។ ខាងក្រោមនេះជាតារាងបង្ហាញអំពីស្ថានភាពផ.ស.ស និងការប្រើប្រាស់កម្លាំងពលកម្មរវាងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងប្រទេសកម្ពុជា ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## តារាងលេខ១
## ការប្រៀបធៀបរចនាសម្ព័ន្ធផ.ស.ស និងតម្រូវការពលកម្មរវាងប្រទេសកំពុងអភិវឌ្ឍឆ្នាំ១៩៨០ និងប្រទេសកម្ពុជាក្នុងទសវត្សរ៍ទី៧០ និង៨០

| បរិយាយ | ប្រទេសកំពុងអភិវឌ្ឍ ១៩៨០ (%) | | | | ប្រទេសកម្ពុជា (%) | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រទេសកំពុងអភិវឌ្ឍទាំងអស់ | | ប្រទេសក្រីក្របំផុត | | ១៩៧០ | | ១៩៨០ | | ១៩៨៩ | |
| | ផ.ស.ស | ពលកម្ម | ផ.ស.ស | ពលកម្ម | ផ.ស.ស | ពលកម្ម | ផ.ស.ស | ពលកម្ម | ផ.ស.ស | ពលកម្ម |
| វិ.កសិកម្ម | ១៩,១ | ៤១,១ | ៥៨,៤ | ៧៧,៨ | ៤០,៩ | ៨១,០ | ៦៩,៦ | ៨៨,៤ | ៤១,៨ | ៧៩,៥ |
| វិ.ឧស្សាហកម្ម | ៣៩,៧ | ១៨,៨ | ២០,០ | ៨,៩ | ១៦,៨ | ៣,៤ | ៤,៨ | ១,២ | ១៤,៦ | ៣,១ |
| វិ.សេវាកម្ម | ៤១,១ | ៤០,៣ | ២១,៦ | ១៣,៣ | ៤២,១ | ១៥,៤ | ២៥,៥ | ១០,៣ | ៤៣,៦ | ១៧,៤ |

ចំពោះវិស័យសេដ្ឋកិច្ចសេវាកម្មវិញ នៅសម័យកាលនោះហាក់មានការរីកលូតលាស់ជាប្រក្រតី ជាពិសេសវិស័យពាណិជ្ជកម្ម និងសេវាកម្មដែលមានទំហំរហូតដល់៤២,១%នៃផ.ស.ស។ ស្ថានភាពបែបនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍផ្សេងៗទៀតដែរ។

## ១.១.២ ស្ថានភាពវិស័យកសិកម្មឆ្នាំ១៩៨០ដល់១៩៨៩

តាមប្រភពឯកសារស្រាវជ្រាវបង្ហាញថា វិស័យកសិកម្មនៅប្រទេសកម្ពុជាត្រូវបានគេកត់សម្គាល់ដោយផ្អែកលើចរិតលក្ខណៈមួយចំនួនដូចខាងក្រោមនេះ ៖

- វិស័យកសិកម្មគឺមានការប្រើប្រាស់គ្រឿងយន្តខ្សោយ ផលិតភាពពលកម្មមានកម្រិតទាប ការប្រមូលផ្តុំផលិតកម្មមានភាពអន់ថយ និងអត្រាផលចំណេញតិចក្នុងការវិនិយោគមួយឯកតាទុនវិនិយោគ។ វិស័យកសិកម្មពឹងផ្អែកស្ទើរទាំងស្រុងទៅលើលក្ខខណ្ឌធម្មជាតិ និងពឹងអាស្រ័យលើភាពមិនទៀងទាត់ផងដែរលើតម្លៃទីផ្សារផលិតផលកសិកម្ម។ ភាពទន់ខ្សោយ

នៃប្រព័ន្ធផលិតកម្មកសិកម្មបានជំរុញឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់លើកកម្ពស់ផលិតកម្ម និងបង្កើនទិន្នផលដំណាំដោយប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាទំនើបៗជាងវិស័យសេដ្ឋកិច្ចដទៃទៀត។

- ក្រៅពីបញ្ហាខាងលើ វិស័យកសិកម្មប្រពៃណីបានគ្របដណ្តប់ក្នុងលក្ខណៈទ្រង់ទ្រាយជាកសិករតូចៗ និងគ្មានការរីកចម្រើន។ ស្ថានភាពនេះបានធ្វើឱ្យមានភាពអសកម្ម និងកង្វះគំនិតផ្តួចផ្តើម ដើម្បីបង្កើតឡើងនូវវិស័យសេដ្ឋកិច្ច-សង្គមផ្សេងៗទៀតបាន។ ជាងនេះទៀត ដោយសារតែបញ្ហាចំណេះដឹង និងកម្រិតវប្បធម៌របស់កសិករទាប កង្វះខាតការទទួលបានព័ត៌មានស្តីអំពីសមិទ្ធផលបច្ចេកទេសកសិកម្មទំនើបៗ កង្វះភាពក្លាហានក្នុងការសម្រេចចិត្តទិញឧបករណ៍បច្ចេកទេសប្រើប្រាស់ និងកង្វះមធ្យោបាយហិរញ្ញវត្ថុសម្រាប់ការវិនិយោគបានក្លាយជាឧបសគ្គចម្បង សម្រាប់ដំណើរការនៃការស្តាបនាវិស័យកសិកម្មជាតិទាំងមូលឡើងវិញ។

## ១.១.២.១ ដំណាំស្រូវ

ចំពោះរចនាសម្ព័ន្ធនៃអនុវិស័យកសិកម្មសំខាន់ៗរបស់ប្រទេសកម្ពុជា យើងរួមមានដំណាំស្រូវនិងដំណាំរួមផ្សំ ដំណាំកៅស៊ូ ការចិញ្ចឹមសត្វ វិស័យជលផល និងរុក្ខកម្ម។ ផលិតកម្មដំណាំស្រូវបានដើរតួនាទីសំខាន់ជាងគេក្នុងសេដ្ឋកិច្ចរបស់កម្ពុជា ព្រោះវិស័យនេះត្រូវបានចូលរួមដោយប្រជាជនភាគច្រើន និងជាប្រភពនៃការរស់រានរបស់ប្រជាពលរដ្ឋខ្មែរ។ នៅក្នុងគោលបំណងដោះស្រាយបញ្ហាសុវត្ថិភាពស្បៀងអាហាររបស់ប្រទេសជាតិ រដ្ឋាភិបាលសម័យនោះបានអនុម័តកម្មវិធីសេដ្ឋកិច្ចសំខាន់ៗពាក់ព័ន្ធនឹងការស្តារការដាំដុះដំណាំស្រូវឡើងវិញ ជាពិសេសបានយកចិត្តទុកដាក់ទៅលើការពង្រីកការភ្ជួររាស់ផ្ទៃដីដាំដុះឱ្យទាន់រដូវកាល ការលើកកម្ពស់ទិន្នផលស្រូវតាមរយៈការប្រើប្រាស់ពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ និងការ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លើកកម្ពស់ផលិតកម្មដំណាំស្រូវតាមរយៈវិធីសាស្ត្រប្រពលវប្បកម្ម។ ក្រៅពីនេះរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ទៅលើនយោបាយទឹក រួមមានការស្តារប្រព័ន្ធធារាសាស្ត្រឡើងវិញ ការបញ្ជ្រាបការប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើប ការប្រើប្រាស់ជីធម្មជាតិ និងជីសរីរាង្គ ក៏ដូចជាចាប់ផ្តើមសម្រិតសម្រាំងការប្រើប្រាស់ពូជស្រូវដែលផ្តល់អតិផលខ្ពស់។ ក្រៅពីនេះទៀត រដ្ឋាភិបាល ក្រោមគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវ ក៏បានរៀបចំអនុវត្តនយោបាយពង្វាតផ្ទៃដីដាំដុះឱ្យកាន់តែធំទូលាយបន្ថែមទៀត។ តាមស្ថិតិឆ្នាំ១៩៦២ ផ្ទៃដីដាំស្រូវមានចំនួនរហូតដល់ជិត៣,៣លានហិកតា។ ប៉ុន្តែមកដល់ឆ្នាំ១៩៨៩ ការស្តារផ្ទៃដីដាំដុះដំណាំស្រូវឡើងវិញទើបតែទទួលបាន១,៩៣លានហិកតាតែប៉ុណ្ណោះ ដែលទំហំនេះនៅមិនទាន់ស្មើនឹងសម័យមុនសង្គ្រាមផង ទោះបីជានៅចន្លោះឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៨ ផ្ទៃដីដាំដុះដំណាំស្រូវត្រូវបានពង្រីករហូតដល់២,៥ដង និងការប្រមូលផលស្រូវបានកើនឡើងដល់៣,៦ដងក៏ដោយ ពីព្រោះនៅឆ្នាំ១៩៦៧ ផ្ទៃដីប្រើប្រាស់សម្រាប់ដំណាំស្រូវមានរហូតដល់២,៥១លានហិកតា។ ចំពោះឆ្នាំដែលទទួលបានទិន្នផលស្រូវខ្ពស់ជាងគេ គឺឆ្នាំ១៩៨៨ ដែលការប្រមូលផលស្រូវបានឈានដល់៧,៧លានតោន។ តាមការវាស់វែងអំពីទិន្នផលស្រូវសម្រាប់ប្រជាពលរដ្ឋម្នាក់ៗ ចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៩ មានការប្រែប្រួលជាវិជ្ជមាន គឺពី១៧៣គីឡូក្រាមដល់៣១៤គីឡូក្រាមក្នុងប្រជាពលរដ្ឋម្នាក់ៗ។ ចាប់តាំងពីឆ្នាំ១៩៨៣ រដ្ឋាភិបាលបានចាប់ផ្តើមនាំចេញផលិតផលស្រូវទៅកាន់ប្រទេសវៀតណាម ហុងកុង និងសិង្ហបុរី។ ប៉ុន្តែនៅបណ្តាឆ្នាំទាំងឡាយណាដែលមិនសូវទទួលបានទិន្នផលស្រូវខ្ពស់ ក៏មានការនាំចូលមកវិញផងដែរ ដូចជានៅឆ្នាំ១៩៨២ជាដើម។

តារាងខាងក្រោមនេះបានបង្ហាញអំពីស្ថានភាពផលិតកម្មដំណាំស្រូវនៅក្នុងប្រទេសកម្ពុជាយើងនាឆ្នាំ១៩៦៦ដល់ឆ្នាំ១៩៨៩៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## តារាងលេខ២
## ទិន្នផលដំណាំស្រូវនៅកម្ពុជាឆ្នាំ១៩៦៦ដល់ឆ្នាំ១៩៨៩

| ឆ្នាំ | ផ្ទៃដីដាំដុះ (ពាន់ហិកតា) | ផ្ទៃដីប្រមូលផល (ពាន់ហិកតា) | ទិន្នផល តោន/ហិកតា | បរិមាណស្រូវ សម្រាប់ម្នាក់ៗ(គីឡូក្រាម) |
|---|---|---|---|---|
| ១៩៦៦ | ២៤១៤ | ២៣៧៦ | ០,៩៨ | ៣៧០ |
| ១៩៦៧ | ២៦១៣ | ២៤៥៧ | ០,៩៧ | ៣៧២ |
| ១៩៦៨ | ២៤៧៣ | ៣២៥១ | ១,៣១ | ៤៧៩ |
| ១៩៧៩ | ៧៧០ | ៦៩៦ | ០,៧៣ | ១១០ |
| ១៩៨០ | ១៤៤១ | ១៦៨៩ | ១,១៧ | ២៥៩ |
| ១៩៨១ | ១៤២៥ | ១៧៤០ | ១,២២ | ២៦០ |
| ១៩៨២ | ១៦៩០ | ១៩៥០ | ១,១៥ | ២៣៣ |
| ១៩៨៣ | ១៧៤០ | ២០៤០ | ១,១៧ | ២៨៩ |
| ១៩៨៤ | ១៤១១ | ១២៥៨ | ០,៨៩ | ៧៣ |
| ១៩៨៥ | ១៤៦១ | ១៨០៧ | ១,២៣ | ២៤១ |
| ១៩៨៦ | ១៧២២ | ២១៣១ | ១,២៦ | ២៧៨ |
| ១៩៨៧ | ១៣៧៨ | ១៨១៥ | ១,៣២ | ២៣០ |
| ១៩៨៨ | ១៩៥៧ | ២៥១៩ | ១,៣៥ | ៣១៤ |
| ១៩៨៩ | ១៩៣២ | ២៥៧២ | ១,៣៣ | ៣០៨ |

សរុបសេចក្តីមក តាមការស្រាវជ្រាវ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា ការអភិវឌ្ឍដំណាំស្រូវចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៩ គឺហាក់នៅមិនទាន់ស្មើនឹងកម្រិតនាសម័យមុនសង្គ្រាមនោះទេ ប៉ុន្តែប្រទេសកម្ពុជាអាចមានលទ្ធភាពក្នុងការជំរុញឱ្យវិស័យនេះមានការរីកលូតលាស់ទៅបានតាមរយៈគោលនយោបាយ២យ៉ាង គឺវិធីសាស្ត្រពង្រីកផ្ទៃដីដាំដុះ និងវិធីសាស្ត្រកសិកម្មប្រពលវប្បកម្ម។

ចំពោះវិធីសាស្ត្រដែលពាក់ព័ន្ធទៅនឹងការពង្វាតផ្ទៃដីដាំដុះ និងការធ្វើប្រពលវប្បកម្ម យើងអាចអនុវត្តបានតាមរយៈយន្តការមួយចំនួនដូចខាងក្រោម ៖

ទី១៖ ការពង្រីកផ្ទៃដីដាំដុះដំណាំស្រូវឱ្យបានធំទូលាយ ដោយឈរលើមូលដ្ឋានប្រើប្រាស់បច្ចេកទេសកសិកម្ម និងបច្ចេកវិទ្យាក្នុងកម្រិតបរិមាណនៅដដែល។

ទី២៖ អភិវឌ្ឍន៍កសិកម្មតាមវិធីសាស្ត្រប្រពលវប្បកម្មដំណាំស្រូវដោយបង្កើនទិន្នផលស្រូវ ផ្អែកលើមូលដ្ឋានប្រើប្រាស់ផ្ទៃដីដាំដុះខ្នាតមួយឯកតាដដែល(ប៉ុន្តែទិន្នផលស្រូវកើនឡើង) តាមរយៈការប្រើប្រាស់ពូជស្រូវល្អៗ ការប្រើប្រាស់ជី និងប្រើប្រាស់បច្ចេកវិទ្យាកសិកម្មទំនើបជាដើម។

ក្រៅពីវិធីសាស្ត្រទាំងអស់ខាងលើនេះ ទាក់ទងនឹងការពង្រីកបរិមាណទិន្នផលស្រូវ បើយោងតាមបទពិសោធន៍បរទេសផ្សេងៗទៀត គេអាចធ្វើទៅបានតាមរយៈការតម្លើងតម្លៃស្រូវ ការគ្រប់គ្រងការប្រមូលផលឱ្យបានល្អ និងការរក្សាទុកដាក់ផលិតផលជៀសវាងការបាត់បង់។

គួរបញ្ជាក់ផងដែរថា ទិន្នផលស្រូវគិតជាមធ្យមក្នុងមួយហិកតានៅចន្លោះឆ្នាំ១៩៨០ដល់១៩៨៨ ស្មើនឹង១,១៧តោន/ហិកតា ដែលនៅសម័យមុនសង្គ្រាម ចន្លោះឆ្នាំ១៩៦២ដល់ឆ្នាំ១៩៦៨ ទទួលបានតែ១,០៨តោន/ហិកតាប៉ុណ្ណោះ។ ស្ថានភាពនេះបង្ហាញអំពីភាពជោគជ័យមួយកម្រិតរបស់យើង ក្នុងការអនុវត្តនយោបាយកសិកម្មប្រពលវប្បកម្ម នាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ជាងនេះទៀត តាមការគណនាបង្ហាញថា ទំហំសេចក្តីត្រូវការផលស្រូវសម្រាប់ពលរដ្ឋម្នាក់ៗគឺស្មើនឹង២៣២គីឡូក្រាម។ ដូច្នេះនៅឆ្នាំ១៩៨៨ យើងមានតម្រូវការ១,៨៦លានតោនប៉ុណ្ណោះ។ ប៉ុន្តែបើយើងបូកបន្ថែមទៀតនូវចំណាយលើការបាត់បង់នៅពេលប្រមូលផល និងការបាត់បង់ពេលកែច្នៃពីស្រូវឱ្យទៅជាអង្ករប្រមាណក្នុងកម្រិតអនុបាតគឺបាត់បង់ស្មើនឹង១,១៥បន្ថែមទៀត។ ហេតុនេះ តម្រូវការសរុបគឺស្មើនឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

២,១៤លានតោន។ ប៉ុន្តែជាក់ស្តែង នៅឆ្នាំ១៩៨៨ យើងបានទទួលផលស្រូវរហូតដល់២,៥១លានតោន មានន័យថា ប្រទេសកម្ពុជាឈានដល់កម្រិតនៃការផ្គត់ផ្គង់ស្រូវដោយខ្លួនឯង លើសពីតម្រូវការ។ ចំពោះតំបន់ផលិតស្រូវសំខាន់ៗរបស់ប្រទេសកម្ពុជាយើងរួមមានខេត្តបាត់ដំបង ព្រៃវែង តាកែវ កំពង់ចាម កណ្តាល កំពត សៀមរាប កំពង់ធំ ស្វាយរៀង និង ពោធិ៍សាត់។ បណ្តាខេត្តទាំង១០ខាងលើនេះមានសក្តានុពលអាចផលិតដំណាំស្រូវបានរហូតដល់ទៅ៨៧,៨%នៃការផលិតស្រូវសរុបរបស់ប្រទេសកម្ពុជា ជាពិសេសខេត្តបាត់ដំបងដែលទទួលបានប្រសិទ្ធនាមងារជាជម្រុកស្រូវ។ នៅឆ្នាំ១៩៦៩ គ្រាន់តែខេត្តបាត់ដំបងមួយគត់អាចមានលទ្ធភាពផលិតស្រូវបានរហូតដល់១៨,៦៨%នៃចំនួនសរុបរបស់ប្រទេស(ផ្ទៃដីដាំដុះ ៤២,៥%) រីឯឆ្នាំ១៩៨៩ ទិន្នផលស្រូវទទួលបាន១៤,៥៤%។ បើយើងសិក្សាវិភាគអំពីទិន្នផលស្រូវក្នុង១ហិកតានៅឆ្នាំ១៩៨៩ យើងពិនិត្យឃើញថា ខេត្តកណ្តាលទទួលបានចំណាត់ថ្នាក់លេខ១(២,២៤តោន/ហិកតា) ខេត្តកំពង់សោមជាប់ចំណាត់ថ្នាក់លេខ២(១,៨២តោន/ហិកតា) ខេត្តក្រចេះជាប់លំដាប់លេខ៣(១,៧៣តោន/ហិកតា) ខេត្តកំពតលំដាប់លេខ៤(១,៥៨តោន/ហិកតា) រីឯតំបន់ភ្នំពេញ ស្ទឹងត្រែង កំពង់ចាម មានលក្ខណៈប្រហែលគ្នា(១,៤៩តោន/ហិកតា)។ សរុបសេចក្តីមក ទិន្នផលដំណាំស្រូវរបស់ប្រទេសកម្ពុជា បើយើងគិតជាមធ្យមសម្រាប់ឆ្នាំ១៩៨៩ មានប្រមាណជា១,៣៣តោន/ហិកតា។

### ១.១.២.២ ដំណាំកៅស៊ូ

អនុវិស័យកសិកម្មទី២របស់ប្រទេសកម្ពុជា គឺដំណាំកៅស៊ូ។ ប្រទេសកម្ពុជាមានលក្ខខណ្ឌអំណោយផលសម្រាប់ដំណាំកៅស៊ូ។ ដូច្នេះហើយបានជាចាប់តាំងពីទសវត្សរ៍ទី៥០ និង៦០ ផ្ទៃដីដំណាំកៅស៊ូត្រូវបានពង្រីកជាបន្តបន្ទាប់ ហើយរហូតដល់ឆ្នាំ១៩៧០ បានឈានដល់៧០.០០០ហិកតា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងនោះ ២៧.៥០០ហិកតាជាផ្ទៃដីប្រមូលផល និងបរិមាណផលិតកម្មកៅស៊ូក្រៃបមានចំនួន៥០.០០០តោន/ឆ្នាំ។ ចំពោះចម្ការកៅស៊ូជាលក្ខណៈគ្រួសារនៅឆ្នាំ១៩៦៨ មានប្រមាណ១៣.០០០ហិកតា។ នៅសម័យកាលនោះ ផ្ទៃដីដាំកៅស៊ូរបស់ប្រទេសកម្ពុជាស្មើនឹង២,៣%នៃដីកសិកម្មសរុប និងមានតម្លៃ៧,៦%នៃតម្លៃផលិតផលកសិកម្មសរុប(ផ.ស.ស កសិកម្ម) និងជាផលិតផលដ៏សំខាន់សម្រាប់ការនាំចេញ។ ដំណាំកៅស៊ូប្រហែល៩២%ត្រូវបានដាំផុះនៅក្នុងចម្ការធំៗនៃខេត្តកំពង់ចាម និងខេត្តក្រចេះ។ តាមការវាយតម្លៃនៅខេត្តរតនគិរី គឺមានផ្ទៃដីប្រមាណ១៥០.០០០ហិកតាដែលមានលក្ខណៈអំណោយផលសម្រាប់ដំណាំកៅស៊ូ ប៉ុន្តែនៅទីនោះ គឺមានបញ្ហាស្មុគស្មាញជាច្រើនសម្រាប់ការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្មបែបនេះ ពោលគឺទាក់ទងនឹងកង្វះកម្លាំងពលកម្ម (ព្រោះដង់ស៊ីតេប្រជាជនទាប) បញ្ហាជំងឺគ្រុនចាញ់ និងការចំណាយខ្ពស់លើមធ្យោបាយដឹកជញ្ជូន ប៉ុន្តែបញ្ហាទាំងអស់នេះអាចដោះស្រាយបាន ប្រសិនបើមានការគ្រប់គ្រងប្រកបដោយសមត្ថភាព។

ផលិតកម្មកៅស៊ូនៅប្រទេសកម្ពុជា ជាទូទៅ បម្រើឱ្យទិសដៅសម្រាប់ការនាំចេញដែលនៅសម័យកាលនោះ ការនាំចេញជ័រកៅស៊ូទទួលបានចំណាត់ថ្នាក់លេខ១ក្នុងចំណោមការនាំចេញសរុប។ ដើម្បីកាត់បន្ថយការចំណាយលើការដឹកជញ្ជូនទឹកជ័រកៅស៊ូ រដ្ឋាភិបាលបានសាងសង់រោងចក្រកែច្នៃទឹកជ័រនៅក្បែរមូលដ្ឋានចម្ការកៅស៊ូធំៗតែម្តង។

ចំពោះសេចក្តីត្រូវការ សម្រាប់ផលិតកម្មក្នុងស្រុក យើងឃើញថាប្រហែល១,១%ទៅ៣%នៃជ័រកៅស៊ូត្រូវបានផ្គត់ផ្គង់ឱ្យសហគ្រាសក្នុងស្រុកសម្រាប់ជាវត្ថុធាតុដើម។ រោងចក្រផលិតកង់រថយន្តនៅតាខ្មៅក្នុងមួយឆ្នាំៗផលិតសំបកកង់រថយន្តបាន២០.០០០គ្រាប់ ផលិតសំបកទោចក្រយានយន្តបាន១២.០០០គ្រាប់ សំបកទោចក្រយានបាន២០០.០០០គ្រាប់ ផលិតទុយោជ័របាន៤០.០០០ម៉ែត្រ ផលិតស្បែកជើងផ្ទាត់ និងផលិតរបស់របរ

ប្រើប្រាស់ផ្សេងៗទៀត។ ដោយឡែក ចំពោះដើមកៅស៊ូវិញ គឺជាមុខទំនិញនាំចេញដ៏សំខាន់មួយទៀត។ ដើមកៅស៊ូ គេអាចប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតគ្រឿងសង្ហារិមយ៉ាងប្រណីត សម្រាប់ការនាំចេញប្ដូរយករូបិយប័ណ្ណផងដែរ។ គួររំឭកដែរថា នៅសម័យនោះ ប្រទេសថៃបានផលិតបច្ចេកវិទ្យាថ្មីក្នុងការផលិតកែច្នៃវត្ថុធាតុពីដើមកៅស៊ូសម្រាប់ធ្វើជាគ្រឿងសង្ហារិម ព្រោះថា ការនាំចេញផលិតផលធ្វើពីដើមកៅស៊ូនៅក្នុងពិភពលោកមានការកើនឡើងយ៉ាងខ្លាំង គឺមានតម្លៃសរុបប្រមាណ៥០លានដុល្លារនៅឆ្នាំ១៩៨៨ ជាពិសេស ការនាំចេញទៅកាន់ប្រទេសជប៉ុន ហុងកុង និងសហរដ្ឋអាមេរិក ដែលធ្វើឱ្យតម្លៃវត្ថុធាតុដើមនេះស្ទុះឡើងពី២០%ទៅ៥០%បន្ថែមទៀត។ ទន្ទឹមនឹងនេះ ដោយសារបញ្ហាគ្រោះទឹកជំនន់នៅភាគខាងត្បូងនៃប្រទេសថៃ និងការដាក់ចេញនូវវិធានការថ្មីៗរបស់រដ្ឋាភិបាលថៃស្ដីពីការហាមឃាត់មិនឱ្យធ្វើអាជីវកម្មព្រៃឈើនៅបណ្ដាខេត្តភាគខាងត្បូងចំនួន១២ខេត្តដែលជាហេតុធ្វើឱ្យសិប្បកម្មគ្រឿងសង្ហារិមពីដើមកៅស៊ូរឹងរឹតតែមានតម្លៃហាងឆេងល្អ។

នៅខែមិថុនា ឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានចាប់ផ្ដើមដំណើរការលើកិច្ចការស្ដារឡើងវិញនូវចម្ការកៅស៊ូដែលធ្លាប់មានពីសម័យមុនៗមក។ នៅឆ្នាំដំបូងនេះ រដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនចម្ការកៅស៊ូរបស់រដ្ឋចំនួន៣កន្លែង ពោលគឺក្រុមហ៊ុន៧មករានៅមូលដ្ឋានជប់ ក្រុមហ៊ុនមិត្តភាព និងសាមគ្គីនៅមេមត់។ ក្រុមហ៊ុនទាំង៣នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានចម្ការកៅស៊ូនៃក្រសួងកសិកម្ម។ ចំពោះរោងចក្រផលិតកៅស៊ូក្រែបរបស់ប្រទេសកម្ពុជា ពីមុនមកធ្លាប់ដំណើរការបានចំនួន៧រោងចក្រ ក៏ប៉ុន្តែ ក្រោយឆ្នាំ១៩៨០ អាចដំណើរការបានតែ២រោងចក្រប៉ុណ្ណោះ គឺរោងចក្រចម្ការជប់ និងឫស្សីកែវ។ ដើម្បីស្ដាបនាហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងសង្គម នៅតំបន់ចម្ការកៅស៊ូឡើងវិញ រដ្ឋាភិបាលសម័យនោះបានខិតខំពុះពារគ្រប់ឧបសគ្គបង្កើតឱ្យមានប្រក្រតីភាពក្នុងវិស័យដ៏សំខាន់នេះ ពោល

គឺបានសាងសង់លំនៅដ្ឋាន មន្ទីរពេទ្យ សាលារៀន និងក្លឹបហាត់ប្រាណ សម្រាប់បុគ្គលិក កម្មករ និងមន្ត្រីរាជការ និងមានការផ្គត់ផ្គង់ជីវភាពជាដើម។ រដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍដំណាំកៅស៊ូដែលក្លាយជាមុខព្រួញសេដ្ឋកិច្ចដ៏មានអាទិភាពមួយក្នុងចំណោមមុខព្រួញសេដ្ឋកិច្ចផ្សេងៗទៀតនៃកម្មវិធីសេដ្ឋកិច្ចរបស់រដ្ឋ ហើយក្នុងជំហានដំបូង គឺសង្កត់ធ្ងន់លើការព្យាបាលដើមកៅស៊ូដែលមានជំងឺ។

ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៩ ផ្ទៃដីដំណាំកៅស៊ូបានស្តារឡើងវិញរហូតដល់២២.៨០០ហិកតា។ កំណើននៃការដាំដុះកើនដល់៣,១៣%នៅឆ្នាំចុងក្រោយ។ បុគ្គលិកកម្មករចម្ការកៅស៊ូសរុបមានចំនួន២៦.២២០នាក់ រីឯការផលិតកៅស៊ូក្រែបវិញឈានដល់៣៣.០០០តោននៅឆ្នាំ១៩៨៨ ក្នុងនោះ ៣០.០០០តោនសម្រាប់ការនាំចេញ។ រហូតដល់ឆ្នាំ១៩៩០ រោងចក្រស្លកៅស៊ូក្រែបមានចំនួន៤ដែលអាចដំណើរការបាន ក្នុងនោះមានរោងចក្រចម្ការកៅស៊ូជប់(មាន១២ខ្សែផលិតកម្ម) រោងចក្រចម្ការកៅស៊ូមេមត់(មាន៦ខ្សែផលិតកម្ម) រោងចក្រចម្ការកៅស៊ូបឹងកេត និងឫស្សីកែវ។

## ១.១.៣ ការប្រើប្រាស់កម្លាំងអូសទាញក្នុងវិស័យកសិកម្ម

### ១.១.៣.១ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម

តាមការសិក្សាបង្ហាញថា មូលដ្ឋានគ្រឿងសម្ភារបច្ចេកទេសដែលបានប្រើប្រាស់ក្នុងវិស័យកសិកម្មនៅកម្ពុជានាសម័យនោះ មានលក្ខណៈជាឧបករណ៍ពលកម្មបែបបុរាណផង និងឧបករណ៍កសិកម្មបែបទំនើបផង។ បើសិក្សាអំពីឧបករណ៍កសិកម្មបែបបុរាណដែលកសិករយើងបានប្រើប្រាស់ជាទូទៅ គឺមានចប នង្គ័ល រនាស់ ប៉ែល ហើយសុទ្ធសឹងជាសម្ភារកសិកម្មផលិតនៅក្នុងស្រុក។ រីឯគ្រឿងបរិក្ខារបច្ចេកទេសកសិកម្មទំនើបយើងឃើញមានត្រាក់ទ័រ ផាល និងរនាស់ត្រាក់ទ័រដែលបាននាំចូលពីបរទេស ក្នុងនោះនាំចូលពីបណ្តាប្រទេសអឺរ៉ុបខាងកើត ហើយបរិក្ខារ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រើប្រាស់មួយចំនួនទៀតទទួលបានតាមរយៈការផ្តល់ជំនួយពីបណ្តាប្រទេស អង្គការអន្តរជាតិនានា។

ចំនួនត្រាក់ទ័រពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ ហើយត្រូវបានគេចុះបញ្ជី នៅឆ្នាំ១៩៨៨ប្រមាណ១.៦១៨គ្រឿង គឺមានការកើនឡើងចំនួន៦ដងធៀបនឹងឆ្នាំ១៩៨០។ ដូច្នេះ ទិន្នន័យនេះគឺមានចំនួនច្រើនជាងសម័យមុនសង្គ្រាមដែលមានមិនដល់១.០០០គ្រឿងផង។ ផ្ទៃដីដែលបានភ្ជួររាស់ដោយថាមពលត្រាក់ទ័រក៏មានការកើនឡើងជាហូរហែ យ៉ាងណាមិញ ដូចជានៅឆ្នាំ១៩៨០ ការភ្ជួររាស់ដោយគ្រឿងយន្តមានតែ៣០.០០០ហិកតាប៉ុណ្ណោះ។ ប៉ុន្តែនៅឆ្នាំ១៩៨៨ ចំនួនត្រាក់ទ័រដែលបានចូលរួមក្នុងការភ្ជួររាស់ដីថ្មីៗទៀត មានប្រមាណ៩១០គ្រឿង គឺស្មើនឹង៥៦,២%នៃចំនួនសរុប មានន័យថា ត្រាក់ទ័រ១គ្រឿងគិតជាមធ្យមអាចភ្ជួរដីបាន២៣៣ហិកតា។ ចំពោះត្រាក់ទ័រចំនួនជិតពាក់កណ្តាលទៀតមិនត្រូវបានប្រើប្រាស់ដោយសារមូលហេតុ កង្វះខាតប្រេងរំអិល ប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ហើយបញ្ហាសំខាន់បំផុត គឺប្រេងឥន្ធនៈមានតម្លៃខ្ពស់។

## ១.១.៣.២ ការប្រើប្រាស់សត្វពាហនៈ

រហូតដល់សម័យកាលនោះ សត្វពាហនៈនៅតែដើរតួនាទីចាំបាច់បម្រើឱ្យកម្លាំងភ្ជួររាស់ អូស ទាញនៅក្នុងវិស័យកសិកម្មរបស់ប្រជាកសិករខ្មែរយើង។ សត្វគោ និងក្របីត្រូវបានកសិករប្រើប្រាស់ក្នុងការភ្ជួររាស់ដីធ្លីក៏ដូចជាប្រើប្រាស់ក្នុងការដឹកជញ្ជូនផលិតផលកសិកម្មនៅតំបន់ជនបទ។ នៅឆ្នាំ១៩៨៨ ក្នុងគោមួយនឹម គិតជាមធ្យម អាចព្យួររាស់ដីស្រែបាន២,៥ហិកតាក្នុងមួយឆ្នាំ។ ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៨ យើងសង្កេតឃើញថា ការពង្រីកបរិមាណចិញ្ចឹមសត្វគោ និងក្របីរបស់ប្រជាកសិករខ្មែរ មានការកើនឡើងគួរឱ្យមោទនៈ ពោលគឺកំណើនប្រចាំឆ្នាំកើនឡើងរហូតដល់១៩,២%។ នៅឆ្នាំ១៩៨៨ សត្វគោ និងក្របីមានចំនួន១.៤៥៦.០០០ក្បាល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានន័យថា កើនឡើងប្រមាណ១,៧៣ដង បើធៀបនឹងឆ្នាំ១៩៨០។ ក៏ប៉ុន្តែ ប្រសិទ្ធភាពនៃការប្រើប្រាស់សត្វពាហនៈជាកម្លាំងអូសទាញ នៅមានកម្រិតទាបនៅឡើយ ព្រោះជាទូទៅ គេអាចប្រើប្រាស់សត្វពាហនៈក្នុងវិស័យកសិកម្មរហូតដល់៨ម៉ោង/ថ្ងៃ។ ប៉ុន្តែដោយសារតែកត្តាអាកាសធាតុ សត្វក្របីមិនអាចធន់នឹងកម្តៅថ្ងៃបានឡើយ ដូច្នេះ ការភ្ជួររាស់គិតជាមធ្យមក្នុង១ថ្ងៃ សម្រេចបានតែ២០អារប៉ុណ្ណោះ។ តាមការសិក្សាខ្លះបញ្ជាក់ថា នៅប្រទេសកម្ពុជា គោ ឬក្របីមួយនឹមមិនអាចភ្ជួររាស់បានលើសពី២ហិកតានោះទេក្នុងមួយឆ្នាំ។ ហេតុដូច្នេះហើយ ទើបកសិករខ្មែរយើង ជាទូទៅបានប្រើប្រាស់សត្វពាហនៈសម្រាប់ធ្វើជាមធ្យោបាយភ្ជួររាស់ អូសទាញដោយមិនសូវទទួលបានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់នោះទេ។

## ១.១.៤ ការប្រើប្រាស់ធនធានដីធ្លី

នៅប្រទេសកម្ពុជា មិនទាន់បានប្រើប្រាស់ដីដែលអាចធ្វើកសិកម្មបានឱ្យអស់លទ្ធភាពនៅឡើយទេ។ នៅសម័យនោះ ប្រទេសកម្ពុជាបានប្រើប្រាស់ដីធ្លីកសិកម្មប្រមាណតែ១៧,២%ប៉ុណ្ណោះ។ ជាឧទាហរណ៍ នៅឆ្នាំ១៩៨៨ ដីដែលបានដាំដុះដំណាំស្រូវបានប្រើប្រាស់តែ៦៨% រីឯផ្ទៃដីសម្រាប់ដាំដំណាំកសិកម្មផ្សេងៗទៀតសម្រេចបានតែ៦៩,៣%លើផ្ទៃដីសរុប។ ដូច្នេះ ទន្ទឹមនឹងគោលនយោបាយអភិវឌ្ឍវិស័យកសិកម្មបែបប្រពលវប្បកម្ម គឺយើងនៅមានលទ្ធភាពអភិវឌ្ឍន៍បែបនយោបាយពង្វាតដីធ្លីបានថែមទៀត។ ប៉ុន្តែ ដោយសារបញ្ហាសង្គ្រាមរ៉ាំរ៉ៃបាននាំមកនូវផលប៉ះពាល់យ៉ាងដំណំដល់ការប្រើប្រាស់សក្តានុពលដីធ្លីកសិកម្ម។ នៅសម័យនោះ រដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់លើការស្តារផ្ទៃដីកសិកម្មឡើងវិញ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមិនទាន់ឈានដល់កម្រិតសម័យមុនសង្គ្រាមនោះដែរ ហើយមានតែដំណាំមួយចំនួនតូច ជាពិសេសដំណាំអំពៅដែលបានឈានដល់កម្រិតខ្ពស់ជាងសម័យមុនសង្គ្រាម។ ជាទូទៅ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីមួយឆ្នាំទៅមួយឆ្នាំ ផ្ទៃដីដាំដុះមានការប្រែប្រួល អាស្រ័យដោយលក្ខខណ្ឌធម្មជាតិ និងការផ្លាស់ប្ដូរមុខដំណាំ។ នៅចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៨ យើងសង្កេតឃើញថា មានការពង្រីកផ្ទៃដីកសិកម្មក្រោមដំណាំស្រូវ បន្លែ បង្ការ សណ្ដែកដី សណ្ដែកសៀង ល្ង អំពៅ ថ្នាំជក់ ក្រចៅ និងកប្បាស ជាពិសេសដំណាំម្រេចដែលមានការរីកលូតលាស់ខ្លាំងជាងគេ។ គ្រាន់តែនៅចន្លោះឆ្នាំ១៩៨៣ដល់ឆ្នាំ១៩៨៨ ដំណាំម្រេចមានការកើនឡើងរហូតដល់២,៤ដង។ ក៏ប៉ុន្តែ ការដាំដុះដំណាំពោតមានការថយចុះទៅវិញ។ ជាការពិតណាស់ កិច្ចការនេះទាក់ទងទៅនឹងកត្តាជាសត្យានុម័ត ពោលគឺកត្តាលក្ខខណ្ឌធម្មជាតិ និងការផ្លាស់ប្ដូរប្រភេទដំណាំ និងកត្តាអត្តនោម័តដែលពាក់ព័ន្ធនឹងយន្តការប្រមូលទិញរបស់រដ្ឋ និងការកំណត់ថ្លៃទំនិញ ការកើនឡើងតម្លៃលើទីផ្សារដែលញ៉ាំងឱ្យកសិករមានចំណាប់អារម្មណ៍ ព្រមទាំងកត្តាផ្សេងៗទៀត។

យើងដឹងហើយថា ភាគច្រើននៃផ្ទៃដីកសិកម្មនៅប្រទេសកម្ពុជាត្រូវបានប្រើប្រាស់ក្រោមដំណាំស្រូវដែលនៅចន្លោះឆ្នាំ១៩៨០ដល់១៩៨៨ មានចំនួនពី៨៦,៧%ដល់៨៩%។ រីឯដំណាំពោត និងសណ្ដែកវិញទទួលបានលំដាប់ថ្នាក់លេខ២ និងលេខ៣លើតម្រូវការប្រើប្រាស់ផ្ទៃដីកសិកម្ម។

បើតាមការសិក្សាវាយតម្លៃរបស់លោក J. Delvert បានបង្ហាញថា នៅប្រទេសកម្ពុជាយើង គឺមានលទ្ធភាពធំធេងណាស់លើការអភិវឌ្ឍវិស័យកសិកម្មបែបពង្វាតផ្ទៃដី ពីព្រោះដីដែលមានប្រយោជន៍ សម្រាប់ការដាំដុះដំណាំគ្រប់ប្រភេទ មានរហូតដល់៥លានហិកតា។ ប៉ុន្តែដីដែលមានជីជាតិល្អបំផុតនោះ មានប្រហែលជាង១លានហិកតា ក្នុងលក្ខណៈជាប្រភេទដីបាសាល់(ដីបន្ទុះភ្នំភ្លើង) រួមមានប្រភេទដីក្រហម ដីខ្មៅ និងដីខ្សាញ់ក្ដាម។ ក្រៅពីនោះ នៅតំបន់វាលទំនាប ជាទូទៅច្រើនជាប្រភេទដីខ្សាច់ ដីល្បាប់ និងដីឥដ្ឋ។

ចាប់ពីឆ្នាំ១៩៨០ដល់១៩៨៨ យើងសង្កេតឃើញថា ផ្ទៃដីដាំដុះ និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការប្រមូលផលស្រូវមានការប្រែប្រួលជាប្រចាំ។ តាមទស្សនៈរបស់យើង មូលហេតុសំខាន់ៗដែលនាំឱ្យមានការប្រែប្រួលទាំងនោះ បណ្ដាលមកពីកត្តាជាសត្យានុម័ត និងអត្តនោម័ត។ ចំពោះកត្តាសត្យានុម័ត គឺមានការទាក់ទងទៅនឹងផលវិបាកដោយសារការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធកសិកម្មពីសង្គ្រាមស៊ីវិល ក្នុងរយៈពេល១៥ឆ្នាំចុងក្រោយ ម្យ៉ាងទៀតក៏ទាក់ទងទៅនឹងកម្លាំងផលិតកម្មដែលនៅមានកម្រិតទាបនៅឡើយផងដែរ។ រីឯកត្តាអត្តនោម័តវិញពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់អង្គការសេដ្ឋកិច្ចផលិតកម្ម មានន័យថា ការចាត់តាំងបែបផែនការងារ ការគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ច-កសិកម្ម ក៏ដូចជាការសម្របសម្រួលដំណើរការផលិតកម្មនានានៅក្នុងប្រទេសគឺហាក់ដូចជាពុំសូវមានប្រសិទ្ធភាពនោះទេ។ បើនិយាយជារួម ការអភិវឌ្ឍកសិកម្មបែបប្រមូលផ្ដុំ ក្នុងទ្រង់ទ្រាយជាក្រុមសាមគ្គីបង្កបង្កើនផលបាននាំមកនូវភាពអសកម្មដល់កសិករខ្មែរយើង។ ជាងនេះទៀត ការកំណត់ថ្លៃផលិតផលតាមទំនើងចិត្តពីសំណាក់ស្ថាប័នសាធារណៈរឹតតែធ្វើឱ្យកសិករមានសតិអារម្មណ៍មិនល្អក្នុងការពង្រីកផលិតផលកសិកម្មរបស់ខ្លួន។ ជាងនេះទៀត ចំពោះគោលគំនិតនៃការបង្កើតក្រុមសាមគ្គីបង្កបង្កើនផលដោយឈរលើមូលដ្ឋានឃោសនាផ្សព្វផ្សាយអំពីមនោគមវិជ្ជាបដិវត្តន៍តាមបែបសេដ្ឋកិច្ចផែនការ ក្រោមទិដ្ឋភាពនយោបាយមួយសំដៅលើរូបភាពនៃការបែងចែកដីធ្លីដល់កសិករ និងគ្មានការជិះជាន់កេងប្រវ័ញ្ចចំពោះវណ្ណៈកសិករពីសំណាក់វណ្ណៈអ្នកមានទ្រព្យដែលទស្សនៈនយោបាយខាងលើនេះត្រូវបានអនុវត្តនៅសម័យកាលនោះដោយគ្មានប្រសិទ្ធភាព។ ការប្រកាន់យកទស្សនៈនិយមបែបនេះរបស់អ្នកដឹកនាំខ្មែរ នាយុគសម័យនោះ គឺអាស្រ័យដោយមានការការពារជំហរនយោបាយរបស់ខ្លួន ទាក់ទិននឹងបម្លាស់ប្ដូរទម្រង់កម្មសិទ្ធិ សំដៅធ្វើឱ្យប្រសើរឡើងនូវស្ថានភាពជីវភាពរបស់កសិករក្រីក្រដែលរស់នៅទីជនបទ។ ពីព្រោះរដ្ឋាភិបាលយល់ឃើញថា កម្មសិទ្ធិឯកជនបានធ្វើឱ្យមានការជិះជាន់សង្កត់សង្កិននៅក្នុងសង្គមដែល

ជាប្រកពនៃភាពក្រីក្ររបស់កសិករខ្មែរ។ អាស្រ័យហេតុនេះ មនោគមវិជ្ជាបដិវត្តន៍និយមដែលបានស្នើឡើងនៅក្នុងកម្មវិធីទំនើបនីយកម្មកសិកម្ម ដោយត្រូវតែផ្តើមចេញពីបម្លាស់ប្តូរកម្មសិទ្ធិឯកជនឱ្យទៅជាកម្មសិទ្ធិសមូហភាព។ ហេតុដូច្នេះហើយទើបមុនខែមេសា ឆ្នាំ១៩៨៩ វិស័យកសិកម្មនៅប្រទេសកម្ពុជា គឺមានចរិតលក្ខណៈក្នុងទម្រង់កម្មសិទ្ធិជាពីរប្រភេទ ពោលគឺកម្មសិទ្ធិសមូហភាព( ជាក្រុមសាមគ្គីបង្កបង្កើនផល) និងកម្មសិទ្ធិឯកជនជាលក្ខណៈគ្រួសារ។ បន្ទាប់ពីប្រទេសកម្ពុជាត្រូវបានរំដោះពីរបបប៉ុល ពត ជាមួយនឹងលក្ខខណ្ឌកង្វះខាតមធ្យោបាយផលិតកម្ម យើងពិនិត្យឃើញថា ទម្រង់សេដ្ឋកិច្ចទាំងអស់នេះ យ៉ាងណាក៏ដោយ ក៏ហាក់មានលក្ខណៈអំណោយផល សម្រាប់គ្រួសារកសិករដែលមានជីវភាពក្រីក្រដែរ។ ប៉ុន្តែជាមួយនឹងការរីកចម្រើនជាបណ្តើរៗនូវស្ថានភាពសេដ្ឋកិច្ចជនបទ យើងសង្កេតឃើញថា ទម្រង់សេដ្ឋកិច្ចខាងលើនេះ ពោលគឺពាក់ព័ន្ធនឹងការបែងចែកទិន្នផលដោយស្មើភាពគ្នា( ចែកផលស្រូវ) ផ្អែកលើចំនួនសមាជិកគ្រួសារ និងកម្លាំងពលកម្ម បាននាំមកនូវបញ្ហាទំនាស់ទស្សនៈគ្នាជាមួយនឹងផលប្រយោជន៍កម្មសិទ្ធិឯកជនរបស់ប្រជាកសិករ។

ភាពបរាជ័យរបស់រដ្ឋាភិបាលសម័យនោះ ចំពោះគោលនយោបាយកសិកម្មអាចពន្យល់បានថា រដ្ឋាភិបាលបានមើលឃើញមាគ៌ាអភិវឌ្ឍន៍ទំនើបកម្មកសិកម្ម តែក្នុងចរន្តបង្កើតជាសហករណ៍កសិកម្មតែប៉ុណ្ណោះ។ ប៉ុន្តែជាតុពិត ទំនើបកម្មកសិកម្មបែបនេះបានក្រសោបយកបញ្ហាដ៏ច្រើនលើសលប់ពីអ្វីដែលរដ្ឋាភិបាលបានពិចារណា ពោលគឺបញ្ហាទាំងនោះស្ថិតនៅត្រង់ថា ប្រព័ន្ធនៃទំនាក់ទំនងផលិតកម្មទាំងមូល តាំងពីបញ្ហាទម្រង់កម្មសិទ្ធិរហូតដល់បែបផែនអង្គការផលិតកម្ម គឺពោរពេញដោយបញ្ហាស្មុគស្មាញដែលរដ្ឋត្រូវដោះស្រាយ។ គួររំឭកថា ចំពោះទម្រង់កម្មសិទ្ធិដែលសមស្របបំផុតនោះ គឺជាប់ពាក់ព័ន្ធទៅនឹងកត្តាប្រយោជន៍របស់កសិករដែលជាទម្រង់អង្គការផលិតកម្មកសិកម្មប្រសើរបំផុត និងគួរយកចិត្តទុកដាក់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាពិសេសបែបប្រពៃណីក្នុងសណ្ឋានជាលក្ខណៈកសិកម្មកម្មសិទ្ធិគ្រួសារ។

ទំនើបកម្មកសិកម្មមិនអាចទទួលបានផ្លែផ្កានោះទេ ប្រសិនបើមិនបានកែលម្អនូវឧបករណ៍បរិក្ខារ ពលកម្ម និងការប្រើប្រាស់បច្ចេកទេសកសិកម្មបែបទំនើបកម្ម ពីព្រោះកន្លងមក កសិករខ្មែរយើងបានប្រើប្រាស់ឧបករណ៍ដែលមានប្រសិទ្ធភាពទាប(ដូចមានបង្ហាញពីទំព័រមុនៗ)។ ដូច្នេះទំនើបកម្មកសិកម្មតម្រូវឱ្យយើងធ្វើកិច្ចការកាន់តែច្រើនឡើង និងសុក្រឹតទាំងឧបករណ៍កសិកម្ម និងការប្រើប្រាស់កម្លាំងពលកម្ម ហើយកត្តាចាំបាច់បំផុតមិនអាចកាត់ថ្លៃបានដែលធ្វើឱ្យមានការអភិវឌ្ឍសង្គម គឺកត្តាធនធានមនុស្ស(បរិមាណកម្លាំងពលកម្មជំនាញ ចំណេះដឹង ទេពកោសល្យ និងមានវិន័យក្នុងការងារ)។ ដើម្បីឈានដល់កម្រិតណាមួយនៃការប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យា ជាការចាំបាច់ត្រូវធ្វើយ៉ាងណាដោយបង្កើតឡើងក្នុងប្រទេសនូវអ្នកឯកទេសដែលមានជំនាញជាច្រើននាក់ ត្រូវមានកម្លាំងពលករដែលមានចំណេះដឹងគ្រប់គ្រាន់ ព្រោះថា សេដ្ឋកិច្ចរបស់បណ្ដាប្រទេសដែលមិនសូវមានការរីកលូតលាស់ ជាទូទៅ បណ្ដាលមកពីបញ្ហាមរតកចំណេះដឹង និងទេពកោសល្យរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសនោះមិនត្រូវបានយកចិត្តទុកដាក់។

នៅប្រទេសកម្ពុជាយើងនាសម័យនោះ អ្វីដែលគួរឱ្យបារម្ភបំផុត គឺស្ថិតនៅលើកង្វះការលើកទឹកចិត្តប្រជាជនឱ្យមានការយល់ដឹងអំពីការដឹកនាំនយោបាយរបស់រដ្ឋាភិបាលដែលហៅថា នយោបាយសមភាព ឬស្មើភាពគ្នា។ ឧទាហរណ៍ គ្រូត្រូវទូម្នាក់មិនគិតថា គាត់មានចំណេះដឹង ឬបទពិសោធន៍កម្រិតណាទេ ប៉ុន្តែត្រូវទទួលបានប្រាក់បៀវត្សស្មើៗគ្នា ខុសពីនៅសម័យកាលឆ្នាំ១៩៥០ដល់ឆ្នាំ១៩៦០ដែលស្ថានភាពរបស់មនុស្សក្នុងសង្គមត្រូវបានកំណត់ដោយទ្រព្យសម្ភារ តាមរយៈចំណេះដឹង និងឧត្តមគតិ។ យើងមិនជំទាស់នោះទេលើកត្តាជាមូលដ្ឋានខ្វះទៀតដែលការអភិវឌ្ឍប្រទេសអាចធ្វើទៅបាន។ ប៉ុន្តែ តាមទស្សនៈរបស់យើង បើប្រជាជនមិនទទួលបាន

ចំណោះដឹង ប្រទេសជាតិមិនអាចចាកចេញផុតពីរង្វង់នៃភាពអន់ថយបាន ឡើយ។ អាស្រ័យហេតុនេះ មូលហេតុនៃភាពក្រីក្ររបស់ប្រទេសមិនមែន កើតមានតែសម្រាប់ប្រទេសដែលស្ថិតនៅក្រោមនឹមអាណានិគម ឬក៏មិន នៅក្រោមអាណានិគមនោះទេ ប៉ុន្តែវាអាស្រ័យដោយការរចេះរៀបចំគោល-នយោបាយសេដ្ឋកិច្ច យន្តការសេដ្ឋកិច្ច និងចិត្តសាស្ត្រសង្គម ដែលអាច ទទួលយកបាននូវគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល។ នៅសម័យ កាលនោះ ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាហាក់ដូចជាមិនទាន់បានឆ្លើយ តបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅឡើយ ព្រោះថា ប្រហែលជា៩៥%នៃសិស្សានុសិស្ស និងនិស្សិតដែលកំពុងសិក្សា ពួកគេហាក់មិនសូវមានជំនឿថា ទទួលបានសញ្ញាបត្របញ្ចប់ការសិក្សានោះ ទេ។ ហេតុផលនេះបានធ្វើឱ្យគុណភាពសិក្សាបានធ្លាក់ចុះ។ ម្យ៉ាងទៀត គោលនយោបាយអប់រំដែលផ្តោតតែលើកត្តាបរិមាណដោយមិនសូវបាន យកចិត្តទុកដាក់លើគុណភាព គោលនយោបាយអប់រំដែលខ្វះព្រលឹង (ជំនឿ) មិនអាចធ្វើឱ្យសេដ្ឋកិច្ច-សង្គមមានការរីកលូតលាស់បានប្រសើរ នោះឡើយ។

ដោយមើលឃើញស្ថានការណ៍ដ៏ស្មុគស្មាញទាំងអស់នេះ រដ្ឋាភិបាល កម្ពុជានាសម័យនោះបានពិចារណាយ៉ាងល្អិតល្អន់ មុននឹងអនុម័តវិធានការ សំខាន់ៗណាមួយសំដៅកែលម្អកំហុសឆ្គងរបស់ខ្លួន និងទាក់ទាញប្រជា កសិករឱ្យចូលរួមសហការ។ ដូច្នេះហើយទើបនៅថ្ងៃទី១២ ខែមេសា ឆ្នាំ ១៩៨៩ មហាសន្និបាតជាតិបុគ្គលិកកម្មករលើកទី២ត្រូវបានប្រារព្ធឡើង ដោយបានអនុម័តនូវសេចក្តីសម្រេចសំខាន់ៗជាច្រើនពាក់ព័ន្ធយ៉ាងខ្លាំង ដល់បញ្ហានៃការអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គម។ គោលគំនិតរួមសំដៅលើ ការបង្កលក្ខណៈឱ្យមានការអភិវឌ្ឍគ្រប់ទម្រង់សេដ្ឋកិច្ច ក្នុងនោះគឺការបើក ភ្លើងខៀវចំពោះទម្រង់កម្មសិទ្ធិឯកជននៅកម្ពុជា។

នៅដំណាក់កាលដំបូងនេះ ត្រូវធ្វើយ៉ាងណាឱ្យមានការផ្លាស់ប្តូរ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និន្នាការនយោបាយមួយនៅក្នុងវិស័យកសិកម្មដែលពីដំណាក់កាលមុនៗ មក នៅប្រទេសកម្ពុជា ការទិញលក់ដីធ្លី ការជួលដីត្រូវបានហាមឃាត់ដោយច្បាប់។ តែកាលៈទេសៈនេះ វិស័យអចលនទ្រព្យត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីជាកម្មសិទ្ធិឯកជន ហើយប្រជាជនអាចលក់ដូរបាន អាចផ្ទេរជាកេរមរតក ឬអាចជួលបានតាមបំណងប្រាថ្នា។ ជាងនេះទៀត គោលនយោបាយកំណែទម្រង់ដីធ្លីនេះមិនសំដៅតែទៅលើដីធ្លីកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែវាពាក់ព័ន្ធផងដែរចំពោះដីលំនៅដ្ឋានរបស់ពួកគេ។ ប្រជាកសិករដោយមានការអនុញ្ញាតតាមផ្លូវច្បាប់ និងពីរដ្ឋអំណាចមូលដ្ឋាន គេអាចទទួលបានបន្ថែមទៀតនូវដីបម្រុងទុករបស់រដ្ឋ(ដីសម្បទានសង្គមកិច្ច)ដែលមានស្រាប់នៅតំបន់នោះ។

គោលនយោបាយក៏មានការផ្លាស់ប្តូរចំពោះវិស័យសហគមន៍ព្រៃឈើផងដែរ។ នៅឆ្នាំ១៩៨៨ ការគ្រប់គ្រងសហគមន៍ព្រៃឈើមានលក្ខណៈស្មុគស្មាញនៅឡើយ ដោយបង្កើតឡើងជាក្រុមសាមគ្គីប្រវាស់ដៃគ្នាដែលពួកគេគ្រាន់តែបានដាំដុះដើមឈើឡើងវិញ ហើយក្រោយមកបានធ្វើការបង្រួបបង្រួមគ្នា ដើម្បីដោះស្រាយបញ្ហារួមដោយខ្លួនឯងប៉ុណ្ណោះ។ បន្ទាប់ពីសហគមន៍ព្រៃឈើប្រវាស់ដៃត្រូវបានរំសាយ ដីធ្លីព្រៃឈើក៏បានបែងចែកគ្នារវាងគ្រួសារកសិករដោយផ្អែកលើទំហំសមាជិកគ្រួសារ។

ក្រៅពីនេះទៀត ការអភិវឌ្ឍវិស័យកសិកម្ម ជានិច្ចកាល ជាប់ទាក់ទិននឹងការអភិវឌ្ឍវិស័យឧស្សាហកម្មរបស់ប្រទេស ក៏ដូចជាកម្រិតរីកលូតលាស់សេដ្ឋកិច្ចនៃប្រទេសជាតិដែលជាទូទៅត្រូវបានកំណត់ឡើងដោយទំហំឧស្សាហកម្មនៅក្នុងផ.ស.ស(GDP)។ ដូច្នេះ ជាបន្តទៀត យើងនឹងធ្វើការវិភាគអំពីការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា។

## ១.១.៥ វិស័យឧស្សាហកម្ម

តាមបម្រាប់ប្រវត្តិសាស្ត្របង្ហាញថា មុនពេលទទួលបានឯករាជ្យភាព

ពីពួកអាណានិគមនិយមនាឆ្នាំ១៩៥៤ វិស័យឧស្សាហកម្មកម្ពុជាស្ទើរតែពុំមានវត្តមាន។ នៅសម័យនោះ រោងចក្រឧស្សាហកម្មដែលបានដំណើរការរួមមានរោងចក្រកែច្នៃជ័រកៅស៊ូ រោងចក្រម៉ាស៊ីនកិនស្រូវ រោងចក្រតម្បាញដែលធ្វើសកម្មភាពក្នុងទិសដៅបម្រើឱ្យការនាំចេញទៅកាន់ប្រទេសក្រោមដំបូលអាណានិគមតែមួយ។ ក្រៅពីនោះ មានតែរោងសិប្បកម្មមួយចំនួនតូចប៉ុណ្ណោះ។ បន្ទាប់ពីទទួលបានឯករាជ្យ ប្រទេសកម្ពុជាបានដាក់ចេញនូវទិសដៅនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មជាតិដែលរហូតដល់សម័យមុនសង្គ្រាម បានធ្វើឱ្យវិស័យឧស្សាហកម្មមានការរីកលូតលាស់គួរឱ្យកត់សម្គាល់។

ប៉ុន្តែលទ្ធផលនៃសង្គ្រាមស៊ីវិលឆ្នាំ១៩៧០ដល់១៩៧៥ និងក្រោមការគ្រប់គ្រងនៃរបបប៉ុល ពត ឆ្នាំ១៩៧៥ដល់១៩៧៩ បានធ្វើឱ្យវិស័យឧស្សាហកម្មជាតិទទួលរងវិនាសកម្មយ៉ាងដំណំ។ បន្ទាប់ពីបានផ្តួលរំលំរបបប៉ុល ពត នាឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានជ្រើសរើសមាគ៌ាអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនដោយធ្វើការស្តារវិស័យឧស្សាហកម្មជាតិដែលបានខ្ទេចខ្ទាំដោយសង្គ្រាម ហើយវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់ទី២ក្នុងសេដ្ឋកិច្ចកម្ពុជា។ ដូចដែលយើងបានបញ្ជាក់កន្លងមកហើយថា នៅឆ្នាំ១៩៨៩ វិស័យឧស្សាហកម្មមានទំហំ១៤,៦%នៃផ.ស.ស ហើយបានផ្គត់ផ្គង់ការងារពលកម្មជិត ៣,១%នៃប្រជាជនខ្មែរយើងនាសម័យនោះ។ រចនាសម្ព័ន្ធផលិតកម្មរួមមានអគ្គិសនី សំបកកង់រថយន្តនិងទោចក្រយាន កៅស៊ូក្រែប ឧស្សាហកម្មគីមី ឧស្សាហកម្មគ្រឿងសំណង់ ឧស្សាហកម្មចំណីអាហារ ឧស្សាហកម្មវាយនភណ្ឌ ឧស្សាហកម្មផលិតបារី និងផ្សេងៗទៀត។ ចំពោះផលិតកម្មដែលលេចធ្លោជាងគេនាសម័យនោះរួមមានការផលិតឧបករណ៍កសិកម្ម និងគ្រឿងបន្លាស់ ការកែច្នៃលោហធាតុ ការកែច្នៃផលិតផលកសិកម្ម និងរោងសិប្បកម្ម។ តំបន់ឧស្សាហកម្មមានទីតាំងស្ថិតនៅរាយប៉ាយផ្សេងៗគ្នានៃផ្ទៃប្រទេស ប៉ុន្តែសម្រាប់រាជធានីភ្នំពេញ តំបន់ជាយក្រុង និងតំបន់ខេត្ត


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កណ្តាលបានគ្របដណ្តប់រហូតដល់៤០% នៃរោងចក្រឧស្សាហកម្មរបស់ប្រទេស។ រីឯខេត្តកំពង់ចាម កំពង់សោម បាត់ដំបង ព្រៃវែង កំពតបានគ្របដណ្តប់៦០%នៃចំនួនរោងចក្រសរុប។ ប៉ុន្តែទំហំផលិតកម្មទំនិញឧស្សាហកម្ម សម្រាប់រោងចក្រសហគ្រាសនៅតំបន់ភ្នំពេញ មានលទ្ធភាពផលិតរហូតដល់៧៣%នៃចំនួនផលិតផលសរុប។ រីឯខេត្តបាត់ដំបងជាប់ចំណាត់ថ្នាក់លេខ២។ គួរបញ្ជាក់ថា នៅប្រទេសកម្ពុជាសម័យនោះ វិស័យឧស្សាហកម្មរីកលូតលាស់តែឧស្សាហកម្មធុនស្រាល និងមធ្យមតែប៉ុណ្ណោះ ហើយស្ថានភាពរោងចក្រឧស្សាហកម្ម និងគ្រឿងសម្ភារផលិតកម្មទៀតសោតជារោងចក្រ សេសសល់ពីសម័យសង្គ្រាម ហើយជាគ្រឿងចក្រផលិតនៅបណ្តាប្រទេសអតីតប្រទេសសង្គមនិយម និងមូលធននិយម។ ដោយសារតែស្ថានភាពរោងចក្រឧស្សាហកម្មមានភាពទ្រុឌទ្រោមធ្វើឱ្យសមត្ថភាពផលិតកម្មទទួលបានបរិមាណក្នុងកម្រិតទាប ហើយទាមទារចាំបាច់នូវការកែលម្អឡើងវិញ និងធ្វើឱ្យមានទំនើបកម្មឧស្សាហកម្ម។

## ១.១.៥.១ ឧស្សាហកម្មអគ្គិសនី

ឧស្សាហកម្មអគ្គិសនីបានដើរតួនាទីសំខាន់បំផុត សម្រាប់ឧស្សាហកម្មរបស់ប្រទេសកម្ពុជានាសម័យនោះ។ តាមការវាយតម្លៃរបស់អ្នកជំនាញបានបង្ហាញថា ការផលិតថាមពលអគ្គិសនីទទួលបានប្រហែល៩,៤លានគីឡូវ៉ាត់(Kw)។ នៅប្រទេសកម្ពុជា តំបន់ទន្លេមេគង្គលើជាទីតាំងដែលមានភាពអំណោយផលដល់ការសាងសង់រោងចក្រវារីអគ្គិសនី។ តាមការសិក្សាលើគម្រោងកម្មវិធីប្រើប្រាស់ធនធានទឹកបានបង្ហាញថា តំបន់ទន្លេមេគង្គលើ និងតាមដងទន្លេផ្សេងៗទៀតអាចមានលទ្ធភាពស្ថាបនារោងចក្រវារីអគ្គិសនីនៅតំបន់នោះ។ ការសាងសង់រោងចក្រវារីអគ្គិសនីនៅតាមដងទន្លេសាប ដៃទន្លេសាប និងទន្លេសាបបានអនុគ្រោះដល់កំណើនធនធានមច្ឆជាតិ ព្រមទាំងធ្វើឱ្យទឹកបឹងទន្លេសាបអាចរក្សាលំនឹងបានល្អទៀតផង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ម្យ៉ាងទៀត ការប្រើប្រាស់ធនធានវារីអគ្គិសនីរបស់ប្រទេសជាអតិបរមាអាចធ្វើឱ្យវិស័យសេដ្ឋកិច្ចទាំងអស់ ពោលគឺវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងការដឹកជញ្ជូន មានការអភិវឌ្ឍ។ ហេតុនេះ កម្មវិធីអភិវឌ្ឍសេដ្ឋកិច្ច និងបច្ចេកទេសតម្រូវឱ្យរដ្ឋាភិបាលត្រូវធ្វើសេចក្តីសម្រេចឱ្យទាន់ពេលវេលា។ ដូច្នេះហើយទើបការបើកសម័យប្រជុំសន្និបាតថ្នាក់ជាតិលើកទី២ របៀបវារៈទី១គឺបានយកចិត្តទុកដាក់ខ្ពស់ទៅលើការពិភាក្សាអំពីគម្រោងអភិវឌ្ឍជាតិ ជាពិសេសការស្តារឡើងវិញ និងការសិក្សាអំពីគម្រោងបញ្ចប់សំណង់វារីអគ្គិសនី។ មហាសន្និបាតបានពិនិត្យលើកម្មវិធីសំខាន់ៗរួមមានការស្តារស្ថានីយរោងចក្រវារីអគ្គិសនីគិរីរម្យឡើងវិញ(កម្លាំង៥០Kwh)ដែលបានស្ថាបនាពីជំនួយបច្ចេកទេសរបស់ប្រទេសយូហ្គូស្លាវី និងការស្ថាបនារោង-ចក្រវារីអគ្គិសនីព្រែកត្នោត(កម្លាំង១៨Kwh)ដែលជាគម្រោងរបស់ប្រទេសអូស្ត្រាលី និងសិក្សាលើគម្រោងនានាតាមដងទន្លេមេគង្គ ព្រមទាំងបានសិក្សាលើផែនការប្រាំឆ្នាំបន្ទាប់ទៀតអំពីការកសាងស្ថានីយវារីអគ្គិសនីរបស់រដ្ឋនៅកំចាយដែលនឹងត្រូវស្ថាបនាក្រោមជំនួយបច្ចេកទេសសហភាពសូវៀត (ក្នុងកម្លាំងថាមពល ១៣០Kwh ប៉ុន្តែនៅរដូវប្រាំង លទ្ធភាពផ្គត់ផ្គង់ទឹកបានតែ២០kwhប៉ុណ្ណោះ) ដូចគ្នាដែរ ការសិក្សាលើគម្រោងសាងសង់វារីអគ្គិសនីនៅតំបន់ភូមិភាគឦសាននៃប្រទេស(កម្លាំងថាមពលពី២០០ទៅ ១០០០Kwh)។

នៅសម័យនោះដែរ ការប្រើប្រាស់ផលិតផលថាមពលអគ្គិសនីរបស់ប្រទេសកម្ពុជាត្រូវបានផលិតឡើងពីប្រភពថាមពលដោយប្រើប្រាស់ស្ថានីយម៉ាស៊ីនភ្លើងដើរដោយប្រេងឥន្ធនៈ។ នៅក្នុងឆ្នាំ១៩៨៨ ផលិតកម្មថាមពលអគ្គិសនីនៅក្នុងប្រទេសបានឈានដល់១៦៥,២២M.Kwh គឺមានការកើនឡើងចំនួន១,៥៧ដងធៀបនឹងឆ្នាំ១៩៨០។ កំណើនផលិតកម្មថាមពលអគ្គិសនីប្រចាំឆ្នាំមានចំនួន៦,៨%នាចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៨។ ជាក់ស្តែង ផលិតកម្មថាមពលអគ្គិសនីនាសម័យនោះហាក់ច្រើនជាងសម័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មុនសង្គ្រាមដែលនៅឆ្នាំ១៩៨៨ បរិមាណថាមពលអគ្គិសនីបានកើនឡើង ៤៤,៣%ធៀបនឹងឆ្នាំ១៩៦៩ និងច្រើនជាងឆ្នាំ១៩៧០ ចំនួន១១ដង ក៏ប៉ុន្តែបញ្ហាប្រឈមស្ថិតនៅត្រង់ថា ការប្រើប្រាស់ថាមពលនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ យ៉ាងណាមិញ ការប្រើប្រាស់ថាមពលនៅក្នុងវិស័យការងារផលិតកម្មគឺមានចំនួនតែ១៥,២៧%ប៉ុណ្ណោះ នៅឆ្នាំ១៩៨៨ រីឯការប្រើប្រាស់ទូទៅរបស់ប្រជាពលរដ្ឋមានទំហំច្រើនជាង៥០% និងការប្រើប្រាស់ផ្នែករដ្ឋបាលមានរហូតដល់១៩,៥៥%។

យើងគួរបញ្ជាក់ដែរថា ស្ថានីយរោងចក្រអគ្គិសនីរបស់ប្រទេសកម្ពុជានាសម័យកាលនោះដំណើរការដោយពឹងផ្អែកលើថាមពលប្រេងឥន្ធនៈដែលនាំចូលពីបរទេស។ ដូច្នេះ ការប្រើប្រាស់ផលិតផលប្រេងឥន្ធនៈដោយគ្មានប្រសិទ្ធភាពសេដ្ឋកិច្ចបែបនេះមិនអាចគេចផុតពីផលប៉ះពាល់ដល់តុល្យភាពជញ្ជីងពាណិជ្ជកម្មនោះឡើយ ហើយទីបំផុត គឺត្រូវជំពាក់បំណុលបរទេស។ យើងអាចធ្វើសេចក្តីសំយោគមួយបែបទៀតថា ការពង្រីកផលិត-កម្មអគ្គិសនីរបស់ប្រទេសកម្ពុជា គឺមិនបានញ៉ាំងឱ្យមានការរីកចម្រើនដល់វិស័យឧស្សាហកម្មប៉ុន្មានទេ ប៉ុន្តែវាបានជួយតែវិស័យសេដ្ឋកិច្ចសេវាកម្មប៉ុណ្ណោះ។ ដូច្នេះ បញ្ហាការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅក្នុងប្រទេសនឹងមានផលវិបាក ហើយជាដំណោះស្រាយ រដ្ឋាភិបាលត្រូវតែគិតគូរពិចារណាអំពីការជីកយកធនធានប្រេងកាត និងឧស្ម័នមកប្រើប្រាស់ជំនួសឱ្យការនាំចូល។ ដូចដែលយើងបានដឹងហើយថា នៅប្រទេសកម្ពុជាយើង តំបន់ខ្ពង់រាបមួយចំនួន តំបន់បឹងទន្លេសាប និងតំបន់មាត់សមុទ្រ( កោះពូលូវ៉ៃ) គឺមានសញ្ញាណខ្លះបង្ហាញថា ប្រទេសកម្ពុជាមានធនធានធម្មជាតិប្រេងកាត និងឧស្ម័នដែលនៅដើមទសវត្សរ៍ទី៧០ ប្រទេសយើងធ្លាប់បានរុករកប្រេងកាតនៅតំបន់មាត់សមុទ្រ ប៉ុន្តែត្រូវអាក់ខានទៅវិញដោយសារតែបញ្ហាសង្គ្រាម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១.១.៥.២ ឧស្សាហកម្មគីមី

ក្រោយឆ្នាំ១៩៨០ ប្រទេសកម្ពុជាត្រូវបានធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធវិស័យផលិតកម្មឧស្សាហកម្ម។ នៅទសវត្សរ៍ទី៧០ និងដើមទសវត្សរ៍ទី៨០ ទំហំផលិតកម្មឧស្សាហកម្មកម្ពុជាបានធ្លាក់ចុះដល់កម្រិតស្ទើរតែសូន្យ ដោយសារផលវិបាកនៃសង្គ្រាមចន្លោះឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ និងក្រោយមក ចូលដល់របបគ្រប់គ្រងរបស់ពួកខ្មែរក្រហម ឆ្នាំ១៩៧៥ដល់១៩៧៩។ ចាប់តាំងពីឆ្នាំ១៩៨០ ទើបបានវិវត្តចូលដំណាក់កាលនៃការស្តារឧស្សាហកម្មរបស់ប្រទេសកម្ពុជាឡើងវិញ។ នៅដំណាក់កាលដំបូង យើងឃើញមានការកើតឡើងនូវបម្លាស់ប្តូររចនាសម្ព័ន្ធក្នុងវិស័យឧស្សាហកម្មកែច្នៃដែលខណៈនោះ ឧស្សាហកម្មគីមីបានឈានមុខគេក្នុងសេដ្ឋកិច្ចកម្ពុជា ភាគច្រើនសម្រាប់ការនាំចេញ។ នៅឆ្នាំ១៩៨៦ រោងចក្រសហគ្រាសចំនួន៧ត្រូវបានបើកឱ្យដំណើរការឡើងវិញ រួមមានរោងចក្រកៅស៊ូក្រែប និងរោងចក្រផ្សេងៗទៀតដែលប្រើប្រាស់វត្ថុធាតុដើមពីជ័រកៅស៊ូធម្មជាតិ រួមមានរោងចក្រផលិតសំបកកង់រថយន្ត ពោះវៀនកង់ សំបករថយន្តធុនធ្ងន់ រថយន្តទេសចរណ៍ ទោចក្រយានយន្ត(ម៉ូតូ) ទោចក្រយាន ស្បែកជើងផ្ទាត់ សាប៊ូ និងផលិតជារបស់ប្រើប្រាស់ផ្សេងៗទៀតធ្វើពីជ័រកៅស៊ូបម្រើឱ្យសេចក្តីត្រូវការទូទៅរបស់ប្រជាពលរដ្ឋ និងការនាំចេញ។ គ្រាន់តែទំហំផលិតកម្មឧស្សាហកម្មគីមីនៅឆ្នាំ១៩៨៨ បានរួមចំណែករហូតដល់៦,៦%នៃផ.ស.ស ឧស្សាហកម្មរបស់កម្ពុជា។ នៅឆ្នាំ១៩៨៧ ប្រទេសកម្ពុជាបានដំណើរការរោងចក្រមេកានិច(យន្តសាស្ត្រ) ផលិតម៉ូទ័របូមទឹក និងបរិក្ខារកសិកម្ម (នង្គ័ល ចប ប៉ែល និងផ្សេងៗទៀត) គ្រឿងឧបករណ៍ប្រើប្រាស់សម្រាប់រោងចក្រកែច្នៃឈើ និងក្តារបន្ទះ ផ្នែកការកែច្នៃលោហធាតុ ផ្នែកក្រឡឹងគ្រឿងយន្តកសិកម្ម និងរោងចក្រជួសជុលគ្រឿងយន្ត និងគ្រឿងបន្លាស់ផ្សេងៗ។

### ១.១.៥.៣ ឧស្សាហកម្មចំណីអាហារ

ឧស្សាហកម្មគ្រឿងឧបភោគបរិភោគក៏បានដើរតួនាទីសំខាន់ណាស់ដែរ សម្រាប់បំពេញសេចក្តីត្រូវការផ្នែកស្បៀងអាហាររបស់ប្រជាពលរដ្ឋ។ ឆ្នាំ១៩៨៨ ទំហំឧស្សាហកម្មចំណីអាហារបានរួមចំណែកយ៉ាងធំក្នុងផ.ស.ស ឧស្សាហកម្មកម្ពុជារហូតដល់៥៥,៨%។ រោងចក្រឧស្សាហកម្មចំណីអាហារបានដំណើរការប្រមាណ៨រោងចក្រ ក្នុងនោះមានរោងចក្រផលិតភេសជ្ជៈ រោងចក្រទឹកកក ម្សៅមី ទឹកផ្លែឈើ ទឹកដោះគោកំប៉ុង( ទឹកដោះគោខាប់) កែច្នៃត្រី និងរោងចក្រកែច្នៃផលិតផលកសិកម្មផ្សេងៗទៀត។ ក្រៅពីនេះយើងឃើញមានរោងចក្រម៉ាស៊ីនកិនស្រូវធំៗមួយចំនួនទៀតដែលមានសមត្ថភាពផលិតអង្ករប្រមាណរហូតដល់៦៥០តោន/ខែសម្រាប់រោងចក្រនីមួយៗដែលស្ថិតនៅតំបន់ភ្នំពេញ បាត់ដំបង កំពង់ចាម សៀមរាប កំពង់ធំ និងព្រៃវែង។

### ១.១.៥.៤ រោងចក្រវាយនភណ្ឌ

ឧស្សាហកម្មវាយនភណ្ឌមានឯកទេសផលិតនូវផលិតផលពីវត្ថុធាតុដើមកប្បាសដែលនៅឆ្នាំ១៩៨៨ បានដំណើរការប្រមាណ៧រោងចក្រសហគ្រាស។ ប៉ុន្តែដោយសារតែបញ្ហាកង្វះខាតវត្ថុធាតុដើម ទើបរោងចក្រសហគ្រាសទាំងអស់នោះដំណើរការមិនបានពេញកម្លាំង។ ជាឧទាហរណ៍ នៅឆ្នាំ១៩៨៨ រោងចក្រវាយនភណ្ឌបានផលិតក្រណាត់គ្រប់ប្រភេទចំនួន ៧,៥៣លានម៉ែត្រ ផលិតស្បៃមុងបាន១,៥១លានម៉ែត្រ និងផលិតភួយបាន១៤៧.០០០ឯកតា។ រីឯរោងចក្រវាយនភណ្ឌនៅខេត្តកំពង់ចាម មានសមត្ថភាពផលិតក្រណាត់ប្រចាំឆ្នាំរហូតដល់៥,២លានម៉ែត្រ និងផលិតអំបោះ១,៥ពាន់តោន។ រោងចក្រធំៗនៅភ្នំពេញ( ភូមិសាស្ត្រពោធិ៍ចិនតុង) ផលិតក្រណាត់បាន៤,៧លានម៉ែត្រ នៅបាត់ដំបងផលិតបាន៤លានម៉ែត្រ និងផលិតអំបោះបាន៧២៥តោន និងរោងចក្រវាយនភណ្ឌតូចៗចំនួន៦ទៀត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅភ្នំពេញផលិតក្រណាត់បាន១២០.០០០ម៉ែត្រ។ រោងចក្របាវក្រចៅខ្លះទៀតក៏ចាប់ផ្តើមដំណើរការ។

## ១.១.៥.៥ ឧស្សាហកម្មសំណង់

បន្ទាប់ពីបានបង្កើតអង្គការរដ្ឋអំណាចប្រជាជន នៅខែមករា ឆ្នាំ១៩៧៩រួចមក រដ្ឋាភិបាលកម្ពុជាបានកំណត់មាគ៌ានយោបាយស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ ក្នុងនោះរដ្ឋបានយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍវិស័យឧស្សាហកម្មគ្រឿងសំណង់ ក្នុងទិសដៅផ្គត់ផ្គង់សម្ភារសំណង់ សម្រាប់ការកែលម្អឡើងវិញនូវបណ្តារោងចក្រដែលបានបំផ្លាញដោយសង្គ្រាម។ ឧស្សាហកម្មគ្រឿងសំណង់នៅសម័យកាលនោះបានដំណើរការប្រមាណ៨រោងចក្រសហគ្រាស ភាគច្រើនជារោងចក្រកែច្នៃឈើ រោងចក្រផលិតឥដ្ឋ ក្បឿង និងការ៉ូ។ នៅឆ្នាំ១៩៨៨ រោងចក្រអារឈើបានផលិតឈើកែច្នៃគិតជាតម្លៃប្រមាណ២៩លានរៀល ឬស្មើនឹង១,៣៣%នៃផ.ស.សឧស្សាហកម្ម។ រយៈពេល៣ឆ្នាំចុងក្រោយ កំណើនឧស្សាហកម្មគ្រឿងសំណង់បានកើនឡើងយ៉ាងគំហុក ដោយសារតែនៅពេលនោះបានលេចឡើងនូវប្បធម៌សាងសង់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋយ៉ាងសស្រាក់សស្រាំ។ ឆ្លើយតបនឹងស្ថានការណ៍នេះ យើងឃើញមានការពង្រីកបរិមាណការងារពលកម្មក្នុងវិស័យនេះផងដែរ ជាពិសេស ការងារពលកម្មតាមរដូវកាលសម្រាប់អ្នកចំណាកស្រុកពីតំបន់ជនបទចូលមកទីក្រុង។

## ១.១.៥.៦ រោងចក្រឧស្សាហកម្មផ្សេងៗទៀត

ប្រទេសកម្ពុជាសម័យនោះក៏មានការរីកលូតលាស់វិស័យឧស្សាហកម្មផ្សេងៗទៀតដែរ ដូចជាឧស្សាហកម្មបារីដែលមានប្រមាណ៣សហគ្រាសនៅភ្នំពេញ រោងចក្រផលិតកញ្ចក់នៅឫស្សីកែវ និងឧស្សាហកម្មកែច្នៃស្បែកសត្វ( ស្បែកគោ)។

បើពិនិត្យជារួម រហូតដល់ឆ្នាំ១៩៨៩ នៅប្រទេសកម្ពុជាបានស្តារឡើងវិញនូវរោងចក្រប្រមាណ៦៩ រោងចក្រឧស្សាហកម្មធំៗ ក្នុងចំណោមរោងចក្រចំនួន៨៧ដែលធ្លាប់មានពីសម័យមុនមក ហើយបរិមាណផលិតផលដែលសម្រេចបាន គិតជាសាច់ប្រាក់ មានចំនួន១,៥៨ពាន់លានរៀល មានន័យថា បានកើនឡើងប្រមាណ១១ដងធៀបនឹងឆ្នាំ១៩៨០ ក៏ប៉ុន្តែនៅមិនទាន់ឈានដល់កម្រិតផលិតកម្មឆ្នាំ១៩៧០នៅឡើយទេ។ តាមការសិក្សាវាយតម្លៃ វិស័យឧស្សាហកម្មបានឈានដល់កម្រិតត្រឹមតែ៧០%នៃឆ្នាំ១៩៧០តែប៉ុណ្ណោះ ហើយផលិតកម្មឧស្សាហកម្មភាគច្រើន ដំណើរការឡើងសម្រាប់តែបំពេញសេចក្តីត្រូវការប្រើប្រាស់នៅក្នុងប្រទេស។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ជាបណ្តើរៗ ទំហំវិស័យឧស្សាហកម្មក្នុងផ.ស.ស និងតម្រូវការចំនួនការងារពលកម្មក្នុងវិស័យនេះ គឺមានការកើនឡើងជាបន្តបន្ទាប់។ មកដល់ចុងទសវត្សរ៍ទី៨០ យើងសង្កេតឃើញមានការប្រែប្រួលរចនាសម្ព័ន្ធក្នុងសេដ្ឋកិច្ចកម្ពុជាជាវិជ្ជមាន ពោលគឺខិតទៅរកស្ថានភាពមួយប្រកៀកប្រកិតនឹងសម័យកាលមុនសង្គ្រាមឆ្នាំ១៩៧០។ ម្យ៉ាងវិញទៀតនៅកាលៈទេសៈនោះដែរ ស្ថានភាពនយោបាយរបស់ប្រទេសកម្ពុជាក៏បានងាកទៅរកសភាពការណ៍មួយនៃកិច្ចការសម្របសម្រួលផ្នែកនយោបាយដែលបានធ្វើឱ្យមានចរន្តនៃការវិនិយោគទុនពីបរទេសមានសន្ទុះកើនឡើងយ៉ាងខ្លាំងក្លា ព្រមទាំងលំហូរចូលការបណ្តាក់ទុនពីសំណាក់អណិកជនខ្មែរក្នុងការស្តារឡើងវិញនូវវិស័យឧស្សាហកម្មជាតិ។

សរុបសេចក្តីមក យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា ស្ថានភាពរចនាសម្ព័ន្ធឧស្សាហកម្មរបស់ប្រទេសកម្ពុជានាសម័យនោះ មានឥរិយាបថនិងលក្ខណៈជាឧស្សាហកម្មបែបប្រពៃណី ហើយការតាំងរោងចក្រសហគ្រាសនៅតាមបណ្តាភូមិសាស្ត្រមួយចំនួន គឺមិនសូវបានគិតគូរដិតដល់ប្រសិទ្ធភាពសេដ្ឋកិច្ចនោះទេ យន្តការសេដ្ឋកិច្ចដំណើរការឡើងតាមបែបបង្គាប់បញ្ជា( សេដ្ឋកិច្ចផែនការ) និងច្រើនតែមានបញ្ហាកង្វះខាតវត្ថុធាតុដើម

កង្វះគ្រឿងបរិក្ខារផលិតកម្ម និងគ្រឿងបន្លាស់ បុគ្គលិកគ្រប់គ្រងមិនសូវមានបទពិសោធន៍ ការប្រើប្រាស់ធនធានអគ្គិសនី និងគ្រឿងចំហេះមិនមានប្រសិទ្ធភាព ដែលទាំងអស់ខាងលើនេះបង្កើតបានជាបញ្ហាដ៏ស្មុគស្មាញបំផុត សម្រាប់ការស្តារវិស័យនេះឡើងវិញ ក៏ដូចជាការធ្វើឱ្យមានប្រក្រតីភាពដល់ការអភិវឌ្ឍឧស្សាហកម្មជាតិទាំងមូល។

## ១.១.៦ វិស័យពាណិជ្ជកម្មក្រៅប្រទេស

ការវិភាគអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក្នុងបំណែងចែកពលកម្មអន្តរជាតិ គឺមិនអាចខ្វះបានទេ ជុំវិញការសិក្សាពិចារណាអំពីតួនាទីរបស់វិស័យទំនាក់ទំនងពាណិជ្ជកម្មក្រៅប្រទេសនោះឡើយដែលវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់បំផុតមួយ សម្រាប់សេដ្ឋកិច្ចប្រទេសកម្ពុជា ព្រោះថា សក្តានុពលសេដ្ឋកិច្ចនៃវិស័យពាណិជ្ជកម្មក្រៅប្រទេសបាន និងកំពុងរីកលូតលាស់ជាលំដាប់។ ជាក់ស្តែងនៅទសវត្សទី៨០ និងដើមទសវត្សរ៍ទី៩០ វិស័យពាណិជ្ជកម្មក្រៅប្រទេសមាននិន្នាការកើនឡើងយ៉ាងស្វាហាប់ដែលចង្វាក់រីកចម្រើនរបស់វា គិតជាមធ្យមប្រចាំឆ្នាំមានប្រមាណ៣%។

នៅប្រទេសកម្ពុជានាសម័យកាលនោះ ប្រតិបត្តិការពាណិជ្ជកម្មក្រៅប្រទេសដំណើរការឡើងដោយអង្គការស្ថាប័នរដ្ឋផង ក្រុមហ៊ុនឯកជនផង និងមានពួកពាណិជ្ជករឯករាជ្យផង។ ជាក់ស្តែង ទំហំពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជន និងពួកពាណិជ្ជករមានកម្រិតធំជាងទំហំពាណិជ្ជកម្មរបស់ស្ថានប័នរដ្ឋពី៣ទៅ៤ដង។ ក៏ប៉ុន្តែដោយសារតែបញ្ហាបច្ចេកទេសនៃដំណើរការស្រង់ស្ថិតិ និងការត្រួតពិនិត្យរបស់អង្គភាពគយមានភាពអសកម្មលើកិច្ចការពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស ដូច្នេះហើយទើបទិន្នន័យស្ថិតិជាផ្លូវការត្រូវបានចុះបញ្ជីតែស្ថិតិពាណិជ្ជកម្មរបស់ស្ថាប័នរដ្ឋតែប៉ុណ្ណោះ។ បញ្ហាទាំងនេះអាចពន្យល់បានថា មូលហេតុដែលកើតឡើងដោយសារកត្តាសត្យានុម័ត និងអត្តនោម័តផងដែរ។

### ១.១.៦.១ ស្ថានភាពជញ្ជីងពាណិជ្ជកម្មអន្តរជាតិ

តាមការសិក្សាស្រាវជ្រាវបង្ហាញថា បន្ទាប់ពីបានផ្តួលរំលំរបបប៉ុល ពត នាឆ្នាំ១៩៧៩ ការនាំចូលទំនិញគ្រប់ប្រភេទដោយវិធីរត់ពន្ធបានចាប់ផ្តើមកើតមានឡើងនៅប្រទេសកម្ពុជាយើងយ៉ាងអនាធិបតេយ្យ ជាពិសេសការនាំចូលទំនិញពីប្រទេសថៃ វៀតណាម សិង្ហបុរី និងពីបណ្តាប្រទេសផ្សេងៗទៀត។ ក្រោយមក រដ្ឋាភិបាលបានចាត់វិធានការរឹតបន្តឹងតាមរយៈការគ្រប់គ្រង ត្រួតពិនិត្យ និងការបង់ពន្ធគយ តាមគ្រប់ច្រករបៀងទាំងអស់ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បណ្តាក្រុមហ៊ុនឯកជន និងពួកពាណិជ្ជករឯករាជ្យបានរិះរកគ្រប់វិធីសាស្ត្រដោយការប្រើប្រាស់ល្បិចកលផ្សេងៗ ដើម្បីគេចវេសពីការត្រួតពិនិត្យ និងការបង់ពន្ធជាផ្លូវការជូនរដ្ឋាភិបាល។ ជាក់ស្តែង មានវិធីសាស្ត្រ២យ៉ាងដែលបង្កលក្ខណៈឱ្យក្រុមហ៊ុនឯកជនទាំងនោះ និងពួកពាណិជ្ជករអាចគេចវេសពីការបំពេញកាតព្វកិច្ចបង់ពន្ធគយជូនរដ្ឋដែលវិធីទាំងនោះមានដូចខាងក្រោម ៖

ទី១៖ ដោយសារតែសម័យនោះ ប្រទេសកម្ពុជានៅមានសង្គ្រាមស៊ីវិល ហេតុនេះរដ្ឋាភិបាលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងត្រួតពិនិត្យតាមខ្សែបន្ទាត់ព្រំដែនដ៏វែងអន្លាយឱ្យបានម៉ត់ចត់នោះទេដែលបង្កលក្ខណៈឱ្យពួកឈ្មួញរកស៊ីខុសច្បាប់ ងាយស្រួលនាំទំនិញឆ្លងកាត់ព្រំដែន។

ទី២៖ ដោយសារមានអង្គភាពរដ្ឋាភិបាលខ្លះហាក់ដូចជាបានលូកដៃអន្តរាគមន៍ដោយផ្ទាល់(អនុវត្តខុសតួនាទី)ជាមួយនឹងប្រតិបត្តិការពាណិជ្ជកម្មក្រៅប្រទេស។

ហេតុដូច្នេះ ចំពោះការសិក្សាវិភាគអំពីប្រតិបត្តិការសេដ្ឋកិច្ចក្រៅប្រទេសរបស់ស្ថាប័នរដ្ឋ យើងពឹងផ្អែកទៅលើទិន្នន័យស្ថិតិផ្លូវការ រីឯការវិភាគអំពីប្រតិបត្តិការសេដ្ឋកិច្ចក្រៅប្រទេសរបស់វិស័យឯកជន គឺអាស្រ័យដោយការវាយតម្លៃ និងប្រមូលបានពីប្រភពផ្សេងៗគ្នា។ ខាងក្រោមនេះ

គឺជាទិន្នន័យផ្លូវការពាក់ព័ន្ធនឹងស្ថានភាពពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសកម្ពុជា ៖

**តារាងលេខ៣**

**ចាមវន្តពាណិជ្ជកម្មក្រៅប្រទេសរបស់ស្ថាប័នរដ្ឋនៃប្រទេសកម្ពុជា(ពាន់រូប្ល)**

| ឆ្នាំ | ការនាំចេញ | ការនាំចូល | ទំហំពាណិជ្ជកម្ម | ឱនភាព |
|---|---|---|---|---|
| **១៩៨០** | ១.៦០៦ | ១.៦៥០ | ៨.២៥៦ | -៥.០៤៤ |
| **១៩៨២** | ១១.៩០៣ | ៥៦.៧៣០ | ៦៨.៦៣៣ | -៤៤.៨៣៧ |
| **១៩៨៤** | ២៤.១៧៩ | ១២០.៩៧៥ | ១៤៥.១៥៤ | -៩៦.៧៩៦ |
| **១៩៨៦** | ៥២.៧៩១ | ១៤៤.៥៣០ | ១៩៧.៣២១ | -៩១.៧៣៩ |
| **១៩៨៨** | ៤៧.៤២៣ | ១៧៩.៣៤០ | ២២៦.៧៦៣ | -១៣១.៩១៧ |
| **១៩៨៩** | ៤៩.៣២០ | ១៨៦.៧១៧ | ២៣៦.០៣៧ | -១៣៧.៣៩៧ |

តារាងខាងលើបង្ហាញថា នៅឆ្នាំ១៩៨៩ ទំហំពាណិជ្ជកម្មក្រៅប្រទេសដែលធ្វើប្រតិបត្តិការដោយស្ថាប័នរដ្ឋ បានពង្រីករហូតដល់២៨,៥ដងធៀបនឹងឆ្នាំ១៩៨០ដែលគិតជារូបិយប័ណ្ណស្មើនឹង២៣៦លានរូប្លៗ ក្នុងនោះ ការនាំចូលបានកើនឡើងរហូតដល់២៨ដង នៅចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៩ រីឯការនាំចេញមានការកើនឡើង៣០ដងៗ ប៉ុន្តែ នៅឆ្នាំ១៩៨៩ បរិមាណនាំចេញទទួលបានតែ២៦%ធៀបនឹងការនាំចូលៗ ជាងនេះទៀត ឱនភាពជញ្ជីងពាណិជ្ជកម្មអន្តរជាតិ គឺបានកើតមានឡើងជាប្រចាំ ធ្វើឱ្យមានការចំណាយខាតបង់ជារៀងរាល់ឆ្នាំ និងនាំឱ្យចុះទន់ខ្សោយនូវតម្លៃរូបិយប័ណ្ណរបស់ប្រទេសៗ

## ១.១.៦.២ ការនាំចេញ

មុខទំនិញនាំចេញសំខាន់ៗរបស់ប្រទេសកម្ពុជារួមមានជាវត្ថុធាតុដើម


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កសិកម្ម( កៅស៊ូ និងស្រូវ) ជាស្បៀងអាហារ( អង្ករ ពោត ម្រេច ត្រីស្រស់ និង ត្រីកែច្នៃ) ថ្នាំជក់ ផលិតផលព្រៃឈើ និងផលិតផលកសិកម្មផ្សេងៗទៀត។

ជ័រកៅស៊ូធម្មជាតិ គឺជាមុខទំនិញដ៏សំខាន់ជាងគេសម្រាប់ការនាំចេញ។ នៅទសវត្សរ៍ទី៥០ និង៦០ ការនាំចេញកៅស៊ូធម្មជាតិទទួលបានចំណាត់ថ្នាក់លេខ២ បន្ទាប់ពីអង្ករ ហើយនៅបណ្តាឆ្នាំខ្លះទៀត ទទួលបានចំណាត់ថ្នាក់លេខ១ ក្នុងចំណោមទំនិញនាំចេញទាំងអស់។ ឆ្នាំ១៩៦៩ ការនាំចេញកៅស៊ូធម្មជាតិមានទំហំស្មើនឹង៤២,៤%ធៀបនឹងការនាំចេញសរុប។ នៅឆ្នាំ១៩៨៩ ការនាំចេញផលិតផលកៅស៊ូមានចំនួន២៨,៧៤ពាន់តោន ទទួលបានចំណាត់ថ្នាក់លេខ១ និងមានទំហំស្មើនឹង៦៧%នៃការនាំចេញសរុប។ ដូច្នេះ ចំនួននេះមានតម្លៃធំធេងណាស់ សម្រាប់ចំណូលជាតិនៅសម័យកាលនោះ ហើយប្រសិនបើមានការប្រែប្រួលតម្លៃ( ជាវិជ្ជមាន ឬអវិជ្ជមាន) ចំពោះទំនិញនេះ នៅលើទីផ្សារអន្តរជាតិ វាអាចនាំមកនូវផលប៉ះពាល់យ៉ាងខ្លាំងចំពោះចំណូលរូបិយប័ណ្ណរបស់ប្រទេសជាតិ។

ទីផ្សារកៅស៊ូធម្មជាតិ មានឥរិយាបថឆ្ពោះទៅរកនិន្នាការដែលការផ្គត់ផ្គង់ខ្ពស់ជាងតម្រូវការប្រើប្រាស់។ ទោះជាយ៉ាងនេះក្តី នៅឆ្នាំ១៩៨៨ ហាក់ដូចជានៅតែបន្តកើនឡើងនូវការផលិតកៅស៊ូក្រេបធម្មជាតិប្រមាណជា៥%។ ដោយឡែកការផលិតជ័រទឹក យើងឃើញថា មានចង្វាក់រីកចម្រើនខ្លាំងក្លាជាងកៅស៊ូក្រេបទៅទៀត ដោយសារតែនៅលើទីផ្សារ មានតម្រូវការវត្ថុធាតុដើមប្រភេទនេះ ហើយម្យ៉ាងទៀត ពាក់ព័ន្ធនឹងការរីករាលដាលនៃជំងឺអេដស៍( បណ្តាលឱ្យមានបញ្ហាកង្វះពលកម្ម) ដែលធ្វើឱ្យជ័រទឹកមានតម្លៃល្អ។ ផ្ទុយទៅវិញ ទីផ្សារជ័រកៅស៊ូស្ងួតកំពុងរងឥទ្ធិពលពីការផលិតជ័រកៅស៊ូសិប្បនិម្មិតដែលកំពុងប្រកួតប្រជែងជាមួយកៅស៊ូធម្មជាតិ ហើយផលិតកម្មជ័រកៅស៊ូសិប្បនិម្មិតបានកើនឡើងរហូតដល់ទៅ៤%។

ផ្សេងពីនេះទៀត ចំពោះមុខទំនិញអង្ករវិញដែលនៅក្នុងទសវត្សរ៍ទី៦០ គឺជាប្រភពដ៏សំខាន់មួយនៃចំណូលរូបិយប័ណ្ណជាតិ ប៉ុន្តែនៅសម័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋកម្ពុជាវិញ អង្ករលែងក្លាយជាផលិតផលសំខាន់សម្រាប់ការនាំចេញទៀត ហើយ ព្រោះបរិមាណស្រូវ ឬអង្ករដែលផលិតបាន មានចំនួនគ្រប់គ្រាន់សម្រាប់តែការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុកតែប៉ុណ្ណោះ។ ប៉ុន្តែ សម្រាប់ពេលអនាគត ដោយសារការផលិតស្រូវអង្ករមានការកើនឡើង ដូច្នេះ ផលិតផលនេះអាចក្លាយជាមុខទំនិញនាំចេញឈានមុខគេក៏អាចថាបាន។

យើងអាចពិនិត្យមើលស្ថានភាពរចនាសម្ព័ន្ធមុខទំនិញកសិកម្មនាំចេញរបស់ប្រទេសកម្ពុជានាសម័យកាលនោះដូចខាងក្រោម ៖

**តារាងលេខ៤**
**រចនាសម្ព័ន្ធមុខទំនិញនាំចេញរបស់កម្ពុជានាទសវត្សរ៍ទី៦០ និង៨០**
**គិតជា(%)**

| មុខទំនិញនាំចេញ | ១៩៦៧ | ១៩៦៩ | ១៩៨៧ | ១៩៨៩ |
|---|---|---|---|---|
| ១. អង្ករ | ៤៩.៨០ | ២៤.៤០ | --- | |
| ២. ជ័រកៅស៊ូ | ២៧.៧០ | ៤២.៥០ | ៦៧.១០ | |
| ៣. សណ្តែកសៀង | --- | ១.១០ | ៧.១០ | |
| ៤. ឈើកែច្នៃ | ៣.១០ | ៥.៩០ | ៧.០០ | |
| ៥. សរសៃអំបោះ | ១.៧០ | ២.៨០ | ៣.៦០ | |
| ៦. ពោត | ៥.៧០ | ៥.៥០ | ២.១០ | |
| ៧. ថ្នាំជក់ | ០.៦០ | --- | ១.៩០ | |
| ៨. ជ័រទឹក | --- | --- | ១.៣០ | |
| ៩. ម្រេច | ២.០០ | ០.១០ | ១.០០ | |
| ១០. សំបកកង់រថយន្ត | --- | --- | ០.៨០ | |
| ១១. ល្ង | ២.៤០ | ១.៤០ | ០.៦០ | |


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាងខាងលើបង្ហាញថា សណ្តែកសៀងទទួលបានចំណាត់ថ្នាក់លេខ២ ក្នុងចំណោមមុខទំនិញនាំចេញទាំង១១មុខ ហើយចំណូលរូបិយប័ណ្ណមានចំនួន៧,១%នៅឆ្នាំ១៩៨៧ទល់នឹង១,១%នៅឆ្នាំ១៩៦៩។ នៅសម័យនោះ ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបាននាំចេញសណ្តែកសៀងជិត៨០០០តោន ពោលគឺច្រើនជាងនៅឆ្នាំ១៩៦៩ចំនួន២ដង។ ចំពោះផលិតផលឈើកែច្នៃជាប់លំដាប់លេខ៣ បើទោះជាប្រាក់ចំណូលកើនឡើងដល់៧%នៅឆ្នាំ១៩៨៧ទល់នឹង៥,៩%នៅឆ្នាំ១៩៦៩ ហើយបរិមាណនាំចេញស្មើនឹង២៤,៨ពាន់ម៉ែត្រគ្រីគុណ គឺប្រហែលជា១/៤នៃសម័យមុនសង្គ្រាម។ ហើយ៦០,៦៨%នៃផលិតផលឈើកែច្នៃត្រូវបាននាំចេញទៅសាធារណរដ្ឋសង្គមនិយមវៀតណាម។ រីឯផលិតផលសរសៃអំបោះ ជាទូទៅបាននាំចេញទៅប្រទេសជប៉ុនដែលនៅឆ្នាំ១៩៦៩ ការនាំចេញមានចំនួន៣,៧ពាន់តោន ហើយនៅឆ្នាំ១៩៨៧ ប្រាក់ចំណូលពីផលិតផលនេះទទួលបាន៣,៦%នៃចំនួនរូបិយប័ណ្ណសរុប និងទទួលបានលំដាប់លេខ៥។ ដោយឡែក ផលិតផលពោតក្រហមតាំងពីទសវត្សរ៍ទី៦០មកម៉្លេះបានក្លាយជាមុខទំនិញនាំចេញដ៏សំខាន់មួយរបស់ប្រទេសកម្ពុជាដែលជារៀងរាល់ឆ្នាំ ការនាំចេញមានចំនួនចន្លោះពី៣៨,៧ពាន់តោនរហូតដល់៦៤,៨ពាន់តោន ប៉ុន្តែនៅឆ្នាំ១៩៨៧ ពោតក្រហមបាននាំចេញតែ៦,៦៥ពាន់តោនប៉ុណ្ណោះ ពោលគឺស្មើនឹង១៧,២%ធៀបនឹងឆ្នាំ១៩៦៩។ ហើយ៧៨,៤%នៃពោតក្រហមបាននាំចេញទៅកាន់ប្រទេសសង្គមនិយមវៀតណាម។ ផ្សេងទីនេះទៀត ទាក់ទងនឹងផលិតផលថ្នាំជក់នៅឆ្នាំ១៩៨៦ បាននាំចេញចំនួន១៤០០តោន ប៉ុន្តែនៅឆ្នាំ១៩៨៧ បានថយចុះមកនៅត្រឹមតែ៦២១តោន(ប្រហាក់ប្រហែលនឹងសម័យមុនសង្គ្រាមឆ្នាំ១៩៦៩)ដែលការធ្លាក់ចុះនេះបណ្តាលមកពីរដ្ឋាភិបាលបានបញ្ចុះតម្លៃទិញចូលរបស់ខ្លួនឱ្យទាបជាងតម្លៃទីផ្សារសេរី ធ្វើឱ្យអ្នកចម្ការមិនមានបំណងលក់ផលិតផលឱ្យក្រុមហ៊ុនរដ្ឋតែម្នាក់ឯង ព្រោះបើលក់ឱ្យឈ្មួញឯកជន គេបានចំណេញច្រើនជាង។ លើសពី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះទៀត ក្រៅពីមុខទំនិញទាំងអស់ខាងលើ យើងមានផលិតផលផលិតសម្រេចផ្សេងទៀត ដើម្បីបម្រើឱ្យការនាំចេញ រួមមានផលិតផលសំបកកង់រថយន្តដែលនៅឆ្នាំ១៩៦៧ ទំហំនាំចេញមានចំនួន៤០០០គ្រាប់។

សរុបសេចក្តីមក បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីបណ្តុំមុខ-ទំនិញកសិកម្មសម្រាប់ការនាំចេញរបស់កម្ពុជារួចមក យើងសង្កេតឃើញថា ប្រភេទមុខទំនិញនាំចេញនៅមានលក្ខណៈអន់ថយ(ស្ទើរតែជាវត្ថុធាតុដើមមិនទាន់កែច្នៃ)។ នៅសម័យកាលនោះ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងជំរុញឱ្យមានការនាំចេញតាមរយៈយុទ្ធសាស្ត្រមួយចំនួនដូចជាទី១៖ ត្រូវធ្វើយ៉ាងណាពង្រីកមុខទំនិញថ្មីៗ សម្រាប់ការនាំចេញ ហើយទី២៖ ត្រូវធ្វើឱ្យមានឯកទេសកម្មច្បាស់លាស់លើមុខទំនិញនាំចេញ។ ចំពោះវិធីសាស្ត្រទី១ អាចធ្វើឱ្យសេដ្ឋកិច្ចរបស់យើងមានចំណងពាក់ព័ន្ធតិចតួចជាមួយនឹងបម្រែបម្រួលថ្លៃទំនិញលើទីផ្សារពិភពលោក ព្រោះបើយើងនាំចេញបានច្រើនមុខ និងមានទំនិញខ្លះមានហាងឆេងល្អ ដូចនេះវាអាចធានា ឬប៉ះប៉ូវថ្លៃដល់មុខទំនិញផ្សេងទៀតដែលមានការធ្លាក់តម្លៃ។ វិធីសាស្ត្រទី២រឹតតែធ្វើឱ្យមានអត្ថប្រយោជន៍ធំធេងចំពោះសេដ្ឋកិច្ច ព្រោះពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលធនធានមនុស្ស និងពង្រីកកន្លែងការងារក្នុងប្រទេស។

### ១.១.៦.៣ ការនាំចូល

សម្រាប់ប្រទេសដែលមានមុខទំនិញប្រើប្រាស់ចាំបាច់ ភាគច្រើនត្រូវបាននាំចូលពីបរទេសក្នុងទិសដៅសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចជាគ្រឿងម៉ាស៊ីន និងគ្រឿងបន្លាស់។ ហេតុនេះ វាជាបញ្ហាប្រឈមមួយចំពោះប្រទេសដែលនាំចេញតែវត្ថុធាតុដើមកសិកម្មតែម្យ៉ាង។

តាំងពីដើមដំបូងនៃការកសាងឧស្សាហូបនីយកម្មនៅកម្ពុជា យើងឃើញថា បានកើតឡើងនូវការផ្លាស់ប្តូររចនាសម្ព័ន្ធមុខទំនិញនាំចូលក្នុងស្រុក។ ក្នុងតារាងទី៥បានបង្ហាញអំពីកិច្ចការទាំងនេះ។ យ៉ាងណាមិញ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចជានៅចន្លោះឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៦៧ ទំហំនៃការនាំចូលទំនិញវិនិយោគ (វត្ថុធាតុដើម)បានកើនឡើង២,៤ដង បើធៀបនឹងឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៥៧ ដែលធ្វើឱ្យចុះថយនូវការនាំចូលមុខទំនិញប្រើប្រាស់ប្រមាណ២,៤ដងក្នុងសមាមាត្រដូចគ្នា។ ប៉ុន្តែ នៅសម័យរដ្ឋកម្ពុជា រចនាសម្ព័ន្ធនាំចូលរបស់ប្រទេសភាគច្រើនជាទំនិញប្រើប្រាស់ដែលក្នុងនោះមាន៦៧%(ក្នុងចំណោមទំនិញប្រើប្រាស់ មាន១៣%ជាគ្រឿងឧបភោគបរិភោគ)។ រីឯទំហំចំណែកទំនិញវិនិយោគមានតែ៦,៦%ប៉ុណ្ណោះ។ បញ្ហានេះ យើងអាចពន្យល់បានជាសត្យានុម័តថា មូលហេតុចម្បងក្នុងការនាំចូលទំនិញវិនិយោគក្នុងទំហំតិចតួចបណ្ដាលមកពីបញ្ហាអសន្តិសុខ និងសង្គ្រាមស៊ីវិលនៅតែបន្តឥតឈប់ឈរ បង្កើតបានជាបរិយាកាសអាប់អួរដល់ការទាក់ទាញអ្នកវិនិយោគ។ គួររំឭកដែរថា នៅសម័យនោះ ទំនិញវិនិយោគដែលនាំចូលមកគឺបានប្រើប្រាស់សម្រាប់ការស្ដារឡើងវិញនូវរោងចក្រសហគ្រាសដែលរងគ្រោះដោយសារសង្គ្រាម។ ចំពោះមូលហេតុជាអត្តនោម័តគឺបណ្ដាលមកពីបញ្ហាគោលនយោបាយរបស់រដ្ឋដែលបានរៀបចំឡើងមិនទាន់បានល្អ ក៏ដូចជារចនាសម្ព័ន្ធតម្រូវការមុខទំនិញជាក់ស្ដែងក្នុងប្រទេសកើតឡើងបែបនេះ ព្រមទាំងផលប៉ះពាល់ពីស្ថានការណ៍នយោបាយអន្តរជាតិផងដែរ។ ជាងនេះទៀត ចំពោះដំណើរការនៃការស្ដារឡើងវិញ និងការកសាងឧស្សាហូបនីយកម្មជាតិដែលពាក់ព័ន្ធទៅនឹងឧស្សាហកម្មធុនស្រាល និងវិស័យកែច្នៃផលិតផលកសិកម្ម នៅតែបន្ត។ ប៉ុន្តែដំណើរការនេះហាក់ដូចជាមានលក្ខណៈយឺតយ៉ាវបំផុត ជាពិសេសទាក់ទងនឹងទំហំទំនិញវិនិយោគបន្តធៀបនឹងបរិមាណនាំចូលសរុប។ ដូច្នេះហើយ ដើម្បីធានាដល់ការជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាការចាំបាច់ត្រូវតែធ្វើឱ្យការនាំចូលទំនិញសម្រាប់វិនិយោគបន្តក្នុងសមាមាត្រប្រមាណពី៣០%ទៅ៣៥%ធៀបនឹងទំនិញនាំចូលសរុប ដោយហេតុថា ការនាំចូលទំនិញប្រភេទនេះ គឺមានសារៈសំខាន់បំផុតសម្រាប់ធ្វើឱ្យមានទំនើបកម្មរោងចក្រសហគ្រាស ការបញ្ជ្រាបបច្ចេកទេស

និងបច្ចេកវិទ្យាផលិតកម្ម និងការផលិតប្រភេទទំនិញថ្មីៗទៀត។ ខាងក្រោមនេះគឺជាតារាងទិន្នន័យទំនិញនាំចូលទៅតាមមុខងារប្រើប្រាស់៖

## តារាងលេខ៥
## មុខងារប្រើប្រាស់របស់ទំនិញនាំចូលមកកម្ពុជា (%)

| ឆ្នាំ | ទំនិញប្រើប្រាស់ទូទៅ | | វត្ថុធាតុដើម និងទំនិញពាក់កណ្ដាលសម្រេច | | ទំនិញវិនិយោគ (គ្រឿងបច្ចេកទេសឧស្សាហកម្ម) |
|---|---|---|---|---|---|
| | ចំណីអាហារ | ផ្សេងៗទៀត (ក្រៅពីអាហារ) | សម្រាប់ប្រើប្រាស់និងវិនិយោគ | ទំនិញវិនិយោគ (វត្ថុធាតុដើម) | |
| ១៩៥៥-១៩៥៧ | ១១ | ៥៩.៨ | ៩.៨០ | ១១ | ៧.៦០ |
| ១៩៦៥-១៩៦៧ | ៤.៨០ | ៣២.៣០ | ១០ | ១១ | ៤១.៩០ |
| ១៩៨៥-១៩៨៧ | ១៣ | ៥៤ | ១២ | ១៤.៤០ | ៦.៦០ |

តារាងខាងលើបានបង្ហាញថា នៅឆ្នាំ១៩៨៥ដល់ឆ្នាំ១៩៨៧ ទំនិញដែលមានមុខងារជាប្រភេទវត្ថុធាតុដើម និងទំនិញពាក់កណ្ដាលផលិតសម្រេចដែលបាននាំចូល មានទំហំ២៦,៤% ក្នុងនោះ១៨% គឺជាប្រេងឥន្ធនៈ និងគ្រឿងចំហេះ ហើយ៨,៤%គឺជាវត្ថុធាតុដើម និងទំនិញពាក់កណ្ដាលសម្រេច ដូចជាវត្ថុធាតុដើមវាយនភណ្ឌ គ្រឿងដែក លោហៈមានពណ៌ វត្ថុធាតុដើមសម្រាប់ផលិតឱសថ និងផ្សេងៗទៀត។ ផ្សេងពីនេះទៀត ចំពោះបញ្ហាសង្គ្រាមស៊ីវិលដែលបានអូសបន្លាយអស់រយៈកាល១២ឆ្នាំមកហើយនោះ បានបន្តចាក់ស្រេះប្រឈមមុខដាក់គ្នាគ្មានទីបញ្ចប់រវាងកងកម្លាំងរដ្ឋាភិបាលជាមួយនឹងកងទ័ពចម្រុះត្រីភាគី ជាហេតុនាំឱ្យរដ្ឋាភិបាលភ្នំពេញងាកទៅរកការនាំចូលគ្រឿងសព្វាវុធយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលការចំណាយលើគ្រឿងសស្ត្រាវុធទាំងអស់នោះអស់ប្រមាណពី២០%ទៅ៣០%នៃថវិកាជាតិជារៀងរាល់ឆ្នាំ។ ប្រទេសដែលលក់អាវុធ គ្រាប់រំសេវ និងសម្ភារសឹកឱ្យប្រទេសកម្ពុជាច្រើនជាងគេគឺសហភាពសូវៀត។ តាម


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការសិក្សាវាយតម្លៃជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានទិញគ្រឿងសព្វាវុធគិតជាសាច់ប្រាក់មានចំនួន៣០លានរូប្លិ៍ ជាលក្ខណៈឥណទានដែលសហភាពសូវៀតផ្ដល់ឱ្យកម្ពុជា។ ដំណាក់កាលក្រោយមក ប្រទេសកម្ពុជាបានទិញអាវុធពីប្រទេសវៀតណាម និងឥណ្ឌា។

## ១.១.៧ សន្និដ្ឋាន

សរុបសេចក្ដីមក បន្ទាប់ពីបានសិក្សាស្រាវជ្រាវអំពីស្ថានភាពវិស័យពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសកម្ពុជា និងអំពីបម្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងបំណែងចែកពលកម្មអន្តរជាតិរួចមក យើងអាចសន្និដ្ឋានបានថា នាសម័យឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាហាក់ដូចជាបានបង្ហាញឱ្យយើងឃើញពីភាពទន់ខ្សោយយ៉ាងខ្លាំង ពិសេសទាក់ទងនឹងការនាំចេញក៏ដូចជាការនាំចូលទំនិញ។ ចំពោះស្ថានភាពទំនិញនាំចេញភាគច្រើនជាផលិតផលវត្ថុធាតុដើមកសិកម្ម និងមានតែមុខទំនិញពី៣ទៅ៤មុខប៉ុណ្ណោះ។ រីឯទំនិញនាំចូលវិញ ច្រើនតែជារបស់របរប្រើប្រាស់ទូទៅ និងចំណីអាហារដែលទំនិញទាំងអស់នោះមិនបម្រើឱ្យទិសដៅនៃការស្ដារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនោះឡើយ។

ម្យ៉ាងទៀត យើងឃើញថា ជាង៦០%នៃទំហំពាណិជ្ជកម្មត្រូវបានរ៉ាប់រងដោយវិស័យឯកជនដែលបានដើរតួនាទីជាឆ្អឹងខ្នងសេដ្ឋកិច្ច-សង្គមក្នុងការបំពេញចំណុចខ្វះខាតក៏ដូចជាមានមុខងារជាអ្នកផ្គត់ផ្គង់សេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋនូវទំនិញសព្វសារពើ។ បើគ្មានវិស័យឯកជននោះទេ រដ្ឋាភិបាលនឹងជួបប្រទះនូវបញ្ហាជាច្រើនឥតគណនាដែលបញ្ហាធំបំផុតនោះគឺ កង្វះខាតរូបិយប័ណ្ណបរទេសក្នុងទិសដៅទិញទំនិញ សម្រាប់ការនាំចូលក្នុងស្រុក។ នៅសម័យនោះ វិស័យឯកជនបាននាំចូលនូវមុខទំនិញសំខាន់ៗជាច្រើនប្រភេទដូចជា ៖

១. ផលិតផលគ្រឿងឧបភោគបរិភោគរួមមានត្រីខកំប៉ុង មីកញ្ចប់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលិតផលស្ករគ្រាប់ ភេសជ្ជៈ និងផ្សេងៗទៀត ។

២. ផលិតផលវាយនភណ្ឌមានក្រណាត់គ្រប់ប្រភេទ និងសម្លៀក-បំពាក់។

៣. ស្បែកជើង។

៤. ផលិតផលគ្រឿងអគ្គិសនីមានទូរទស្សន៍ ម៉ាញេ ក្បាលវីដេអូ នាឡិកា ម៉ាស៊ីនគិតលេខ និងផ្សេងៗទៀត។

៥. គ្រឿងអេឡិចត្រូនិចមានទូទឹកកក ម៉ាស៊ីនត្រជាក់ កង្ហារ ម៉ាស៊ីនភ្លើងជាដើម។

៦. រថយន្តទេសចរណ៍។

៧. គ្រឿងសង្ហារិម និងសម្ភារប្រើប្រាស់ក្នុងគេហដ្ឋាន។

៨. ឱសថ។

ចំពោះទំនិញទាំងអស់ខាងលើនេះត្រូវបានលក់ដូរចែកចាយដោយភ្នាក់ងារឯកជនក្នុងស្រុក នៅលើទីផ្សារពាសពេញផ្ទៃប្រទេស។ ឈ្មួញឯកជនទាំងឡាយតែងមានទំនាក់ទំនងជិតស្និតជាមួយនឹងពាណិជ្ជករថៃ សិង្ហបុរី តៃវ៉ាន់ ហុងកុង វៀតណាម និងប្រទេសផ្សេងៗទៀតដែលបានក្លាយជាតឹកតាងវប្បធម៌មួយនៅក្នុងទំនាក់ទំនងនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់ប្រទេសកម្ពុជា។

## ១.២ រចនាសម្ព័ន្ធនៃសេដ្ឋកិច្ច-សង្គមរបស់ប្រទេសកម្ពុជា

### ១.២.១ ការសិក្សាលើទ្រឹស្តីជាមូលដ្ឋានជុំវិញសណ្ឋាននៃសេដ្ឋកិច្ច-សង្គម

តាមការសិក្សាស្រាវជ្រាវបង្ហាញថា រចនាសម្ព័ន្ធនៃសេដ្ឋកិច្ច-សង្គមរបស់ប្រទេសនីមួយៗតែងតែមានការជាប់ជំពាក់ទៅនឹងកត្តាសេដ្ឋកិច្ចខាងក្នុងរបស់ខ្លួនជាចាំបាច់ក្នុងចំណោមកត្តាដទៃជាច្រើនទៀតរបស់វាដែលជះឥទ្ធិពលដល់ដំណើរការនៃការតាក់តែងឡើងនូវគោលនយោបាយសេដ្ឋ-កិច្ចក្រៅប្រទេសរបស់រដ្ឋ។ ជាងនេះទៀត បើតាមប្រភពឯកសាររបស់សេដ្ឋ-


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិទូសូវៀតបានលើកឡើងថា កន្លងមកមានស្នាដៃតិចណាស់ដែលបាន សិក្សាស្រាវជ្រាវ និងបំភ្លឺអំពីបទពិសោធន៍នានាដែលមានឥទ្ធិពលទៅលើ ទ្រង់ទ្រាយ ឬសណ្ឋានសេដ្ឋកិច្ច-សង្គមរបស់បណ្ដាប្រទេសកំពុងអភិវឌ្ឍ ក្នុងទិសដៅប្រើប្រាស់ជាយន្តការ សម្រាប់ការរៀបចំគោលនយោបាយ សេដ្ឋកិច្ចក្រៅប្រទេស។ ភាពចន្លោះប្រហោងត្រង់ចំណុចនេះហាក់មិនទាន់បាន បំពេញនៅឡើយទេ រហូតដល់កាលៈទេសៈកន្លងមក។ ក៏ប៉ុន្តែចំពោះការ វិភាគអំពីទំនាក់ទំនងនៃខ្សែចំណងទាក់ទិនដែលមិនអាចកាត់ផ្ដាច់បាន និង អំពើរវាងគ្នានៃគោលនយោបាយសេដ្ឋកិច្ច គឺវាមានអត្ថិភាពពិតប្រាកដនៅ ក្នុងបទពិសោធន៍ទាំងឡាយដែលបានប្រើប្រាស់ជាគោលការណ៍ក្នុងក្រឹត្យ ក្រមវិចារវិទ្យា( ទស្សនវិជ្ជានៃការពិចារណាឃើញដ៏ត្រឹមត្រូវ) និងគោល- ការណ៍បែបសម្ភារនិយមជាប្រវត្តិ។

ចំពោះយន្តការជាវិធីសាស្ត្រដ៏សំខាន់បំផុត សម្រាប់ការសិក្សាវិភាគ ទៅលើបញ្ហាទំនាក់ទំនងគ្នាខាងលើនេះ គឺពាក់ព័ន្ធទៅនឹងស្ថានភាពមួយ ស្ដីអំពីទិដ្ឋភាពសម្ព័ន្ធរួម ឬចំណងតែមួយដែលជាធម្មជាតិនៃសេដ្ឋកិច្ច-សង្គម ពោលគឺរវាងគោលការណ៍ផ្នែកនយោបាយសេដ្ឋកិច្ចខាងក្នុង និងខាងក្រៅ ប្រទេសដែលមិនអាចញែកចេញពីគ្នាបាន ហើយព្រមទាំងមានភាពជា និរន្តរ៍នៃទំនាក់ទំនងរវាងគ្នា។ គោលនយោបាយសេដ្ឋកិច្ចក្នុងប្រទេស និង ក្រៅប្រទេស គឺជាផ្នែកមួយនៃគោលនយោបាយរួមរបស់វាដែលត្រូវឈរ លើមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច-សង្គមតែមួយប៉ុណ្ណោះ។

ក្នុងកិច្ចការនេះ យើងឃើញមានអ្នកស្រាវជ្រាវរបស់សូវៀតមួយ ចំនួនបានចាត់ទុកថា មូលដ្ឋានគ្រឹះនៃគោលនយោបាយសេដ្ឋកិច្ចផ្នែកខាង ក្នុងក៏ដូចជាក្រៅប្រទេសតែងតែផ្សារភ្ជាប់ជាមួយដួងកែវនៃផលប្រយោជន៍ សេដ្ឋកិច្ចរបស់វណ្ណៈ ឬស្រទាប់ប្រជាជនមួយចំនួននៅក្នុងសង្គមនោះដែល ពួកគេជាអ្នកកាន់កាប់នូវមធ្យោបាយផលិតកម្មជាកម្មសិទ្ធិ។ បញ្ហានេះគឺ ជាប្រភពដ៏សំខាន់បំផុតដែលបណ្ដាប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុង

អភិវឌ្ឍក្នុងតតិយលោក ជាមួយនឹងការលូតលាស់សេដ្ឋកិច្ចកម្រិតមធ្យម ក្នុងនិន្នាការមូលធននិយម ក៏ដូចជាប្រទេសអភិវឌ្ឍសេដ្ឋកិច្ចតិចតួចដែលទម្រង់កំណត់វណ្ណៈសេដ្ឋកិច្ច មិនទាន់បានរំលេចចេញជារូបរាងជាក់លាក់នៅឡើយ ពោលគឺប្រទេសទាំងអស់នេះហើយ ដែលបានប្រើប្រាស់យន្តការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការគ្រប់គ្រងអំណាចនយោបាយដើម្បីធ្វើឱ្យមានស្ថិរភាពដែលប្រកបទៅដោយតុល្យភាពលំនឹងនៅក្នុងសង្គមរបស់ខ្លួន ដោយផ្អែកទៅលើមូលដ្ឋាននៃការសិក្សាវិភាគយ៉ាងត្រឹមត្រូវអំពីប្រភេទសណ្ឋានសេដ្ឋកិច្ច-សង្គមនីមួយៗរបស់គេ និងអំពីវណ្ណៈដែលបានកាន់កាប់មធ្យោបាយផលិតកម្មសង្គម ក៏ដូចជាអំពីក្រុមអ្នកដឹកនាំនយោបាយ។ ក្នុងលក្ខខណ្ឌនៃការដឹកនាំតាម«បែបផែនផលិតកម្មអាស៊ី» ព្រមទាំងនិន្នាការគ្រប់គ្រងអំណាចរដ្ឋរបស់បណ្ដាប្រទេសរីកចម្រើនតិចតួចក្នុងតតិយលោក និងការផ្ទេរមរតកខាងលើដែលប្រសូតចេញពីវណ្ណៈសង្គម ក៏ដូចជាពាក់-ព័ន្ធនឹងអ្នកគ្រប់គ្រងពីខាងលើនោះ គឺជាកិច្ចការដ៏មានសារៈសំខាន់បំផុតដែលត្រូវតែសិក្សាវិភាគ ជាពិសេស ទាក់ទងនឹងកត្តាផលប្រយោជន៍ជាឫសគល់របស់វា ថាតើវណ្ណៈណាខ្លះ និងស្រទាប់សង្គមណាដែលជាអ្នកកាន់កាប់កម្មសិទ្ធិមធ្យោបាយផលិតកម្ម ថែមទាំងត្រូវសិក្សាអំពីក្រុមមនុស្សសំខាន់ៗ និងបក្សពួករបស់គេ និងសិក្សាអំពីកម្លាំងគ្រប់គ្រងនយោ-បាយរបស់រដ្ឋ ថាតើអំណាចរដ្ឋស្ថិតនៅក្នុងកណ្ដាប់ដៃរបស់ក្រុមណាខ្លះជាដើម។ អាចនិយាយបានថា ការប្រមូលផ្តុំជាវណ្ណៈ ឬស្រទាប់ផ្សេងៗគ្នានៃសង្គមនោះ និងអានុភាពនៃការគ្រប់គ្រងនយោបាយ គឺពិតជាបានកើតចេញពីពូជពង្សនៃខ្សែសន្តានអ្នកដឹកនាំឆ្នើម( The Elite) ឬចេញពីឈាមជ័រអ្នកមានទ្រព្យធនដែលជាបណ្ដើរៗបានញែកខ្លួនចេញពីវណ្ណៈសង្គមថ្នាក់ក្រោម ហើយអត្ថប្រយោជន៍ដែលទទួលបានពីពួកគេ បានស្ដែងឡើងតាមរយៈរូបភាពមួយដែលធ្វើឱ្យកើតមានស្ថិរភាពនយោបាយ និងមានគម្លាតវណ្ណៈដោយប្រយោល។

ក្រោមការដឹកនាំដោយក្រុមមនុស្សដែលជោគជ័យទាំងអស់នោះ ធ្វើឱ្យកើតមានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងប្រពៃដែលស្តែងចេញតាមរយៈផលប្រយោជន៍ជាតិទាំងមូល។ ហេតុដូច្នេះហើយទើបគោលនយោបាយសេដ្ឋកិច្ចសម្រាប់ខាងក្នុង និងក្រៅប្រទេសចាំបាច់ត្រូវតែស្ថាបនាឡើងក្នុងលក្ខណៈឯកភាពគ្នា ឬស្រុះស្រួលគ្នារវាងវណ្ណៈ និងវណ្ណៈ ពិសេសទៅទៀតត្រូវដឹងថា តើមធ្យោបាយផលិតកម្មដែលមានម្ចាស់កម្មសិទ្ធិ បានស្ថិតក្នុងកណ្តាប់ដៃរបស់ក្រុមណាខ្លះ និងត្រូវធ្វើយ៉ាងណាឱ្យមានភាពត្រូវរ៉ូវគ្នារវាងគ្រប់ស្រទាប់វណ្ណៈប្រជាជន ក៏ដូចជាឯកភាពជាមួយអំណាចរដ្ឋដែលដឹកនាំដោយក្រុមមនុស្សឆ្នើមក្នុងសង្គមនោះ។ ដោយមើលឃើញពីសារៈសំខាន់អំពីទំនាក់ទំនងលើគ្រប់ផ្នែកនៃគោលនយោបាយខាងក្រៅប្រទេសដែលជាវិស័យពាក់ព័ន្ធនឹងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ហេតុនេះ តម្រូវឱ្យយើងត្រូវតែធ្វើការយកចិត្តទុកដាក់ខ្ពស់។

ចំពោះមធ្យោបាយជាមូលដ្ឋានក្នុងយុគសម័យនៃទស្សនៈនយោបាយថ្មីស្តីពីទំនាក់ទំនងជាលក្ខណៈការទូតបានធ្វើឱ្យកើតមានសេចក្តីសម្រេចជុំវិញវិធានការសេដ្ឋកិច្ចចាំបាច់មួយចំនួន រួមមានការបង្កើតលក្ខខណ្ឌអភិវឌ្ឍសេដ្ឋកិច្ចខាងក្នុងប្រទេស ការចូលរួមក្នុងបំណែងចែកពលកម្មអន្តរជាតិ ការចូលជាសមាជិកស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ បង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងបំណងការពារ និងរក្សាឱ្យបាននូវបរិយាកាសជុំវិញ។ ម្យ៉ាងទៀត ចំពោះអង្គការ ស្ថាប័ននានា និងចលនាថ្មីៗទៀតក៏ត្រូវតែបំពេញមុខងារផ្នែកទំនាក់ទំនងការទូតនេះដែរ។ រីឯការប្រើប្រាស់បច្ចេកសព្ទខាងវិស័យនយោបាយក៏ត្រូវតែបំពេញតួនាទីជាភាសាការទូតជាមួយមហាជនផងដែរ។

ម្យ៉ាងទៀត ការរៀបចំឱ្យបានប្រសើរប្រកបដោយអានុភាពសេដ្ឋកិច្ចនយោបាយ និងកម្លាំងវណ្ណៈក្នុងសង្គមមួយ ជាចាំបាច់ត្រូវជាប់ទាក់ទងនឹងចំណងជាប្រចាំជាមួយតួនាទីដ៏សំខាន់របស់វាចំពោះលក្ខណៈ ទ្រង់ទ្រាយ

នៃសណ្ឋានសេដ្ឋកិច្ចរបស់ប្រទេស។ ហេតុនេះហើយទើប ក្នុងការសិក្សារបស់យើង តម្រូវឱ្យធ្វើការសិក្សាវិភាគអំពីទំនាក់ទំនងជុំវិញលក្ខណៈនៃទ្រង់ទ្រាយសេដ្ឋកិច្ច ឬសណ្ឋានសេដ្ឋកិច្ចផ្សេងៗគ្នានៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

គេអាចញែកបំបែកសណ្ឋានសេដ្ឋកិច្ចជាពីរលក្ខណៈ គឺបែបប្រពលភាព និងវិបុលភាពនៃការរីកលូតលាស់របស់វា។ ការរីកលូតលាស់បែបប្រពលភាពហាក់ដូចជាបង្ហាញពីឥទ្ធិពលយ៉ាងខ្លាំងក្លា និងសកម្មបំផុតទៅលើជីវិតសេដ្ឋកិច្ចទាំងមូល ហើយបានញ៉ាំងឱ្យខ្សែចង្វាក់សេដ្ឋកិច្ចមានការរីកចម្រើនក្នុងកម្រិតកំពូល។ ទម្រង់ខាងលើនេះទាក់ទងទៅនឹងសណ្ឋានសេដ្ឋកិច្ចរបស់វិស័យរដ្ឋ និងសេដ្ឋកិច្ចពួកនាយទុននិយមឯកជន ព្រមទាំងពាណិជ្ជកម្មតូចតាច។ រីឯការអភិវឌ្ឍសេដ្ឋកិច្ចបែបវិបុលភាពវិញ គឺសំដៅលើការអភិវឌ្ឍដែលមានឥទ្ធិពលជាប្រយោលទៅលើជីវិតសេដ្ឋកិច្ច និងមានឥរិយាបថរីកចម្រើនក្នុងខ្សែចង្វាក់យឺតយ៉ាវបំផុត។ ដោយសារតែសណ្ឋាននៃសេដ្ឋកិច្ចនីមួយៗត្រូវបានទទួលខុសត្រូវដោយក្រុមវណ្ណៈដោយឡែកពីគ្នា និងមានអត្ថប្រយោជន៍សេដ្ឋកិច្ចរៀងៗខ្លួន ដូច្នេះហើយបានជាគោលនយោបាយសេដ្ឋកិច្ចជាតិ រួមទាំងនយោបាយសេដ្ឋកិច្ចក្រៅប្រទេសផងនោះត្រូវតែរៀបចំឡើងដោយឈរលើមូលដ្ឋាននៃផលប្រយោជន៍ដែលមានវិសាលភាពគ្របដណ្តប់ដល់គ្រប់បណ្តាភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។ យ៉ាងណាមិញ នៅប្រទេសកម្ពុជាយើងនាពេលកន្លងមក យើងពិនិត្យឃើញថាបានរៀបគោលនយោបាយសេដ្ឋកិច្ចជាតិរបស់ខ្លួនដែលធ្វើការកំណត់ថាសណ្ឋានសេដ្ឋកិច្ចបែបនេះ ឬប្រភេទបែបនោះមានសារៈសំខាន់ជាងទ្រង់ទ្រាយផ្សេងទៀត ទីបំផុតបានធ្វើឱ្យយើងជួបប្រទះនូវភាពបរាជ័យទាំងស្រុង។ ករណីជាក់ស្តែងដូចជាការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្នុងទសវត្សរ៍ទី៦០ និង៧០ជាដើមដែលហាក់ដូចជាបានយកចិត្តទុកដាក់ខ្ពស់តែទៅលើសណ្ឋានសេដ្ឋកិច្ចជាតិដែលផ្តល់ផលប្រយោជន៍ដល់វណ្ណៈអ្នកមានទ្រព្យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឬពួកនាយទុនប៉ុណ្ណោះ ហើយជាលទ្ធផលចុងក្រោយ បាននាំមកនូវភាព អន្តរាយដល់ខ្លួន ព្រោះតែភាពមិនសប្បាយចិត្តពីសំណាក់កសិករក្រីក្រ ទីបំផុតឈានដល់ការតស៊ូនយោបាយ និងបះបោរផ្តួលរំលំរបបកាន់អំណាច។ ដូចគ្នាដែរ ចំពោះគោលនយោបាយសេដ្ឋកិច្ចក្នុងរបបខ្មែរក្រហមដែលបាន ការពារយ៉ាងមោះមុត តែចំពោះផលប្រយោជន៍កសិករក្រីក្រថ្នាក់ក្រោមដែល ជាទីអវសាន បាននាំមកនូវភាពអន្តរាយដូចគ្នាដល់សេដ្ឋកិច្ចជាតិទាំងមូល។

ក៏ប៉ុន្តែគួរបញ្ជាក់ដែរថា សណ្ឋានសេដ្ឋកិច្ចនីមួយៗ ជាការពិតណាស់ វាបង្ហាញពីឥទ្ធិពលចំពោះសេដ្ឋកិច្ចដោយឡែកៗពីគ្នា សម្រាប់ការតាក់តែង គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់រដ្ឋ ហើយសណ្ឋានសេដ្ឋកិច្ច ដ៏មានឥទ្ធិពលបំផុតនោះ គឺជាសណ្ឋានសេដ្ឋកិច្ចបែបនាយទុនឯកជន និង សេដ្ឋកិច្ចសាធារណៈដែលប្រភេទទាំងពីរនេះ បានធ្វើឱ្យមានការអភិវឌ្ឍ យ៉ាងស្វាហាប់បំផុត។ ម្យ៉ាងវិញទៀត ក្រុមអ្នកតំណាងគ្រប់សណ្ឋានសេដ្ឋកិច្ច ទាំងអស់នោះតែងតែបានចូលរួមសហការដោយផ្ទាល់ផង និងប្រយោលផង ក្នុងដំណើរការតាក់តែងគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេស និងដើម្បី បន្សាំគោលនយោបាយនេះឱ្យបម្រើដល់ផលប្រយោជន៍ទាំងឡាយរបស់ ខ្លួន។ ខាងក្រោមនេះ យើងនឹងពិនិត្យមើលអំពីសណ្ឋាននៃសេដ្ឋកិច្ច-សង្គម របស់ប្រទេសកម្ពុជានាយុគសម័យសាធារណរដ្ឋប្រ ជាមានិតកម្ពុជា ៖

## តារាងលេខ៦
## ទំហំផលិតកម្មសង្គមគ្រប់សណ្ឋានសេដ្ឋកិច្ច គិតជា%

| **បរិយាយ** | **១៩៨៥** | **១៩៨៦** | **១៩៨៧** | **១៩៨៨** | **១៩៨៩** |
|---|---|---|---|---|---|
| ១.វិស័យសេដ្ឋកិច្ចរដ្ឋ | ២១.០៩ | ១៨.៨០ | ១៨.២០ | ១៧.៥០ | ១៦.០០ |
| ២.វិស័យសេដ្ឋកិច្ចនាយទុនឯកជន | ៣៥.៧០ | ៣៨.៤០ | ៣៩.៥០ | ៤០.៦០ | ៤២.៨០ |
| ៣. សេដ្ឋកិច្ចកសិដ្ឋាន | ៤៣.២១ | ៤២.៨០ | ៤២.៣០ | ៤១.៣០ | ៤១.២០ |

**សម្គាល់ ៖** គណនាតាមទិន្នន័យក្រសួងផែនការ, ភ្នំពេញ, ឆ្នាំ១៩៩០, ទំព័រ១០



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមតារាងខាងលើបង្ហាញថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា គឺមានសណ្ឋាន៣យ៉ាង ឬសណ្ឋានចម្រុះ។ ដូច្នេះហើយទើបការសិក្សារបស់យើងភាគច្រើនបានផ្តោតទៅលើការសិក្សាវិភាគអំពីរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គម ជាពិសេសអំពីទំនាក់ទំនងរបស់វាជាមួយគ្រប់ទម្រង់កម្មសិទ្ធិក្នុងផលិតកម្មសង្គមសរុប ព្រមទាំងសិក្សាពីឥទ្ធិពលរបស់វាទៅលើឥរិយាបថនៃកំណើនសេដ្ឋកិច្ចជាតិ។

ដូចដែលអ្នកប្រាជ្ញសូវៀត គឺលោក P. I. Polchikov បានលើកឡើងថា «គ្រប់សណ្ឋានសេដ្ឋកិច្ចគឺមានលក្ខណៈឯករាជ្យម្ចាស់ការ និងប៉ិនប្រសប់ជំរុញដល់ការរីកលូតលាស់ដោយខ្លួនឯង»។ បញ្ហាសណ្ឋានសេដ្ឋកិច្ចចម្រុះខាងលើនេះត្រូវបានបកស្រាយយ៉ាងល្អក្នុងប្រកពអក្សរសិល្ប៍សេដ្ឋកិច្ចសូវៀត។ ក៏ប៉ុន្តែ មានអ្នកប្រាជ្ញខ្លះបានសិក្សាវិភាគដោយឈរលើស្ថានភាពទ្រឹស្តីនេះ ប៉ុន្តែបានបកស្រាយក្នុងលក្ខណៈលម្អៀង និងផ្តល់តម្លៃជាអាទិភាពដាច់ខាតទៅរកទម្រង់មួយដែលខ្ពស់ជាងទម្រង់មួយទៀត។ នៅទីបំផុតទម្រង់អន់ថយបែរជាមានស្ថានភាពល្អប្រសើរជាង។ យ៉ាងណាក៏ដោយនៅដំណាក់កាលក្រោយមកទៀតក្នុងអក្សរសិល្ប៍សេដ្ឋកិច្ចសូវៀតក៏បានចាប់ផ្តើមពិនិត្យឡើងវិញនូវវិធីសាស្ត្រសិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍសេដ្ឋកិច្ចរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍ ប៉ុន្តែនិន្នាការនៃការពិចារណាឡើងវិញនេះក៏ហាក់ដូចជានៅតែទន់ទោរទៅរកទំនោរមួយជុំវិញទស្សនៈទានបែបសេដ្ឋកិច្ចអន្តរកាលឆ្ពោះទៅរកទ្រង់ទ្រាយសេដ្ឋកិច្ចផែនការនៃលិទ្ធិសង្គមនិយមដែលរបកគំហើញបែបនេះ មិនសូវឆ្លើយតបទៅនឹងសភាព-ការណ៍ពិតរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍទាំងនោះឡើយ បើទោះបីជាគេបានជ្រើសរើសមាគ៌ាអភិវឌ្ឍមួយបែបមិនមែនជាមូលធននិយមក៏ដោយ។

ផ្សេងពីនេះទៀត គោលបំណងនៃការសិក្សាវិភាគយ៉ាងសំខាន់របស់យើងស្ថិតនៅលើការកំណត់អំពីអត្ថន័យនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមរបស់ប្រទេសសំដៅលើការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសប្រកប

ដោយប្រសិទ្ធភាព។ ក្នុងកិច្ចការនេះ យើងពិនិត្យឃើញថា រចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជាហាក់ដូចជាមិនទាន់បានរំលេចចេញជារូបរាងពិតប្រាកដនៅឡើយទេ ហើយបាន និងកំពុងស្វែងរកដំណើរការជាថាមវន្ត ជុំវិញការបង្កជាវណ្ណៈផ្សេងៗពីស្រទាប់សង្គមដែលក្នុងបញ្ហានេះរដ្ឋាភិបាលក៏ពុំទាន់បានកំណត់ជាក់លាក់ និងផ្តល់ជាទិន្នន័យត្រឹមត្រូវថាតើស្រទាប់ណាខ្លះបានស្ថិតក្នុងលំដាប់នៃវណ្ណៈបែបណានោះទេ។ ជាក់ស្តែងមូលដ្ឋានគ្រឹះដែលប្រទាក់ក្រឡាក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមនៅកម្ពុជាបានដំណើរការជាមួយនឹងសណ្ឋានសេដ្ឋកិច្ចបែបចម្រុះ បើទោះបីជាទំនាក់-ទំនងរវាងទម្រង់សេដ្ឋកិច្ច និងក្រុមវណ្ណៈក្នុងសង្គមខ្មែរនាសម័យកាលនោះហាក់ដូចជាមានលក្ខណៈមិនទាន់ត្រូតស៊ីគ្នាទាំងស្រុងទៅនឹងសណ្ឋានសេដ្ឋកិច្ចនីមួយៗរបស់វា ព្រោះមានស្រទាប់វណ្ណៈខ្លះដែលស្ថិតក្នុងសណ្ឋានដូចគ្នា តែមានលំដាប់កម្រិតសេដ្ឋកិច្ចផ្សេងៗគ្នានៅឡើយ។ ត្រង់ចំណុចនេះយើងឃើញថា រដ្ឋាភិបាលបានធ្វើការព្យាយាមតាមរយៈការសម្តែងចេញនូវសកម្មភាពនានា និងផ្តល់ជាអត្ថប្រយោជន៍យ៉ាងធំធេង សម្រាប់គ្រប់សណ្ឋានសេដ្ឋកិច្ចទាំងអស់ ដោយខិតខំប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនទៅលើភ្នាក់ងារទាំងឡាយក្នុងវិស័យទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ និងទៅលើបណ្តាញសង្គមរបស់បណ្តាប្រទេសដទៃទៀតក្នុងគោលបំណងបង្កើតឱ្យមានឱកាសសេដ្ឋកិច្ច សម្រាប់ប្រទេសរបស់ខ្លួន និងអាចធ្វើការបត់បែនគោល-នយោបាយសេដ្ឋកិច្ចសម្របសម្រួលទៅតាមស្ថានភាពពិតនៃពិភពលោក។

យោងតាមទ្រឹស្តីខ្លះបង្ហាញថា គោលនយោបាយសេដ្ឋកិច្ច ក្នុងនោះរួមទាំងនយោបាយសេដ្ឋកិច្ចក្រៅប្រទេសផងដែរ បានសម្តែងឡើងនូវឆន្ទៈរបស់ខ្លួនក្នុងការកំណត់ក្រុមអ្នកដឹកនាំសង្គម ស្រទាប់វណ្ណៈសំខាន់ៗ និងអ្នកដឹកនាំឆ្នើម។ ក្រុមមនុស្សសំខាន់ៗទាំងនោះបានស្ថិតក្នុងជួរអ្នកគ្រប់គ្រងក្បាលម៉ាស៊ីនរដ្ឋដែលអាចដឹកនាំនយោបាយក្នុងទិសដៅឆ្ពោះទៅរកការទទួលបាននូវអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងក្នុងប្រទេសក៏ដូចជានៅក្នុងទំនាក់-

ទំនងសេដ្ឋកិច្ចក្រៅប្រទេស។ អត្ថប្រយោជន៍សេដ្ឋកិច្ចទាំងអស់នេះគឺបាន ដើរស្របគ្នាជាមួយនឹងផលប្រយោជន៍នៃក្រុមផ្សេងៗទៀតនៅក្នុងសង្គម ក្នុង លក្ខណៈជាគោលដៅរួមមួយ ហើយភាពជោគជ័យនេះ ក៏ដោយសារតែ ការត្រៀមខ្លួនបានល្អពីគ្រប់ស្រទាប់នៃសណ្ឋានសេដ្ឋកិច្ចទាំងអស់ឆ្ពោះទៅ រកការឯកភាពគ្នាដែលអាចទទួលយកបានគ្រប់ភាគី។ ប៉ុន្តែគួរបញ្ជាក់ថា ស្ថានភាពទំនាក់ទំនងផ្ទៃក្នុងនៃវណ្ណៈសំខាន់ៗទាំងនោះតែងតែកើតមាន បញ្ហាជារឿយៗពាក់ព័ន្ធទៅនឹងការបែងចែកជាស្រទាប់វណ្ណៈ និងកើតមាន បញ្ហាទំនាស់ទស្សនៈគ្នា ហើយជាញឹកញាប់បានបង្កើតជាបក្សពួកនិយម ផ្អែកលើស្ថានភាពសេដ្ឋកិច្ចនៃក្រុមនីមួយៗ។ ជាងនេះទៀត វណ្ណៈទាំងនោះ គឺមានចំណាប់អារម្មណ៍ក្នុងកម្រិតផ្សេងៗគ្នាទៅលើសកម្មភាពការងារនៃ ការកំណត់ខ្លឹមសារនៃការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស។

ទិដ្ឋភាពខាងលើនេះ ជាញឹកញាប់បានសម្តែងចេញនូវវិធីសាស្ត្រ ឬ ជាគំនិតផ្សេងៗចំពោះកិច្ចការជាចម្បងនៃការរៀបចំគោលនយោបាយ សេដ្ឋកិច្ចក្រៅប្រទេសពីសំណាក់វណ្ណៈសង្គមនានា និងពីការបង្រួបបង្រួម ខាងសេដ្ឋកិច្ចដែលនាំឱ្យកើតមានផលប្រយោជន៍ដល់សង្គម និងប្រទេស ជាតិទាំងមូល។

ផ្សេងពីនេះទៀត ចំពោះរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមរបស់ប្រទេស អាចឆ្លុះបញ្ចាំងអំពីកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច លក្ខណៈពិសេសជុំវិញ ផលិតកម្មសាឡើងវិញរបស់វា។ រីឯសក្តានុពលសេដ្ឋកិច្ចរបស់រដ្ឋអាចក្លាយ ជាកត្តាដ៏សំខាន់មួយក្នុងចំណោមកត្តាចាំបាច់ផ្សេងៗទៀតដែលចូលរួមក្នុង ដំណើរការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស។ ពិសេសទៅ ទៀត ការដែលអាចឈានដល់កម្រិតនៃការរីកលូតលាស់នូវអានុភាពផលិត-កម្មសង្គមរបស់ប្រទេស គឺអាស្រ័យដោយកត្តាតម្រូវការពីខាងក្រៅប្រទេស ដែលចេះតែមានការកើនឡើងជាលំដាប់ ហើយស្របជាមួយគ្នានេះនាំឱ្យ មានការយកចិត្តទុកដាក់ទៅលើការផ្គត់ផ្គង់ផ្អែកពីខាងក្នុងប្រទេសក្នុង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លក្ខណៈជាការបណ្ដាក់ទុនវិនិយោគម៉ាស៊ីនផលិតកម្ម ឬធនធានអ្នកឯកទេស ហើយអាចជាឱកាសនៃការប្រើប្រាស់សក្ដានុពលទាំងអស់នេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន ក្នុងទិសដៅជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ដោយឡែក ការបង្រួបបង្រួមសហគ្រាសសេដ្ឋកិច្ច និងភាពឯករាជ្យនៃសណ្ឋានសេដ្ឋកិច្ចនីមួយៗ ដោយសារតែកត្ដាជំរុញពីទីផ្សារខាងក្រៅប្រទេសជាហេតុនាំឱ្យមានការលើកកម្ពស់ខ្លឹមសារ និងតម្លៃនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស។ ម្យ៉ាងវិញទៀត កិច្ចការនេះគឺនាំមកនូវភាពរុងរឿងដល់គ្រប់សមាសភាគសេដ្ឋកិច្ចទាំងអស់ក្នុងក្របខ័ណ្ឌនយោបាយក្រៅប្រទេសរបស់រដ្ឋ។

គួរបញ្ជាក់ថា គោលនយោបាយក្រៅប្រទេសរបស់ប្រទេសណាក៏ដោយ តែងតែកើតចេញពីការបន្ដពីគោលនយោបាយខាងក្នុងប្រទេសដែលបានឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងគ្នានូវអានុភាពវណ្ណៈក្នុងសង្គមនោះ និងដំណើរការឡើងអាស្រ័យដោយមានផលប្រយោជន៍ដល់ពួកអ្នកដឹកនាំផ្ដើមក៏ដូចជាមានផលប្រយោជន៍ដល់វណ្ណៈ និងស្រទាប់សង្គមដែលមានលំដាប់ខ្ពស់ក្នុងប្រទេសនោះ។ ចំពោះផលប្រយោជន៍របស់វណ្ណៈខាងលើនេះ គឺមានឥទ្ធិពលជាវិជ្ជមានក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសដែលទស្សនវិស័យដ៏ចម្បងនេះហាក់ដូចជាបានសម្ដែងឡើងមិនមែនជាផលប្រយោជន៍របស់វណ្ណៈណាមួយនោះទេ តែជារបស់ជាតិ។ ពាក់ព័ន្ធនឹងគោលនយោបាយនេះ លោក V. I. Lenin ក៏បានចូលរួមចំណែកក្នុងការស្រាវជ្រាវដោយបានលើកឡើងថា «ដួងកែវជាឫសគល់ដែលជ្រៅបំផុតនោះ ពោលគឺទាំងគោលនយោបាយខាងក្នុងក៏ដូចជាខាងក្រៅរបស់ប្រទេស គឺរដ្ឋជាអ្នកកំណត់អំពីផលប្រយោជន៍សេដ្ឋកិច្ច និងអំពីស្ថានភាពសេដ្ឋកិច្ចរបស់វណ្ណៈទាំងនោះ និយាយជារួម គឺមានតែរដ្ឋប៉ុណ្ណោះ»។ ពិសេសទៅទៀតនោះ ភាពជាទំនាក់ទំនងរវាងគោលនយោបាយខាងក្នុង និងក្រៅប្រទេសត្រូវតែមានសភាពទន់ភ្លន់ ងាយបត់បែន ឬរស់រវើក។ មានន័យថា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ការអភិវឌ្ឍគោលនយោបាយសេដ្ឋកិច្ចសម្រាប់ខាងក្នុង និងក្រៅប្រទេសមិនត្រូវស្ថិតនៅដដែលៗនោះទេ ព្រោះបរិយាកាសក្រៅប្រទេស ជានិច្ចកាល មានការផ្លាស់ប្តូរ ហើយជាញឹកញាប់មិនបានឆ្លើយតបទៅនឹងផលប្រយោជន៍របស់ជាតិខ្លួនទេ។ ដូច្នេះហើយបានជាផែនការសេដ្ឋកិច្ចសម្រាប់រយៈពេលខ្លី(ពី១ឆ្នាំទៅ៣ឆ្នាំ)មួយចំនួនគឺមានលក្ខណៈមិនស៊ីគ្នាជាមួយនឹងគោលនយោបាយសេដ្ឋកិច្ចខាងក្រៅប្រទេសឡើយ និងមានផ្នែកខ្លះក៏មិនបានឆ្លើយតបទៅនឹងគោលនយោបាយខាងក្នុងប្រទេសទៀតផង។ ម្យ៉ាងវិញទៀត ការប្រែប្រួលបរិយាកាសខាងក្នុង ក៏ដូចជាខាងក្រៅប្រទេស ជារឿយៗបានធ្វើឱ្យកើតមានបញ្ហាមួយចំនួនជុំវិញការផ្តាច់ទំនាក់ទំនងរវាងអ្វីៗដែលបានកំណត់រួចហើយជាមួយនឹងផែនការដែលបានគ្រោងទុករបស់រដ្ឋ។

## ១.២.២ លក្ខណៈពិសេសនៃសណ្ឋានសេដ្ឋកិច្ចកម្ពុជា និងបទពិសោធន៍ចុងទសវត្សរ៍ឆ្នាំ១៩៨០

ដោយសារតែកត្តាតម្លៃអត្ថន័យដ៏ធំធេងជុំវិញការសិក្សាវិភាគអំពីរចនាសម្ព័ន្ធនៃសេដ្ឋកិច្ច-សង្គម និងនយោបាយដែលពាក់ព័ន្ធនឹងការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស ហេតុនេះ តម្រូវឱ្យយើងឈានទៅពិនិត្យមើលអំពីស្ថានភាពនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងសណ្ឋានជាសេដ្ឋកិច្ចមានលក្ខណៈប្រភេទទ្រង់ទ្រាយចម្រុះ។

យើងដឹងថា វិស័យសេដ្ឋកិច្ចត្រូវបានដើរតួនាទីចម្បងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ យើងអាចពន្យល់បានមិនត្រឹមតែភាពអន់ថយនៃវិស័យអាជីវកម្មឯកជនរបស់ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការតស៊ូទាមទាររបស់អ្នកដឹកនាំខ្មែរនាសម័យកាលនោះឆ្ពោះទៅកាន់ការប្តេជ្ញាចិត្តក្នុងតួនាទីរបស់រដ្ឋដែលជាក្បាលម៉ាស៊ីន ឬជាកងចក្រធ្វើដំណើរឈានទៅ

រកលទ្ធិសង្គមនិយមថែមទៀតផង។ យើងឃើញថា រចនាសម្ព័ន្ធសេដ្ឋកិច្ច បែបរដ្ឋបាលបញ្ជា គឺជាគំរូ ឬម៉ូឌែលដ៏ផូផង់មួយក្នុងលក្ខខណ្ឌនៃប្រទេស ដែលមានសង្គ្រាមស៊ីវិល។ ហេតុនេះហើយបានជាបន្ទាប់ពីបានផ្តួលរំលំ របបខ្មែរក្រហមភ្លាម ប្រទេសកម្ពុជាបានចាប់ផ្តើមឡើងនូវដំណើរការធ្វើរដ្ឋ តូបនីយកម្ម(ជាតូបនីយកម្ម)នូវសហគ្រាសឧស្សាហកម្ម និងបានធ្វើការ ពិនិត្យលើនិន្នាការនៃមនោគមវិជ្ជាមួយតាមរយៈយន្តការនៃការស្តាបនា មូលដ្ឋានសម្ភារបច្ចេកទេសបាញ់ឆ្ពោះទៅរកលទ្ធិសង្គមនិយម។ ឈរលើ ទស្សនៈគោលនយោបាយបែបនេះ កម្មសិទ្ធិរដ្ឋត្រូវបានប្រកាសជាឱឡារិក ថា ជាកម្មសិទ្ធិសង្គមនិយម(កម្មសិទ្ធិសមូហភាព)។ ពោលគឺទំហំវិស័យ សេដ្ឋកិច្ចរបស់រដ្ឋនាសម័យកាលនោះ ត្រូវបានគេវាយតម្លៃថា មានការស្តារ ឡើងវិញយ៉ាងឆាប់រហ័សនៅក្នុងដំណើរនៃជីវិតសេដ្ឋកិច្ច-សង្គមរបស់ប្រទេស កម្ពុជា ដោយបានពង្រីកទំហំវិស័យសេដ្ឋកិច្ចរដ្ឋដែលជាគោលដៅយ៉ាង ដាច់ខាតនៃគោលនយោបាយសេដ្ឋកិច្ចរដ្ឋាភិបាល។ សកម្មភាពទាំងអស់ នេះបាននាំទៅរកភាពផ្តាច់មុខរបស់រដ្ឋលើគ្រប់វិស័យសេដ្ឋកិច្ចជាតិទាំងមូល ដែលរដ្ឋាភិបាលបានអន្តរាគមន៍ដោយផ្ទាល់នៅក្នុងជីវិតសេដ្ឋកិច្ចជាតិ។ ការធ្វើមជ្ឈការអំណាចដ៏ស្រួចស្រាវក្នុងវិស័យសេដ្ឋកិច្ចរហូតដល់ឆ្នាំ១៩៨៩ បែបនេះបានធ្វើឱ្យរោងចក្រសហគ្រាសរបស់រដ្ឋតែមួយចំនួនតូចប៉ុណ្ណោះ បានទទួលផលចំណេញ។ រីឯរោងចក្រសហគ្រាសរបស់រដ្ឋភាគច្រើនទៀត បានរស់នៅក្នុងលក្ខណៈរដ្ឋឧបត្ថម្ភធន។ ចំពោះមូលហេតុដ៏ចម្បងនៃភាព ក្ស័យធនរបស់សហគ្រាសរដ្ឋគឺពាក់ព័ន្ធនឹងយន្តការសេដ្ឋកិច្ចបែបបង្គាប់ បញ្ជារួមមាន ៖ គោលនយោបាយកំណត់ថ្លៃទំនិញមិនច្បាស់លាស់ មជ្ឈការ អំណាច កង្វះការប្រកួតប្រជែង គ្មានការលើកទឹកចិត្ត និងប្រព័ន្ធធនាគារ មិនរីកចម្រើនជាដើម។

ដោយយល់អំពីការធ្វើឱ្យមានកំហុសធ្ងន់ធ្ងរកន្លងមក ទើបនៅពាក់ កណ្តាលឆ្នាំ១៩៨៩ រដ្ឋាភិបាលបានសម្រេចចិត្តធ្វើកំណែទម្រង់សេដ្ឋកិច្ច


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាលើកដំបូងនៅក្នុងវិស័យឧស្សាហកម្មដោយជ្រើសរើសមាត់ ឯកជន ភាវូបនីយកម្មសហគ្រាសរដ្ឋចំពោះពេងចក្រមួយចំនួន។ ជាលទ្ធផល យើងឃើញថា ទំហំផលិតផលសង្គមសរុបបានថយចុះពី២១,១%នៅឆ្នាំ១៩៨៥ មកនៅត្រឹម១៦%នៅចុងឆ្នាំ១៩៨៩។ ប៉ុន្តែ យើងក៏មិនអាចមើលរំលងអំពីតួនាទីរបស់រដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិនោះទេ។ បើតាមបទពិសោធន៍ទាំងឡាយរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍដែលមានការរីកលូតលាស់ជាមួយនឹងបែបផែនសេដ្ឋកិច្ចទីផ្សារសេរី បានបង្ហាញថា ក្រោមការទទួលខុសត្រូវក៏ដូចជាការត្រួតពិនិត្យរបស់រដ្ឋទៅលើវិស័យសេដ្ឋកិច្ចជាយុទ្ធសាស្ត្រ និងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗដែលក្នុងតម្លៃនេះ រដ្ឋគឺពិតជាបានរួមចំណែកយ៉ាងសកម្ម និងសំខាន់បំផុតដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ រដ្ឋអាចធ្វើសកម្មភាពដោយប្រយោលទៅលើដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាតាមរយៈនយោបាយនៃការបង្កើតថ្លៃ នយោបាយពន្ធ ការវិនិយោគរបស់រដ្ឋ និងគោលនយោបាយឥណទានជាដើម។ រដ្ឋាភិបាលមានតួនាទីសំខាន់បំផុតលើកិច្ចការសម្របសម្រួលដល់កម្មវិធីនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។

ឥទ្ធិពលដ៏ធំធេងមិនអាចកាត់ថ្លៃបានចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជានាសម័យនោះ គឺពាក់ព័ន្ធនឹងការចូលរួមពីវិស័យសេដ្ឋកិច្ចឯកជនតែម្តង។ ជាក់ស្តែង នៅឆ្នាំ១៩៨៣ ទំហំចំណែកវិស័យសេដ្ឋកិច្ចឯកជនបានគ្របដណ្តប់រហូតដល់៤២,៣%នៃផលិតផលសង្គមសរុប។ ប៉ុន្តែនៅដើមទសវត្សទី៨០ រដ្ឋាភិបាលមិនត្រឹមតែមិនបានឱ្យតម្លៃណាមួយទៅលើតួនាទីនៃវិស័យឯកជននោះទេ ថែមទាំងទប់ស្កាត់ការរីកពលដាលរបស់សេដ្ឋកិច្ចឯកជនថែមទៀតផង។ ផែនការចំពោះមុខ គឺបានប្រើប្រាស់មនោគមវិជ្ជាអូសទាញបញ្ចុះបញ្ចូលដែលផ្ទុយពីការចង់បានរបស់ប្រជាពលរដ្ឋ ព្រមទាំងបានព្យាយាមរារាំងដល់ការប្រសូតឡើងនូវពពួកមូលធននិយម( នាយទុន )ធំៗរបស់ប្រទេស។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៨៩ រដ្ឋបានចាប់ផ្តើមពិចារណាឡើងវិញក្នុងលក្ខណៈស៊ីជម្រៅពីអត្ថប្រយោជន៍នៃវិស័យសេដ្ឋកិច្ចឯកជនដែលបានធ្វើឱ្យរដ្ឋមើលឃើញ និងចាត់ទុកថា ទម្រង់វិស័យឯកជនជាទស្សនៈវិស័យដ៏ពិសិដ្ឋមួយនៃគោលនយោបាយសេដ្ឋកិច្ចជាតិ។ លក្ខណៈពិសេសនៃការអភិវឌ្ឍមូលធនឯកជនរបស់ជាតិមានការទាក់ទងនឹងលក្ខណៈពិសេសនៃសកម្មភាពសេដ្ឋកិច្ចរបស់វា ព្រោះថា អ្នកចូលរួមហាក់ដូចជាចង់បង្ហាញបំណងរបស់ខ្លួននៃការបណ្តាក់ទុនវិនិយោគ ហើយជាអាទិភាពនោះគឺចំពោះវិស័យពាណិជ្ជកម្ម និងសេវាកម្មដែលទំហំដើមទុនវិនិយោគជាដំបូងមិនសូវធំធេងនោះទេ រីឯសាច់ប្រាក់សម្រាប់បង្វិលវិញក៏មានល្បឿនលឿនជាងវិស័យសេដ្ឋកិច្ចដទៃដែរ។ ជាក់ស្តែង វិស័យពាណិជ្ជកម្មមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅប្រទេសកម្ពុជានាសម័យនោះ បើប្រៀបធៀបទៅនឹងវិស័យសេដ្ឋកិច្ចផលិតកម្មផ្សេងៗទៀតដែលមានបច្ចេកទេសស្មុគស្មាញ ហើយវិស័យពាណិជ្ជកម្មក៏មានការពាក់ព័ន្ធតិចតួចផងដែរលើកិច្ចការច្បាប់ទម្លាប់(ក្រឹត្យក្រមគតិយុត្តិ)។ វិស័យពាណិជ្ជកម្មក្នុងស្រុក ជាតុពិតគឺជាសកម្មភាពនៃការបន្ត ឬការតភ្ជាប់ពីពាណិជ្ជកម្មក្រៅប្រទេសដែលផ្គត់ផ្គង់ទំនិញនៅលើទីផ្សារក្នុងបរិមាណច្រើនជាងវិស័យផលិតកម្មក្នុងស្រុក។ ជាងនេះទៀត យើងឃើញថា វិស័យឯកជនក៏បានដើរតួនាទីចម្បងផ្នែកចែក-ចាយទំនិញស្ទើរគ្រប់ទីកន្លែងនៃប្រទេស ហើយទំហំចំណែករបស់វាមានរហូតដល់ប្រមាណ៨០%ទៅ៨៥%ក្នុងទង្វើជាលក្ខណៈលក់រាយ ហើយ៩០%នៃទំនិញគឺជាផលិតផលគ្រឿងឧបភោគបរិភោគ។ ពិសេសជាងនេះទៀត យន្តការនៃវិស័យពាណិជ្ជកម្មក្នុងស្រុកបានសម្តែងឡើង ព្រមទាំងធ្វើជាអ្នកកំណត់តម្លៃទំនិញស្ទើរគ្រប់មុខនៅលើទីផ្សារ កំណត់អត្រាប្តូរប្រាក់រៀលជាមួយនឹងរូបិយប័ណ្ណបរទេស និងការកំណត់តម្លៃដុំមាសនិងត្បូងពេជ្រមានតម្លៃជាដើម។ ដូច្នេះហើយទើបវិស័យសេដ្ឋកិច្ចឯកជននាសម័យកាលនោះបានក្លាយជាវិស័យមួយដែលបង្កើតបានជាសំណុំនៃចំណុច


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសព្វរវាងវិស័យសេដ្ឋកិច្ចទាំងមូលនៅក្នុងប្រទេសកម្ពុជា។

ចំពោះវិស័យឧស្សាហកម្មឯកជនវិញ ភាគច្រើនមានលក្ខណៈជាសហគ្រាសខ្នាតតូចៗ ឬមធ្យមដែលជាទូទៅមានបុគ្គលិក-កម្មករប្រមាណពី៥ទៅ៦០នាក់។ សហគ្រាសទាំងនេះ រួមមានរោងចក្រឧស្សាហកម្មធុនស្រាល និងឧស្សាហកម្មចំណីអាហារដែលទទួលបានអត្រាប្រាក់ចំណេញខ្ពស់ និងមានលក្ខណៈងាយស្រួលដល់ការស្រង់ដើមទុនរបស់ខ្លួនមកវិញដែលបានចំណាយក្នុងការវិនិយោគកន្លងមក។ ស្របជាមួយគ្នានេះដែរដំណើរការប្រមូលផ្ដុំទុនវិនិយោគនៅក្នុងវិស័យនេះបានកើតមានឡើងក្នុងសភាពយឺតយ៉ាវក្រៃលែង និងមានដែនកំណត់ ព្រោះដោយសារតែបញ្ហាអវត្តមាននៃទម្រង់សេដ្ឋកិច្ចទំនើបដែលអាចឱ្យគេបោះពុម្ពសញ្ញាប័ណ្ណភាគហ៊ុនរបស់សហគ្រាស និងគ្មានទីផ្សារមូលបត្រ។

ចំណែកឯនៅក្នុងវិស័យសេដ្ឋកិច្ចកសិកម្មវិញបានបង្ហាញថា ប្រទេសកម្ពុជានាសម័យកាលនោះមានលក្ខណៈជាសេដ្ឋកិច្ចបែបមូលធននិយមដែលនៅខណៈនោះ មិនទាន់រីកចម្រើនទូលំទូលាយនៅឡើយទេ។ ចំពោះស្ថានភាពសេដ្ឋកិច្ចដ៏សំខាន់បំផុតក្នុងវិស័យនេះគឺទាក់ទងទៅនឹងផលទុនសម្រាប់ការប្រមូលទិញផលិតផលកសិកម្ម និងការលក់ដូរផលិតផលដែលជាសេចក្ដីត្រូវការចាំបាច់របស់ប្រជាជននៅតំបន់ជនបទ។ ជាទូទៅ ការធ្វើសកម្មភាពសេដ្ឋកិច្ចរបស់កសិករភាគច្រើនគឺជាម្ចាស់ដីដែលមានកម្មសិទ្ធិតូចៗប៉ុណ្ណោះ ហើយបានកាន់កាប់ដីធ្លីពី១ទៅ៣ហិកតា។ បន្ទាប់ពីបានធ្វើការរំលាយក្រុមសាមគ្គីបង្កបង្កើនផល(សហករណ៍កសិកម្ម)នៅក្នុងខែមេសា ឆ្នាំ១៩៨៩រួចមក យើងពិនិត្យឃើញថា ធនធានដីធ្លីត្រូវគេបែងចែកឱ្យគ្រួសារកសិករនៅជនបទក្នុងទំហំសមាមាត្រស្របតាមច្បាប់ភូមិបាលដែលបានកំណត់។ ហេតុនេះហើយទើបបានជានៅតំបន់ជនបទក្នុងសម័យកាលនោះ យើងពុំឃើញមានគ្រួសារប្រជាកសិករណាមួយគ្មានដីធ្លីសម្រាប់ប្រកបរបរកសិកម្មនោះទេ ហើយក៏ពុំទាន់ឃើញមានការប្រមូលផ្ដុំដីធ្លីក្នុង


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទំហំធំៗនៅក្នុងដៃបុគ្គលណានោះដែរ។ គ្រួសារកសិករខ្មែរយើងភាគច្រើនគឺជាអ្នកផលិតទំនិញកសិកម្មខ្នាតតូចដែលការងារចម្បងរបស់ពួកគេសម្រាប់តែការដោះស្រាយបញ្ហាជីវភាពរស់នៅតែប៉ុណ្ណោះ ជាមួយនឹងការប្រើប្រាស់ពលកម្មផ្ទាល់ខ្លួន និងពលកម្មក្នុងសមាជិកគ្រួសាររបស់ពួកគេ។ នៅឆ្នាំ១៩៨៩ ទំហំកសិដ្ឋានរបស់កសិករមានសណ្ឋានតូចៗដែលបរិមាណទិន្នផលរបស់គេបានគ្របដណ្ដប់រហូតដល់៦១,២%នៃផលិតផលសង្គមសរុប។ ទាក់ទងនឹងទម្រង់សេដ្ឋកិច្ចពាណិជ្ជកម្មតូចៗទាំងនោះមានចរិតលក្ខណៈជាអាទិភាពទៅលើកំណើនបែបវិបុលភាព(បែបយថាហេតុ)ដែលផ្សាភ្ជាប់ការផលិតទៅនឹងទំនិញកសិកម្ម និងមានដំណើរការផលិតបែបធម្មជាតិ ហើយទម្រង់នេះដែរបានដើរតួនាទីជាមូលដ្ឋានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជានាសម័យនោះ។ គួរបញ្ជាក់ថា ការសិក្សាស្រាវជ្រាវអំពីកម្រិតជីវភាពរបស់កសិករដែលមានលក្ខណៈផ្សេងៗគ្នានៅកម្ពុជាគឺជាកិច្ចការដ៏លំបាកមួយ ព្រោះតែបញ្ហាកង្វះទិន្នន័យស្ថិតិគ្រប់គ្រាន់។ បើពិនិត្យមើលទៅលើការប្រើប្រាស់ការជួលកម្លាំងពលកម្មវិញ នៅសម័យនោះ ហាក់មិនសូវមានការរីកលូតលាស់នោះទេ សម្រាប់តំបន់ជនបទហេតុនេះហើយទើបសូចនាករដែលអាចទុកចិត្តបានស្ដីអំពីកំណើននៃភាពមិនស្មើគ្នានៃទ្រព្យធនរបស់គេបានក្លាយជាប្រធានបទនៃការបែងចែកធន-ធានដីធ្លីស្រែចម្ការក៏ដូចជាការបែងចែកឧបករណ៍ពលកម្មសម្រាប់វិស័យកសិកម្ម។

បន្ទាប់ពីបានអនុវត្តច្បាប់ស្ដីពីកម្មសិទ្ធិឯកជនលើដីធ្លី នៅឆ្នាំ១៩៨៩ យើងឃើញថា ដីស្រែចម្ការរបស់ក្រុមប្រវាស់ដៃ(សហករណ៍កសិកម្ម)ត្រូវបែងចែកទៅឱ្យកសិករដោយគ្មានការបង់ប្រាក់។ ចំពោះទំហំផ្ទៃដីដែលតម្រូវឱ្យគ្រួសារកសិករអាចទទួលបាននោះ គឺអាស្រ័យដោយមានទំហំដីបម្រុងទុក(ដីសម្បទានសង្គមកិច្ច) និងដង់ស៊ីតេប្រជាជនដែលរស់នៅតំបន់នោះផងដែរ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.២.៣ ការវិនិយោគជាមួយនឹងដំណើរការឆ្ពោះទៅរកមូលធននិយម

ក្រៅពីវិស័យសេដ្ឋកិច្ចខាងលើនេះ យើងឃើញថា ការវិនិយោគបរទេសនាសម័យនោះហាក់ដូចជាបានដើរតួនាទីយ៉ាងសំខាន់ណាស់ដែរនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ក្នុងលក្ខខណ្ឌដែលប្រទេសកម្ពុជានៅមានបញ្ហាសង្គ្រាមស៊ីវិលនៅឡើយ ព្រមទាំងកង្វះបរិយាកាសសមស្របសម្រាប់ការបណ្តាក់ទុនបរទេស យើងសង្កេតឃើញថា មានក្រុមហ៊ុនបរទេសជាច្រើនបានសម្រេចចិត្តបណ្តាក់ទុនវិនិយោគរបស់ខ្លួននៅកម្ពុជា ប៉ុន្តែជាអាទិភាពគឺតែក្នុងវិស័យពាណិជ្ជកម្មនិងសេវាកម្មសង្គម និងក្នុងវិស័យអាជីវកម្មសណ្ឋាគារតែប៉ុណ្ណោះ។ បើពិនិត្យជារួម យន្តការនៃការទាក់ទាញទុនវិនិ-យោគបរទេសពីសំណាក់រដ្ឋាភិបាលសម័យនោះបានអនុវត្តគោលការណ៍អនុគ្រោះពន្ធយ៉ាងច្រើនចំពោះក្រុមហ៊ុនទាំងនោះ។ ក៏ប៉ុន្តែបញ្ហាសំខាន់ស្ថិតនៅត្រង់ថា បើរដ្ឋាភិបាលមិនទាន់បានធ្វើកំណែទម្រង់សេដ្ឋកិច្ចនោះទេក្រុមហ៊ុនបរទេសក៏មិនទាន់ប្រញាប់ប្រញាល់ចូលមកបណ្តាក់ទុនវិនិយោគរបស់ខ្លួននោះដែរក្នុងសេដ្ឋកិច្ចកម្ពុជា។

នៅប្រទេសកម្ពុជា ទម្រង់វិនិយោគដែលរីកចម្រើនជាងគេនាសម័យនោះគឺការវិនិយោគលើវិស័យពាណិជ្ជកម្ម។ ចំពោះការវិនិយោគទុននៅក្នុងវិស័យឧស្សាហកម្មវិញ ខណៈនោះនៅមិនទាន់ទទួលបានការគាំទ្រច្រើននោះទេ។ ហេតុនេះ អាចឱ្យយើងសំយោគបានថា លទ្ធិមូលធននិយមនៅកម្ពុជានាសម័យកាលនោះកំពុងស្ថិតនៅលើរបត់នៃការចាប់ផ្តើមប្រមូលផ្តុំមូលធនជាប្រាក់ដើមទុន។

បើពិនិត្យជារួម ដូចគ្នានឹងបណ្តាប្រទេសតតិយលោកភាគច្រើនដែរ គឺដំណើរការនៃការប្រែក្លាយខ្លួនឆ្ពោះទៅរកលទ្ធិមូលធននិយមជាតិនៅកម្ពុជាត្រូវបានចាប់ផ្តើមឡើងជាមួយនឹងវិស័យចរាចរទំនិញជាមូលដ្ឋាន។ម្យ៉ាងទៀត បើតាមការប្រៀបធៀបជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍភាគ-ច្រើន យើងពិចារណាឃើញថា លទ្ធិមូលធននិយមនៅកម្ពុជានាសម័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នោះបានស្ថិតនៅលើដំណាក់កាលនៃការកកើតឡើងប៉ុណ្ណោះ។ នៅទីនេះ ពួកពាណិជ្ជករបានប្រមូលផ្តុំគ្នាជាវណ្ណៈដែលកាន់កាប់មធ្យោបាយផលិត-កម្មសង្គម ជាអ្នកកំណត់តម្លៃបន្ថែមលើមុខទំនិញ និងជាអ្នកជួលកម្លាំងពលកម្មដែលស្តែងចេញជារូបភាពសង្គមមួយនៃកំណាកំណើតរបបមូល-ធននិយមមួយ។

កំណើនអានុភាពសេដ្ឋកិច្ចយ៉ាងគំហុកក្នុងការបណ្តាក់ទុនវិនិយោគរបស់ប្រជាពលរដ្ឋនៅកម្ពុជាបែបនេះបានបង្ហាញអំពីឆន្ទៈនៃការកំណត់គោលបំណងរបស់ខ្លួនក្នុងទិសដៅនៃការពង្រឹងគោលជំហរដោយឥតរាថយ ហើយសកម្មភាពរបស់ស្ថាប័នរដ្ឋក៏បានសម្របសម្រួល និងបានទាញយកប្រយោជន៍របស់ខ្លួនមកវិញដែរ។ ការរីកលូតលាស់នូវលទ្ធិមូលធននិយមនៅកម្ពុជាសម័យនោះបានប្រើប្រាស់វិធីសាស្ត្រយ៉ាងច្រើន សម្រាប់ការពង្រឹងឥទ្ធិពលនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួន។ ចំពោះវិធីសាស្ត្រដែលសំខាន់បំផុតនោះគឺសំដៅលើការបង្កើតឱ្យមានទំនាក់ទំនងគ្នាជាមួយនឹងថ្នាក់ដឹកនាំក្បាលម៉ាស៊ីនរដ្ឋបាលថ្នាក់កណ្តាល និងមន្ត្រីរដ្ឋបាលថ្នាក់មូលដ្ឋាន ហើយជាមួយនឹងការជួយជ្រោមជ្រែងរបស់ពួកគេ(អ្នកដឹកនាំ)គឺបានធ្វើឱ្យមានឥទ្ធិពលយ៉ាងខ្លាំងក្លាដល់ការតាក់តែងគោលនយោបាយរដ្ឋ និងដំណើរការនៃការធ្វើសេចក្តីសម្រេចទៅលើកម្មវិធីសេដ្ឋកិច្ចបានជាក់លាក់។

ក្នុងយុគសម័យសេរីភាវូបនីយកម្មនៃជីវិតសេដ្ឋកិច្ចថ្មី យើងពិនិត្យឃើញថា ជុំវិញវត្ថុបំណងនៃការពង្រីកឥទ្ធិពលរបស់ខ្លួនទៅលើក្បាលម៉ាស៊ីនដឹកនាំរដ្ឋ អ្នកតំណាងរបស់ពួកនាយទុនជាតិបានធ្វើសកម្មភាពមួយដោយធ្វើការជ្រើសរើសក្នុងលក្ខណៈជាដៃគូអាជីវកម្មរបស់ខ្លួន ក្នុងនោះមាន ថ្នាក់ដឹកនាំរដ្ឋជាន់ខ្ពស់ មន្ត្រីគណបក្ស ឬមន្ត្រីយោធាក្នុងការបង្កើតជាក្រុមហ៊ុនអាជីវកម្មរួមគ្នា ឬជាសមាគមផ្សេងៗ។ ជាពិសេសទៅទៀតចំពោះការធ្វើទំនាក់ទំនងដោយផ្ទាល់របស់អ្នកតំណាងក្រុមហ៊ុនជាមួយនឹងមន្ត្រីរដ្ឋាភិបាល និងគណបក្សនយោបាយក្នុងទិដ្ឋភាពបែបការិយាល័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធិបតេយ្យដូចនេះបានធ្វើឱ្យគេអាចទទួលបាននូវអាទិភាពជាគន្ទឹះក្រៅផ្លូវច្បាប់ និងអាចឈានដល់ការពង្រឹងស្ថានភាពរបស់ខ្លួនលើចាកអាជីវកម្មដើម្បីទទួលបានមុខតំណែងល្អៗក្នុងក្រុមហ៊ុនឯកជនទៀតផង។ ម្តងម្កាលមន្ត្រីគណបក្សនយោបាយ និងមន្ត្រីយោធាបានធ្វើជាខ្នងបង្អែកដល់តំណាងក្រុមហ៊ុនឯកជនទាំងនោះថែមទៀត។

នៅប្រទេសកម្ពុជានាសម័យកាលនោះ ដោយសារតែបញ្ហាកង្វះវិធានការច្បាប់សមស្របជាផ្លូវការបានធ្វើឱ្យក្រុមហ៊ុនទាំងឡាយមិនបានធ្វើការចុះបញ្ជីឱ្យបានត្រឹមត្រូវនោះទេ ហើយក្នុងករណីភាគច្រើន ក្រុមហ៊ុនទាំងនោះបានចងសម្ព័ន្ធភាពជាមួយគ្នាក្នុងទ្រង់ទ្រាយជាលក្ខណៈគ្រួសារ (ខ្សែស្រឡាយ) ឬការបង្កើតជាសម្ព័ន្ធមិត្ត ឬបក្សពួកនិយមតាមរបៀបនៃការទទួលស្គាល់គ្នា។ ម្យ៉ាងទៀត សម្ព័ន្ធភាពទាំងអស់នេះមានការគ្រប់គ្រងជារចនាសម្ព័ន្ធក្នុងបែបផែនផលិតកម្ម-ពាណិជ្ជកម្មយ៉ាងជាក់លាក់ដែលបានផ្តល់លទ្ធភាពឱ្យយើងធ្វើជាមូលដ្ឋានគ្រឹះ សម្រាប់ការសិក្សាវិភាគស្តីអំពីវត្តមាននៃក្រុមហ៊ុនឯកជនខ្នាតតូច និងធំនានានៅកម្ពុជា។

## ១.២.៤ សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ប្រទេសកម្ពុជានាសម័យកាលនោះពុំទាន់មានសមាគមអ្នកជំនួញនៅឡើយទេ ក៏ប៉ុន្តែដើម្បីពង្រឹងគោលជំហរនយោបាយរបស់ពួកនាយទុនដែលជាក្រុមហ៊ុនឯកជន ជាពិសេស ក្រុមហ៊ុនខ្នាតមធ្យម និងខ្នាតធំដែលពួកគេបានបង្រួបបង្រួមគ្នាជាលក្ខណៈ«ក្រៅប្រព័ន្ធគតិយុត្តិ»។ ចំពោះការបង្កើតសមាគមអាជីវកម្ម«ក្រៅផ្លូវច្បាប់»ក្រោមការគ្រប់គ្រងរបស់សេដ្ឋីជំនួញណាម្នាក់ដែលមានឥទ្ធិពល បានញ៉ាំងឱ្យកើតមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយនឹងស្ថាប័នគ្រប់គ្រងអំណាចជាន់ខ្ពស់ដែលផ្តល់ជាឱកាសក្នុងការទាមទារទៅលើការដាក់សម្ពាធផ្សេងៗជុំវិញដំណើរការអនុម័តលើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយសេដ្ឋកិច្ច និងនយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋទាំងមូល។

ម្យ៉ាងវិញទៀត ទាក់ទងនឹងសកម្មភាពផ្នែកពាណិជ្ជកម្មក្រៅប្រទេស ដែលបានកើតមានឡើងនៅចុងទសវត្សរ៍ទី៨០ និងដើមទសវត្សរ៍ទី៩០ យើងឃើញថា តាមរយៈការចូលរួមពីសំណាក់ពាណិជ្ជករឯកជន និងមន្ត្រីរដ្ឋាភិបាលដែលស្ថានភាពបែបនេះបង្ហាញនូវសក្ខីភាពមួយស្ដីអំពីការកើតមានឡើងនូវយុគសម័យថ្មីនៃរបត់សេដ្ឋកិច្ច-សង្គមរបស់កម្ពុជាក្នុងនិន្នាការនៃការរីកចម្រើនតាមមាគ៌ាមូលធននិយមប្រកបទៅដោយលក្ខណៈបើកទូលាយ និងចូលជ្រៅទៅក្នុងគំរូប្រទេសឥណ្ឌូណេស៊ី មានន័យថា ជាការច្របាច់បញ្ចូលគ្នារវាងលទ្ធិមូលធននិយមបែបពាណិជ្ជកម្ម និងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។ ទាំងនេះគឺជាស្ថានភាពមួយដែលនាំមកនូវស្វាកស្នាមវប្បធម៌ដ៏មានអានុភាពចំពោះឥរិយាបថនៃការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់ខ្លួន។

ជាងនេះទៀត រចនាសម្ព័ន្ធនៃសេដ្ឋកិច្ច-សង្គមរបស់រដ្ឋបាននាំមកនូវឥទ្ធិពលយ៉ាងធំធេងដល់ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចដែលបានតាក់តែងឡើងស្របតាមក្រឹត្យក្រមច្បាប់សេដ្ឋកិច្ច និងនយោបាយរូបិយវត្ថុជាប្រាក់រៀល។

យើងអាចបញ្ជាក់បន្ថែមទៀតថា គោលនយោបាយជាយុទ្ធសាស្ត្រខាងលើនេះនឹងអាចដំណើរការទៅបាន ហើយក៏នឹងអាចក្លាយជាសកម្មភាពពិតនោះ លុះត្រាតែយុទ្ធសាស្ត្រនេះត្រូវបានតាក់តែងឡើងដោយផ្អែកលើមូលដ្ឋាននៃការអភិវឌ្ឍប្រកបដោយសេរីភាព ហើយមានការចូលរួមពីគ្រប់បណ្ដាសណ្ឋានសេដ្ឋកិច្ចទាំងអស់ដោយគ្មានការលើកតម្កើងចំពោះសណ្ឋានសេដ្ឋកិច្ចណាមួយឱ្យខ្ពស់ជាងគេនោះទេ។ ជាឧទាហរណ៍ ដូចជាយុទ្ធសាស្ត្រនៃការដឹកនាំសេដ្ឋកិច្ចពីអតីតកាលដែលធ្លាប់បានអនុវត្តក្នុងនិន្នាការមួយសំដៅទប់ស្កាត់មុខងាររបស់វិស័យឯកជន និងលើកកម្ពស់តែតួនាទីរបស់វិស័យសេដ្ឋកិច្ចសាធារណៈដែលយុទ្ធសាស្ត្របែបនេះធ្លាប់បាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធ្វើឱ្យយើងរងផលប៉ះពាល់យ៉ាងដំណំ។ ជាងនេះទៀត នៅក្នុងលក្ខខណ្ឌនៃសេដ្ឋកិច្ចដែលពោរពេញទៅដោយទម្រង់ជាច្រើនបែបនេះ បានធ្វើឱ្យគ្រប់សណ្ឋានសេដ្ឋកិច្ចទាំងអស់មានការរីកលូតលាស់ទៅតាមក្រឹត្យក្រមនៃច្បាប់សេដ្ឋកិច្ចផ្ទាល់របស់ខ្លួន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យុទ្ធសាស្ត្រទាំងនេះតម្រូវឱ្យយើងធ្វើការសិក្សាឱ្យបានត្រឹមត្រូវអំពីថាមវន្តនៃរាល់បណ្តាវិស័យទាំងអស់។ ហេតុនេះហើយទើបការបង្កើតពុទ្ធិចំពោះរចនាសម្ព័ន្ធនៃសេដ្ឋកិច្ច-សង្គមជាការចាំបាច់បំផុត សម្រាប់ការចូលរួមចំណែកតាក់តែងគោលនយោបាយសេដ្ឋកិច្ច និងការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍នានា។

## ១.៣ តួនាទីរដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅប្រទេសកម្ពុជា

### ១.៣.១ អត្ថន័យរបស់រដ្ឋ សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍ

បន្ទាប់ពីទទួលបានឯករាជ្យមក ប្រទេសកម្ពុជាយើងបានព្យាយាមស្វែងរកមាគ៌ាអភិវឌ្ឍមួយដែលស័ក្តិសមបំផុតរបស់ខ្លួនតាមរយៈបទពិសោធន៍ជាច្រើន ដើម្បីតម្រង់ទិសឱ្យបានត្រឹមត្រូវ និងដេញឱ្យទាន់បណ្តាប្រទេសមួយចំនួននាពេលខាងមុខ។ នៅសម័យកាលនោះ យើងសង្កេតឃើញថា ប្រទេសកម្ពុជាបានបើកចំហលើគ្រប់ទំនាក់ទំនងទាំងអស់ ក្នុងនោះក៏បានទទួលយកឥទ្ធិពលនានាទាំងផ្នែកទស្សនៈ និងទាំងវិស័យនយោបាយ។ ពិសេសទៅទៀត គ្រប់ទម្រង់អង្គការរដ្ឋ អង្គការសង្គម ស្ថាប័ននយោបាយដែលធ្លាប់មានជាបទពិសោធន៍ ក៏ដូចជាវិធីសាស្ត្រផ្សេងៗទៀត ដែលគេសិក្សារកឃើញជារបកគំហើញអស់រយៈកាលជាច្រើនសតវត្សរ៍កន្លងមករបស់ប្រទេសអភិវឌ្ឍសេដ្ឋកិច្ច ក៏ត្រូវបាននាំយកមកអនុវត្តក្នុងប្រទេសកម្ពុជា និងប្រើប្រាស់បម្លែងឱ្យទៅជាការប្រតិបត្តិជាក់ស្តែងលើគ្រប់វិស័យទាំងអស់ឆ្លើយតបទៅនឹងលក្ខខណ្ឌរបស់ប្រទេសកម្ពុជា។ ជាងនេះទៀត ចំពោះកិច្ចការកំណែទម្រង់មនោគមវិជ្ជានយោបាយរបស់ប្រទេសក៏បានផ្តល់នូវសន្ទុះបន្ថែមទៀតដល់ការអភិវឌ្ឍទៅមុខជាបន្តបន្ទាប់លើមូលដ្ឋានអន់

ខ្សោយរបស់ខ្លួនដែលធ្លាប់មាន ហើយកំណែទម្រង់ដ៏មហិមានេះបានព្យាយាមធ្វើឱ្យមានការផ្លាស់ប្ដូរមូលដ្ឋានគ្រឹះ និងរុញច្រានប្រទេសកម្ពុជាឱ្យឆ្ពោះទៅរកការអភិវឌ្ឍក្នុងដំណាក់កាលថ្មីមួយទៀត។

បើយើងសិក្សាវិភាគទៅលើអត្ថន័យសំខាន់ៗរបស់រដ្ឋនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍក្នុងតតិយលោក យើងសង្កេតឃើញថា ទស្សនៈនេះត្រូវបានគេធ្វើកំណត់ត្រា និងលើកឡើងយ៉ាងច្រើនអំពីបញ្ហានានា ដូចរៀបរាប់ខាងលើនេះ។ យើងអាចធ្វើសេចក្ដីសំយោគខ្លឹមសារទាំងនោះអំពីលក្ខណៈពិសេសនៃអំណាចរដ្ឋដូចខាងក្រោមនេះ ៖

ទី១៖ អត្ថន័យរបស់រដ្ឋហាក់ដូចជាមានដំណើរការជាធម្មជាតិទៅ ហើយក្នុងនិន្នាការមួយទៅរកការបង្អាក់ផលប្រយោជន៍ផ្សេងៗដែលអាចកើតមានពីសង្គមរបស់ខ្លួន។ ផ្ទុយទៅវិញ រដ្ឋធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀតសម្រាប់អ្នកស្ថិតនៅលើស្ថានភាពខ្ពស់ជាងគេក្នុងសង្គមនោះ។

ទី២៖ ចំពោះនិន្នាការបែបខាងលើនេះ ក្នុងលក្ខណៈដោយអានុភាពនៃកម្លាំងពិសេសណាមួយដែលបានកើតឡើងក្នុងទិដ្ឋភាពជាអន្តរកាលសំដៅដល់ការអភិវឌ្ឍសង្គមនោះ ដូច្នេះ ក្នុងលក្ខខណ្ឌដោយអំណាចនៃកម្លាំងប្រកបដោយតុល្យភាពនៃសង្គមនោះនឹងធ្វើឱ្យមានការចុះទន់ខ្សោយដល់វណ្ណៈសំខាន់ៗរបស់ខ្លួនទៅវិញ។

ទី៣៖ មានសសរស្ដម្ភពីរ និងមានធាតុផ្សំពីរយ៉ាងនៃអំណាចរបស់រដ្ឋ ពោលគឺកម្លាំងអាជ្ញាសឹក និងអានុភាពការិយាល័យធិបតេយ្យដែលជាអ្នកបង្កើតឡើងនូវផលប្រយោជន៍របស់រដ្ឋ និងទាមទារទៅរកការការពារអភ័យឯកសិទ្ធិ ហើយដោយឈរលើស្ថានភាពបែបនេះបង្កឱ្យមានការប្រឈមមុខដាក់គ្នា សូម្បីតែជាមួយវណ្ណៈគ្រប់គ្រងវិស័យសេដ្ឋកិច្ចក៏ដោយ។

ទី៤៖ ដោយសារតែការបាត់បង់នូវលំនឹងនយោបាយរវាងស្ថាប័នសំខាន់ៗនៃអំណាចរដ្ឋ ពោលគឺបាត់បង់តុល្យភាពគ្រប់គ្រងរវាងអង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអំណាចតុលាការ ដូច្នេះហើយទើប

ជំរុញឱ្យរដ្ឋមានទំនោរទៅរកការប្រើប្រាស់អំពើហិង្សាក្នុងតួនាទីដឹកនាំអំណាចរដ្ឋដោយចៀសមិនរួច។

លក្ខណៈទ្រឹស្តីខាងលើនេះមានអត្ថប្រយោជន៍ដ៏សំខាន់បំផុត សម្រាប់ការស្វែងយល់អំពីតួនាទីរបស់រដ្ឋនៅប្រទេសកម្ពុជា។ ព្រោះថា ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសក្នុងតតិយលោកដែរដែលជាទូទៅ តាមរយៈការប្រព្រឹត្តទៅរបស់ខ្លួនមានការរីកលូតលាស់ដោយការប្រើប្រាស់កម្លាំងក្នុងការបំពេញតួនាទីរដ្ឋទៅលើគ្រប់វិស័យសេដ្ឋកិច្ច-សង្គម គ្រប់សកម្មភាពនយោបាយ និងវប្បធម៌ជាដើម។ បញ្ហានេះត្រូវបានគេកត់សម្គាល់តាំងពីយូរលង់ណាស់មកហើយ ដោយអ្នកស្រាវជ្រាវរបស់សូវៀត និងអ្នកស្រាវ-ជ្រាវបរទេសជាច្រើនរូបទៀតនៃបណ្តាប្រទេសកំពុងអភិវឌ្ឍ ហើយបានផ្តល់ជារបកគំហើញជាឯកច្ឆន្ទមួយទៅលើការស្ថាបនាដំណើរការទាំងឡាយរបស់ខ្លួន ក៏ប៉ុន្តែ គ្រាន់តែការសិក្សាវិភាគ ឬការរែកញែកអំពីធម្មជាតិរបស់វាត្រូវបានធ្វើឡើងតាមលក្ខណៈវិធីសាស្ត្រផ្សេងៗគ្នា និងជាទម្លាប់ ត្រូវបានឆ្លងកាត់ការពិចារណាពិនិត្យពិច័យអំពីកម្រិតនៃការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងវិស័យសេដ្ឋកិច្ចតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត យើងពិនិត្យឃើញថា សង្គមរបស់យើងនាសម័យនោះហាក់មិនទាន់បានកំណត់ជាក់លាក់អំពីវណ្ណៈនៅឡើយទេដែលមានលក្ខណៈពិសេសផ្សេងៗពីគ្នា ហើយភាគច្រើនបានគ្របដណ្តប់ទៅដោយក្រុមអ្នកផលិតខ្នាតតូចៗ រីឯពួកសក្តិភូមិម្ចាស់ដី ឬពាក់កណ្តាលស័ក្តិភូមិស្ទើរតែពុំសូវកើតមាន។ ក្រៅពីនេះ ពួកនាយទុនខាងពាណិជ្ជកម្ម និងឧស្សាហកម្មទាំងឡាយច្រើនមិនសូវសម្បូណ៌ធនធានហិរញ្ញវត្ថុ និងភាគច្រើនជាជនជាតិចិន។ ប្រការនេះបានកាត់ផ្តាច់ពួកវណ្ណៈមូលធននិយមពីប្រជាជនកម្ពុជាដែលពលរដ្ឋភាគច្រើនជាជនជាតិខ្មែរ។ ភាពទន់ខ្សោយខាងផ្នែកសេដ្ឋកិច្ចនៃរបបមូលធននិយមនៅកម្ពុជាសម័យនោះបានទ្រទ្រង់ទៅដោយភាពឯករាជ្យម្ចាស់ការខ្លះដែរចំពោះនិន្នាការនៃការអភិវឌ្ឍមហិមារបស់ខ្លួន។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាថ្មីនេះទៀត យើងសង្កេតឃើញមានការរីកលូតលាស់នូវទំនោរមួយឆ្ពោះទៅរកសេដ្ឋកិច្ចបែបរដ្ឋតូបនីយកម្ម។

ក្នុងលក្ខខណ្ឌដែលប្រទេសជាតិកំពុងតែមានបញ្ហាអស្ថិរភាពផ្នែកសេដ្ឋកិច្ចផងនោះ យើងឃើញថា ក្នុងស្ថានភាពបែបនេះវាហាក់ដូចជាបានបង្កឱ្យមានលក្ខខណ្ឌអំណោយផលដល់ការកកើតឡើងយ៉ាងឆាប់រហ័ស និងស្រួចស្រាវបំផុត ចំពោះការច្របល់បញ្ចូលគ្នានូវនិន្នាការនយោបាយផ្សេងៗ ក៏ដូចជាមនោគមវិជ្ជាទាំងឡាយដល់សង្គមកម្ពុជាក្នុងសម័យកាលនោះ។ ម្យ៉ាងទៀត ភាពអន់ថយផ្នែកសេដ្ឋកិច្ច និងកង្វះការបង្រួបបង្រួមគ្នាព្រមទាំងអវត្តមាននូវកម្លាំងចលករពិតប្រាកដមិនអាចជំរុញឱ្យមានការដឹកនាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឱ្យដល់កម្រិតមួយ និងដំណោះស្រាយចំពោះបញ្ហាកិច្ចការរបស់ជាតិជារួម ដែលអាចកំណត់បាននូវលក្ខខណ្ឌចាំបាច់ដល់ការធ្វើអន្តរាគមន៍ឱ្យបានទូលំទូលាយពីអំណាចរដ្ឋក្នុងវិស័យផលិតកម្មបានឡើយ ជាពិសេស នៅក្នុងដំណើរការវិនិយោគ ការប្រមូលផ្តុំធនធាននានាទាំងក្នុង និងក្រៅប្រទេស និងការពង្រីកកម្រិតសន្សំរបស់ខ្លួនផងដែរ។ ដំណើរការនេះអាចកើតមានឡើងទៅបានក្នុងលក្ខខណ្ឌដែលរដ្ឋមានការព្យាយាមយ៉ាងខ្លាំងក្លាទៅរកការលុបបំបាត់ចោលនូវភាពអន់ថយខាងវិស័យសេដ្ឋកិច្ច-សង្គមតាមរយៈទំនើបនីយកម្មកសិកម្ម ហើយឆ្ពោះទៅរកម៉ូឌែលមួយនៃឧស្សាហកម្មផលិតកម្ម និងការបង្រួបបង្រួមគ្នាលើវិស័យសេដ្ឋកិច្ចដោយពឹងផ្អែកលើមូលដ្ឋាននៃការបង្កើតឡើងនូវទីផ្សារជាតិនៅក្នុងប្រទេស។

ស្ថានភាពស្តីពីការពង្រឹងអានុភាពតួនាទីរបស់រដ្ឋនៃប្រទេសកំពុងអភិវឌ្ឍ យើងពិនិត្យឃើញថា មានអ្នកស្រាវជ្រាវជាច្រើននាក់បានសិក្សាព្រមទាំងបានរកឃើញនូវការផ្សារភ្ជាប់គ្នាជុំវិញទំនាក់ទំនងមួយជាមួយនឹងការប្រើប្រាស់គំរូជាប្រវត្តិសាស្ត្រនៅក្នុងសកម្មភាពនៃសតវត្សរ៍ចុងក្រោយនេះ ពោលគឺពាក់ព័ន្ធទៅនឹងស្ថាប័ននយោបាយនានា ក៏ដូចជាស្ថាប័នរដ្ឋ-បាលរបស់ខ្លួនដែលមានន័យថា ជាសមាសធាតុដ៏សំខាន់បំផុតមួយនៃឧត្តម-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គតិក្រោមទស្សនៈថា ការស្ថាបនាជាតិដ៏មហិមា។

ចំពោះការចូលរួមរបស់ប្រទេសនៅក្នុងបំណែងចែកពលកម្មអន្តរជាតិ យើងឃើញថា បានបង្កើតឡើងនូវបណ្តាក្រុមថ្មីៗបន្ថែមទៀតដែលទទួលបានចំណាប់អារម្មណ៍អំពីផលប្រយោជន៍របស់ខ្លួន ហើយជាទីបំផុតនោះធ្វើឱ្យកើតមានកម្មវត្ថុមួយទាក់ទងនឹងការសម្របសម្រួលរបស់រដ្ឋ។

នៅក្នុងដំណាក់កាលទីមួយនៃគោលនយោបាយស្ថាបនាជាតិដ៏មហិមាពីលើមូលដ្ឋានដែលមានស្រាប់មកហើយនោះ វាធ្លាប់បានកើតមានឡើងតាំងពីអតីតកាលរួចមកហើយចំពោះបណ្តាប្រទេសអន់ថយនៅក្នុងតតិយលោកដែលជាចរិតលក្ខណៈដ៏ពិសេសមួយ និងមិនមែនជាទម្លាប់។ ក្នុងខ្លឹមសារនៃទំនាក់ទំនងផលិតកម្មថ្មីរបស់ខ្លួន(តាមបែបមូលធននិយម ឬក៏បែបផែនសង្គមនិយមក៏ដោយ) បានរុញច្រានប្រទេសឱ្យទៅដល់ស្ថានភាពមួយដែលស្ថិតក្រោមឥទ្ធិពលនៃការគ្រប់គ្រងរដ្ឋតាមបែបការិយាល័យធិបតេយ្យ(មានច្បាប់ទម្លាប់ស្មុគស្មាញ)។

ជាងនេះទៀត ការសិក្សាវិភាគអំពីអំណាចរដ្ឋហាក់ដូចជាតម្រូវឱ្យធ្វើការលើកឡើងពាក់ព័ន្ធដល់ការបើកកកាយលើអត្ថន័យខ្លឹមសារ និងតួនាទីនៃការិយាល័យធិបតេយ្យរបស់រដ្ឋដែលប្រៀបបានទៅនឹងស្រទាប់ពិសេសបំផុតក្នុងអំណាចរដ្ឋសម្រាប់ធ្វើជាយន្តការមួយក្នុងការគ្រប់គ្រងដំណើរការសេដ្ឋកិច្ច-សង្គម និងការគ្រប់គ្រងវិស័យនយោបាយ ព្រមទាំងវិស័យចិត្តសាស្ត្រសង្គមផងដែរនៅក្នុងប្រទេសនោះ។ ក៏ប៉ុន្តែ ភាពប្រាកដប្រជាណាមួយដែលគ្មានលក្ខណៈសុក្រឹតជុំវិញការយល់ដឹងអំពី«ការិយាល័យធិបតេយ្យ»ដែលគេយកទៅអនុវត្តនៅក្នុងបណ្តាប្រទេសលោកខាងកើត និងការប្រតិបត្តិរបស់ពួកគេ សម្រាប់អត្ថន័យពាក់ព័ន្ធនឹងការកំណត់លក្ខណៈវិនិច្ឆ័យចំពោះបុគ្គលទាំងឡាយទាក់ទងដល់អ្នកគ្រប់គ្រងកិច្ចការរដ្ឋបាលក៏ដូចជាអ្នកគ្រប់គ្រងស្ថាប័ននយោបាយសំខាន់ៗដែលធ្លាប់បានកើតមានឡើងចំពោះប្រទេសលោកខាងកើត ហើយក្នុងបញ្ហានេះដែរ យើង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សង្កេតឃើញថា វិស័យនយោបាយ និងវិស័យរដ្ឋបាលជាប្រវត្តិមិនបាន ធ្វើការកំណត់ព្រំដែននៃតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ ឬបានដាក់លាក់នោះទេដែលបញ្ហាទាំងអស់នេះបាននាំមកនូវភាពជំពាក់ជំពិនលើការបំពេញមុខងាររដ្ឋបាលរបស់ខ្លួន។ ក្នុងលក្ខខណ្ឌជាអន្តរកាលនៃការអភិវឌ្ឍសង្គម យើងឃើញថា ក្បាលម៉ាស៊ីនដឹកនាំបែបការិយាល័យធិបតេយ្យគឺជាមជ្ឈ-មណ្ឌលអំណាចដ៏រឹងមាំបំផុតដែលតួនាទីនយោបាយរបស់ស្ថាប័ននេះមាននិន្នាការមួយទៅរកការរីករាលដាលតាមរយៈការប្រើប្រាស់អំណាចនីតិ-ប្រតិបត្តិថ្នាក់មូលដ្ឋាន។

គួរបញ្ជាក់ដែរថា ការិយាល័យធិបតេយ្យរបស់រដ្ឋនាសម័យទំនើបជាទូទៅផ្សំឡើងដោយក្រុមបញ្ញវន្ត និងមួយផ្នែកតូចកើតចេញពីប្រភពមន្ត្រីវិស័យយោធាដែលធ្លាប់បានចូលរួមក្នុងចលនាតស៊ូធ្វើបដិវត្តន៍។ ចំពោះកំណើនចំនួនថ្នាក់ដឹកនាំក្បាលម៉ាស៊ីនរដ្ឋក្នុងទម្រង់ការិយាល័យធិបតេយ្យក៏ដូចជាការពង្រីកយ៉ាងឆាប់រហ័សនូវចំនួនមន្ត្រីជាថ្នាក់ដឹកនាំផ្សេងៗទៀតគឺជាបាតុភូតមួយដែលមានចរិតលក្ខណៈជាវប្បធម៌ទៅហើយ សម្រាប់បណ្ដាប្រទេសកំពុងអភិវឌ្ឍទាំងឡាយដែលមាននិន្នាការពាក់ព័ន្ធនឹងខ្លឹមសារនេះក្នុងកម្រិតខ្ពស់បំផុត ពោលគឺជាមួយនឹងបញ្ហាជាច្រើនទៀតដែលធ្លាប់បានលើកឡើងកន្លងមក យ៉ាងណាមិញដូចជាកិច្ចការពង្រីកនូវតួនាទីរបស់រដ្ឋដែលជាមធ្យោបាយដ៏ចម្បងដល់ការជំរុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គម។ ជាងនេះទៀត ដូចដែលអ្នកប្រាជ្ញ G. I Mirski បានលើកឡើងដែរថា «ការគ្រប់គ្រងរបស់ពួកគេពូកែ(ប៉ិនប្រសប់)ក្នុងការបង្កើតឱ្យមានទិដ្ឋភាពបែបនោះឯង ហើយការតម្រង់ទិសចិត្តសាស្ត្រសង្គមចំពោះការប្រើប្រាស់វិស័យសេវាកម្មរដ្ឋ(សេវាសាធារណៈ) ទទួលការអំពាវនាវជាបឋមជាពិសេស ជាធន្ទះដែលមានការផ្ដត់ផ្គង់ធានាចំពោះកិច្ចការនេះទៀតផង»។

ក៏ប៉ុន្តែ មានអ្នកស្រាវជ្រាវជាច្រើនកន្លងមកតែងតែមានទស្សនៈ និងការសិក្សាវិភាគដោយឡែកៗពីគ្នាទៅលើកម្រិតនៃការធ្វើអន្តរាគមន៍របស់



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រដ្ឋចំពោះកិច្ចការអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គម។

បើយើងពិនិត្យទៅលើក្បួនសឹករបស់វិស័យយោធាវិញនៅប្រទេសកម្ពុជានាសម័យនោះ យើងសង្កេតឃើញថា វិធីសាស្ត្រនៃការពង្រឹងនិន្នាការនយោបាយជាអន្តរកាលឆ្ពោះទៅរកលទ្ធិសង្គមនិយមគឺបានស្ថាបនាឡើងតាមរយៈប្រព័ន្ធរដ្ឋបាលបែបមជ្ឈការដ៏មហិមាដែលបានចាក់ស្រេះក្នុងវិស័យរដ្ឋផ្នែកសេដ្ឋកិច្ចជាមួយនឹងក្បាលម៉ាស៊ីនការិយាល័យធិបតេយ្យយ៉ាងមុតមាំ។ ក៏ប៉ុន្តែ ការដឹកនាំអំណាចរដ្ឋថ្នាក់កណ្តាល និងអន្តរាគមន៍របស់រដ្ឋដោយផ្ទាល់នោះជាប់ពាក់ព័ន្ធទៅនឹងការចំណាយថវិកាដ៏ធំធេងដែលជានិច្ចកាលមិនបានឆ្លើយតបចំពោះទស្សនៈដែលថា ធ្វើឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ច សម្រាប់ប្រទេសជាតិនោះទេ។

## ១.៣.២ តួនាទីបក្ស និងរដ្ឋចំពោះគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស

សហគ្រាសរដ្ឋក្នុងករណីភាគច្រើនមានលក្ខណៈផ្តាច់មុខ និងហាក់មិនសូវមានសកម្មភាពមមាញឹកប៉ុន្មាននោះទេ ហើយការគ្រប់គ្រងទៀតសោតមានសភាពអន់ថយ និងមិនទទួលបានប្រាក់ចំណេញ។ ម្យ៉ាងទៀតការពង្រីកលើការចំណាយថវិការបស់រដ្ឋ កំណើនបំណុលរដ្ឋ ឱនភាពហិរញ្ញវត្ថុ និងវិធានការដោះស្រាយបញ្ហាអតិផរណា បាននាំមកនូវអស្ថិរភាពសេដ្ឋកិច្ច-សង្គម។ ទាក់ទងនឹងបញ្ហានេះ រដ្ឋាភិបាលបានពិនិត្យឡើងវិញតាមរយៈវិធីសាស្ត្រនានាជុំវិញការធ្វើអន្តរាគមន៍របស់រដ្ឋ និងការពិនិត្យតួនាទីរដ្ឋក្នុងសេដ្ឋកិច្ចក៏ដូចជាការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសផងដែរ។ នាសម័យនោះ យើងឃើញមានការចាប់ផ្តើមឡើងនូវដំណើរការឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ព្រមទាំងមានការយកចិត្តទុកដាក់លើតួនាទីរបស់វិស័យសេដ្ឋកិច្ចឯកជនចំពោះសេដ្ឋកិច្ចកម្ពុជា។

ការត្រួតពិនិត្យលើយុទ្ធសាស្ត្រអភិវឌ្ឍបានដើរស្របគ្នាជាមួយនឹងការពង្រឹងការយកចិត្តទុកដាក់ទៅលើទស្សនទាននៃការអភិវឌ្ឍសេដ្ឋកិច្ច

ទីផ្សារ។ ថ្នាក់ដឹកនាំរដ្ឋភាគច្រើនរបស់ប្រទេសកម្ពុជានាពេលនោះបាន ចាប់ផ្ដើមគាំទ្រចំពោះមាគ៌ានៃសេដ្ឋកិច្ចទីផ្សារ។ មនោគមវិជ្ជាសេដ្ឋកិច្ចទីផ្សារបានក្លាយជាមូលដ្ឋានគ្រឹះ ឬជាបង្អែកដល់ទស្សនទានខាងលើនេះ មុនពេលកើតមានវណ្ណៈសង្គម និងបានក្លាយជាការផ្សាំរបស់វាទៅនឹងលក្ខខណ្ឌនៃសេដ្ឋកិច្ចដែលមានច្រើនសណ្ឋាន។ យន្តការទីផ្សារសេរីត្រូវបានកំណត់ឡើងជា៤ប្រភេទ(រួមមានទីផ្សារកម្លាំងពលកម្ម ទីផ្សារទំនិញ ទីផ្សារមូលធន និងរូបិយវត្ថុ)ដែលជាឧបករណ៍ដ៏សំខាន់បំផុតសម្រប-សម្រួលដល់ចរន្តទីផ្សារ និងបានបង្កលក្ខណៈដល់ការប្រើប្រាស់ធនធានទៅតាមគ្រប់គោលបំណងដែលត្រូវបំពេញ។

គួរបញ្ជាក់ថា ការគ្រប់គ្រងនយោបាយសង្គមនាសម័យនោះបានដំណើរការឡើងដោយគណបក្សប្រជាជនបដិវត្តន៍កម្ពុជាតែមួយគត់ និងបានចូលរួមប្រកួតប្រជែងក្នុងតំណែង និងតួនាទីជាអ្នកដឹកនាំកម្លាំងក្នុងសង្គមរបស់កម្ពុជា។ គណបក្សនេះមានសមាជិកភាពប្រមាណជាង២០ម៉ឺននាក់ ហើយនៅក្នុងសកម្មភាពគណបក្សរបស់ខ្លួនភាគច្រើនគ្របដណ្ដប់ទៅដោយអង្គការសង្គមនានាដែលបានបង្រួបបង្រួមគ្នាជារណសិរ្សបង្រួប-បង្រួមជាតិតែមួយ ដើម្បីការពារផលប្រយោជន៍ជាតិដូចជាសម្ព័ន្ធយុវជនបដិវត្តន៍ប្រជាជន សហជីព សមាគមស្ត្រី និងសមាគមព្រះសង្ឃជាដើម។

ផ្សេងពីនេះទៀត នៅក្នុងសន្និបាតបក្ស និងសន្និសីទក៏បានសិក្សាកំណត់អំពីទិសដៅគោលនយោបាយជាគោលការណ៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលបានគាំទ្រស្វាគមន៍ចំពោះកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ព្រមទាំងកំណត់ទិសដៅសំខាន់ៗទាក់ទងនឹងគោលនយោបាយសេដ្ឋកិច្ចក្នុង និងក្រៅប្រទេស។

ជាទូទៅ មានកិច្ចការជាច្រើនដែលមានលក្ខណៈជាយុទ្ធសាស្ត្រសម្រាប់លើកមកពិភាក្សានៅក្នុងគណៈកម្មការកណ្ដាល( មជ្ឈិមបក្ស) និងក្នុងគណៈកម្មាធិការថ្នាក់ការិយាល័យនយោបាយដែលជាដំបូងនោះ ត្រូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បានគេផ្ទេរការពិភាក្សាទៅឱ្យសន្និបាតថ្នាក់ជាតិ សម្រាប់ធ្វើការពិនិត្យមើលលើកិច្ចការទាំងអស់នេះសិន។ ម្តងម្កាល បើគ្មានការឯកភាពពីស្ថាប័ននីតិបញ្ញត្តិថ្នាក់ការិយាល័យនយោបាយ ឬគណៈកម្មការកណ្តាលរបស់គណបក្សដែលបានអនុម័តលើសេចក្តីសម្រេចនោះទេ វាជាបញ្ហាប្រឈមមួយ ព្រោះបញ្ញត្តិនេះ ក្រោយមកបានក្លាយជាមូលដ្ឋានដ៏សំខាន់បំផុត(ឯកសារឧបសម្ព័ន្ធយោង) សម្រាប់ការតាក់តែងនូវគោលនយោបាយសេដ្ឋកិច្ច និងយុទ្ធសាស្ត្រក្នុង និងក្រៅប្រទេស។ យើងអាចបញ្ជាក់បន្ថែមទៀតថា រាល់ការតែងតាំងសម្រាប់មុខតំណែងថ្នាក់ខ្ពស់ ឬសំខាន់ៗ គឺត្រូវតែឆ្លងកាត់ការឯកភាពពីសំណាក់គណៈកម្មាធិការការិយាល័យនយោបាយជាមុនសិន។ ដូច្នេះ យើងពិនិត្យឃើញថា គឺមានលក្ខណៈដូចគ្នាទាំងស្រុងជាមួយនឹងបណ្តាប្រទេសទាំងឡាយក្នុងតតិយលោកដែលមានការដឹកនាំប្រទេសដោយបក្សតែមួយ។

ម៉្យាងទៀត គណៈកម្មការប្រជាជនបដិវត្តន៍បានសម្តែងឥទ្ធិពលរបស់ខ្លួនក្នុងដំណើរការជុំវិញតួនាទីនៃការដឹកនាំការងារតាមរយៈខ្សែបណ្តាញអង្គការបក្សមូលដ្ឋាន ក្នុងនោះមានគណៈកម្មការបក្សខេត្ត គណបក្សស្រុក ឬគណៈកម្មការបក្សក្រុងដែលជាអ្នកចូលរួមអនុម័តដោយផ្ទាល់ទៅលើការប្រព្រឹត្តទៅនៃសេចក្តីសម្រេចនានាផ្នែកកិច្ចការនយោបាយ និងការងារសេដ្ឋកិច្ចសំខាន់ៗដែលជាលទ្ធផល យើងឃើញថា រចនាសម្ព័ន្ធចាត់តាំងរបស់បក្សបែបការិយាល័យធិបតេយ្យត្រូវបានបង្កើតឡើងនៅក្នុងប្រទេសទាំងអស់នោះ។

សម្រាប់ប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសក្នុងតតិយលោកផ្សេងៗទៀតដែរ ចំពោះតួនាទីដ៏ធំនៅក្នុងជីវិតនយោបាយរបស់ប្រទេស ក៏ដូចជាឥទ្ធិពលក្នុងការរៀបចំគោលនយោបាយក្រៅប្រទេសត្រូវបានដឹកនាំដោយកម្លាំងយោធា(វិស័យយោធា)ក្នុងរយៈពេលប្រមាណជា២០ឆ្នាំចុងក្រោយនេះ(គិតមកដល់ឆ្នាំ១៩៩០)ដែលការដឹកនាំរដ្ឋ ស្ថិតក្រោមឥទ្ធិពលនៃវិស័យ

យោធា។

កំប៉ុន្តែ វាក៏ជាលក្ខខណ្ឌសមស្របមួយដែរ សម្រាប់ការប្រើប្រាស់កម្លាំងទ័ពនៅក្នុងសង្គមកម្ពុជានាសម័យកាលនោះ ព្រោះនៅកាលៈទេសៈនោះ ប្រទេសកម្ពុជាយើងបានកើតមានបញ្ហាអស្ថិរភាពផ្នែកនយោបាយក្នុងលក្ខណៈរ៉ាំរ៉ៃអស់រយៈកាលប្រមាណជាពី២០ទៅ២៥ឆ្នាំមកហើយ ដែលជាដំបូងឡើយ បានកើតមានឡើងដោយសារតែផលវិបាកនៃបញ្ហាបែកបាក់ផ្ទៃក្នុងរបស់សង្គមខ្មែរ ព្រោះតែមូលហេតុនៃការយល់ឃើញ និងការប្រកាន់យកទស្សនៈនយោបាយក៏ដូចជាមនោគមវិជ្ជាផ្សេងៗគ្នា។ ម្យ៉ាងទៀតដោយសារតែមានភាពទន់ខ្សោយនៃគោលជំហររបស់កម្លាំងនយោបាយសំខាន់ៗនៃប្រទេសពីគ្រប់ភាគីទាំងអស់ ពោលគឺទាំងភាគីឆ្វេងនិយម ភាគីអព្យាក្រឹតក៏ដូចជាភាគីក្រុមស្តាំនិយម។ ក្នុងស្ថានភាពនេះ អ្នកស្រាវជ្រាវរបស់សូវៀត គឺលោក G. I Mirski ក៏បានលើកឡើងដែរថា «ផលវិបាកនៃភាពមិនស៊ីគ្នា(ឬមិនឆ្លើយតប)របស់រចនាសម្ព័ន្ធសង្គមចំពោះកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងផលវិបាកនៃការអាក់អន់ចិត្តរបស់សង្គមយ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលការអភិវឌ្ឍជាតិបែបនេះ ដោយសារតែការកសាងជាតិបានស្ថិតក្នុងលក្ខខណ្ឌកង្វះនីតិវិធីគតិយុត្តិត្រឹមត្រូវ សម្រាប់ប្រទេសក្រោយសម័យកាលដែលទើបចេញពីនឹមអនានិគមនិយម»។

ស្របតាមអត្ថន័យនេះ បម្លាស់ប្តូររបបនយោបាយនៅប្រទេសកម្ពុជាតែងតែកើតមានឡើងក្រោមលទ្ធផលនៃការផ្លាស់ប្តូរមួយតាមរយៈវិធីនៃការប្រើប្រាស់កម្លាំងនៅក្នុងសង្គមដែលបម្រើឱ្យប្រយោជន៍កិច្ចការនយោបាយនៃក្រុមណាមួយដែលក្នុងខ្លឹមសារនេះហាក់ដូចជាបានសម្តែងឡើងជាអត្ថប្រយោជន៍របស់វណ្ណៈណាមួយជាកំណត់។ ជាទូទៅយើងឃើញថា ការដឹកនាំរបស់កម្លាំងនយោបាយនេះបានប្រើប្រាស់កម្លាំងអាវុធសឹក សម្រាប់ធ្វើជាមធ្យោបាយ។ ក្នុងលក្ខណៈបែបនេះ យើងអាចពន្យល់បានថា ចំពោះសង្គមមួយដែលមានការបែកខ្ញែកគ្នារហូតដល់កម្រិតធំធេងបែបនេះ បាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ញ៉ាំងឱ្យគ្រប់ភាគីនៃកម្លាំងនយោបាយទាំងអស់ត្រូវតែបង្កើតកម្លាំងទ័ពរៀងៗខ្លួន។ ចំពោះបញ្ហានេះដែរ នៅក្នុងសង្គមកម្ពុជានាសម័យនោះ ពុំទាន់មានវប្បធម៌ប្រជាធិបតេយ្យ ពុំទាន់មានប្រពៃណីនយោបាយល្អ និងគ្មានស្ថាប័ននយោបាយដែលអាចប្រឹក្សាយោបល់ជាមួយគ្នាបាន សម្រាប់ការរៀបចំសង្គមស៊ីវិលឱ្យបានសមស្របណាមួយនៅឡើយទេ។ ជាងនេះទៀត ចំពោះអង្គការរដ្ឋអំណាចតែងតែបានឈរលើគោលការណ៍ប្រើប្រាស់កម្លាំងជាមូលដ្ឋានដូចដែលអ្នកប្រាជ្ញសូវៀតគឺលោក N. A Simon បានអះអាងដែរថា «ប្រទេសកម្ពុជាសម័យនោះជាសាធារណរដ្ឋបែបសកានិយមដែលហាក់មិនបានបង្ហាញពីមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងសង្គមមួយដែលមានភាពស៊ីចង្វាក់គ្នានោះទេ...»។

គួរបញ្ជាក់ដែរថា យន្តការសម្រាប់សេដ្ឋកិច្ចក្រៅប្រទេសជាធាតុផ្សំដ៏សំខាន់បំផុតនៃយន្តការសេដ្ឋកិច្ចជាតិទាំងមូល។ ការកែតម្រូវរបស់រដ្ឋចំពោះវិស័យទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងដំណើរការអភិវឌ្ឍនៃរដ្ឋនោះដោយខ្លួនឯង។ មានបទពិសោធន៍ដែលជាគំរូជាច្រើនជុំវិញការកែតម្រូវសេដ្ឋកិច្ច និងកែតម្រូវទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស បាននាំមកនូវការបង្កើតអង្គការ ឬស្ថាប័ននានាដែលបានទទួលខុសត្រូវលើកិច្ចការនៃការតាក់តែងយុទ្ធសាស្ត្រសេដ្ឋកិច្ចក្រៅប្រទេសជារួម និងជាអ្នកទទួលខុសត្រូវចំពោះដំណើរការលើគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសប្រកបដោយលក្ខណៈឯកភាពគ្នាផងដែរ។

ទាក់ទងនឹងមូលដ្ឋានចម្បងក្នុងយន្តការនៃការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសមានការពាក់ព័ន្ធទៅនឹងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ និយាយជារួមគឺក្រុមប្រឹក្សារដ្ឋមន្ត្រីរបស់រដ្ឋកម្ពុជា។ ការដឹកនាំរបស់ស្ថាប័នថ្នាក់មជ្ឈិមលើវិស័យសេដ្ឋកិច្ចក៏ដូចជាសកម្មភាពសេដ្ឋកិច្ចក្រៅប្រទេស គឺមានសភាពរឹងមាំបំផុតនៅប្រទេសកម្ពុជាសម័យនោះ។ បញ្ហាគោលនយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ចក្រៅប្រទេសជាច្រើនត្រូវបានដោះស្រាយ និងធ្វើសេចក្ដីសម្រេច ដោយស្ថាប័នក្រុមប្រឹក្សារដ្ឋមន្ត្រី ក៏ដូចជាការពង្រីកដំណើរការជុំវិញសេចក្ដីសម្រេចចំពោះបញ្ហាជាក់លាក់ផ្សេងៗទៀត។ អាចនិយាយបានថា ក្រុមប្រឹក្សារដ្ឋមន្ត្រីក៏អាចជាអ្នកមានសិទ្ធិគ្រប់គ្រាន់ក្នុងការផ្ដល់ការអនុញ្ញាតនានា ដូចជាផ្ដល់សិទ្ធិដល់ការស្ថាបនាសហគ្រាសចម្រុះជាមួយមូលធនបរទេស និងជាអ្នកផ្ដល់អាជ្ញាប័ណ្ណដល់ការនាំចេញ និងការនាំចូលទំនិញសព្វសារពើ ព្រមទាំងផ្ដល់សិទ្ធិនាំចូលគ្រឿងបរិក្ខារជាច្រើនទៀត ហើយក៏ជាអ្នកកំណត់កម្រិតនៃលក្ខខណ្ឌអនុគ្រោះផ្សេងៗសម្រាប់ដៃគូអភិវឌ្ឍន៍ដែលជាវិនិយោ-គិនបរទេសទៀតផង។

ពិសេសជាងនេះទៀត សម្រាប់សម័យកាលនោះ នាកាលៈទេសៈចុងក្រោយ យើងសង្កេតឃើញថា ក្នុងដំណើរការរៀបចំនីតិវិធី និងការធ្វើសកម្មភាពជុំវិញទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រទេស មានការចូលរួមដោយផ្ទាល់តែម្ដងពីសំណាក់មេដឹកនាំរដ្ឋាភិបាលកម្ពុជា។ នៅក្នុងទីស្ដីការនាយករដ្ឋមន្ត្រី ក៏បានបង្កើតនាយកដ្ឋានឯកទេសកម្មទាក់ទងនឹងបញ្ហាគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសផងដែរ។ ជាក់ស្ដែង នៅចន្លោះឆ្នាំ ១៩៨៩ដល់១៩៩០ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើដំណើរជាច្រើនលើកច្រើនសារទៅប្រទេសថៃក្នុងគោលបំណងដោះស្រាយកិច្ចការសេដ្ឋកិច្ចសំខាន់ៗជាច្រើនពាក់ព័ន្ធទៅនឹងសកម្មភាពសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាជាមួយនឹងប្រទេសថៃ។ ជាមរតកចុងក្រោយ បានឈានដល់ការចុះកិច្ចព្រមព្រៀងជាមួយគ្នាស្ដីអំពីទំនាក់ទំនងពិសេសលើកិច្ចការសេដ្ឋកិច្ច ព្រមទាំងបានបង្កើតជាគណៈកម្មការសម្របសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងពីរ និងបានពង្រីកបន្ថែមទៀតនូវការចូលរួមផ្នែកទុនវិនិយោគរបស់ប្រទេសថៃក្នុងវិស័យឯកជនភាវូបនីយកម្មទាក់ទងនឹងសហគ្រាសឧស្សាហកម្មរដ្ឋ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.៣.៣ ស្ថាប័ន និងនីតិវិធីលើគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស

*យន្តការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសត្រូវបានតាក់តែងឡើងតាមរយៈការចូលរួមពីសំណាក់មុំទាំងបីរបស់លេខាធិការដ្ឋានសំខាន់ៗរួមមានលេខាធិការដ្ឋាននាយករដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងក្រសួងផែនការ។ ប៉ុន្តែជាចុងក្រោយ គឺក្រសួងពាណិជ្ជកម្មផ្នែកទំនាក់ទំនងក្នុង និងក្រៅប្រទេសជាអ្នកទទួលខុសត្រូវជាផ្លូវការ ហើយតួនាទីចម្បងបំផុតក្នុងចំណោមស្ថាប័នទាំងបីខាងលើនេះ គឺក្រសួងពាណិជ្ជកម្មផ្នែកទំនាក់ខាងក្នុង និងក្រៅប្រទេសជាអ្នកទទួលបន្ទុកដោយផ្ទាល់លើកិច្ចការគ្រប់គ្រង និងតម្រង់ទិសគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស។ ក្រសួងនេះបានដើរតួជាអ្នកចាត់ចែងនូវរាល់សកម្មភាពនាំចេញ ឬនាំចូល និងការបង្រួបបង្រួមសហការក្នុងការរៀបចំដំណើរការ។ដើម្បីសម្រួលដល់កិច្ចការទាំងអស់របស់ក្រសួងពាណិជ្ជកម្មផ្នែកការងារក្នុង និងក្រៅប្រទេស គេបានបង្កើតនាយកដ្ឋានទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសឡើង។ នាយកដ្ឋាននេះជាអ្នកអនុវត្តគោលនយោបាយនាំចេញ ឬនាំចូល និងសម្របសម្រួលកែលម្អលើកិច្ចការទំនាក់ទំនងផ្នែកសេដ្ឋកិច្ចជាមួយបណ្ដាប្រទេសផ្សេងៗទៀត ពោលគឺជាអ្នកដឹកនាំសកម្មភាពចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម ព្រមទាំងជាអ្នកចូលរួមសម្របសម្រួលជាមួយក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេសក្នុងកិច្ចការបំពេញកិច្ចសន្យាក៏ដូចជាទទួលបាននូវព័ត៌មានទាំងឡាយស្ដីពីស្ថានភាពសេដ្ឋកិច្ចរបស់បណ្ដាប្រទេសនានាស្ដីពីរចនាសម្ព័ន្ធទីផ្សារលើវិស័យពាណិជ្ជកម្មអន្តរជាតិ និងផ្សេងៗទៀត។*

*ចំពោះក្រសួងផែនការវិញបានដើរតួនាទីជាអ្នកកត់ត្រារាល់រចនាសម្ព័ន្ធមុខទំនិញ និងកត់ត្រាបរិមាណទំនិញដែលបាននាំចេញ និងនាំចូលមកក្នុងប្រទេស ព្រមទាំងកំណត់អំពីទំហំតម្រូវការប្រើប្រាស់ទំនិញនៅក្នុងប្រទេស។ រីឯអង្គការស្ថាប័នជាច្រើនផ្សេងទៀតដែលជាស្ថាប័នអន្តរវិស័យ និងជំនាញ រួមមានក្រសួងហិរញ្ញវត្ថុ ក្រសួងការបរទេស ធនាគារជាតិនៃ*


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជាបានដើរតួនាទីចម្បងទី២ក្នុងយន្តការរៀបចំគោលនយោបាយរូបិយប័ណ្ណ។ ក៏ប៉ុន្តែ គ្រប់វិធានការទាំងអស់ត្រូវតែទទួលបានការឯកភាពជាមុនសិនពីសំណាក់លេខាធិការដ្ឋាននាយករដ្ឋមន្ត្រី។

ដោយឡែកក្រសួងការបរទេសចំពោះកម្រិតទទួលខុសត្រូវរបស់ខ្លួនលើសេចក្តីសម្រេចផ្សេងៗពាក់ព័ន្ធទៅនឹងគោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ ជាទូទៅមានលក្ខណៈតិចតួចប៉ុណ្ណោះ។ ពោលគឺមានតែនៅចុងឆ្នាំ១៩៩០ដែលក្រសួងការបរទេសរបស់កម្ពុជាបានបង្កើតនាយកដ្ឋានទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិឡើង។ ការបង្កើតឡើងនូវអង្គភាពថ្មីនេះក្នុងគោលបំណងពង្រឹងឥទ្ធិពលរបស់ក្រសួងការបរទេសលើសេចក្តីសម្រេចចំពោះកិច្ចការទាំងឡាយជុំវិញគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសក៏ដូចជាដើម្បីបំពេញលើកិច្ចការសម្របសម្រួលមួយចំនួន សម្រាប់ទិសដៅគោលនយោបាយការបរទេស និងសេដ្ឋកិច្ចក្រៅប្រទេសផងដែរ។

ចំពោះនីតិវិធីអនុម័តលើសេចក្តីសម្រេចក្នុងយន្តការដឹកនាំរដ្ឋនៅកម្ពុជាសម័យនោះ គឺត្រូវមានការឯកភាពគ្នារហូតដល់ទៅបីកម្រិតឯណោះ។ នៅក្នុងនីតិវិធីទាំងអស់នេះ យើងពិនិត្យឃើញថា បន្ទាប់ពីបានសិក្សា និងតាក់តែងគោលនយោបាយនៅឯលេខាធិការដ្ឋាននាយករដ្ឋមន្ត្រីដោយឈរលើសំណូមពរ និងអនុសាសន៍សំខាន់ៗរបស់ស្ថាប័ននេះរួចមក វិធានការសេដ្ឋកិច្ចក្រៅប្រទេសត្រូវបានបញ្ជូនទៅកាន់ខុទ្ទកាល័យការិយាល័យនយោបាយនៃបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលជាក្បាលម៉ាស៊ីនដឹកនាំបែបប្រមូលផ្តុំដ៏សំខាន់មួយរបស់ប្រទេស។ ដូច្នេះ លុះណាតែមានការគាំទ្រជាឯកច្ឆន្ទពីស្ថាប័នការិយាល័យនយោបាយរួចសិន ទើបគេអាចបញ្ជូនបទបញ្ញត្តិទាំងនេះទៅកាន់សន្និបាតថ្នាក់ជាតិនៅឯស្ថាប័នរដ្ឋសភាដើម្បីអនុម័តជាផ្លូវការ ឬក៏អាចបញ្ជូនឯកសារនេះភ្លាមៗតែម្តងទៅកាន់ក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងទម្រង់ជាការអនុម័តរួមរបស់ខុទ្ទកាល័យការិយាល័យនយោបាយដែលជាស្ថាប័នដ៏សំខាន់បំផុត សម្រាប់យកទៅប្រតិបត្តិតែម្តង។ អាស្រ័យ

ហេតុនេះ ស្ថាប័នការិយាល័យនយោបាយគឺជាស្ថាប័នមួយដែលមានឥទ្ធិពលលើសលប់ក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជានាសម័យនោះ។ ក្នុងអត្ថន័យនេះ លក្ខណៈពិសេសជុំវិញដំណើរការអនុម័តលើសេចក្តីសម្រេចសំខាន់ៗនាសម័យនោះ លុះត្រាតែមានវត្តមានចាំបាច់នៃអ្នកគ្រប់គ្រងបក្ស និងរដ្ឋរបស់ប្រទេសដូចបានលើកឡើងក្នុងស្ថាប័នទាំងបីខាងលើនេះ។ ចំពោះស្ថាប័ននយោបាយទាំងអស់នោះបានបង្កើតឡើងដោយឈរលើគោលការណ៍ទំនាក់ទំនងផ្ទាល់ខ្លួនផង និងទំនាក់ទំនងគ្រួសារផង ហើយក៏បានឈរលើទស្សនៈគំនិតនយោបាយ និងបញ្ហាជាតិសាសន៍ព្រមទាំងកត្តាផលប្រយោជន៍។ ស្ថាប័នអភិរក្សដាច់ខាតជាកម្លាំងទី១ដែលបុកនេះត្រូវបានដឹកនាំដោយប្រធានរដ្ឋសភាគឺលោក ជា ស៊ីម ដោយមានអង្គការមហាជន និងក្រុមព្រះសង្ឃ ដែលបានចូលរួមពីកម្លាំងនយោ-បាយភាគច្រើននៅក្នុងប្រទេស។ ក្នុងលទ្ធផលបម្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំសំខាន់ៗជាច្រើនរូបនាដំណាក់កាលចុងក្រោយនេះក៏បានធ្វើឱ្យបក្សនយោបាយកាន់អំណាចអាចសម្រេចបាននូវការតែងតាំងមន្ត្រីសំខាន់ៗដែលជាមនុស្សរបស់ក្រុមខ្លួន។ យើងឃើញថា បក្សកាន់អំណាចសម័យនោះបានពឹងផ្អែកលើកម្លាំងទ័ព ព្រមទាំងប្រើប្រាស់ស្ថាប័នក្រសួងមហាផ្ទៃ និងអង្គការមហាជនជាកសិករភាគច្រើនសម្រាប់ធ្វើជាមូលដ្ឋានគាំទ្រ។

ម្យ៉ាងវិញទៀត កម្លាំងទី២ជាបុកដែលធ្វើកំណែទម្រង់ក្រុមនេះត្រូវបានដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានពឹងផ្អែកលើក្រុមបញ្ញវន្តមួយចំនួន និងសម្អាងលើប្រជាកសិករភាគច្រើនដែលរស់នៅជនបទជាអ្នកគាំទ្រ និងប្រើប្រាស់ពួកនាយទាហានជាខ្នងបង្អែក។ ចំពោះកម្លាំងទី៣របស់បក្សកាន់អំណាចសម័យនោះត្រូវបានដឹកនាំដោយលោក សាយ ភូថង ដែលមានតួនាទីជាប្រធានគណៈកម្មាធិការការិយាល័យនយោបាយ និងដឹកនាំសមាជិកការិយាល័យនយោបាយ។ ក្នុងបុកទី៣នេះត្រូវការចូលរួមពីសំណាក់ថ្នាក់ដឹកនាំបក្ស និងរដ្ឋជាច្រើរូបដែលមានសញ្ជាតិ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាថៃ។ លោក សាយ កូចង់ បានទទួលការគាំទ្រ និងមានការជឿជាក់យ៉ាងមុតមាំពីសំណាក់មេដឹកនាំវៀតណាម។ ឥទ្ធិពលនយោបាយរបស់លោក សាយ កូចង់ នៅពេលនោះ ស្ថិតនៅលើចំណុចពិសេសមួយត្រង់ថា លោកបានធ្វើឱ្យចុះទន់ខ្សោយនូវស្ថានភាពសង្គ្រាមស៊ីវិលនៅកម្ពុជា និងបានព្យាយាមដឹកនាំគោលនយោបាយមួយដែលនាំមកនូវតុល្យភាពនៃទំនាក់ទំនងល្អរវាងប្រទេសជិតខាងទាំងពីររបស់ខ្លួន ពោលគឺប្រទេសថៃ និងប្រទេសវៀតណាម។ គួរបញ្ជាក់ដែរថា នៅសម័យកាលនោះ ប្រទេសកម្ពុជាបានជួបប្រទះនូវបញ្ហាសង្គ្រាមស៊ីវិលយ៉ាងសន្ធោសន្ធៅដែលធ្វើឱ្យកម្ពុជាកាន់តែមានការទាក់ទងយ៉ាងខ្លាំងជាមួយប្រទេសវៀតណាមលើវិស័យយោធា ហើយក៏មានការទាក់ទងជាមួយនឹងប្រទេសថៃផងដែរលើកិច្ចការបំពេញសេចក្តីត្រូវការផលិតផលសម្រាប់ទីផ្សារក្នុងស្រុកដោយបាននាំចូលនូវគ្រប់មុខទំនិញដែលពុំមានក្នុងស្រុក។ ដោយមូលហេតុនេះហើយទើបរដ្ឋាភិបាលប្រទេសកម្ពុជាសម័យនោះបានប្រឹងប្រែងធ្វើឱ្យមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលប្រទេសថៃដែលចង់ ឬមិនចង់ ប្រទេសថៃបានផ្តល់ជម្រកដល់កងទ័ព និងជនភៀសខ្លួនខ្មែរដែលជាក្រុមប្រឆាំង ហើយបានរត់ទៅជ្រកកោននៅទីនោះ។ ហេតុនេះ ប្រទេសថៃក៏ជាអ្នកដើរតួនាទីដ៏សំខាន់មួយដែរក្នុងយុទ្ធសាស្ត្រសម្រាប់នយោបាយក្រៅប្រទេស និងយុទ្ធ-សាស្ត្រសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា។ ជាក់ស្តែង ក្នុងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចជាមួយប្រទេសមូលធននិយម យើងពិនិត្យឃើញថា ថ្នាក់ដឹកនាំខ្មែរសម័យនោះបានផ្តល់សិទ្ធិជាអាទិភាពចំពោះក្រុមហ៊ុនឯកជនរបស់ថៃដែលក្នុងកិច្ចការនេះដែរ បានអនុញ្ញាតឱ្យយើងធ្វើជាមូលដ្ឋានគ្រឹះដើម្បីសិក្សាអំពីកត្តានានារបស់ប្រទេសថៃចំពោះគោលនយោ-បាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាយើង។

ផ្សេងពីនេះទៀត នៅសម័យនោះ នៅក្នុងស្ថាប័នរដ្ឋសភាតែងតែបានដឹកនាំសន្និបាតថ្នាក់ជាតិ និងបានកសាងមូលដ្ឋានច្បាប់ចំពោះគោលនយោ-

បាយសេដ្ឋកិច្ចក្រៅប្រទេសក្នុងទម្រង់ជាក្រឹត្យច្បាប់ និងបទបញ្ញត្តិមួយចំនួនសម្រាប់ជាទុនក្នុងការពិភាក្សាលើការតាក់តែងច្បាប់ដូចជាការអនុម័តលើច្បាប់ថវិកាកំណត់អត្រាកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេសជាមួយបណ្ដាប្រទេសនានានៅលើសកលលោកបានកសាងច្បាប់ស្ដីពីការវិនិយោគបរទេស និងរៀបចំនីតិវិធីលើការតាមដានចំពោះការអនុវត្តលើសកម្មភាពរបស់អង្គការអំណាចនីតិប្រតិបត្តិជាដើម។

ដូច្នេះ ការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួល និងក្រោមសម្ពាធនយោបាយនៃក្រុមសំខាន់ៗខាងលើនេះ ពោលគឺថ្នាក់ការិយាល័យនយោបាយ ថ្នាក់គណៈកម្មាធិការកណ្ដាល(មជ្ឈិម)នៃបក្សប្រជាជនបដិវត្តន៍កម្ពុជា និងបញ្ហាខ្លះត្រូវបានដោះស្រាយនៅកម្រិតសន្និបាតទូទាំងប្រទេស។

## ១.៤ សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមក បន្ទាប់ពីបានសិក្សាស្រាវជ្រាវនៅក្នុងជំពូកទី១នេះរួចមក យើងអាចកំណត់ជាសេចក្ដីសន្និដ្ឋានរួមដូចខាងក្រោមនេះ ៖

- ប្រទេសកម្ពុជាជាប្រទេសកសិកម្ម ហើយសេដ្ឋកិច្ចរបស់ប្រទេសនេះបានឈរលើមូលដ្ឋានផលិតកម្មកសិកម្ម។ ជាងនេះទៀត ផលិតកម្មកសិកម្មដែលមិនសូវប្រើគ្រឿងយន្តដែលស្របជាមួយនឹងបញ្ហានេះ បានធ្វើឱ្យផលិតភាពពលកម្មមានលក្ខណៈទាប ហើយការប្រមូលផ្ដុំផលិតកម្មក៏មិនបានល្អ ចំណែកឯអត្រាផលចំណេញលើការវិនិយោគប្រាក់ដើមទុន១ឯកតាមានកម្រិតទាប ហើយជាទូទៅ ការប្រកបរបរកសិកម្មភាគច្រើនមានការពាក់ព័ន្ធទៅនឹងលក្ខខណ្ឌធម្មជាតិ។

- ប្រទេសកម្ពុជាសម័យនោះបាន និងកំពុងស្ថិតនៅលើរបត់មួយនៃការចាប់ផ្ដើមឡើងនូវឧស្សាហូនីយកម្មប៉ុណ្ណោះ។ ទំហំសហគ្រាសឧស្សា-

ហកម្មច្រើនមានទ្រង់ទ្រាយខ្នាតតូច(ជាលក្ខណៈគ្រួសារ) និងធុនមធ្យម ជាមួយនឹងការប្រើប្រាស់ឧបករណ៍ផលិតកម្ម និងបច្ចេកវិទ្យាចាស់ៗដែលបានសេសសល់ពីសម័យមុនឆ្នាំ១៩៥០។ ចំពោះវិធីសាស្ត្រក្នុងការធ្វើឱ្យមានទំនើបកម្មផលិតកម្មជាចាំបាច់តម្រូវឱ្យមានការពង្រីកបរិមាណទំនិញនាំចេញ ដើម្បីប្រមូលផ្តុំមូលធន។ ហេតុនេះហើយ ភាពចាំបាច់របស់យើងដែលជាមធ្យោបាយនោះ គឺត្រូវតែពង្រីកមុខទំនិញនាំចេញឱ្យបានច្រើន ព្រោះថា ភាពសុក្រឹតក្នុងវិស័យផលិតកម្មភាគច្រើនអាស្រ័យដោយមានប្រាក់ចំណូលពីការនាំចេញ។ ដូច្នេះហើយ ទំនើបកម្មឧស្សាហកម្មត្រូវតែចាប់ផ្តើមជាដំបូងចេញពីលទ្ធភាពនៃមុខទំនិញនាំចេញរបស់ប្រទេស។ ចំពោះលក្ខណៈចាំបាច់នៃការពង្រីកការនាំចេញត្រូវបានកំណត់ក្រោមលក្ខខណ្ឌមួយថា តើត្រូវធ្វើយ៉ាងណាឱ្យសេចក្តីត្រូវការក្នុងស្រុកបានផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ជាមុនសិន ហើយមិនត្រឹមតែផ្គត់ផ្គង់ដោយសារតែផលិត-កម្មក្នុងស្រុកនោះទេ ប៉ុន្តែដោយសារការនាំចូលពីបរទេសទៀតផងដែលទំហំទាំងអស់នោះអាស្រ័យដោយបរិមាណនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋព្រមទាំងអាស្រ័យដោយប្រាក់ចំណូលពីការនាំចេញ។

- សេដ្ឋកិច្ចកម្ពុជាសម័យនោះជាសេដ្ឋកិច្ចមានច្រើនសណ្ឋាន(ចម្រុះ) ក្នុងនោះវិស័យសេដ្ឋកិច្ចរដ្ឋបានដើរតួនាទីចម្បង។ ក៏ប៉ុន្តែ នៅចុងទសវត្សរ៍ទី៨០ បានចាប់ផ្តើមដំណើរការឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ។ ចំពោះឥទ្ធិពលដ៏ធំធេងទៅលើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសបានពឹងផ្អែកលើវិស័យមូលធនឯកជនដែលបានគ្របដណ្តប់រហូតដល់៤២,៨%នៃផ.ស.ស។ សេដ្ឋកិច្ចកសិកម្មរបស់កសិករខ្មែរយើងច្រើនកើតចេញពីកម្មសិទ្ធិតូចៗដែលបានកាន់កាប់ដីធ្លីស្រែចម្ការពី១ទៅ៣ហិកតា។ ក្នុងលក្ខខណ្ឌសង្គ្រាមស៊ីវិលនិងអវត្តមានបរិយាកាសវិនិយោគសមស្របបានធ្វើឱ្យមូលធនបរទេសនាសម័យកាលនោះ មានចំនួនតិចតួចក្នុងសេដ្ឋកិច្ចកម្ពុជា។

- លក្ខណៈពិសេសនៃយន្តការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅ

ប្រទេសនាសម័យកាលចុងក្រោយបង្អស់នោះស្ថិតនៅលើមាគ៌ាមួយដែលឈរលើគោលការណ៍ឯកភាពគ្នារវាងថ្នាក់ដឹកនាំនៃអង្គសន្និបាតជាតិ(រដ្ឋសភា) រវាងលេខាធិការដ្ឋានកំណែទម្រង់រដ្ឋរបស់នាយករដ្ឋមន្ត្រី និងរវាងប៊ុកនៃសមាជិកការិយាល័យនយោបាយដែលបានដឹកនាំដោយលោក សាយ ភូថង់។ គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាត្រូវបានតាក់-តែងឡើងដោយផ្ទាល់ក្នុងលក្ខណៈជាទម្រង់ត្រីភាគី រួមមានទីស្តីការនាយករដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងក្រសួងផែនការ។ ស្ថាប័នទាំងបីខាងលើនេះមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើដំណើរការតាក់តែងគោលនយោបាយសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេសរបស់កម្ពុជា និងជាអ្នកកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍។

សរុបមក ចំពោះជំហានបន្តនៃការសិក្សាស្រាវជ្រាវ យើងនឹងឈានទៅរកការសិក្សាវិភាគលើការកំណត់យុទ្ធសាស្ត្រសេដ្ឋកិច្ច និងគោលនយោ-បាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាក្នុងទសវត្សរ៍ទី៨០។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក២
# គោលបំណង និងមធ្យោបាយ នៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស

## ២.១ ទិសដៅជាមូលដ្ឋាននៃយុទ្ធសាស្ត្រសេដ្ឋកិច្ចក្រៅប្រទេស នាទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០

*តាមការស្រាវជ្រាវបង្ហាញថា បម្លាស់ប្តូរនូវលក្ខខណ្ឌទាំងក្នុង និងក្រៅប្រទេសលើកិច្ចដំណើរការផលិតកម្មសារឡើងវិញនៅប្រទេសកម្ពុជាបាននាំមកនូវប្រទីបបំភ្លឺផ្លូវជុំវិញមាគ៌ានៃការរៀបចំយុទ្ធសាស្ត្រសេដ្ឋកិច្ចសម្រាប់ក្នុង និងក្រៅប្រទេសរបស់ខ្លួន។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយស្ថិតនៅក្រោមឥទ្ធិពលនៃផលប្រយោជន៍នៃអំណាចរដ្ឋាភិបាល និងអំណាចនៃកម្លាំងនយោបាយក្នុងប្រទេស ក៏ដូចជាបានស្ថិតនៅក្រោមឥទ្ធិពលនៃមាគ៌ាមួយដែលពាក់ព័ន្ធទៅនឹងមនោគមវិជ្ជាសេដ្ឋកិច្ចរបស់បដិវត្តន៍កម្ពុជានាសម័យកាលនោះ។*

*យ៉ាងណាមិញ បន្ទាប់ពីបានរំដោះប្រទេសចេញពីរបប ប៉ុល ពត យើងឃើញថា នៅចំពោះមុខរដ្ឋាភិបាលថ្មី កិច្ចការដែលសំខាន់ជាងគេបំផុតនោះគឺទាក់ទងទៅនឹងបញ្ហាដែលថា តើត្រូវធ្វើយ៉ាងណាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេស សម្រាប់ពេលអនាគត ព្រមទាំងការស្តារខឿនសេដ្ឋកិច្ចជាតិឡើងវិញ ជាពិសេសគឺការស្តារវិស័យឧស្សាហកម្ម និងការកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចបញ្ជា( សេដ្ឋកិច្ចផែនការ)។ ហេតុដូច្នេះការបង្កើតឱ្យមានលក្ខខណ្ឌអំណោយផល សម្រាប់ការស្តាបនាវិស័យសេដ្ឋ-*


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កិច្ចឡើងវិញ និងការថែរក្សាឱ្យបាននូវស្ថិរភាពនយោបាយក្នុងប្រទេស គឺជាកិច្ចការដ៏ចាំបាច់ដែលទាំងអស់ខាងលើនេះជាគោលបំណងយ៉ាងសំខាន់មួយនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា។ ជាងនេះទៀត ចំពោះលក្ខខណ្ឌទាំងអស់នេះ ថ្នាក់ដឹកនាំនៃប្រទេសកម្ពុជានាសម័យនោះបានយកចិត្តទុកដាក់ខ្ពស់ដល់ការលើកកម្ពស់តួនាទីរបស់បក្ស និងរដ្ឋក្នុងការប្រមូលផ្តុំធនធានក្នុង និងក្រៅប្រទេស ដើម្បីអភិវឌ្ឍជាតិ។ ទន្ទឹមនឹងនេះដែរ ក្នុងស្ថានភាពដែលប្រទេសជាតិកំពុងតែមានបញ្ហាអស្ថិរភាពខាងនយោបាយ យើងពិនិត្យឃើញថា ប្រព័ន្ធសេដ្ឋ-កិច្ចបែបបង្គាប់បញ្ជាហាក់ដូចជាមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តលើកិច្ចការងារ ព្រោះប្រព័ន្ធនេះអាចឆ្លើយតបបានចំពោះផលប្រយោជន៍នៃបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលជាបក្សគ្រប់គ្រងអំណាច។ ជាងនេះទៀត ឆ្លើយតបទៅនឹងបញ្ហានេះដែរ ថ្នាក់ដឹកនាំរបស់ប្រទេសកម្ពុជានាសម័យកាលនោះបានជ្រើសរើសយកម៉ូឌែលអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈមាគ៌ាមួយផ្តោះទៅរកនិន្នាការសង្គមនិយម។

ដូចដែលយើងបានបញ្ជាក់ជារឿយៗហើយថា ប្រទេសកម្ពុជាជាប្រទេសកសិកម្ម ហេតុនេះគោលនយោបាយកសិកម្មជានិច្ចកាលត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់អ្នកដឹកនាំបក្ស និងរដ្ឋ។ ម្យ៉ាងវិញទៀត នៅតំបន់ជនបទស្រែចម្ការត្រូវបានគេចាត់ទុកថា ជាតំបន់សេដ្ឋកិច្ចយ៉ាងសំខាន់បំផុតរបស់ក្រុមចលនាតស៊ូធ្វើបដិវត្តន៍តាំងពីអតីតកាល ដូច្នេះហើយ តំបន់ស្រែចម្ការបានក្លាយជាមុខព្រួញនៃកម្មវិធីរបស់រដ្ឋយ៉ាងសកម្មសម្រាប់វិស័យសេដ្ឋកិច្ច វិស័យសង្គម និងវិស័យនយោបាយទៀតផង ដែលកម្មវិធីទាំងអស់នោះត្រូវបានគេច្របាច់បញ្ចូលគ្នាទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មជាតិ ពោលគឺកម្មវិធីទាំងអស់សម្រាប់តំបន់នោះតែងតែជាប់ពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម ហើយចំពោះកិច្ចការផ្សេងៗជាច្រើនទៀតសម្រាប់តំបន់ជនបទត្រូវបានក្លាយជាគោលដៅរួមមួយនៃកិច្ចការអភិវឌ្ឍ

សេដ្ឋកិច្ច និងសង្គម។

ផ្អែកលើកម្មវិធីដែលមានលក្ខណៈទ្រង់ទ្រាយ និងមានទិសដៅច្រើនយ៉ាងខាងលើនេះ មានគោលបំណងជាចម្បង គឺចង់ធ្វើយ៉ាងណាឱ្យមានការកាត់បន្ថយភាពតានតឹងផ្នែកសង្គម និងរក្សាឱ្យបាននូវស្ថិរភាពនយោបាយក្នុងប្រទេសក៏ដូចជាការគ្រប់គ្រងប្រជាជនជនបទឱ្យបានល្អ និងគាំទ្ររបបគ្រប់គ្រងសម័យនោះ។ ដោយហេតុថា នៅតំបន់ជនបទនៃប្រទេសកម្ពុជាគឺជាតំបន់ដែលមានសារៈសំខាន់បំផុត ហើយក៏ជាតំបន់ដែលធ្លាប់បានដើរតួនាទីយ៉ាងសំខាន់ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាល ហើយក៏នៅតែជាតំបន់ដែលមានលក្ខខណ្ឌភូមិសាស្ត្រអំណោយផលជាងគេផ្នែកសេដ្ឋកិច្ចដែលមិនទាន់បានរៀបចំឱ្យបានប្រសើរនៅឡើយជុំវិញការងារសេដ្ឋកិច្ច និងសង្គម។ ចំពោះយុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យកសិកម្មសម័យនោះ គឺត្រូវបានតាក់តែងឡើងជាកម្រងកម្មវិធីសំខាន់ៗដូចខាងក្រោមនេះ ៖

- ត្រូវជំរុញល្បឿនកំណើនផលិតកម្មកសិកម្ម
- ការបង្កើតជាក្រុមសាមគ្គីបង្កបង្កើនផលដែលជាទម្រង់នៃការចាប់ផ្តើមរបបសេដ្ឋកិច្ចកសិកម្មប្រមូលផ្តុំ
- ការអភិវឌ្ឍតំបន់កសិកម្មសំខាន់ៗដោយផ្អែកលើមូលដ្ឋានគ្រឹះនៃដំណើរការរបស់កម្លាំងផលិតកម្មកសិកម្មដោយផ្ទាល់។

ជាក់ស្តែងចំពោះកម្មវិធីអភិវឌ្ឍន៍ចំណុចដំបូងគេ យើងពិនិត្យឃើញថា បានសម្រេចជោគជ័យដ៏ត្រចះត្រចង់ ព្រោះប្រទេសកម្ពុជាសម័យនោះបានប្រកាសថា ទទួលបានសមិទ្ធផលជាផ្លែផ្កាជុំវិញការផ្គត់ផ្គង់ស្បៀងអាហារដោយខ្លួនឯង ពោលគឺចំពោះផលិតផលស្រូវអង្ករតែម្តង។ គួរបញ្ជាក់ដែរថា ក្នុងស្ថានភាពដែលប្រទេសនៅមានសង្គ្រាមស៊ីវិល ហេតុដូច្នេះសំខាន់បំផុតនោះគឺត្រូវតែថែរក្សា និងការពារកសិករឱ្យស្ថិតនៅក្រោមឥទ្ធិពលនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលកាន់អំណាច។ ដោយយោងលើស្ថានការណ៍ខាងលើនេះ ទើបកើតមានហេតុផលចាំបាច់ក្នុងការស្តាបនានៅតំបន់ជនបទ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នូវរចនាសម្ព័ន្ធសេដ្ឋកិច្ចដ៏ល្អ និងអង្គការនយោបាយមួយជាកំណត់។ ហេតុដូច្នេះហើយបានជាតម្រូវឱ្យមានការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល (ក.ស.ប) នៅតំបន់ជនបទស្រែចម្ការ ព្រោះវាជាបញ្ហាចាំបាច់បំផុត។

ទម្រង់នៃផលិតកម្មកសិកម្មខាងលើនេះ នៅសម័យកាលនោះ ត្រូវបានគេពង្រីកជាបន្តបន្ទាប់ចំពោះទម្រង់សេដ្ឋកិច្ចកសិកម្មប្រភេទនេះ ព្រោះអង្គការផលិតកម្មបែបនេះគឺជាទម្រង់មួយបានជំរុញឱ្យមានការលើកកម្ពស់ជីវភាពរស់នៅសម្រាប់តំបន់ជនបទ ព្រមទាំងរក្សាបាននូវទំនាក់ទំនងផលិតកម្មប្រមូលផ្តុំរបស់កសិករក្នុងវិស័យផលិតកម្ម ប៉ុន្តែបែបផែនផលិតកម្មនេះហាក់ដូចជាត្រូវបានរិះគន់ថា ជាគោលនយោបាយកសិកម្មបែបសម័យប៉ុល ពតទៅវិញ ទាំងគោលការណ៍អង្គការពលកម្មរបស់កសិករ ទាំងការបែងចែកផលិតផលកសិកម្ម។ ផ្សេងពីនេះទៀត ដោយសារតែការអនុញ្ញាតឱ្យមានការអភិវឌ្ឍទំនាក់ទំនងទីផ្សារសេរីនៅសម័យនោះ ហេតុនេះគេបានស្នើឡើងផងដែរនូវទម្រង់សេដ្ឋកិច្ចផ្សេងៗទៀត រួមមានទម្រង់សេដ្ឋកិច្ចជាកម្មសិទ្ធិឯកជនរបស់កសិករ និងការបែងចែកផលិតផលកសិកម្មរវាងពួកគេដោយខ្លួនឯង។ ចំពោះអង្គការកសិកម្មជាក្រុមសាមគ្គីបង្កបង្កើនផលត្រូវបានចាត់ទុកថា ជាវិធានការនៃការចាត់ចែងផលិតកម្មដែលបានធ្វើឱ្យគេឈានដល់ការប្រមូលផ្តុំកម្លាំងថាមពលចាំបាច់ សម្រាប់ការកែលម្អដីធ្លី និងការស្តារឡើងវិញនូវវិស័យកសិកម្ម ក្រោយពីបានធ្លាក់ចុះផលិតកម្មកសិកម្មនាសម័យកាលកន្លងមក។ បញ្ហាកង្វះខាតធនធានមនុស្សដែលមានគុណភាព ការបាត់បង់សមត្ថភាពពលកម្មទាំងស្រុង ឬដោយអន្ទើ ក្នុងចំណោមប្រជាជននៅជនបទ ការបាត់បង់កម្លាំងអូសទាញ បាត់បង់ឧបករណ៍កសិកម្ម ភាពខ្វះខាតនៃប្រព័ន្ធធារាសាស្ត្រ និងផ្លូវគមនាគមន៍ជាដើម-ល-។ ទាំងអស់នេះគឺជាមូលហេតុនៃការបង្កើតក្រុមសាមគ្គីបង្កបង្កើនផលឡើង។ ដូច្នេះ ការរៀបចំឱ្យមានអង្គការនៃក្រុមសាមគ្គីបង្កបង្កើនផល បាននាំមកនូវការប្រមូលផ្តុំគ្នានូវមធ្យោបាយផលិតកម្មទាំងអស់ដែលនៅសេសសល់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីសម័យមុនៗ ក្នុងទិសដៅប្រើប្រាស់ជាកម្លាំងរួមមួយ និងសម្រាប់ជាមូលដ្ឋានក្នុងការទ្រទ្រង់ជីវភាពរស់នៅចំពោះស្រទាប់ប្រជាជនជនបទដែលមានកង្វះខាតខ្លាំងផ្នែកអាហារ និងជាជនងាយរងគ្រោះផងនោះ។ ពិសេសជាងនេះទៀត គោលនយោបាយសេដ្ឋកិច្ច-សង្គមរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជានាតំបន់ជនបទសម័យនោះ បានកសាងឡើងដោយឈរលើវប្បធម៌ និងប្រពៃណីជួយគ្នាទៅវិញទៅមក ឬហៅថា ធ្វើស្រែប្រវាស់ដៃគ្នា ដែលនយោបាយបែបនេះ ចាត់ទុកថា ជាមធ្យោបាយមួយឆ្ពោះទៅរកវិស័យកសិកម្មប្រមូលផ្តុំនីយកម្ម ដោយពុំមានរូបភាពបង្ខិតបង្ខំ។ សមាជិកគ្រួសារកសិករនៃក្រុមសាមគ្គីបង្កបង្កើនផលបានទទួលសិទ្ធិឯករាជ្យក្នុងការបង្កើតក្រុមផលិតកម្មរបស់ខ្លួនដែលប្រមូលផ្តុំគ្នាពីអ្នកជិតខាង។ ម្យ៉ាងទៀត ពួកគេក៏មានសិទ្ធិក្នុងការជួលដីពីអាជ្ញាធរបន្ថែមទៀត ឬជួលដីពីក្រុមសាមគ្គីដទៃទៀតជាបណ្តោះអាសន្ន ដើម្បីពង្រីកការងារអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសាររបស់ខ្លួនផងដែរ។

## ២.១.១ ប្រភេទក្រុមសាមគ្គីបង្កបង្កើនផល និងការបែងចែកពលកម្ម

ក្រុមសាមគ្គីបង្កបង្កើនផលនៅសម័យនោះត្រូវបានគេបែងចែកជាបីប្រភេទដោយអាស្រ័យលើកម្រិតនៃទំហំកម្លាំងពលកម្ម និងអាស្រ័យលើមធ្យោបាយផលិតកម្មកសិកម្មសំខាន់ៗផងដែរ។ ចំពោះក្រុមសាមគ្គីនីមួយៗបានប្រសូតឡើងចេញពីការប្រមូលផ្តុំគ្នាពី១០ទៅ២០គ្រួសារ។

បើយើងពិនិត្យមើលចំពោះក្រុមសាមគ្គីប្រភេទទី១គឺជាក្រុមដែលមានទំហំសមាជិកពលកម្មច្រើនជាងគេ ហើយដីស្រែចម្ការសម្រាប់ប្រកបរបរកសិកម្មស្ថិតនៅជាកម្មសិទ្ធិរួមគ្នា និងការប្រើប្រាស់រួម។ ទន្ទឹមនឹងនេះ ការដាំដុះដំណាំស្រូវក្នុងរដូវកាលក៏ដូចជាការភ្ជួររាស់ដី ការសាបព្រោះ ការដាំដុះ ការប្រមូលផលស្រូវ ការដឹកជញ្ជូនផលស្រូវចេញពីស្រែចម្ការគឺដំណើរការឡើងដោយសមាជិកនៃគ្រួសារកសិករក្នុងលក្ខណៈជាការងារ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រួមគ្នាបែបសហករណ៍ពលកម្ម។ ពួកគេអាចធ្វើសេចក្តីសម្រេចផ្សេងៗ តាមរយៈអង្គប្រជុំរួមក្នុងក្រុម ជាពិសេសលើកិច្ចការសំខាន់ៗ និងការបែងចែកភោគផលស្រូវរបស់ពួកគេ។ ចំពោះកសិករដែលស្ថិតក្នុងវ័យពលកម្ម ត្រូវបានបែងចែកជាពីរលក្ខណៈវិនិច្ឆ័យ ពោលគឺជាកសិករក្រុមទី១ដោយសំដៅទៅលើក្រុមកសិករដែលពេញវ័យកម្លាំងពលកម្ម(ឬកម្លាំងស្នូល) និងមានសុខភាពមាំមួន អាចបំពេញការងារធ្ងន់ៗបាន រីឯកសិករក្រុមទី២ សំដៅលើកសិករវ័យក្មេង ឬកុមារជំទង់ និងមនុស្សវ័យចំណាស់។ ការគណនាបរិមាណពលកម្មត្រូវបានកំណត់ឡើងជាចំនួនថ្ងៃធ្វើពលកម្ម សម្រាប់កសិករម្នាក់ៗក្នុងមួយរដូវកាល។ ហេតុដូចនេះ មូលដ្ឋាននៃការបែងចែកភោគផលស្រូវបានធ្វើឡើងដោយគិតជាចំនួនថ្ងៃពលកម្មរបស់កសិករម្នាក់ៗ ដែលសម្រាប់កសិករក្រុមទី១(ឬកម្លាំងស្នូល) ត្រូវទទួលបានពី៧០%ទៅ៨០%នៃផលិតផលស្រូវសរុបដែលនៅសេសសល់ គឺសម្រាប់ក្រុមទី២។ ក៏ប៉ុន្តែ សម្រាប់គ្រួសារទាំងឡាយណាដែលមានសមាជិកគ្រួសារភាគច្រើនមិនបានស្ថិតក្នុងវ័យពលកម្ម(ជាកុមារជំទង់ ឬមនុស្សចាស់ជរា) ក៏ត្រូវទទួលបានភោគផលបន្ថែមដែរ។

ម្យ៉ាងវិញទៀត ចំពោះការបែងចែកទិន្នផលស្រូវ ដោយឈរលើមូលដ្ឋានគិតជាចំនួនថ្ងៃពលកម្ម និងការបែងចែកក្រុមកសិករជាពីរលក្ខណៈវិនិច្ឆ័យផ្សេងៗគ្នាបាននាំមកនូវភាពយុត្តិធម៌ចំពោះពួកគេ។ ក៏ប៉ុន្តែ ពុំមែនរាល់កសិករនៃប្រភេទទី១អាចធ្វើការតែម្នាក់ឯងបាននោះទេ ឬចេះធ្វើការងារអ្វីៗបានដូចៗគ្នានោះដែរ។ ហេតុនេះ ខ្នាតសមភាពដែលបានកំណត់ឡើងសម្រាប់ធ្វើជាមូលដ្ឋាននៃការបែងចែកផលប្រយោជន៍ដោយគិតជាចំនួនថ្ងៃពលកម្ម បាននាំមកនូវភាពអសកម្ម និងបាត់បង់ការចាប់អារម្មណ៍ពីសំណាក់កសិករដែលធ្វើការងារខ្លាំងក្លា ឬសកម្មជាងគេ។ ហេតុដូច្នេះ ការបែងចែកផលស្រូវតាមរយៈវិធីសាស្ត្រច្រើនយ៉ាងដោយផ្អែកលើសមិទ្ធផលការងារសរុប ក៏ដូចជាផ្អែកលើផលិតភាពពលកម្មរបស់ពួកគេ គឺជាវិធីសាស្ត្រ

ដ៏ត្រឹមត្រូវបំផុត មានន័យថា ត្រូវតែមានការបែងចែកទិន្នផលស្រូវតាមវិធីសាស្ត្រដោយឡែកៗពីគ្នា សម្រាប់លក្ខណៈវិនិច្ឆ័យផ្ទៃក្នុងនៃក្រុមនីមួយៗ ដោយអាស្រ័យលើកត្តាគុណភាព និងកត្តាបរិមាណពលកម្មដែលបានអនុវត្តការងារ។ ចំពោះអ្នកដែលធ្វើការងារច្រើន និងមានបទពិសោធន៍ខ្លាំងក្លា ត្រូវទទួលបានផលស្រូវច្រើនជាងគេ។ ហេតុនេះ មិនគប្បីធ្វើការបែងចែកដោយស្មើភាពគ្នានោះទេ ព្រោះអាចនាំមកនូវការថយចុះបរិមាណផលិតកម្មដំណាំស្រូវទៅវិញ។ ជាងនេះទៀត ប្រធានក្រុមដែលជាតំណាងត្រូវបានគេជ្រើសតាំងជារៀងរាល់ឆ្នាំដោយអង្គប្រជុំរួមរបស់ក្រុមសាមគ្គីបង្កបង្កើនផល(ក.ស.ប) ហើយគាត់មានតួនាទីចាំបាច់ក្នុងការចូលរួមនៅក្នុងសកម្មភាពផលិតកម្មដោយស្មើភាពគ្នា ដូចសមាជិកក្រុមដទៃទៀតដែរ ប៉ុន្តែគាត់អាចអវត្តមានក្នុងផលិតកម្មបានតែក្នុងករណីដែលត្រូវទៅបំពេញការកិច្ចផ្សេងៗទៀត ទាក់ទងទៅនឹងការគ្រប់គ្រង ឬការងារទាំងឡាយណាដែលបម្រើផលប្រយោជន៍រួមសម្រាប់ក្រុមសាមគ្គីបង្កបង្កើនផលទាំងមូល។

ចំពោះក.ស.បប្រភេទទី២គឺជាទម្រង់ផលិតកម្មកសិកម្មដែលផ្អែកលើមូលដ្ឋាននៃប្រព័ន្ធប្រវាស់ដៃគ្នាដែលធ្លាប់មានជាប្រពៃណីរបស់ខ្លួនតាំងពីយូរលង់ណាស់មកហើយ។ ក.ស.បប្រភេទទី២នេះត្រូវបានបង្កើតឡើងដោយធ្វើការបង្រួបបង្រួមគ្នាប្រមាណពី១០ទៅ១៧គ្រួសារក្នុងមួយក្រុមៗ ហើយបែងចែកជាក្រុមតូចៗបន្តទៀត គឺពី៣ទៅ៥គ្រួសារក្នុងមួយក្រុមៗ ហើយក្រុមនីមួយៗបានទទួលដីប្រើប្រាស់ពីមួយទៅបីឆ្នាំ។ បន្ទាប់ពីក្រុមកសិករបានបំពេញកិច្ចការធ្ងន់ៗរួមគ្នារួចមក ដូចជាការដាស់ដី ការភ្ជួររាស់ដី ការសាបសំណាបជាដើមរួចរាល់ហើយ ក្រោយមកទៀត ដីស្រែទាំងនោះត្រូវបានបែងចែកទៅឱ្យគ្រួសារផ្សេងៗគ្នាដែលគ្រួសារនីមួយៗត្រូវតែចាត់ចែងការដាំដុះបន្តដោយខ្លួនឯង រួមមានការដកសំណាប ការស្ទូង ការថែទាំ និងការច្រូតកាត់ជាដើម។ ចំពោះការបែងចែកដីធ្លីសម្រាប់គ្រួសារនីមួយៗវិញបានធ្វើឡើងជារៀងរាល់ឆ្នាំដោយធ្វើយ៉ាងណាឱ្យមានភាពយុត្តិធម៌ដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាស្រ័យលើគុណភាពដីធ្លី និងទំហំគ្រួសារផងដែរ ក៏ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះ ស្ថិតនៅត្រង់ថា បន្ទាប់ពីពួកគេបានបំពេញការងារសំខាន់ៗជាមួយគ្នារួចមកដូចជាការភ្ជួររាស់ដី ឬការសាបសំណាបជាដើមដែលសម្រាប់កិច្ចការងារបន្ទាប់ទៀតនោះ ត្រូវប្រគល់ឱ្យទៅក្រុមតូចៗ(ពី៣ទៅ៥គ្រួសារ) សម្រាប់គ្រប់គ្រងបន្ត តែមិនមែនទៅឱ្យគ្រួសារនីមួយៗនោះទេ។ ជាងនេះទៀត សម្រាប់ការដាំដុះបន្ត ត្រូវបែងចែកជាពីរលក្ខណៈពោលគឺសម្រាប់លក្ខណៈទី១សំដៅលើគ្រួសារកសិករដែលមានទំហំពី៣ទៅ៥គ្រួសារនោះពួកគេអាចធ្វើការរួមគ្នាតែម្តងក៏បាន រីឯសម្រាប់លក្ខណៈទី២ គេអាចអភិវឌ្ឍជាលក្ខណៈគ្រួសារ ឬករណីខ្លះទៀត ក៏អាចធ្វើការរួមគ្នាដោយអន្ទើក៏សឹងមាន។ ដូច្នេះ ទម្រង់អង្គការផលិតកម្មក.ស.បប្រភេទទី២មានលក្ខណៈបែបផែនផលិតកម្មប្រមូលផ្តុំ ឬជាទម្រង់ចម្រុះ។

ផ្សេងពីនេះទៀត ក.ស.បប្រភេទទី៣គឺជាទម្រង់ផលិតកម្មមួយប្រភេទផ្សេងទៀតនៃការអភិវឌ្ឍសេដ្ឋកិច្ចកសិកម្មដែលដីធ្លីកសិកម្មត្រូវបែងចែករវាងគ្រួសារនៃសមាជិកក្រុមទាំងអស់ ហើយការងារដាំដុះដំណាំស្រូវត្រូវបានអនុវត្តដោយគ្រួសារនីមួយៗរៀងៗខ្លួន។ ការបែងចែកដីធ្លីរវាងគ្រួសារនីមួយៗបានកំណត់ឡើងតាមគោលការណ៍ស្មើភាពគ្នាដោយផ្អែកលើគុណភាពដីកសិកម្ម ទំហំគ្រួសារ និងបរិមាណពលកម្មដែលត្រូវបំពេញការងារ។ ដោយហេតុថា សមាជិកគ្រួសារកសិករនៃក.ស.បរបស់ប្រភេទទី៣ដែលមានកម្លាំងអូសទាញជាសត្វពាហនៈក្នុងចំនួនច្រើនផ្សេងៗគ្នា ដូច្នេះ គេអាចប្រើប្រាស់ការជួលសត្វពាហនៈជាលក្ខណៈឯកជនទៅឱ្យគ្រួសារផ្សេងទៀតក៏បាន។ ក្នុងស្ថានភាពបែបនេះបាននាំមកនូវការកើតមានទម្រង់លក្ខណៈនៃការអភិវឌ្ឍសេដ្ឋកិច្ចជនបទជុំវិញទំនាក់ទំនងនៃការជួលសត្វគោ ឬក្របីតាមរយៈការផ្តល់សត្វពាហនៈជាលក្ខណៈកម្ចីឥណទានដែលមានការរីកចម្រើនដែរនាសម័យនោះ។ គួរបញ្ជាក់ដែរថា ក្នុងចំណោមសមាជិកគ្រួសារកសិករនៃក.ស.បប្រភេទទី៣ក៏កើតមាននូវទម្រង់បែបប្រវាស់ដៃគ្នាសុទ្ធសាធ

និងការជួលសត្វពាហនៈបន្ថែមៗ ឧទាហរណ៍ ៖ ម្ចាស់គោក្របីអាចជួលសត្វពាហនៈរបស់ខ្លួនទៅឱ្យក្រុមគ្រួសារណាដែលខ្វះខាតកម្លាំងអូសទាញ ហើយម្ចាស់គោក្របីខ្លួនឯងក៏អាចទៅជួយភ្ជួររាស់ ឬបំពេញកិច្ចការស្រែចម្ការផ្សេងៗទៀតឱ្យអ្នកជួលដែលក្រោយមកគ្រួសារដែលបានជួលគោ ឬក្របីពីគេនោះ ត្រូវមកបំពេញការងារសងជំនួសវិញក្នុងតម្លៃពលកម្មដូចគ្នាដែលគេបានជួយដល់ខ្លួនៗ

ក្រៅពីកិច្ចការខាងលើនេះ នៅសម័យកាលនោះដែរ យើងពិនិត្យឃើញថា បន្ទាប់ពីក្រុមគ្រួសាររបស់កសិករនៃក.ស.បបានប្រមូលភោគផលស្រូវរបស់ខ្លួនរួចមក ពួកគេបានយកទៅលក់ឱ្យរដ្ឋមួយចំនួន ឬមួយភាគស្របតាមតម្លៃដែលរដ្ឋបានកំណត់ទុកជាមុនៗ ផលិតផលលើសរបស់កសិករជាទូទៅបានលក់ទៅឱ្យរដ្ឋក្នុងតម្លៃចរចាគ្នាទៅតាមតំបន់នីមួយៗនៃប្រទេសៗ ឆ្លើយតបទៅនឹងកិច្ចការទាំងនេះ សហគ្រាសកសិកម្មរបស់រដ្ឋចាំបាច់ត្រូវតែរៀបចំជាទំនិញរបស់ខ្លួន ដើម្បីលក់មុខទំនិញប្រើប្រាស់នានា ក៏ដូចជាគ្រឿងបរិក្ខារកសិកម្មសំខាន់ៗទៅឱ្យកសិករវិញក្នុងអត្រាតម្លៃជាក់ស្តែងដែលអាចដោះដូរគ្នាបាន ប៉ុន្តែអត្រាតម្លៃទំនិញរបស់រដ្ឋត្រូវតែមានកម្រិតតម្លៃទាបជាងតម្លៃទីផ្សារសេរីៗ ទន្ទឹមនឹងនេះដែរ ចំពោះប្រតិបត្តិការទិញនិងលក់បានដំណើរការតាមរយៈភ្នាក់ងារដែលជ្រើសតាំងចេញពីតំណាងនៃក.ស.បៗ

ផ្សេងពីនេះទៀត បញ្ហាដែលបានកើតមានឡើងចំពោះមុខនៃគោលនយោបាយតម្លៃនៅសម័យនោះ គឺជាទូទៅ ច្រើនមានការពាក់ព័ន្ធទៅនឹងការប្រកួតប្រជែងគ្នាពីសំណាក់ពួកឈ្មួញកណ្តាលដែលបានរៀបចំឡើងដោយក្រុមឈ្មួញឯកជនៗ ពួកឈ្មួញទាំងអស់នោះតែងតែបានដើរតួនាទីជាអ្នកទិញស្រូវអង្ករដោយផ្ទាល់ពីកសិករ ដោយធ្វើការប្រកួតប្រជែងគ្នាជាមួយអង្គភាពរដ្ឋ ហើយបានប្រមូលទិញក្នុងអត្រាតម្លៃខ្ពស់ជាងតម្លៃរដ្ឋ (នៅសម័យនោះ តម្រូវការស្រូវអង្ករលើទីផ្សារខ្ពស់ជាងការផ្គត់ផ្គង់) ដែល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទីបំផុត កសិករភាគច្រើនបានលក់ផលិតផលរបស់ខ្លួនទៅឱ្យឈ្មួញឯកជនច្រើនជាងការលក់ទៅឱ្យអង្គភាពរដ្ឋ ពីព្រោះទទួលបានផលប្រយោជន៍សេដ្ឋកិច្ចខ្ពស់ជាង។ ជាងនេះទៀត ពួកឈ្មួញឯកជនហាក់ដូចជាបានសិក្សាយ៉ាងច្បាស់លាស់អំពីសេចក្តីត្រូវការរបស់កសិករ ព្រមទាំងបានយល់ច្បាស់ផងដែរអំពីយន្តការនៃសេដ្ឋកិច្ចទីផ្សារសេរីដែលធ្វើឱ្យពួកគេអាចទទួលបាននូវអាទិភាពលើធាតុឈុតនៃទីផ្សារទិញ និងលក់ស្រូវអង្ករ។ ចំណែកឯអង្គភាពរដ្ឋវិញទើបតែបានចាប់ផ្តើមបញ្ជ្រាបខ្លួនចូលទៅក្នុងដំណើរការនៃកិច្ចការអាជីវកម្មថ្មីប៉ុណ្ណោះ ហើយប្រាក់ចំណូល និងចំណាយរបស់ខ្លួនដែលទទួលបានពីការធ្វើអាជីវកម្មទៀតសោត គឺពុំអាស្រ័យលើទំហំនៃអត្រាថ្លៃដើមរបស់សេដ្ឋកិច្ចជាក់លាក់នោះទេ ព្រោះតែការប្រើប្រាស់វិធីសាស្ត្រនៃការគ្រប់គ្រងសេដ្ឋកិច្ចបែបរដ្ឋបាលបញ្ជា( សេដ្ឋកិច្ចផែនការ) ហេតុដូច្នេះហើយ ក្នុងកាលៈទេសៈខ្វះ រដ្ឋមិនអាចបំពេញការប្រមូលទិញផលិតផលកសិកម្មពីកសិករឱ្យបានសមស្របទៅតាមផែនការបានកំណត់នោះឡើយ។ ទន្ទឹមនឹងនេះដែរ បញ្ហាដែលរដ្ឋមិនអាចបំពេញផែនការរបស់ខ្លួនទៅបានបានជំរុញឱ្យរដ្ឋធ្វើសេចក្តីសម្រេចមួយដែលទាក់ទងទៅនឹងការធ្វើកំណែទម្រង់មគោបាយហិរញ្ញវត្ថុ និងទំនិញរបស់រដ្ឋជាជំហានៗលើការប្រមូលទិញផលិតផលកសិកម្មពីកសិករឱ្យបានគ្រប់ចំនួន។ ចំពោះការបង្កើតក.ស.បប្រភេទទី១ គឺជាទម្រង់មួយនៃការប្រមូលផ្តុំនីយកម្មសេដ្ឋកិច្ច-កសិកម្មនៅប្រទេសកម្ពុជាដែលបានបង្កប់ទៅដោយខ្លឹមសារជាអាទិភាពយ៉ាងជាក់លាក់ហើយក៏នៅមានភាពខ្វះចន្លោះច្រើនណាស់ដែរ។ ចំណុចជាអាទិភាពស្ថិតនៅត្រង់ថា អង្គការផលិតកម្មកសិកម្មធំៗសម័យនោះបានបើកលទ្ធភាពដ៏ធំធេងក្នុងការប្រើប្រាស់សមិទ្ធផលបរិក្ខារបច្ចេកទេសវិទ្យាសាស្ត្រ និងការអនុវត្តគោលនយោបាយប្រពលវប្បកម្មកសិកម្មជាដើម ក៏ប៉ុន្តែទម្រង់សេដ្ឋ-កិច្ចជនបទបែបប្រមូលផ្តុំខាងលើនេះហាក់ដូចជាមានលក្ខណៈអាថ៌កំបាំង និងបង្កជាគ្រោះថ្នាក់សម្រាប់ខ្លួនឯង តាមរយៈការគាស់រំលើងវណ្ណៈកសិករ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចេញពីស្រែចម្ការ និងបានធ្វើឱ្យចំណាប់អារម្មណ៍របស់ពួកគេចុះខ្សោយ ដោយសារតែការអនុវត្តទម្រង់សេដ្ឋកិច្ចកសិកម្មដែលគ្មានប្រសិទ្ធភាពក្នុងការបែងចែកថ្លៃពលកម្មរបស់ក.ស.បប្រភេទទី១។ ដោយឡែក ចំពោះការបង្កើតក.ស.បប្រភេទទី៣ដែលឈរលើមូលដ្ឋានសេដ្ឋកិច្ចកសិកម្មគ្រួសារដែលបានផ្សារភ្ជាប់គ្នារវាងម្ចាស់ដីជាមួយនឹងស្រែចម្ការរបស់ខ្លួនដោយមិនបានបង្ខិតបង្ខំឱ្យមានការប្រើប្រាស់ជាអតិបរមានូវសមិទ្ធផលវិទ្យាសាស្ត្រ និងបច្ចេកទេសកសិកម្មដែលទម្រង់បែបនេះហាក់ដូចជាមានប្រសិទ្ធភាពជាងទៅវិញ។ កិច្ចការសំខាន់បំផុតត្រូវតែកំណត់យកនូវទម្រង់អង្គការផលិតកម្មដ៏សមស្របមួយសម្រាប់សម័យនោះដែលអាចផ្សារភ្ជាប់ការចាប់អារម្មណ៍ពីគ្រប់មជ្ឈដ្ឋានគ្រួសារកសិករជនបទ ដោយធ្វើយ៉ាងណាឱ្យពួកគេចេះធ្វើការថែទាំ និងកែលម្អដីធ្លីកសិកម្មរបស់ខ្លួនឱ្យមានគុណភាព និងថែទាំមធ្យោបាយផលិតកម្មឱ្យបានប្រសើរ ពោលគឺត្រូវលុបបំបាត់ទស្សនៈស្មើភាពគ្នាក្នុងបំណែងចែកផលិតផលកសិកម្មរបស់ពួកគេចោល។

ក្រៅពីនេះទៀត បើយើងពិនិត្យមើលទៅលើគម្រោងរបស់ក.ស.បប្រភេទទី២វិញហាក់ដូចជាមានលក្ខណៈទន់ភ្លន់ជាង ដោយសារការកំណត់យកយន្តការសេដ្ឋកិច្ចចម្រុះ គឺបញ្ចូលគ្នារវាងក.ស.បប្រភេទទី១ និងទី៣ ដែលក្នុងនោះ គេបានបញ្ចូលសមាសធាតុនៃយន្តការសេដ្ឋកិច្ចបែបប្រមូលផ្តុំផង និងបែបគ្រួសារនិយមផង។ ការអនុវត្តបានបង្ហាញថា ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទម្រង់ផលិតកម្មបែបនេះមានតម្លៃខ្ពស់ជាងប្រភេទទី១ និងទី៣ ដែលទំហំនៃការចូលរួមរបស់គ្រួសារកសិករ និងទិន្នផលសរុបមានការកើនឡើងជាលំដាប់ ដូចជានៅឆ្នាំ១៩៨៦ មានរហូតដល់៦៩,១% និងចំនួនអង្គការផលិតកម្មមានប្រមាណជា៦៩.០១២ក.ស.បជាប្រភេទទី២។ យើងអាចសង្កេតមើលទិន្នន័យ និងនិន្នាការសេដ្ឋកិច្ចជនបទនាសម័យកាលនោះដូចខាងក្រោមនេះ ៖

## តារាងលេខ៧
## ទិន្នន័យសេដ្ឋកិច្ចក.ស.ប និងទំហំផលិតកម្មនាឆ្នាំ១៩៧៩-១៩៨៦

| ឆ្នាំ | ចំនួន ក.ស.ប | ចំនួន ក.ស.ប គិតជា% | | | បរិមាណ ក.ស.ប គ្រប់ប្រភេទ | | |
|---|---|---|---|---|---|---|---|
| | | ក.ស.ប ១ | ក.ស.ប ២ | ក.ស.ប ៣ | ក.ស.ប ១ | ក.ស.ប ២ | ក.ស.ប ៣ |
| ១៩៧៩ | ៥០,០០០ | ៣ | ២៧ | ៧០ | ១.៥០០ | ១៣.៥០០ | ៣៥.០០០ |
| ១៩៨០ | ៩៦.៥០០ | ៣៥ | ៤០ | ២៥ | ៣៣.៧៧៥ | ៣៨.៦០០ | ២៤.១២៥ |
| ១៩៨១ | ១០៦.៣០០ | ៣៦ | ៤៣ | ២១ | ៣៨.២៦៨ | ៤៥.៧០៩ | ២២.៣២៣ |
| ១៩៨២ | ៩៥.៣០០ | ៣៤ | ៤១ | ២៥ | ៣២.៤០២ | ៣៩.០៧៣ | ២៣.៨២៥ |
| ១៩៨៣ | ១០២.៩៥០ | ៣០ | ៥១ | ១៩ | ៣០.៨៨៥ | ៥២.៥០៥ | ១៩.៥៦០ |
| ១៩៨៤ | ១០២.៩៥០ | ១០ | ៥៥ | ៣៥ | ១០.២៩៥ | ៥៦.៦២៣ | ៣៦.០៣២ |
| ១៩៨៥ | ១០២.១០៥ | ២៥,២ | ៦០,៧ | ១៤,១ | ២៥.៧៩៣ | ៦២.០៦៦ | ១៤.២៤៦ |
| ១៩៨៦ | ៩៩.៨៧២ | ២២,៨ | ៦៩,១ | ៨,១ | ២២.៧៧៣ | ៦៩.០១៤ | ៨.០៨៥ |

***សម្គាល់ ៖ - ក.ស.ប១ សំដៅលើក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី១**
**- ក.ស.ប២ សំដៅលើក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី២**
**- ក.ស.ប៣ សំដៅលើក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី៣។**

ក្រៅពីអង្គការផលិតកម្មរបស់ក.ស.បដែលបានដាំដុះដំណាំស្រូវ យើងពិនិត្យឃើញថា នៅកម្ពុជាសម័យនោះ ក៏មានក.ស.បផ្នែកនេសាទផងដែរ និងការកែច្នៃអនុផលព្រៃឈើដែលគេហៅថា សហករណ៍នេសាទ ឬសហ-ករណ៍កែច្នៃឈើដែលបានកើតចេញពីសមាជិកស្ម័គ្រចិត្តនៅជនបទ។ ជាទូទៅ សមាជិកសហករណ៍ខាងលើនេះមានបំណងបង្កើតជាក្រុមសាមគ្គីដើម្បីទទួលបានការអនុញ្ញាតពីរដ្ឋអំណាចមូលដ្ឋាន ហើយពួកគេបានវិនិយោគរួមគ្នាសម្រាប់ដំណើរការអាជីវកម្មរបស់ខ្លួន និងអាចទទួលបានឥណទានពីរដ្ឋផងដែរ។

ហេតុដូចនេះ ចន្លោះឆ្នាំ១៩៨០-១៩៨៨ គោលនយោបាយសេដ្ឋកិច្ចកសិកម្មរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងរដ្ឋាភិបាលសម័យនោះ ពុំបាននាំមកនូវសមិទ្ធផលសេដ្ឋកិច្ចដែលគួរឱ្យមោទនៈនោះឡើយ។ អង្គការកសិកម្មប្រមូលផ្តុំនៅជនបទ បើទោះបីជាអង្គការទាំងនោះអាចដំណើរការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានក្នុងលក្ខខណ្ឌដែលប្រទេសនៅមានសង្គ្រាម និងអាចស្តារឡើងវិញនូវផលិតផលកសិកម្មក៏ដោយ ប៉ុន្តែគេនៅតែមិនទាន់មានសមត្ថភាពផលិតឱ្យស្មើនឹងសម័យកាលមុនសង្គ្រាមឆ្នាំ១៩៦៩បាននោះឡើយ។ លើសពីនេះទៅទៀត ទំហំផលិតកម្មរបស់ផលិតផលកសិកម្មសំខាន់ៗគ្រប់ប្រភេទបានឈានដល់កម្រិតប្រមាណតែ៧០%ប៉ុណ្ណោះ បើធៀបទៅនឹងសម័យមុនសង្គ្រាម។ ជាឧទាហរណ៍ ផលិតផលស្រូវដែលជាអាហារដ៏សំខាន់របស់ប្រជាជនខ្មែរ សម្រាប់ប្រជាពលរដ្ឋម្នាក់ៗនាសម័យនោះ គឺស្មើនឹង៣០៩គីឡូក្រាមប៉ុណ្ណោះនៅឆ្នាំ១៩៨៩ មានន័យថា មានទំហំ២ដងទាបជាងសម័យមុនសង្គ្រាម។ រីឯចំនួនសត្វពាហនៈវិញ មានប្រមាណតែ៨០%ប៉ុណ្ណោះ បើធៀបទៅនឹងឆ្នាំ១៩៦៩។ ខាងក្រោមនេះគឺជាទិន្នន័យស្ថិតិផលិតផលកសិកម្មសំខាន់ៗនៅសម័យនោះ។

## តារាងលេខ៨
## ផលិតកម្មនៃផលិតផលកសិកម្មសំខាន់ៗនៅកម្ពុជា
## នាឆ្នាំ១៩៦៩-១៩៨៩ (ពាន់តោន)

| បរិយាយ | ១៩៦៩ | ១៩៨០ | ១៩៨៥ | ១៩៨៨ | ១៩៨៩ |
|---|---|---|---|---|---|
| ១. ស្រូវ | ៣.៨១៤ | ១.៨៧៦ | ១.៨០៧ | ២.៥០០ | ២.៥៧២ |
| ២. ពោត | ១៣៧ | ១០១ | ៤២ | ៦០ | ៩០ |
| ៣. សណ្តែកដី | ២៣ | ២,៤ | ៤,៩០ | ៥,២០ | ៥,៨០ |
| ៤. សណ្តែកសៀង | ៥,៥០ | ៣,០០ | ១៣,១០ | ១៦,១០ | ១៦,៩០ |
| ៥. ល្ង | ១០,៨០ | ១,៥០ | ៥,៦០ | ៥,៨០ | ៥,៩០ |
| ៦. សណ្តែកបាយ | ៩,៤០ | _ | ៣,៣០ | ៤,២០ | ៤,៧០ |
| ៧. ថ្នាំជក់ | ១៦,៣០ | ៥,៣០ | ៥,៦០ | ៦,៧០ | ៧,៥០ |
| ៨. កៅស៊ូ | ៤៦ | ១,៣០ | ១៧,៧០ | ៣៣ | ៣៩ |


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ម្យ៉ាងវិញទៀត នៅដំណាក់កាលដំបូងនៃការចាប់ផ្តើមឡើងនៃអង្គការផលិតកម្មប្រមូលផ្តុំដែលបានស្នើឡើងតាមរយៈការបង្កើតជាក្រុមសាមគ្គីបង្កបង្កើនផលក្រោមយន្តការសេដ្ឋកិច្ចបង្គាប់បញ្ជាដែលរដ្ឋាភិបាលសម័យនោះយល់ថា គោលដៅនេះអាចប៉ុនប្រសប់ដល់ការធ្វើឱ្យកំណើនផលិតកម្មផលិតផលកសិកម្មមានសន្ទុះកើនឡើងយ៉ាងលឿនបំផុត ហើយអាចបញ្ជ្រាបការប្រើប្រាស់បច្ចេកវិទ្យាទំនើបផងដែរ សម្រាប់ការដាំដំណាំស្រូវនិងដំណាំជាប្រពៃណីដទៃទៀត។ តែផ្ទុយទៅវិញ គោលនយោបាយកសិកម្មបែបពលកម្មប្រមូលផ្តុំ(ពលកម្មរួមគ្នា)ដែលពុំទទួលបានការចាប់អារម្មណ៍ពីសំណាក់ប្រជាកសិករបែបនេះ យើងពិនិត្យឃើញថា គឺមិនអាចពង្រីកទំហំផលិតកម្មបាននោះឡើយ។

## ២.១.២ ឯកជនភាវូបនីយកម្ម និងទ្រឹស្តីអភិវឌ្ឍសេដ្ឋកិច្ច

ការស្តាបនាអង្គការផលិតកម្មដែលមិនបានផ្តល់ប្រសិទ្ធភាពសេដ្ឋកិច្ចតាមរយៈម៉ូឌែលនៃអង្គការផលិតកម្មប្រមូលផ្តុំក្នុងវិស័យកសិកម្ម បាននាំមកនូវកំណើនសេដ្ឋកិច្ចដ៏យឺតយ៉ាវបំផុតលើការអភិវឌ្ឍផលិតផលកសិកម្មព្រមទាំងធ្វើឱ្យមានភាពមិនសប្បាយចិត្តពីសំណាក់ប្រជាពលរដ្ឋជនបទទៀតផងដែលជាហេតុនាំឱ្យរដ្ឋអំណាចមូលដ្ឋានសម័យនោះ បានរិះរកវិធានការនានា ដើម្បីកែលម្អចំណុចខ្វះខាតរបស់ខ្លួន និងទាក់ទាញទំនុកចិត្តពីប្រជាកសិករ។ ឆ្លើយតបទៅនឹងបញ្ហានេះ ទើបនៅក្នុងមហាសន្និបាតថ្នាក់ជាតិលើកទីIIដែលបានប្រារព្ធឡើងក្នុងខែមេសា ឆ្នាំ១៩៨៩ បានចេញសេចក្តីសម្រេចលើកទី១របស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឆ្ពោះទៅរកមាគ៌ាមួយដែលហៅថា ឯកជនភាវូបនីយកម្មវិស័យកសិកម្មនៅប្រទេសកម្ពុជា។ ក្នុងមហាសន្និបាតនេះបានអនុម័តលើសេចក្តីសម្រេចចំនួន៣ចំណុចទាក់ទងទៅនឹងគោលនយោបាយកសិកម្មដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

- ការកំណត់គោលនយោបាយជុំវិញបញ្ហាកម្មសិទ្ធិ និងការប្រើប្រាស់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដីធ្លីកសិកម្ម

- គោលនយោបាយផលិតកម្មផលិតផលកសិកម្មតាមគោលការណ៍ប្រវាស់ដៃគ្នា

- គោលនយោបាយស្តីអំពីទំនាក់ទំនងរបស់ប្រជាកសិករនៅតំបន់ជនបទ។

ចំពោះសេចក្តីសម្រេចទាំងបីចំណុចខាងលើនេះ ក្រោយមកត្រូវបានរដ្ឋសភាជាតិគាំទ្រ និងបានអនុម័តតាមផ្លូវច្បាប់។

ក្នុងខ្លឹមសារដើមនៃសេចក្តីសម្រេចខាងលើនេះ យើងពិនិត្យឃើញថា សេចក្តីសម្រេចស្តីអំពីកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី មានខ្លឹមសារសំខាន់បំផុតដែលមានទិន្នាការផ្តោះទៅរកកម្មសិទ្ធិឯកជនលើកិច្ចការដីធ្លី។ បើទោះជាដីធ្លីទាំងអស់នៅសម័យនោះ បើយើងពិចារណាតាមផ្លូវច្បាប់គឺជាកម្មសិទ្ធិរបស់រដ្ឋដែលត្រូវបានផ្ទេរជាបណ្តើៗដោយឥតគិតថ្លៃទៅឱ្យគ្រួសារកសិករដែលកំពុងប្រើប្រាស់វា។ ចំពោះទំហំដីស្រែចម្ការវិញត្រូវបានកំណត់ដោយផ្អែកលើលក្ខខណ្ឌភូមិសាស្ត្រ ផ្អែកលើបរិមាណដីជាក់ស្តែងដែលបម្រុងទុក និងចំនួនមនុស្សនៅក្នុងគ្រួសារនីមួយៗ។ រដ្ឋបានផ្តល់ដីធ្លីជាលក្ខណៈសម្បទានទៅតាមការពិនិត្យ និងសម្រេចរបស់ខ្លួន រីឯប្រជាកសិករវិញត្រូវបង់ពន្ធលើការប្រើប្រាស់ដីធ្លីទៅឱ្យរដ្ឋវិញ។ ចំពោះដីធ្លីមួយចំនួនទៀតត្រូវបានហាមឃាត់សម្រាប់ការផ្ទេរជាកម្មសិទ្ធិឯកជន ក្នុងនោះមានដីដែលគ្របដណ្តប់ទៅដោយព្រៃឈើ ដីជាអាងស្តុកទឹកធម្មជាតិ តំបន់ដែលមានរ៉ែក្នុងដី តំបន់នេសាទ ទីតាំងវត្ថុវប្បធម៌(វត្ថុបុរាណ) និងតំបន់ប្រវត្តិសាស្ត្រ ទីវត្តអារាម និងឧទ្យានជាតិជាដើម។

ក៏ប៉ុន្តែលើកិច្ចការរានដីធ្លី និងការកែលម្អដីស្រែចម្ការបានអនុញ្ញាតឱ្យម្ចាស់កម្មសិទ្ធិជួលកម្លាំងពលកម្ម ប៉ុន្តែមិនអនុញ្ញាតឱ្យជួលគ្រឿងចក្រធំៗ ដើម្បីចូលរុករានដីស្រែចម្ការទាំងនោះឡើយ។ បើយោងតាមខ្លឹមសារនៃសេចក្តីសម្រេច ដីធ្លីកសិកម្មទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋ មានន័យថា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កសិករមានសិទ្ធិតែលើការកាន់កាប់ និងការប្រើប្រាស់តែប៉ុណ្ណោះ ប៉ុន្តែការអនុវត្តជាក់ស្តែងវិញ យើងឃើញថា គ្រួសារកសិករមានសិទ្ធិស្របច្បាប់ក្នុងការផ្ទេរកេរមរតកដីធ្លីទាំងអស់នោះទៅឱ្យកូនចៅរបស់ខ្លួន ព្រមទាំងមានសិទ្ធិពេញលេញក្នុងការលក់ដូរឱ្យទៅបុគ្គលផ្សេងទៀតបាន ហេតុនេះដីធ្លីសម័យនោះជាកម្មសិទ្ធិរបស់រដ្ឋតែនៅក្នុងក្រដាសតែប៉ុណ្ណោះ រីឯសភាពពិតតាមផ្លូវច្បាប់ និងផ្លូវសេដ្ឋកិច្ចវិញ ជាកម្មសិទ្ធិរបស់គ្រួសារកសិករ និងម្ចាស់កម្មសិទ្ធិ។ ជាងនេះទៅទៀត វិធានការទាំងអស់នេះមានគោលដៅច្បាស់លាស់ គឺចង់ធ្វើឱ្យប្រសើរឡើងនូវចរន្តនៃការប្រើប្រាស់ដីធ្លីដែលជាផលប្រយោជន៍ដល់កសិករ និងធ្វើឱ្យមានការរីកចម្រើនដល់ផ្នែកផលិតកម្មកសិកម្មឆ្ពោះទៅរកការផ្គត់ផ្គង់ស្បៀងអាហារដោយខ្លួនឯង ក៏ដូចជាពង្រីកការនាំចេញផលិតផល ហើយញ៉ាំងឱ្យអ្នកផលិតមានឱកាសលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន និងអាចស្តារឡើងវិញនូវសតិអារម្មណ៍ល្អក្នុងភាពជាម្ចាស់លើដីធ្លីពិតប្រាកដ។

ចំណែកឯសេចក្តីសម្រេចជុំវិញគោលនយោបាយ( ចំណុចទី២)ស្តីពីផលិតកម្មផលិតផលកសិកម្មតាមគោលការណ៍ជួយគ្នាទៅវិញទៅមកវិញ (តាមលក្ខណៈប្រវាស់ដៃគ្នា) យើងពិនិត្យឃើញថា មានទិសដៅឆ្ពោះទៅរកដំណោះស្រាយមួយពាក់ព័ន្ធទៅនឹងទម្រង់អង្គការផលិតកម្មបែបប្រមូលផ្តុំ( ការងាររួម)ឱ្យទៅជាបែបផលិតកម្មជាលក្ខណៈគ្រួសារវិញ។ ម្យ៉ាងទៀតក្រុមសាមគ្គីបង្កបង្កើនផល( ក.ស.ប)ដែលជាប្រភេទអង្គការផលិតកម្មជនបទ គឺត្រូវរំសាយចោល។ ប៉ុន្តែនៅមាននិន្នាការលើកទឹកចិត្ត គាំទ្រលើគោលនយោបាយជួយគ្នាដោយស្ម័គ្រចិត្ត ជាពិសេសក្នុងការបំពេញការងារធ្ងន់ៗក្នុងវាលស្រែ ឬចម្ការ( ពីព្រោះគ្រួសារខ្វះមានស្ត្រីជាមេគ្រួសារ និងមានកូនច្រើន)។ ក្នុងបញ្ហានេះដែរ ការរំសាយចោលទម្រង់ក.ស.បបានធ្វើឱ្យកើតមានបញ្ហាថ្មីៗជាច្រើនទៀត នៅក្នុងវិស័យកសិកម្ម ហេតុនេះហើយទើបរដ្ឋាភិបាលសម័យនោះបានពិចារណាលើការបង្កើតគោលនយោ-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បាយកសិកម្មបែបថ្មីដែលបានពិនិត្យបន្ថែមទៅលើការបង្កើតឱ្យមានជាសហគមន៍កសិកម្មជំនួសវិញដែលសហគមន៍នេះនាំមកនូវការការពារសិទ្ធិនិងផលប្រយោជន៍ដល់គ្រួសារកសិករ តាមរយៈការផ្ដល់ការអនុគ្រោះនានារួមមានការនាំចូលគ្រឿងយន្តនិងបរិក្ខារកសិកម្ម នាំចូលជីកសិកម្ម លើកទឹកចិត្តចំពោះការកសាងផ្លូវជនបទនិងទំនប់ ប្រលាយទឹកក៏ដូចជាការអភិវឌ្ឍសហគ្រាសកែច្នៃវត្ថុធាតុដើមកសិកម្ម និងធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថិរភាពថ្លៃទំនិញកសិកម្មជាដើម។ សរុបមក ការរំសាយចោលក.ស.បនៅតំបន់ជនបទដែលជាអង្គការផលិតកម្មមិនមានប្រសិទ្ធភាព និងបង្កប់ដោយរូបភាពគ្រប់គ្រងបែបការិយាល័យធិបតេយ្យច្រើនជាន់ថ្នាក់ដែលក្រោយមកត្រូវបានជំនួសដោយការគ្រប់គ្រងតាមរបៀបរចនាសម្ព័ន្ធថ្មីៗវិញនាដំណាក់កាលនោះ។

ចំពោះបញ្ហាខាងលើនេះ បើយើងវិភាគតាមទស្សនៈនៃអ្នកដឹកនាំខ្មែរសម័យនោះបានពន្យល់ថា ការរំសាយក.ស.ប និងភាពបរាជ័យរបស់វាគឺដោយសារតែប្រទេសកម្ពុជានាដំណាក់កាលនោះហាក់នៅមានភាពក្មេងខ្ចីនៅឡើយ សម្រាប់ការអនុវត្តសេដ្ឋកិច្ចកសិកម្មបែបប្រមូលផ្ដុំ(រួមគ្នា)។ ផ្ទុយទៅវិញ បើតាមទស្សនៈរបស់យើង(ជាអ្នកស្រាវជ្រាវនិក្ខេបបទនេះ) យល់ឃើញថា ម៉ូឌែលអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទរបស់កម្ពុជាដែលបានអូសបន្លាយអស់រយៈពេល៩ឆ្នាំ(១៩៨០-១៩៨៩) ដោយប្រើប្រាស់ទម្រង់សេដ្ឋកិច្ចបែបក.ស.ប ជាពិសេសក.ស.បប្រភេទទី១ គឺមិនអាចទៅរួចនោះទេ (មានន័យថាជាប់គាំង) ព្រោះពុំបានគិតគូរច្បាស់លាស់ដល់ផលប្រយោជន៍ជាក់លាក់នៃអ្នកផលិត និងគ្មានការប្រកួតប្រជែងជាសកល។ បទពិសោធន៍ពិភពលោកបានអះអាងថា សំខាន់បំផុតពុំមែនសំដៅលើម៉ូឌែលណាមួយឬគ្រឿងផ្សំជាកំណត់ណាមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទនោះទេ ប៉ុន្តែរឿងដែលត្រូវយកចិត្តទុកដាក់បំផុតនោះ គឺសំដៅលើការបង្កើតយន្តការផលិតកម្មសមស្របមួយដោយចេះតាក់តែង ឬកែច្នៃទម្រង់ដែលមានជម្រើស

ច្រើនយ៉ាងស្របទៅតាមលក្ខខណ្ឌធម្មជាតិ និងប្រពៃណីទំនៀមទម្លាប់របស់ប្រទេសនោះ។ សរុបមក បើសិនជាយើងគ្រប់គ្រងដែលកំណត់យកគោលការណ៍តែមួយ សម្រាប់ទាំងអស់គ្នា នោះវានឹងនាំមកនូវភាពរលាយសាបសូន្យគ្រប់កំណែទម្រង់ទាំងអស់។ យ៉ាងណាមិញ បើយោងតាមការស្រាវជ្រាវរបស់សង្គមវិទូអង់គ្លេសគឺលោក Teodor Shanin ជាអ្នកប្រាជ្ញដ៏ល្បីឈ្មោះម្នាក់ក្នុងចំណោមអ្នកស្រាវជ្រាវផ្នែកការងារសង្គម បានស្រាវជ្រាវរកឃើញទ្រឹស្តីមួយចំនួនជុំវិញទស្សនទាននៃការអភិវឌ្ឍសេដ្ឋកិច្ចកសិកម្ម និងជនបទដូចខាងក្រោមនេះ ៖

- ម៉ូឌែលទី១ ៖ ផលិតកាន់តែធំ កាន់តែប្រសើរ
- ម៉ូឌែលទី២ ៖ វិនិយោគកាន់តែច្រើន ទទួលផលកាន់តែធំ
- ម៉ូឌែលទី៣ ៖ បើអ្នកផលិតចាប់អារម្មណ៍កាន់តែខ្លាំង ការងារទាំងអស់កាន់តែប្រសើរឡើង
- ម៉ូឌែលទី៤ ៖ ត្រូវទទួលស្គាល់កត្តាកំណត់របស់សហគ្រាសដែលមិនអាស្រ័យតែលើកត្តាពលកម្មរបស់កសិករនោះទេ ប៉ុន្តែបញ្ហាសំខាន់ជាងនេះគឺជីវិតផ្ទាល់ខ្លួនរបស់កសិករទៅវិញទេ។

តាមទស្សនៈរបស់ Teodor Shanin យើងពិនិត្យឃើញថា អនុគមន៍រវាងម៉ូឌែលទី៣ និងទី៤មានលក្ខណៈស័ក្តិសមជាងគេ។ ម្យ៉ាងទៀត តម្លៃនៃទស្សនៈម៉ូឌែលទី៣ពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ចជាលក្ខណៈគ្រួសារ និងសេដ្ឋកិច្ចកសិដ្ឋាន ប៉ុន្តែការរីកលូតលាស់ជាផ្ទៃផ្ការបស់ម៉ូឌែលនេះមិនអាចដោះស្រាយបញ្ហាទាំងអស់បានដោយឯកឯងនោះទេ កិច្ចការដែលសំខាន់ជាងនេះទៀតនោះ យើងមិនអាចនិយាយថា ទម្រង់អង្គការផលិតកម្មមួយណាប្រសើរជាងមួយណានោះឡើយ តែបញ្ហាសំខាន់បំផុតត្រូវធ្វើយ៉ាងណាដើម្បីឱ្យកសិករមានលទ្ធភាពជ្រើសរើសមាគ៌ាមួយដែលពួកគេត្រូវដើរដោយខ្លួនឯង( ជាទម្រង់បែបក.ស.ប ឬបែបជាសេដ្ឋកិច្ចគ្រួសារ)។ ជាធម្មតា ក្នុងការជ្រើសរើសទម្រង់ផលិតកម្មនានា វាអាចមានកំហុសខ្លះដែរដែលចៀស



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មិនរួច ប៉ុន្តែកសិករអាចកែលម្អបានដោយខ្លួនឯង ហើយការខាតបង់ក៏មិនធ្ងន់ធ្ងរនោះដែរ ជាជាងការជ្រើសរើសទម្រង់ផលិតកម្មដែលមានការគ្រប់គ្រងច្រើនជាន់ថ្នាក់ និងដោយបង្ខិតបង្ខំឱ្យកសិករទទួលយកទម្រង់ដែលពួកគេមិនពេញចិត្ត។

ផ្សេងពីនេះទៀត ទិសដៅគោលនយោបាយសេដ្ឋកិច្ចកសិកម្មដ៏សំខាន់មួយក្នុងចំណោមទិសដៅផ្សេងៗទៀតនៃបក្សប្រជាជនបដិវត្តន៍កម្ពុជាសំដៅលើមាគ៌ាផលិតកម្មបែបប្រពលវប្បកម្ម។ ក្នុងកិច្ចប្រជុំពេញអង្គនៃគណៈកម្មការមជ្ឈិមបក្សដែលបានធ្វើឡើងនៅខែមករា ឆ្នាំ១៩៨៤ស្តីពីគោលនយោបាយទំនាក់ទំនងផលិតកម្មរបស់កសិករនៅជនបទ បានកំណត់ថា «ជាការចាំបាច់ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការធ្វើសេដ្ឋកិច្ចកសិកម្មបែបប្រពលវប្បកម្ម ជាពិសេសការផលិតស្រូវ»។ កិច្ចប្រជុំពេញអង្គបានយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការបច្ចេកទេសនិងបច្ចេកវិទ្យា និងកត្តាលក្ខខណ្ឌភូមិសាស្ត្រក្នុងការផលិត។ អង្គប្រជុំបានកំណត់ថា «ដើម្បីលើកកម្ពស់ផលិតភាពផលិតកម្មក្នុងវិស័យសេដ្ឋកិច្ចកសិកម្មដែលប្រសើរបំផុតត្រូវជំរុញល្បឿនការប្រើប្រាស់សមិទ្ធផលវិទ្យាសាស្ត្រ និងបរិក្ខារទំនើប ការពង្រីកប្រព័ន្ធធារាសាស្ត្រ ការជ្រើសរើសពូជដំណាំផ្តល់ផលខ្ពស់ ការប្រើប្រាស់ជីធម្មជាតិ និងគីមី ក៏ដូចជាការថែទាំល្អ»។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៨៤ ក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈកម្មការមជ្ឈិមបក្សបានប្រជុំពិភាក្សា និងតាក់តែងកម្មវិធីឯកទេសនីយកម្ម សម្រាប់តំបន់កសិកម្មនៅក្នុងប្រទេស ប៉ុន្តែកម្មវិធីនេះពុំបានដំណើរការឡើយ។ រដ្ឋាភិបាលនៅសម័យនោះគឺបានពង្រីកការចូលរួមដោយផ្ទាល់ក្នុងការស្តាបនាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តកសិកម្ម(ភាគច្រើនបានសាងសង់ប្រព័ន្ធធារាសាស្ត្រ)។ ជាងនេះទៀត រដ្ឋាភិបាលបានចូលរួមក្នុងចលនាទិញដូរផលិតផលផងដែរ(ដោយរដ្ឋបានពង្រីកការប្រមូលទិញផលិតផលកសិកម្ម)។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.១.៣ ដំណើរស្តារឡើងវិញនូវវិស័យឧស្សាហូបនីយកម្ម

ក្រៅពីការខិតខំជម្នះរាល់ឧបសគ្គលើការអភិវឌ្ឍវិស័យកសិកម្មដ៏ចាំបាច់នោះ ដើម្បីការរស់រានឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា ការអភិវឌ្ឍវិស័យឧស្សាហូនីយកម្មក៏ត្រូវបានរដ្ឋពិនិត្យឡើងវិញផងដែរដែលជាលក្ខខណ្ឌចាំបាច់ក្នុងការបំពេញនូវសេចក្តីត្រូវការប្រចាំថ្ងៃក៏ដូចជាបំពេញផែនការក្នុងចក្ខុវិស័យសម្រាប់អនាគតដែលវិស័យឧស្សាហកម្មនេះត្រូវបានរដ្ឋាភិបាលចាត់ទុកថា ជាវិស័យយុទ្ធសាស្ត្រមួយទៀតក្នុងរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជានាសម័យកាលនោះ។

ជាក់ស្តែង នៅពាក់កណ្តាលទសវត្សរ៍ទី៧០ ពោលគឺនៅក្នុងការគ្រប់គ្រងដោយរបបប៉ុល ពត យើងឃើញថា រោងចក្រសហគ្រាសស្ទើរតែទាំងអស់ត្រូវបានគេបំផ្លាញចោល ឬបញ្ឈប់សកម្មភាពទាំងស្រុង។ ក្រោយឆ្នាំ១៩៧៩ គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលក្នុងវិស័យអភិវឌ្ឍន៍ឧស្សាហកម្មត្រូវបានយកចិត្តទុកដាក់ និងស្តារឡើងវិញដោយបានប្រែក្លាយរោងចក្រសហគ្រាសទាំងអស់នោះឱ្យទៅជាវិស័យឧស្សាហកម្មរដ្ឋដែលនាំមុខក្នុងសេដ្ឋកិច្ចជាតិ។ ការងារស្តារឡើងវិញបានចាប់ផ្តើមឡើងភ្លាមៗ បន្ទាប់ពីថ្ងៃទទួលបានជ័យជម្នះលើរបបប៉ុល ពតនៅឆ្នាំ១៩៧៩ដែលជាទូទៅ ស្ថិតក្រោមការជួយសហការពីសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត និងបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបខាងកើត។ ក៏ប៉ុន្តែ កិច្ចការស្តារឡើងវិញនេះអាចដំណើរការបានតែនៅក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាទីរួមខេត្តតែប៉ុណ្ណោះ ដោយសារតែនៅសម័យកាលនោះ សង្គ្រាមស៊ីវិលនៅតែកើតមាននៅឡើយ។ មកដល់ឆ្នាំ១៩៩០ រដ្ឋបានស្តារឡើងវិញនូវរោងចក្រសហគ្រាសបានរហូតដល់៦៩សហគ្រាសក្នុងចំណោម៨៧រោងចក្រដែលធ្លាប់មានពីមុនមក។ ជារៀងរាល់ឆ្នាំ ក្នុងការអភិវឌ្ឍវិស័យនេះដែរ រដ្ឋបានចំណាយដើមទុនវិនិយោគរហូតដល់ទៅ១០%ទៅ១៥%នៃថវិការដ្ឋ។

ចំពោះការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងវិស័យសេដ្ឋកិច្ចជាតិលើដងវិថី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃការស្តាបនា និងការពង្រីកវិស័យសេដ្ឋកិច្ចរដ្ឋត្រូវបានចាត់ទុកជាគោលនយោបាយឧស្សាហកម្មដ៏ចម្បងមួយរបស់ប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសកំពុងអភិវឌ្ឍនានាជាច្រើនទៀតក្នុងនិន្នាការមូលធននិយម យើងពិនិត្យឃើញថា វិស័យសេដ្ឋកិច្ចរដ្ឋត្រូវបានចាត់ទុកថា ជាវិស័យគន្លឹះក្នុងដំណោះស្រាយលើភាពអន់ថយ និងឈានទៅរកការរីកលូតលាស់សេដ្ឋកិច្ចជាតិដោយឯករាជ្យ។ ក៏ប៉ុន្តែ ការប្រែក្លាយសេដ្ឋកិច្ចរដ្ឋឱ្យទៅជាវិស័យចម្បង និងឈានមុខគេបាននាំមកនូវការបង្កើតទម្រង់គ្រប់គ្រងដោយក្បាលម៉ាស៊ីនរដ្ឋ ក្នុងវិស័យសេដ្ឋកិច្ចបែបមជ្ឈការ។ ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្មភាគច្រើន ជាប់ពាក់-ព័ន្ធទៅនឹងវិស័យកសិកម្មដែលក្នុងនោះមានការពង្រឹងដោយផ្ទាល់សម្រាប់វិស័យឧស្សាហកម្មផលិតកម្ម តាមរយៈការប្រើប្រាស់វត្ថុធាតុដើមកសិកម្មក្នុងការកែច្នៃជាផលិតផលសម្រេច ឬពាក់កណ្តាលសម្រេច។ រដ្ឋបានផ្តល់ការអនុគ្រោះពន្ធ និងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ផលិតកម្មខ្នាតតូច និងសិប្បកម្មគ្រួសារដែលទាក់ទងទៅនឹងការកែច្នៃផលិតផលកសិកម្ម។

ការរីកលូតលាស់នៃផលិតកម្មខ្នាតតូច និងសិប្បកម្មគ្រួសារបានក្លាយជាទិសដៅដ៏សំខាន់បំផុតសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មនាសម័យទំនើបដែលមានឥរិយាបថសម្រាប់បំពេញដំណាក់កាលនានាក្នុងដំណើរការផលិតកម្ម។ សម្រាប់ទិសដៅនេះ ក្នុងវិស័យឧស្សាហូបនីយកម្ម និងសិប្បកម្មបាននាំមកនូវដំណោះស្រាយបញ្ហាសេដ្ឋកិច្ច និងសង្គមយ៉ាងចាំបាច់បំផុតនៅក្នុងប្រទេស ពោលគឺបានជួយដោះស្រាយលើបញ្ហាបង្កើតការងារថ្មីៗបន្ថែមទៀត។ ទាក់ទងទៅនឹងកិច្ចការនេះ ការគាំទ្រទៅលើសហ-គ្រាសខ្នាតតូច និងសិប្បកម្មគ្រួសារ សម្រាប់គ្រប់អនុវិស័យនៃសិប្បកម្មផលិតកម្ម ជាកត្តាគន្លឹះ ព្រោះវិស័យនេះបានប្រើប្រាស់ទុនវិនិយោគបន្តិច-បន្តួច ប៉ុន្តែទទួលបានលទ្ធភាពធំធេងក្នុងយន្តការផលិតដោយដៃ។ ក្នុងមហាសន្និបាតលើកទី៤នៃបក្សប្រជាជនបដិវត្តន៍កម្ពុជានៅខែមីនា ឆ្នាំ១៩៨១បាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រេចជ្រើសរើសមាគ៌ាអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដោយផ្តោតជាអាទិភាពទៅលើវិស័យឧស្សាហកម្មខ្នាតតូច មធ្យម និងសិប្បកម្ម។ ឧស្សាហកម្មខ្នាតតូច និងមធ្យម ជាទូទៅប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ហើយមិនទាមទារការវិនិយោគធំដុំ និងមានការចំណាយទុនបង្វិលជាអប្បបរមា ប៉ុន្តែអាចដំណើរការផលិតជាទំនិញទៅបាន។ ផលិតផលឧស្សាហកម្មប្រភេទនេះច្រើនតែបម្រើឱ្យសេចក្តីត្រូវការសម្រាប់ទីផ្សារក្នុងស្រុកដែលមានដែនកំណត់ ប៉ុន្តែងាយស្រួលបត់បែនទៅតាមការចង់បាននៃទីផ្សារ ទាំងបរិមាណមុខទំនិញ ទាំងទំហំរបស់វា។

ឧស្សាហកម្មគ្រួសារ និងសិប្បកម្មបានដើរតួនាទីសំខាន់បំផុតក្នុងការស្តារសេដ្ឋកិច្ចកម្ពុជានាសម័យនោះឡើងវិញ ជាពិសេស លើការបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋស្ទើរគ្រប់មុខទំនិញចំបាច់។ ហេតុដូច្នេះហើយការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់រដ្ឋគឺការគាំទ្រឱ្យមានការបង្កើតជាអង្គការសិប្បកម្ម ក្នុងលក្ខណៈសហគមន៍ផលិតកម្ម ក៏ដូចជាការផលិតក្នុងលក្ខណៈទ្រង់ទ្រាយគ្រួសារដែលសហគ្រាសគ្រួសារប្រភេទនេះ ជាទូទៅបានទទួលជំនួយឧបត្ថម្ភពីរដ្ឋលើផ្នែកវត្ថុធាតុដើម និងផ្នែកអគ្គិសនី។ នៅឆ្នាំ១៩៨២ ប្រទេសកម្ពុជាបានអនុម័តលើសេចក្តីសម្រេចដ៏សំខាន់មួយរបស់គណៈកម្មការមជ្ឈិមបក្សលេខ២៤៧ ស្តីអំពីការបង្កើតឱ្យមានសហគ្រាសគ្រួសារ និងសិប្បកម្មផលិតកម្មដែលបង្ហាញអំពីទិសដៅដ៏ចម្បងក្នុងការអភិវឌ្ឍឧស្សាហកម្ម។ សហគ្រាសទាំងនេះបានក្លាយជាវិស័យសេដ្ឋកិច្ចឧស្សាហកម្មក្នុងទម្រង់ជាសហគមន៍ផលិតកម្មដែលជាក្រុមសាមគ្គីសិប្បកម្មផលិតកម្ម(ក.ស.ផ) ដោយឈរលើកម្មសិទ្ធិរួម(សហកម្មសិទ្ធិ) និងការបង្រួបបង្រួមគ្រួសារផលិតករជាច្រើនដែលមានភាគហ៊ុនផ្សេងៗគ្នា និងមានមធ្យោបាយពលកម្មរៀងៗខ្លួន។ ជុំវិញកិច្ចការនេះដែរ រដ្ឋបានកំណត់វិធានការច្បាប់តាមរយៈគោលនយោបាយពន្ធដារ និងការទទួលបានប្រាក់កម្ចីឥណទានពីធនាគារជាតិដែលក្នុងនោះអ្នកទទួលបានជាអាទិភាពគឺជាក្រុមដែល


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធ្វើសកម្មភាពផលិត ហើយមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយសហគ្រាសរដ្ឋ ឬក្រុមដែលផលិតនូវផលិតផលថ្មីៗ។ គួរបញ្ជាក់ដែរថា មានប្រភពពីរយ៉ាងដែលអាចទទួលបានវត្ថុធាតុដើមពីរដ្ឋ រួមមានការឧបត្ថម្ភពីរដ្ឋដោយផ្ទាល់ និងតាមរយៈកិច្ចព្រមព្រៀង។

ជាងនេះទៀត គោលបំណងដែលសំខាន់ជាងគេក្នុងការបង្កើត ក.ស.ផ បែបសហគមន៍ មានគោលដៅច្បាស់លាស់ ព្រោះតែរដ្ឋាភិបាលចង់ឱ្យសហគ្រាសទាំងអស់នោះពង្រីកបរិមាណផលិតទំនិញប្រើប្រាស់ឱ្យបានទូលំទូលាយ និងអូសទាញពួកពាណិជ្ជករឯកជនឱ្យមកចូលរួមក្នុងចរន្តនៃក.ស.ផ និងក្នុងវិស័យផលិតកម្ម ហើយធ្វើយ៉ាងណាដើម្បីប្រមូលផ្តុំមូលធនឯកជនឱ្យមកបម្រើផលប្រយោជន៍សម្រាប់ការផលិតក្នុងសេដ្ឋកិច្ច និងសង្គម។

គួររំឭកផងដែរថា នៅឆ្នាំ១៩៨៦ នៅទីក្រុងភ្នំពេញ ត្រូវបានចុះបញ្ជីស្ថិតិសហគ្រាសខ្នាតតូច និងសិប្បកម្មគ្រួសារ បានប្រមាណជា១៦៩៧ សហគ្រាសដែលក្នុងនោះ ១៨២សហគ្រាសមានឯកទេសកម្មផ្នែកផលិតលោហធាតុ ២៥៨ជាសហគ្រាសកែច្នៃផលិតផលកសិកម្ម ៥៥៨ជាពោង-ជាងជួសជុលនិងបម្រើសេវាកម្ម ៧៩ជាសហគ្រាសផលិតទំនិញពីវត្ថុធាតុជ័រផ្លាស្ទិក ៥៣ជាសហគ្រាសដេរសម្លៀកបំពាក់ ផ្នែកតម្បាញ និងដេរស្បែកសត្វ ៥៥ជាសហគ្រាសកែច្នៃឈើ និងឫស្សី និង៩៣ជាសហគ្រាសកាត់កញ្ចក់។ នៅឆ្នាំ១៩៨៨ ចំនួនសហគ្រាសខាងលើនេះបានពង្រីកបរិមាណរហូតដល់១៧៣០សហគ្រាស គឺមានការកើនឡើងប្រមាណ២,៥% ធៀបនឹងឆ្នាំ១៩៨៦ រីឯការងារពលកម្មបានកើនឡើងដល់៧២០៥នាក់ កើនឡើងជិត២%ធៀបនឹងឆ្នាំ១៩៨៦។ ទំហំផលិតផលសរុបប្រចាំឆ្នាំមានចំនួន៣៨១,២៦លានរៀលស្មើនឹង២%នៃតម្លៃផលិតកម្មឧស្សាហកម្មជាតិ។ មុខទំនិញសរុបមានជាង១០០ប្រភេទ។

នៅក្នុងមហាសន្និបាតលើកទី៥នៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ក្នុង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខែវិច្ឆិកា ឆ្នាំ១៩៨៥ បានដាក់កំហិតឱ្យមានការពង្រីកការផលិតប្រចាំឆ្នាំ ផ្នែកឧស្សាហកម្មផលិតកម្ម និងឧស្សាហកម្មគ្រួសារ ចាប់ពី១៥%ទៅ២០% ប៉ុន្តែកំណើនប្រចាំឆ្នាំគិតជាមធ្យមចន្លោះឆ្នាំ១៩៨១-១៩៨៥ មានតែ១៥% ប៉ុណ្ណោះដែលភាគច្រើនកើតឡើងលើតែវិស័យស្តារឡើងវិញនូវសំណង់សហគ្រាស។

ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍវិស័យថាមពលវិញ យើងឃើញថា ក៏បានក្លាយជាកិច្ចការដ៏សំខាន់បំផុតមួយដែលបានកំណត់ក្នុងយុទ្ធសាស្ត្រឧស្សាហកម្ម ដោយហេតុថា វិស័យថាមពលមានទំនាក់ទំនងដោយផ្ទាល់ជាមួយការអភិវឌ្ឍឧស្សាហូបនីយកម្មដែលបានទាមទារឱ្យមានការពង្រីកទំហំចំណាយលើការផលិតថាមពលអគ្គិសនី។ បញ្ហាទាំងអស់នេះទាមទារឱ្យមានការសាងសង់រោងចក្រស្ថានីយផ្គត់ផ្គង់អគ្គិសនីដែលទ្រទ្រង់ដោយវត្ថុធាតុដើមនាំចូល។ រោងចក្រអគ្គិសនី ជាទូទៅបានតាំងនៅទីក្រុងភ្នំពេញដែលជាកន្លែងប្រមូលផ្តុំរោងចក្រសហគ្រាសប្រមាណ២ភាគ៣ និងជាទីក្រុងនៃរាជធានីរបស់ប្រទេសកម្ពុជា។ បើទោះបីជាប្រទេសកម្ពុជាយើងមានលក្ខណៈអំណោយផលយ៉ាងខ្លាំងចំពោះការស្ថាបនាស្ថានីយវារីអគ្គិសនីយ៉ាងណាក៏ដោយ ក៏យើងមិនអាចស្តារស្ថានីយវារីអគ្គិសនីឡើងវិញបានទេ ដោយសារតែបញ្ហាសង្គ្រាម និងអសន្តិសុខសង្គម។

យើងដឹងហើយថា ទិសដៅនៃការអភិវឌ្ឍឧស្សាហកម្មជាយុទ្ធសាស្ត្ររបស់កម្ពុជា អាចញ៉ាំងឱ្យមានភាពរីកលូតលាស់ដល់វិស័យឧស្សាហកម្មឯកជនដែលរដ្ឋាភិបាលខ្វះលទ្ធភាពក្នុងការប្រមូលផ្តុំមូលធនឯកជន ដើម្បីចូលរួមចំណែកក្នុងវិស័យឧស្សាហកម្មជាតិ។ ជាក់ស្តែង ដើម្បីអូសទាញធនធានមូលធនឯកជននៅឆ្នាំ១៩៨៣ រដ្ឋាភិបាលដែលដឹកនាំដោយបក្សប្រជាជនកម្ពុជាបានចេញបទបញ្ជាឱ្យមានការដោះស្រាយការស្ថាបនាសហគ្រាសឧស្សាហកម្មឯកជន និងរោងជាង។ ប៉ុន្តែដំណាក់កាលដំបូងនៃសកម្មភាពរបស់វិស័យឯកជនបានកំហិតព្រំដែនត្រឹមអនុវិស័យឧស្សាហ-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្មមិនមែនយុទ្ធសាស្ត្រប៉ុណ្ណោះ ពោលគឺតែក្នុងឧស្សាហកម្មធុនស្រាល និងឧស្សាហកម្មចំណីអាហារ។ បទពិសោធន៍នៃជីវភាពរស់នៅបង្ហាញថា ការធ្វើអាជីវកម្មបែបមូលធនតូចតាចអាចទទួលបានផលចំណេញខ្ពស់ និងមានអាទិភាពជាច្រើន។ ក្នុងន័យនេះ ពីមួយឆ្នាំទៅមួយឆ្នាំ យើងសង្កេតឃើញថា ចំនួនសហគ្រាសឯកជនមានការរីកលូតលាស់ជានិច្ច។ ដូចជានៅឆ្នាំ១៩៨៨ ទំហំឧស្សាកម្មឯកជនបានឈានទៅដល់៥៣,៣៦%ទល់នឹង៤៦,៧%នៅឆ្នាំ១៩៨៦។ កំណើនជាមធ្យមប្រចាំឆ្នាំរបស់វិស័យនេះមានប្រមាណជា២៧,៥% គឺចំនួន៨%លឿនជាងចង្វាក់កំណើននៃទំហំផលិតកម្មឧស្សាហកម្មរបស់ប្រទេស។

## ២.១.៤ ឧបសគ្គ និងកំណែទម្រង់វិស័យឧស្សាហកម្មទៅរកសេរីភាវូបនីយកម្ម

ក្នុងលក្ខខណ្ឌដែលវិស័យឧស្សាហកម្មឯកជនបានបង្ហាញអំពីប្រសិទ្ធភាពខ្ពស់របស់ខ្លួនក្នុងសេដ្ឋកិច្ច សម្រាប់សហគ្រាសរដ្ឋមួយចំនួនវិញបែរជាចាប់ផ្តើមដំណើរការឡើងដោយមិនពេញកម្លាំង និងមានផលិតភាពពលកម្មទាប ហើយសហគ្រាសភាគច្រើនទៀតសោតបានធ្វើសកម្មភាពដោយពុំទទួលបានផលចំណេញ។ ស្ថានភាពបែបនេះអាចពន្យល់បានថា បញ្ហាជាសត្យានុម័ត គឺបណ្តាលមកពីកង្វះខាតនៃវត្ថុធាតុដើម កង្វះថាមពលអគ្គិសនី ប្រេងឥន្ធនៈ បរិក្ខារនិងគ្រឿងបន្លាស់ និងបញ្ហានៃការគ្រប់គ្រងធនធានមនុស្សផងដែរ។ ចំពោះមូលហេតុជាអត្តនោម័តវិញ គឺបណ្តាលមកពីបញ្ហាមួយចំនួនដូចខាងក្រោម ៖

ទី១ ៖ កត្តានយោបាយឧស្សាហកម្មត្រូវបានតាក់តែងឡើងក្រោមឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោលនៃមនោគមវិជ្ជាសិទ្ធាន្តនិយម (ភាពមានៈ ឬចចេសរឹងរូស)ឆ្ពោះទៅរកនិន្នាការនៃលទ្ធិសង្គមនិយមក្រោមឥទ្ធិពលផ្តាច់ការនិយមនៃតួនាទីរបស់រដ្ឋ និងបក្សក្នុងដំណើរការឧស្សាហូប-

នីយកម្ម។ បើយើងពិនិត្យមើលលើការថតចម្លងម៉ូឌែលរបស់វៀតណាម និង សូវៀត យើងឃើញថា មានការគ្រប់គ្រងដែលមានលក្ខណៈជារចនាសម្ព័ន្ធ រដ្ឋបាលបង្គាប់បញ្ជា និងមានភាពច្រើនជាន់ថ្នាក់នៃដំណើរការអនុម័តលើ សេចក្តីសម្រេច និងសិទ្ធិសេរីភាពរបស់សហគ្រាសត្រូវបានកំហិតព្រំដែន។

ទី២ ៖ ការតាក់តែងឡើងនូវផែនការក្នុងសេដ្ឋកិច្ចមានលក្ខណៈតែ មួយចំហៀងប៉ុណ្ណោះ ពោលគឺធ្វើសេចក្តីសម្រេចដោយអង្គការមជ្ឈិមដែល ជាស្ថាប័នផ្តល់អនុសាសន៍ និងកំណត់ផែនការសេដ្ឋកិច្ចដោយគ្មានការ ពិភាក្សាមតិយោបល់ពីសហគ្រាស និងពុំបានសិក្សាពីបញ្ហានានារបស់ សហគ្រាស។

ទី៣ ៖ សហគ្រាសរដ្ឋគ្មានសិទ្ធិជួលកម្លាំងពលកម្មដោយខ្លួនឯង ឡើយ។

ទី៤ ៖ ទំហំប្រាក់បៀវត្សត្រូវបានកំណត់ដោយអង្គការមជ្ឈិម ហើយ ប្រាក់បៀវត្សរបស់បុគ្គលិកកម្មករមិនអាស្រ័យលើលទ្ធផលការងារពល-កម្មរបស់ខ្លួននោះឡើយដែលធ្វើឱ្យចុះខ្សោយនូវការចាប់អារម្មណ៍លើការ-ងារផលិតកម្ម។

ទី៥ ៖ សហគ្រាសរដ្ឋពុំមានសិទ្ធិចាត់ចែងការងារហិរញ្ញវត្ថុរបស់ខ្លួន ដែលខំរកបាននោះឡើយ។ ក្នុងខណៈនេះ រដ្ឋាភិបាលនៅចុងឆ្នាំ១៩៨៣ បានបញ្ចូលវិធីសាស្ត្រគណនាថវិកាដែលបម្រើផលប្រយោជន៍សហគ្រាស ប៉ុន្តែអាចធ្វើទៅបានសម្រាប់តែសហគ្រាសមួយចំនួនតូចប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ដោយមិនគិតថា ឆ្នាំ១៩៨៦-១៩៨៨ កំណើនឧស្សា-ហកម្មផលិតកម្មរបស់រដ្ឋជាមធ្យមប្រចាំឆ្នាំមានចំនួន១១,១៨% ប៉ុន្តែកំណើន នេះអាចទទួលបានដោយសារតែកត្តាពង្រីកទិន្នន័យសហគ្រាសរដ្ឋតែ ប៉ុណ្ណោះ។ ចំពោះបញ្ហានេះដែរ យើងពិនិត្យឃើញថា ចង្វាក់កំណើន ឧស្សាហកម្មរដ្ឋមានចំនួន២,៤៥ដងទាបជាងកំណើនឧស្សាហកម្មរបស់ វិស័យឯកជនក្នុងរយៈពេលដូចគ្នា។ លើសពីនេះទៅទៀត ការធ្លាក់ចុះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសិទ្ធភាព និងភាពគ្មានធនជាប្រចាំរបស់សហគ្រាសរដ្ឋភាគច្រើនបាន កើតឡើងជាបន្តបន្ទាប់។ រីឯទំហំប្រាក់ចំណូលក្នុងផ.ស.សក្នុងដំណាក់កាល ខាងលើនេះក៏គ្មានការប្រែប្រួលនោះដែរ។ ក្រៅពីនោះ ប្រសិទ្ធភាពសេដ្ឋកិច្ចទាបរបស់សហគ្រាសឧស្សាហកម្មរដ្ឋបាននាំឱ្យមានការកាត់បន្ថយទំហំទុនវិនិយោគរបស់រដ្ឋពី២ភាគ៣រហូតដល់១ភាគ៣ក្នុងឆ្នាំ១៩៨៦-១៩៨៨។ ផ្ទុយទៅវិញក្នុងដំណាក់កាលដូចគ្នានេះដែរ ចំពោះទំហំវិនិយោគវិស័យឯកជនបានកើនឡើងពី១ភាគ៣ដល់២ភាគ៣នៃទំហំទុនវិនិយោគសរុប។

ផ្សេងពីនេះទៀត ផលប៉ះពាល់ជាអវិជ្ជមានពីគោលនយោបាយសេដ្ឋកិច្ចនាសម័យនោះជំរុញឱ្យរដ្ឋពិនិត្យឡើងវិញដោយផ្តល់អាទិភាពទៅរកជ្រុងម្ខាងនៃនិន្នាការសេរីភាវូបនីយកម្ម។ គួរបញ្ជាក់ថា មនោគមន៍សេរីភាវូបនីយកម្មក្នុងជីវិតសេដ្ឋកិច្ចមានគោលដៅមួយ គឺចង់ផ្សព្វផ្សាយ ឬឃោសនា មានន័យថា ធ្វើឡើងដើម្បីផ្លាស់ប្តូរទំនាក់ទំនងឱ្យកាន់តែទូលាយរវាងប្រទេសលោកខាងលិចជាមួយប្រទេសកំពុងអភិវឌ្ឍ ជាពិសេស ទៅកាន់របបគ្រប់គ្រងមួយនៅប្រទេសកម្ពុជាយើង។ នៅចុងឆ្នាំ១៩៨៨ និងដើមឆ្នាំ១៩៨៩ រដ្ឋាភិបាលប្រទេសកម្ពុជាយើងបានម្ចីម្នាដាក់ឱ្យដំណើរការនូវគោលនយោបាយឯកជនភាវូបនីយកម្មក៏ដូចជាធ្វើកំណែទម្រង់លើយន្តការសេដ្ឋកិច្ចរវាងពេងចក្រសហគ្រាសរដ្ឋ។ គោលនយោបាយឧស្សាហកម្មថ្មីនេះមានទិសដៅក្នុងការលើកកម្ពស់ការចាប់អារម្មណ៍ពីប្រជាពលរដ្ឋលើលទ្ធផលការងារពលកម្មរបស់ខ្លួន និងដកហូតទស្សនៈចែកផលស្មើភាពគ្នាដោយងាកមកបង្កើតក្រុមហ៊ុនអាជីវកម្មឯកជន និងទាក់ទាញមូលធនបរទេសឱ្យបានច្រើន និងបរិក្ខារផលិតកម្ម។ ការអនុវត្តប្រភេទសេដ្ឋកិច្ចចម្រុះតាមរយៈការបង្រួបបង្រួមមូលធនរដ្ឋ និងឯកជនបានធ្វើឱ្យយើងទទួលបានការរីកលូតលាស់យ៉ាងលឿន។

ការធ្វើកំណែទម្រង់យន្តការសេដ្ឋកិច្ចបានចាប់ផ្តើមឡើងចេញពីដំណើរការឆ្លងកាត់នៃពេងចក្រ សហគ្រាសរបស់រដ្ឋ ពីសេដ្ឋកិច្ចបញ្ជាផ្តោះទៅរក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការគិតគូរអំពីផលសេដ្ឋកិច្ចបែបឯកជន និងការផ្គត់ផ្គង់ហិរញ្ញវត្ថុដោយខ្លួនឯង។ សហគ្រាសដែលត្រូវផ្ទេរទៅឯកជន ត្រូវបានផ្តល់សិទ្ធិពេញលេញ និងមានឯករាជ្យភាពលើការងារសេដ្ឋកិច្ច ជាពិសេស ការកំណត់ទំហំប្រាក់បៀវត្សពលកម្ម និងការកំណត់ចំនួន ឬបរិមាណកម្លាំងបុគ្គលិកកម្មករជាដើម ក៏ប៉ុន្តែ ការធ្វើកំណែទម្រង់ដោយពុំមានការកែលម្អទៅលើទំនើបកម្មគ្រឿងបរិក្ខារ និងម៉ាស៊ីនផលិត គឺពុំអាចនាំមកនូវលទ្ធផលដែលរំពឹងទុកនោះឡើយ ហើយការធ្វើកំណែទម្រង់បែបនេះ វាគ្រាន់តែជាការនាំមកនូវការផ្លាស់ប្តូររបៀបរបបចាត់ចែងសេដ្ឋកិច្ច និងការបែងចែកប្រាក់ចំណូលរបស់សហគ្រាសតែប៉ុណ្ណោះ ប៉ុន្តែពុំអាចផ្លាស់ប្តូរប្រសិទ្ធភាពវិស័យផលិត-កម្មនោះបានឡើយ។

គោលនយោបាយថ្មីរបស់រដ្ឋាភិបាលបានស្នើឡើងឱ្យមានការអនុវត្តនិន្នាការឯកជនភាវូបនីយកម្មតាមរយៈវិធីសាស្ត្រមួយ ដោយជាជំហានដំបូងបង្អស់ រដ្ឋអាចលក់រោងចក្រសហគ្រាសរបស់ខ្លួនដែលមិនទទួលបានផលចំណេញ។ ម្យ៉ាងទៀត ក្នុងបរិបទនេះ មូលធនឯកជនបានហូរចូលមកក្នុងសហគ្រាសនឹងកែលម្អរោងចក្រសហគ្រាសចាស់ៗ ការដោះដូរឧបករណ៍ការជួសជុលបរិក្ខារចាំបាច់ ហើយអាចកាត់បន្ថយចំនួនបុគ្គលិកកម្មករ ចំនួនវិស្វករ អ្នកគ្រប់គ្រងដែលលើសចំនួនជាដើម។ ប៉ុន្តែប្រាក់ចំណូលសម្រាប់បុគ្គលិកនឹងត្រូវពង្រីកពី៣ទៅ៤ដង។ ម្ចាស់សហគ្រាសមានសិទ្ធិបណ្តេញចេញ ឬក៏ជ្រើសរើសបុគ្គលិកថ្មីបន្ថែមទៀតទៅតាមតម្រូវការរបស់ខ្លួន។ វិធានការនៃសេដ្ឋកិច្ចថ្មីនេះបានធ្វើឱ្យផលិតភាពផលិតកម្មមានភាពប្រសើរឡើងជាងមុន ទាំងបញ្ហាវិន័យលើវិស័យការងារ ទាំងការជំរុញឱ្យមានការយកចិត្តទុកដាក់របស់កម្មករនិយោជិត ក៏ដូចជាវិស្វករបានខ្ពស់ជាងមុន។ ព្រោះថា ប្រសិនបើនៅពេលមុនៗ សហគ្រាសរដ្ឋទាំងនោះបានដំណើរការឡើងដោយមិនពេញកម្លាំងផលិតកម្ម ដោយសារមូលហេតុជាសត្យានុម័តផ្សេងៗ ប៉ុន្តែបន្ទាប់ពីការធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ម្ចាស់សហ-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រាសអាចមានលទ្ធភាពប្រើប្រាស់ចំណេះដឹង និងទេពកោសល្យគ្រប់គ្រងលើដំណើរការផលិតកម្មរបស់ខ្លួន និងអាចដោះស្រាយបានទូវបញ្ហាអសកម្មទាំងអស់នោះបានផងដែរ។ សហគ្រាសក៏អាចចាប់ផ្ដើមដំណើរការផលិតកម្មរបស់ខ្លួនដោយទៀងទាត់ និងប្រកបដោយផលចំណេញ និងក្នុងបរិមាណបុគ្គលិក កម្មករ និយោជិត តិចជាងមុនៗ។

## ២.១.៥ ការចាប់ផ្ដើមទីផ្សារហិរញ្ញវត្ថុ(ធនាគាររដ្ឋ និងឯកជន)

ក្រៅពីការវិភាគលើគោលនយោបាយសេដ្ឋកិច្ចវិស័យកសិកម្មផលិតកម្ម និងក៏ដូចជាវិស័យឧស្សាហកម្មរួចមក យើងពិនិត្យឃើញថា ការធ្វើកំណែទម្រង់របស់រដ្ឋនាសម័យកាលនោះហាក់ពុំបានឈានចូលដល់ការកែលម្អណាមួយពាក់ព័ន្ធទៅនឹងប្រព័ន្ធធនាគារនោះទេដែលវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់បំផុតមួយក្នុងចរន្តសេដ្ឋកិច្ចទីផ្សារសេរី។ នៅសម័យនោះ រដ្ឋបានព្យាយាមរក្សាភាពផ្ដាច់មុខលើវិស័យធនាគារ ក៏ប៉ុន្តែអង្គភាពរដ្ឋ ពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រមូលផ្ដុំធនធានហិរញ្ញវត្ថុឱ្យបានច្រើនពីដៃសហគ្រាសឯកជន និងប្រជាពលរដ្ឋបាននោះឡើយ។ ហេតុដូច្នេះហើយ បើពុំមានការរីកលូតលាស់នូវប្រព័ន្ធធនាគារនោះទេ វិនិយោគិនបរទេសពុំអាចផ្គត់ផ្គង់ហិរញ្ញវត្ថុទៅលើគម្រោងធំៗរបស់ខ្លួនបានឡើយដោយសារតែបញ្ហាកង្វះទីផ្សារហិរញ្ញវត្ថុឯកជនដែលជាអ្នកសម្របសម្រួល។ ឆ្លើយតបទៅនឹងបញ្ហានេះ យើងឃើញថា នៅប្រទេសកម្ពុជាហាក់ដូចជាបានបង្កើតជាទីផ្សារមីក្រូហិរញ្ញវត្ថុឯកជនតូចតាចជាច្រើនដែលបានបំពេញមុខងាររបស់ទីផ្សាររូបិយវត្ថុខ្លះដែរដោយមានប្រតិបត្តិការទិញ និងដោះដូរសាច់មាសជាមួយនឹងរូបិយប័ណ្ណបរទេសក៏ដូចជារូបិយវត្ថុជាតិ។

ក្រៅពីនេះ ក៏មានការកើតឡើងនូវកំណើនមូលធនក្នុងស្រុកដែលមានឥរិយាបថសម្រាប់ដំណាក់កាលដំបូងៗនៃការរីកលូតលាស់លទ្ធិមូលធននិយម។ ហេតុនេះហើយ ដើម្បីជំរុញល្បឿនដល់ដំណើរការសេរីភាវូប-

នីយកម្ម ជាការចាំបាច់ត្រូវតែចាប់ផ្ដើមដំណើការដោយឈានទៅរកការធ្វើកំណែទម្រង់ប្រព័ន្ធធនាគារនៅក្នុងប្រទេសតាមរយៈគោលការណ៍វិមជ្ឈការប្រព័ន្ធធនាគារ និងការបង្កើតឱ្យមានធនាគារជាច្រើន ហើយត្រូវលុបបំបាត់ចោលភាពផ្ដាច់មុខក្នុងប្រព័ន្ធធនាគារ និងការផ្ដើមឡើងនៃឯកជនភាវូបនីយកម្ម។ ការបង្កលក្ខណៈឱ្យមានភាពសកម្មនិយមរបស់ប្រព័ន្ធទីផ្សារហិរញ្ញវត្ថុក្នុងស្ថានភាពដែលរដ្ឋាភិបាលកំពុងតែជួបប្រទះការលំបាកផ្នែកធនធានមូលធនបែបនេះ យើងគួរគប្បីដោះស្រាយបញ្ហាទាំងអស់នេះតាមលក្ខណៈរូបភាពផ្សេងៗដោយបង្កើតឱ្យមានជាធនាគារឯកជន ឬជាធនាគារពាណិជ្ជកម្មចម្រុះ ឬក៏អាចបង្កើតជាសាខាធនាគារបរទេសនៅក្នុងប្រទេសផងដែរ។ ចំពោះបញ្ហាដែលពាក់ព័ន្ធទៅនឹងកំណើននៃកង្វះខាតថវិការដ្ឋដោយសារតែការពង្រីកការចំណាយរដ្ឋលើវិស័យយោធា វិស័យរដ្ឋបាលព្រមទាំងការបំពេញបន្ថែមលើខ្វះចំណាយមូលធនយ៉ាងច្រើនសន្ធឹកសន្ធាប់ថែមទៀត សម្រាប់ការបណ្ដាក់ទុនវិនិយោគលើសហគ្រាសរដ្ឋ ការចំណាយលើការប៉ះប៉ូវចំពោះសហគ្រាសរដ្ឋដែលពុំទទួលបានប្រសិទ្ធភាពសេដ្ឋកិច្ចនិងភាពទន់ខ្សោយនៃប្រព័ន្ធធនាគារឥណទានដែលទាំងអស់ខាងលើនេះបង្ខំឱ្យរដ្ឋាភិបាលនាសម័យនោះ រត់ទៅរកការបោះពុម្ពសាច់ប្រាក់បន្ថែមទៀតជាប្រចាំ លើសពីផែនការច្បាប់ថវិកាដែលបានកំណត់ទុក ដើម្បីបំពេញខ្វះចំណាយដែលខ្វះខាត ជាពិសេស លើការចំណាយចរន្ត និងចំណាយមូលធន( ដូចជាករណីនៅឆ្នាំ១៩៨២ រដ្ឋខ្វះខាតថវិកាប្រមាណ២៥,៩%នៃផែនការថវិកានៅឆ្នាំ១៩៨៣ ខ្វះខាត១៧,៥% និងឆ្នាំ១៩៨៨ ខ្វះខាត៧,៩%)។ ជាក់ស្ដែងនៅឆ្នាំ១៩៩០ រដ្ឋាភិបាលបានបោះពុម្ពសាច់ប្រាក់បន្ថែមរហូតដល់ទៅ២,៥ពាន់លានរៀល ដើម្បីបង្គ្រប់ឱនភាពថវិការបស់ខ្លួន។ ការអនុវត្តលើបញ្ហាស្មុគស្មាញចំពោះម៉ាក្រូសេដ្ឋកិច្ច ពោលគឺបាននាំមកនូវបញ្ហាអតិផរណា និងការជាប់គាំងចំពោះសាច់ប្រាក់បង្វិលរបស់ស្ថាប័ន។

ឆ្លងតាមការសិក្សាវិភាគខាងលើនេះ យើងពិនិត្យឃើញថា យុទ្ធសាស្ត្រ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់ប្រទេសកម្ពុជា នាចុងទសវត្សទី៨០ គឺត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានកំណែទម្រង់ក្នុងវិស័យសេដ្ឋកិច្ច និងមានទិសដៅសកម្មភាពមួយ ជុំវិញការធ្វើសេចក្តីសម្រេចចំពោះដំណោះស្រាយបញ្ហាសង្គម ហើយដែលបានធ្វើឡើងក្នុងបំណងជាក់លាក់ គឺការថែរក្សារបបគ្រប់គ្រងនយោបាយរបស់រដ្ឋាភិបាល។ បើយើងវិភាគលើគោលបំណង និងឧត្តមភាពនៃគោលនយោបាយសេដ្ឋកិច្ចវិញ យើងសង្កេតឃើញថា វាបានបង្កជាលក្ខខណ្ឌអំណោយផលមួយមិនត្រឹមតែដើម្បីបន្សាំកិច្ចការសេដ្ឋកិច្ចទៅរកលក្ខខណ្ឌនៃបម្លាស់ប្តូរមួយយ៉ាងឆាប់រហ័សទាំងខាងក្នុងក៏ដូចជាខាងក្រៅប្រទេសតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចទប់ទល់បាននឹងភាពបរាជ័យនៃគោលនយោបាយសេដ្ឋកិច្ចបង្គាប់បញ្ជាទៀតផង ព្រមទាំងមានកម្មវិធីរបស់ខ្លួនច្បាស់លាស់ និងមានលក្ខណៈចាំបាច់ផងដែរក្នុងការវាយដណ្តើមយកការគាំទ្រពីសំណាក់ក្រុមមហាជនជាកសិករ ជាបុគ្គលិករដ្ឋ ជាកម្មកររោងចក្រ ក្រុមអាជីវករសក្តិភូមិជនបទ និងពួកមូលធនជាតិ ហើយជាងនេះទៀត អាចទាក់ទាញគ្រប់វណ្ណៈប្រជាពលរដ្ឋក្នុងសង្គមខ្មែរបានថែមទៀតផង។

ដោយឡែក ចំពោះការសិក្សាលើគោលនយោបាយសេដ្ឋកិច្ច ក៏គួរគប្បីពិនិត្យមើលផងដែរទៅលើទីតាំងនៃការកាន់កាប់អំណាចដែលខ្ពស់បំផុតដែលជាសារធាតុផ្សំនៃឥទ្ធិពលគោលនយោបាយរដ្ឋ សម្រាប់ការអនុវត្តនិងការតម្រង់ទិសឆ្ពោះទៅរកការវាយលុក និងទាក់ទាញដណ្តើមយកសំឡេងគាំទ្រ សម្រាប់ការបោះឆ្នោតសកលនៅកម្ពុជានាសម័យកាលនោះ។ ដូច្នេះហើយទើបបានជានៅចុងទសវត្សរ៍ទី៨០ គឺបានកើតមានឡើងនូវបម្លាស់ប្តូរយ៉ាងខ្លាំងក្លា ជាពិសេស ពាក់ព័ន្ធទៅនឹងនយោបាយផ្ទៃក្នុង និងផែនការយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា។ ការអនុវត្តយន្តការសេរីភាវូបនីយកម្មចំពោះគោលនយោបាយកសិកម្ម និងឧស្សាហកម្មបាននាំមកនូវការរៀបចំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសដូចខាងក្រោមនេះ ៖

- ត្រូវពង្រីកទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មជាផ្លូវការជាមួយបណ្ដាប្រទេសដែលកំពុងអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាជាមួយប្រទេសលូតលាស់ខាងសេដ្ឋកិច្ចនៃពិភពមូលធននិយម ហើយដោយសារតែភាពបរាជ័យចំពោះទស្សនទានសេដ្ឋកិច្ចដែលមាននិន្នាការឆ្ពោះទៅរកសង្គមនិយមនេះ ហើយជាហេតុនាំឱ្យយើងបាត់បង់ជំនឿ និងការគាំទ្រពីប្រជាពលរដ្ឋ។

- ការទទួលស្គាល់តួនាទីវិស័យឯកជនជាតិនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដែលបង្កលក្ខណៈឱ្យមានការទាក់ទាញការវិនិយោគទុនឯកជនពីបរទេស និងធ្វើឱ្យមានការផ្លាស់ប្ដូរទំនាក់ទំនងរបស់រដ្ឋាភិបាលចំពោះក្រុមហ៊ុនបរទេស និងក្រុមហ៊ុនសាជីវកម្មធំៗ។

## ២.២. ទិសដៅជាមូលដ្ឋាននៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់ប្រទេសកម្ពុជា នាសម័យទំនើប

គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសគឺមានលក្ខណៈជាប្រព័ន្ធនៃវិធានការសំខាន់ៗដែលបានទាក់ទងទៅនឹងអំណាចរដ្ឋ ហើយក៏មានទិសដៅជំរុញដល់ការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ចជាមួយនឹងបណ្ដាប្រទេសនានាក្នុងបំណងប្រើប្រាស់ជាអាទិភាពនៃការបែងចែកពលកម្មអន្តរជាតិសម្រាប់ការពង្រឹងវិស័យសេដ្ឋកិច្ច ព្រមទាំងការផ្គត់ផ្គង់សេចក្ដីត្រូវការផ្នែកទំនិញរបស់ប្រទេសជាតិឱ្យបានពេញលេញផងដែរ។ ចំពោះដំណើរការនៃការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសត្រូវបានស្នើឡើងជុំវិញការកំណត់គោលដៅជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលនៅក្នុងកិច្ចការទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសទាំងមូល និងជាមួយនឹងបណ្ដាប្រទេសមួយចំនួនក៏ដូចជាជាមួយក្រុមប្រទេសនានាដែលតម្រូវឱ្យមានការតាក់តែងគោលនយោបាយជាយុទ្ធសាស្ត្រ និងមធ្យោបាយ ដើម្បីឈានដល់ការសម្រេចបានជុំវិញគោលដៅដែលបានកំណត់ទុក។

ជាទូទៅ គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសពុំអាចកាត់ផ្ដាច់ចេញ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីទំនាក់ទំនងជាមួយនឹងគោលនយោបាយសេដ្ឋកិច្ចក្នុងប្រទេសរបស់រដ្ឋនោះបានទេ អាចនិយាយបានថា ចំពោះការតាក់តែងឡើងនូវលក្ខខណ្ឌអំណោយផលនៃសេដ្ឋកិច្ចក្រៅប្រទេសចំពោះការអភិវឌ្ឍសេដ្ឋកិច្ចជាតិ វាគឺជាកិច្ចការដ៏ចម្បងបំផុតនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស។ នៅក្នុងដំណាក់កាលនៃទសវត្សរ៍ទី៨០ គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាបានធ្វើដំណើរការឆ្លងកាត់ពីដំណាក់មួយទៅដំណាក់កាលមួយទៀតជាបន្តបន្ទាប់ ហើយចំពោះដំណាក់កាលនីមួយៗវិញសុទ្ធសឹងតែបានកំណត់គោលបំណងយ៉ាងច្បាស់លាស់ និងប្រាកដប្រជាចំពោះអាទិភាពនៃគោលនយោបាយនោះដែលកិច្ចការទាំងអស់នេះ យើងអាចបែងចែកជាគោលការណ៍រួមនៃគោលនយោបាយសេដ្ឋកិច្ចទាំងអស់នោះ ស្របតាមលំដាប់លំដោយរបស់វាដូចខាងក្រោមនេះ៖

- បានធ្វើការអភិវឌ្ឍវិស័យពាណិជ្ជកម្មក្រៅប្រទេសដោយផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក និងមានកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយនឹងបណ្តាប្រទេសនៅលើពិភពលោកដោយមិនអាស្រ័យលើនិន្នាការនិងលទ្ធិនយោបាយសង្គមរបស់ពួកគេនោះឡើយ។

- បានធ្វើទំនាក់ទំនងដោយស្មើភាពគ្នាក្នុងវិស័យទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស និងទទួលបានអត្ថប្រយោជន៍ទាំងសងខាង។

- មិនធ្វើអន្តរាគមន៍ណាមួយទៅលើកិច្ចការផ្ទៃក្នុងនៃប្រទេសជាដៃគូនិងមានការគោរពដោយម៉ឺងម៉ាត់បំផុតចំពោះអធិបតេយ្យភាពរដ្ឋជាដៃគូចំពោះកិច្ចការទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស។

- បានបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយសុច្ឆន្ទៈចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងសេដ្ឋកិច្ចដែលបានឯកភាពគ្នាជាមួយបណ្តារដ្ឋបរទេសនានា។

- បានខិតខំជំរុញឱ្យវិស័យពាណិជ្ជកម្មក្រៅប្រទេស មានកិច្ចសហប្រតិបត្តិការល្អលើផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសតាមរយៈមាគ៌ាសេរីភាវូប-

នីយកម្ម។

- បានខិតខំបន្សាំគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសឆ្ពោះទៅរកសេចក្ដីត្រូវការដ៏ជាក់លាក់ និងស្របតាមលក្ខណៈពិសេសនៃសេដ្ឋកិច្ចរបស់ប្រទេស។

- បានស្នើឡើងនូវតម្រូវការនៃការប្រើប្រាស់ជំនួយបរទេស និងជំនួយអន្តរជាតិ ព្រមទាំងវិស័យឥណទាន ដើម្បីពង្រីងសក្ដានុពលផលិតកម្ម។

- បានធ្វើឱ្យប្រសើរឡើងផងដែរនូវបរិយាកាសវិនិយោគបរទេស និងការផ្ទេរបច្ចេកវិទ្យាផលិតកម្មថ្មីៗ។

ក្រៅពីនេះទៀត ក្នុងលក្ខខណ្ឌដែលយើងបានធ្វើអន្តរជាតូបនីយ-កម្មលើគ្រប់វិស័យនៃជីវិតសេដ្ឋកិច្ចបែបនេះ យើងពិនិត្យឃើញថា ការធ្វើទំនាក់ទំនងផ្នែកសេដ្ឋកិច្ចទៅវិញទៅមកតាមរយៈគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសតែងតែមានការពាក់ព័ន្ធទៅនឹងដំណើរការនៃការយល់ឃើញផ្សេងៗគ្នាជាអត្តនោម័តចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសដែលជាប្រទេស«តតិយលោក»។ សម្រាប់ការបើកឡើងនូវសករាជនៃទស្សនៈនយោបាយថ្មី យើងពិនិត្យឃើញថា វាគឺជាតម្រូវការដ៏ស្មុគស្មាញបំផុតមួយនៃការធ្វើទំនាក់ទំនងគ្នាដែលតម្រូវឱ្យយើងដាក់ចេញនូវផែនការយុទ្ធ-សាស្ត្រថ្មីៗទៀតចំពោះមុខគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់រដ្ឋ។

## ២.២.១ ទំនាក់ទំនងរវាងសេដ្ឋកិច្ច និងនយោបាយ

ចំពោះបញ្ហានៃការធ្វើទំនាក់ទំនងគ្នាបែបវិចារវិទ្យា( ទំនាក់ទំនងដ៏ឈ្លាសវៃ)ផ្នែកសេដ្ឋកិច្ច និងនយោបាយ គឺត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់លាស់ដោយស្នាដៃអ្នកស្រាវជ្រាវរបស់អ្នកប្រាជ្ញសូវៀត។ យ៉ាងណាមិញ បើយោងតាមទ្រឹស្ដីរបស់លោក វ្លាឌីមៀ លេនីន (V. I Lenin) ក៏បានអះអាងថា «គោលនយោបាយបានបង្កប់អត្ថន័យសេដ្ឋកិច្ចរួចទៅហើយ» ដែលក្នុងនោះ បានសម្ដែងឡើងនូវខ្លឹមសារជានយោបាយ ក៏ប៉ុន្តែត្រូវបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បិទបាំងទៅដោយគោលដៅនៃឫសគល់សេដ្ឋកិច្ច សំដៅបម្រើឱ្យវណ្ណៈគ្រប់-គ្រងនានានៅក្នុងសង្គមនោះ។ លោកបានអះអាងទៀតថា «ធ្វើនយោបាយមិនអាចគ្មានអ្វីដែលសំខាន់ជាងផលសេដ្ឋកិច្ចនោះដែរទេ» មានន័យថាការធ្វើនយោបាយក៏ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចដែរ ហើយបើពុំមានការប្រើប្រាស់ស្នៀតនយោបាយដែលមានប្រសិទ្ធភាពត្រឹមត្រូវនោះទេ វណ្ណៈក្នុងសង្គមនោះក៏មិនអាចរក្សា ឬការពារអ្នកគ្រប់គ្រងរបស់ខ្លួនបានដែរ។ ដោយឡែក បើវិភាគតាមទស្សនៈរបស់លោក Bukarin ក៏បានលើកឡើងផងដែរថា យើងមិនអាចញែកចេញពីគ្នាអំពីរឿងនយោបាយ និងសេដ្ឋកិច្ចបាននោះទេដែលអ្នកប្រាជ្ញសូវៀត V. I Lenin បានកំណត់អំពីទស្សនៈនេះរួចទៅហើយ។

ក៏ប៉ុន្តែ នៅយុគសម័យចុងក្រោយនេះ ពិភពលោកត្រូវបានលើកតម្កើងអ្នកគាំទ្រចំពោះវិធានការសេដ្ឋកិច្ចនានា និងការធ្វើជំនួញដែលបានចាត់ទុកថា ពិភពលោកយើងនេះបានឈានចូលដល់សករាជថ្មីមួយទៀតដែលផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍដែលមានតួនាទីចម្បងបង្អស់នោះគឺការកសាងសេដ្ឋកិច្ច។ សារណានេះត្រូវបានវាយដណ្តើមយកទឹកចិត្តអ្នកគាំទ្រច្រើនឡើងៗក្នុងចំណោមអ្នកនយោបាយ អ្នកជំនួញ និងអ្នកវិទ្យាសាស្ត្រនៃប្រទេសមួយចំនួនធំ ជាពិសេស នៅបណ្តាប្រទេសអឺរ៉ុបខាងកើត និងប្រទេសកំពុងអភិវឌ្ឍក្នុងនិន្នាការទើបតែឆ្ពោះទៅរកសង្គមនិយម។ ក្នុងប្រទេសទាំងនោះបាន និងកំពុងប្រសូតឡើងនូវដំណើរការយ៉ាងសំខាន់របស់ខ្លួនដោយឆ្លងកាត់ពីប្រព័ន្ធសេដ្ឋកិច្ចបែបរដ្ឋបាលបញ្ជាទៅរកសេដ្ឋកិច្ចទីផ្សារសេរី ឬចេញពីទស្សនៈគម្ពីរនិយមទៅរកទស្សនៈជាក់ស្តែង( Pragma-tism) ឬចេញពីសតវត្សរ៍មនោគមវិជ្ជាឆ្ពោះទៅរកសតវត្សរ៍អភិវឌ្ឍសេដ្ឋកិច្ចជាពិសេស សម្រាប់បណ្តាប្រទេសជាច្រើនលើពិភពលោកនាសម័យនោះដែលបាននិងកំពុងរងការគំរាមកំហែងផ្នែកសេដ្ឋកិច្ច។

ភាពជាទំនាក់ទំនងរវាងសេដ្ឋកិច្ច និងកិច្ចការនយោបាយ គឺអាស្រ័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយកត្តាខាងក្នុង និងខាងក្រៅរបស់វាជុំវិញការអភិវឌ្ឍសង្គមនោះ។ ប្រព័ន្ធជាក់លាក់នៃកត្តាទាំងពីររបស់វាមានលក្ខណៈជាបន្ទាត់ត្រង់ និងមានទំនាក់ទំនងជាស្វ័យប្រវត្តិជាមួយនឹងការងារនយោបាយ ហើយមានករណីខ្លះទៀត កិច្ចការនយោបាយក្រៅប្រទេស វាអាស្រ័យលើក្រឹត្យក្រមសេដ្ឋកិច្ចជាអ្នកសម្រេច។ លើសពីនេះទៅទៀត នយោបាយគឺជាអ្វីៗទាំងអស់ដែលមិនត្រឹមតែជាគោលបំណងដែលត្រូវធ្វើនោះទេ ប៉ុន្តែវាគឺជាការបញ្ជាឬជំរុញដោយបំណងសេដ្ឋកិច្ចផងដែរដែលនយោបាយខ្លួនឯងហាក់ដូចជាបានសម្តែងចេញនូវឥទ្ធិពលជាវិជ្ជមានទៅលើសេដ្ឋកិច្ចទៅវិញ។

គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវរបស់យើង ជុំវិញគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសបានប្រសូតចេញពីសេចក្តីត្រូវការចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ពិសេសទៅទៀត រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិដែលគោលនយោបាយនេះអាចជួយបង្ហាញអំពីឥទ្ធិពលបញ្ច្រាសមកវិញរបស់វាចំពោះសេដ្ឋកិច្ច។ ផ្សេងពីនេះទៀត លក្ខណៈពិសេសនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស វាគឺជាគ្រឿងផ្សំរបស់នយោបាយក្រៅប្រទេសដែលក្នុងនោះដែរ វាហាក់ដូចជាបានដើរតួរងនៅក្នុងឆាកនយោបាយមួយនេះ។ ប្រសិនបើទំនាក់ទំនងលើវិស័យសេដ្ឋកិច្ចបានបង្ហាញអំពីភាពជិតស្និទ្ធរបស់ខ្លួនចំពោះនយោបាយក្នុងស្រុក ប៉ុន្តែបើចំពោះនយោបាយក្រៅប្រទេសវិញ ទំនាក់ទំនងលើវិស័យសេដ្ឋកិច្ចហាក់ដូចជាបានបិទបាំងទៅដោយស្រមោលនយោបាយក្រៅប្រទេស។ អាស្រ័យហេតុនេះ នយោបាយសេដ្ឋកិច្ចក្រៅប្រទេសបានតាក់តែងឡើងដោយយោងលើលទ្ធផលនៃអំពើទៅវិញទៅមករវាងសេដ្ឋកិច្ច និងនយោបាយដែលជាសមាសធាតុរបស់នយោបាយសេដ្ឋកិច្ចផង និងធាតុផ្សំនៃនយោបាយការបរទេសផង។

គួរបញ្ជាក់ថា កិច្ចការងារទូតរបស់សេដ្ឋកិច្ចគឺជាកិច្ចការដ៏សំខាន់បំផុតមួយដែលមានការពាក់ព័ន្ធទៅនឹងនយោបាយសេដ្ឋកិច្ចក្រៅប្រទេស


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់រដ្ឋ។ កិច្ចការទូតនាសម័យទំនើប គប្បីមានស្នៀតជាយុទ្ធវិធី និងសិល្បៈក្នុងដំណើរការការងារលើវិស័យនយោបាយក្រៅប្រទេសរបស់ខ្លួន មានន័យថា ត្រូវចេះបង្កើតជាគម្ពីរយុទ្ធសាស្ត្រ និងក្បួនខ្នាតសម្រាប់ចាប់យកសមិទ្ធផលដែលខ្លួនបានកំណត់ទុកជាគោលដៅ ដើម្បីដណ្តើមយកផលប្រយោជន៍សេដ្ឋកិច្ច ស្របតាមនិន្នាការរីកលូតលាស់របស់ប្រទេសមួយចំនួនក៏ដូចជាលើពិភពលោកទាំងមូលផងដែរ។ ជាក់ស្តែង បើយើងពិនិត្យលើជ្រុងម្ខាងនៃកិច្ចការងារទូត វាហាក់ដូចជាដំណើរការលើកិច្ចការនយោបាយទាំងស្រុង ប៉ុន្តែជាតុពិត ការងារទូតបានធ្វើទង្វើយ៉ាងសកម្មទៅរកផលប្រយោជន៍សេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រទេស ហើយប៉ុនប្រសប់ក្នុងការតាក់តែង ឬស្ថាបនាជាស្ពានចម្លង សម្រាប់ទាក់ទងគ្នាក្នុងវិស័យសេដ្ឋកិច្ច និងនយោបាយនៅលើឆាកអន្តរជាតិ។

លើសពីនេះទៅទៀត ការធ្វើអន្តរជាតូបនីយកម្មលើវិស័យសេដ្ឋកិច្ចជាគោលជំហរចាំបាច់ គឺត្រូវទាមទារនូវការសន្ទនាយ៉ាងទូលាយ និងគ្រប់ជ្រុងជ្រោយក្នុងករណីខ្វះ ពោរពេញដោយការប្រឈមមុខដាក់គ្នាជាមួយសហគមន៍អន្តរជាតិក្នុងទិសដៅស្វែងរកដំណោះស្រាយសមស្របរួមគ្នាដែលអាចទទួលយកបានទាំងសងខាង និងឈរលើក្រឹត្យក្រមជាសត្យានុម័តនៃការអភិវឌ្ឍជីវិតសេដ្ឋកិច្ចពិភពលោក។

ជាទូទៅ បញ្ហាសេដ្ឋកិច្ចបានដើរតួនាទីក្នុងលំដាប់ទីមួយទៀតផងក្នុងចំណោមវិស័យជាអាទិភាពនៃគោលនយោបាយក្រៅប្រទេសទាំងអស់របស់រដ្ឋដោយមិនអាចប្រកែកបាន។ ប្រភេទដ៏ទំនើបនៃការធ្វើអន្តរជាតូបនីយកម្មផ្នែកសេដ្ឋកិច្ចច្រើនតែពាក់ព័ន្ធទៅនឹងការបង្ខិតបង្ខំទៅលើទំនាក់ទំនងជាមួយបណ្តារដ្ឋទន់ខ្សោយដែលបង្ខំឱ្យបណ្តារដ្ឋទាំងអស់នោះ ត្រូវតែកែលម្អជាច្រើនទៅលើលក្ខខណ្ឌសេដ្ឋកិច្ចសង្គមរបស់ខ្លួនដែលធ្លាប់តែមានជាប្រពៃណី ក្នុងនោះមានបញ្ហាសន្តិសុខជាតិផងដែរ ព្រមទាំងការគាបសង្កត់តាមរយៈផ្លូវសេដ្ឋកិច្ច។ សម័យកាលនោះដែរ ការហាមឃាត់


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងការនាំចេញ-នាំចូលទំនិញជាថាមពល ឬក៏ការបិទច្រកទីផ្សារសម្រាប់នាំចេញជាដើមដែលទាំងអស់នេះអាចនាំមកនូវការឈឺចាប់ និងមានផលប៉ះពាល់ដល់ផលិតកម្ម នាំមកនូវការផ្ទុះឡើងនូវអតិផរណា ធ្វើឱ្យមានការបែកបាក់នយោបាយផ្ទៃក្នុង និងឈានដល់ការលេចចេញនូវទំនាស់យ៉ាងស្រួចស្រាវទាំងក្នុងតំបន់ និងនៅលើឆាកអន្តរជាតិថែមទៀត។

យោងលើការសិក្សាស្រាវជ្រាវបង្ហាញដែរថា វិស័យការទូតខាងសេដ្ឋកិច្ចដោយឈរលើទំនាក់ទំនងជាទ្វេភាគីគឺជាវិធានការដ៏ប្រពៃណី និងមានសារៈសំខាន់បំផុតមួយនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់រដ្ឋ។ បទពិសោធន៍នេះបានក្លាយជាមធ្យោបាយដ៏ល្អនាសម័យកាលកន្លងមក (ទសវត្សរ៍ទី៨០)។ តម្លៃនៃវិស័យការទូតជាលក្ខណៈទ្វេភាគីផ្នែកសេដ្ឋកិច្ចរបស់កម្ពុជានាសម័យនោះ មិនត្រូវបានបណ្ដាប្រទេសមូលធននិយមជឿនលឿននានា និងប្រទេសកំពុងអភិវឌ្ឍមួយចំនួនធំទទួលស្គាល់ឡើយ រួមទាំងអង្គការសហប្រជាជាតិក៏ដូចជាអង្គការសេដ្ឋកិច្ច-ហិរញ្ញវត្ថុអន្តរជាតិផងដែរ។ ហេតុនេះហើយ ប្រទេសកម្ពុជាជាក់ស្ដែងធ្លាប់បានបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ឱ្យបានត្រឹមត្រូវលើវិស័យការទូត និងវិស័យសេដ្ឋកិច្ចដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ សម្រាប់ដំណើរការគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស។ ប៉ុន្តែអ្វីដែលយើងគួរតែស្វែងយល់នោះស្ថិតនៅត្រង់ថា ប្រទេសកម្ពុជាយើងសម័យនោះបានខិតខំធ្វើការងារជាច្រើនលើវិស័យការទូត និងវិស័យសេដ្ឋកិច្ច ជាក់ស្ដែងនៅតាមបណ្ដោយក្រសួងជាច្រើនលើវិស័យការទូត និងក្រុមប្រឹក្សារដ្ឋមន្ត្រីជាដើម បានបង្កើតការិយាល័យជំនាញ(ឬនាយកដ្ឋាន)ដែលធ្វើការងារទំនាក់ទំនងការបរទេស។ ការបំពេញមុខងារសេដ្ឋកិច្ចយ៉ាងទូលាយត្រូវបទទួលបន្ទុកដោយស្ថានទូតខ្មែរដែលតាំងនៅបរទេស និងមានតំណាងផ្នែកពាណិជ្ជកម្មរបស់ខ្លួនក្នុងប្រទេសទាំងនោះដែលបានធ្វើទំនាក់ទំនងការទូត និងការងារសេដ្ឋកិច្ចយ៉ាងសកម្មជាមួយរដ្ឋកម្ពុជា ព្រមទាំងមានគណៈប្រតិភូគ្រប់ជាន់ថ្នាក់ ធ្វើជាអ្នក


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្របសម្រួល។ ទិសដៅជាមូលដ្ឋាននៃការងារទូតលើវិស័យសេដ្ឋកិច្ចរបស់កម្ពុជាជាលក្ខណៈទ្វេភាគី គឺសំដៅលើប្រទេសទាំងឡាយណាដែលមានទំនាក់ទំនងការទូតជាមួយរដ្ឋកម្ពុជាប៉ុណ្ណោះ ជាពិសេស សាធារណរដ្ឋសង្គមនិយមសហភាពសូវៀត(ស.ស.ស.ស) និងបណ្ដាប្រទេសនៅប៉ែកអឺរ៉ុបខាងកើត។ ក៏ប៉ុន្តែ សម្រាប់ប្រទេសដែលពុំបានទទួលស្គាល់រដ្ឋកម្ពុជានោះ ត្រូវបានអនុវត្តជាទំនាក់ទំនងការទូតបែបមិនផ្លូវការ សម្រាប់ការទ្រទ្រង់ និងពង្រីកការទាក់ទងគ្នាលើវិស័យជំនួញ។ ការប្ដេជ្ញាចិត្តខ្ពស់បំផុតរបស់រដ្ឋកម្ពុជានាសម័យនោះបានផ្ដោតជាសំខាន់ទៅលើការស្វែងរកទីផ្សារលក់ចេញផលិតផលជាតិ ស្វែងរកប្រភពហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យាចូលក្នុងប្រទេស ការទាក់ទាញមូលធនបរទេស និងស្វែងរកជំនួយបរទេសជាដើម។

## ២.២.២ សម្ពាធនយោបាយអន្តរជាតិលើសេដ្ឋកិច្ចកម្ពុជា

នៅសម័យកាលនោះ ចំពោះប្រទេសភាគច្រើនដែលធ្លាប់តែមិនទទួលស្គាល់រដ្ឋកម្ពុជា និងធ្លាប់តែបានផ្ដាច់ជំនួយអភិវឌ្ឍន៍ដោយអនុលោមតាមការណែនាំរបស់អង្គការសហប្រជាជាតិ(អ.ស.ប)ក្នុងទំនាក់ទំនងជាមួយរដ្ឋកម្ពុជា ដូច្នេះសម្រាប់ការឆ្លើយតបទៅនឹងបញ្ហានេះ រដ្ឋាភិបាលភ្នំពេញបានប្រើប្រាស់នីតិវិធីរបស់ខ្លួន ដោយគាំទ្រទំនាក់ទំនងជាមួយប្រទេសទាំងនោះដោយផ្ទាល់ និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួត ជាពិសេសជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដើម្បីកិច្ចដំណើរការលើវិស័យគោលនយោបាយសេដ្ឋកិច្ចរបស់ខ្លួន។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិទាំងអស់នោះតែងតែបានផ្ដល់ហិរញ្ញវត្ថុដល់ប្រទេសកម្ពុជាដែលភាគច្រើនជាប្រទេសលោកខាងលិច។ ក្នុងទំនាក់ទំនងទាំងអស់នេះ យើងពិនិត្យឃើញថា រដ្ឋាភិបាលភ្នំពេញតែងតែបានសម្ដែងឡើងនូវចរិតលក្ខណៈប្រកបដោយភាពទន់ភ្លន់ចំពោះទំនាក់ទំនងការទូតលើវិស័យសេដ្ឋកិច្ចជាលក្ខណៈទ្វេភាគីដែលបានធ្វើឱ្យទំនាក់ទំនងគ្នាមានភាពកក់ក្ដៅ និងស្និទ្ធស្នាលគ្រប់

បណ្ដាអង្គការអន្តរជាតិទាំងអស់ ព្រមទាំងបានទាក់ទាញពួកគេឱ្យចូលរួមក្នុងការស្ដាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម និងបានផ្ដល់ជាជំនួយបន្ទាន់ទៀតផង។ ជាក់ស្ដែង ដូចជានៅទីក្រុងភ្នំពេញនាដំណាក់កាលនោះ គឺមានអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិប្រមាណជាង ៣០បាន និងកំពុងបំពេញការងារនៅទីនេះដោយបានផ្ដល់ជាជំនួយជារៀងរាល់ឆ្នាំក្នុងទំហំសាច់ប្រាក់១០លានដុល្លារ។ ជំនួយភាគច្រើនគឺបានយកទៅប្រើប្រាស់លើការស្ដាបនាប្រព័ន្ធធារាសាស្ត្រ និងការស្ដារឡើងវិញក៏ដូចជាការពង្រីកបន្ថែមនូវវិស័យកសិកម្មផលិតកម្ម ការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងអភិវឌ្ឍវិស័យអប់រំ ព្រមទាំងការចូលរួមស្ដារវិស័យឧស្សាហកម្ម និងការបណ្ដុះបណ្ដាលមន្ត្រីរាជការជាដើម-ល-។

ក្រោយឆ្នាំ១៩៨៩ យើងសង្កេតឃើញថា តាមរយៈអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិបានចាប់ផ្ដើមផ្ដល់ជាជំនួយមនុស្សធម៌ជានិម្មិតរូបដល់ប្រទេសកម្ពុជា ក៏ប៉ុន្តែប្រទេសដែលជាសមាជិកនៃអង្គការក្រៅរដ្ឋាភិបាលទាំងនោះ មានគោលជំហរស្អប់ខ្ពើមចំពោះរដ្ឋាភិបាលកាន់អំណាចក្នុងទំនាក់ទំនងនយោបាយក៏ដូចជាសេដ្ឋកិច្ចពាណិជ្ជកម្មលើកលែងតែប្រទេសបារាំងមួយប៉ុណ្ណោះ។ ជាប្រពៃណីរបស់ខ្លួន ប្រទេសបារាំងបានប្រកាន់ខ្ជាប់នូវគោលជំហរបែបអព្យាក្រឹត្យ ហើយបានលូកដៃចូលជ្រៅជាងគេក្នុងការរួមចំណែកដោះស្រាយ និងសម្របសម្រួលបញ្ហានយោបាយកម្ពុជា ព្រមទាំងបានផ្ដល់ជំនួយមនុស្សធម៌គ្រប់ប្រភេទដល់រដ្ឋាភិបាលរបស់លោកហ៊ុន-សែនទៀតផង។ ជាងនេះទៀត នៅដំណាក់កាលឆ្នាំចុងក្រោយ ទំនាក់-ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសកម្ពុជាជាមួយនឹងទីក្រុងប៉ារីសមានសន្ទុះកើនឡើងយ៉ាងខ្លាំងក្លាគួរឱ្យកត់សម្គាល់។ ដោយឡែក ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈច្រកទ្វារនៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ក្នុងនោះមានប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិកជាដើម ក៏បានងាកមកផ្ដល់ជំនួយមនុស្សធម៌ដល់រដ្ឋាភិបាលភ្នំពេញផងដែរ ហើយខណៈនោះ ប្រទេស


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អូស្ត្រាលី បានក្លាយជាប្រទេសដែលបានផ្តល់ជំនួយអន្តរជាតិច្រើនជាងគេ ពោលគឺចាប់ពីឆ្នាំ១៨៨៥-១៩៩០ ប្រទេសមួយនេះបានបរិច្ចាគថវិការបស់ខ្លួនប្រមាណជា៣,៨៩លានដុល្លារមកឱ្យរដ្ឋាភិបាលភ្នំពេញ។ រហូតដល់ចុងទសវត្សរ៍ទី៨០ ការបង្ហាញអំពីសកម្មភាព និងតួនាទីរបស់ក្បាលម៉ាស៊ីនដឹកនាំនៃរដ្ឋាភិបាលកម្ពុជាក្នុងដំណើរទំនាក់ទំនងការទូត ចំពោះវិស័យសេដ្ឋកិច្ច កាន់តែបានលេចចេញជារូបរាងយ៉ាងច្បាស់លាស់ជាងមុន ដូចជានៅចន្លោះឆ្នាំ១៩៨៩-១៩៩០ លោកនាយករដ្ឋមន្ត្រី ហ៊ុន-សែន បានធ្វើដំណើរទៅបំពេញទស្សនកិច្ចផ្លូវរដ្ឋជាច្រើនលើកច្រើនសារនៅប្រទេសថៃ ក្នុងគោលបំណងធ្វើកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្មក្រៅប្រទេសសំខាន់ៗ។ ជាលទ្ធផលប្រទេសទាំងពីរបានឈានទៅដល់ការឯកភាពគ្នា និងបានចុះកិច្ចព្រមព្រៀងលើទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មព្រមទាំងបានពង្រីកការចូលរួមផ្នែកមូលធនរបស់ប្រទេសថៃក្នុងវិស័យឧស្សាហកម្មដែលពាក់ព័ន្ធនឹងដំណើរការធ្វើឯកជនភាវូបនីយកម្មរោងចក្រ-សហគ្រាសរដ្ឋទៀតផង។

នៅសម័យកាលនោះដែរ ទន្ទឹមនឹងការរីកលូតលាស់យ៉ាងទូលំទូលាយជុំវិញវិស័យទំនាក់ទំនងការទូតផ្នែកសេដ្ឋកិច្ចក្នុងទម្រង់ជាទ្វេភាគីដែលជាការអនុវត្តថ្មីរបស់អង្គការអន្តរជាតិ និងជាបទពិសោធន៍ដ៏ពិសិដ្ឋមួយដែលធ្លាប់បានអនុវត្តកន្លងមកដោយអង្គការនានានៅលើសកលលោក ជាពិសេសគឺអង្គការសហប្រជាជាតិដែលអង្គការនេះធ្លាប់បានបង្កើតទម្រង់ទំនាក់ទំនងការងារពាក់ព័ន្ធនឹងសកម្មភាពការទូតលើគ្រប់វិស័យទាំងអស់។

ឆ្លើយតបទៅនឹងនិន្នាការខាងលើនេះដែរ ប្រទេសកម្ពុជាបានធ្វើសកម្មភាពយ៉ាងសកម្មផងដែរក្នុងការចូលរួមក្នុងបណ្តាញនៃសម្ព័ន្ធភាពទំនាក់ទំនងកាទូតជាមួយនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍនៅលើពិភពលោកដោយផ្សារភ្ជាប់ខ្លួនចូលក្នុងបក្សសម្ព័ន្ធភូមិសាស្ត្រនយោបាយតែមួយលើគ្រប់វិស័យទាំងអស់។ ជាការពិតណាស់ អត្ថប្រយោជន៍សេដ្ឋកិច្ចរបស់

ប្រទេសកម្ពុជា ជាទូទៅ ពុំបានត្រូតស៊ីគ្នាទាំងស្រុងជាមួយនឹងដង់វិថីសេដ្ឋកិច្ច នៃប្រទេសក្រីក្រផ្សេងៗទៀតនោះទេ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើទង្វើណាមួយរួមគ្នា វាហាក់ដូចជាបានបង្កលក្ខណៈងាយស្រួល និង ធ្វើឱ្យមានអារម្មណ៍វិជ្ជមានចំពោះការស្វែងរកដំណោះស្រាយនយោបាយ នៅកម្ពុជា។ ផ្ទុយទៅវិញ ភាពប្រឈមមុខដាក់គ្នាដោយសារតែការប្រកាន់ យកនិន្នាការនយោបាយនៃប្រព័ន្ធប្លុកពីរផ្សេងគ្នាក្រោមរូបភាពរបស់«សង្គ្រាម ត្រជាក់» ធ្វើឱ្យយើងមិនអាចគេចផុតពីផលប៉ះពាល់ជាអវិជ្ជមានចំពោះ ផែនការកម្មវិធី និងសកម្មភាពរួមរបស់ប្រទេសកំពុងអភិវឌ្ឍដែលបានខិតខំ រៀបចំឡើងដោយស្ថាប័នអង្គការសហប្រជាជាតិ និងអង្គការតំបន់របស់ ប្រទេសកំពុងអភិវឌ្ឍ និងដោយចលនានៃប្រទេសឯករាជ្យមិនចូលបក្ស សម្ព័ន្ធនោះឡើយ។

លើសពីនេះទៅទៀត ផ្អែកលើប្រភពឯកសារជាមូលដ្ឋានដែលសិក្សា អំពីបញ្ហាសេដ្ឋកិច្ច និងសង្គមដែលបានរៀបចំឡើងដោយស្ថាប័នមួយចំនួន របស់អង្គការសហប្រជាជាតិ និងការស្រាវជ្រាវរបស់ចលនាប្លុកប្រទេស ឯករាជ្យមិនចូលបក្សសម្ព័ន្ធអស់រយៈពេលជិត៣០ឆ្នាំ( នៅក្នុងទសវត្សរ៍ទី ៦០ រហូតដល់ពាក់កណ្តាលទសវត្សរ៍ទី៨០)ដែលសម្រាប់ដំណាក់កាលដំបូង នៃខ្លឹមសារទំនាក់ទំនងការទូតគ្រប់ជ្រុងជ្រោយរបស់ប្រទេសកំពុងអភិវឌ្ឍ គឺហាក់ដូចជាបានបង្កប់ទៅដោយចរិតលក្ខណៈម្យ៉ាងដោយទោរទន់ទៅរក និន្នាការនយោបាយនីយកម្ម( នយោបាយជាធំ) ច្រើនជាងនិន្នាការនយោ-បាយបែបសេដ្ឋកិច្ចដែលក្នុងស្នាដៃទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំងអំពី អត្ថន័យរបស់ខ្លួនចំពោះទស្សនទាននៃរបៀបរបបនៃការចាត់ចែងសេដ្ឋកិច្ច អន្តរជាតិបែបថ្មី។ នេះអាចបញ្ជាក់បន្ថែមទៀតថា ទស្សនទាននៃក្រឹត្យក្រម អភិវឌ្ឍសេដ្ឋកិច្ចខាងលើនេះពុំបានបង្ហាញអំពីទម្រង់ការដាក់លាក់ណា មួយចំពោះគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសនោះទេ ក៏ប៉ុន្តែជារួម រដ្ឋាភិបាលកម្ពុជានាសម័យកាលនោះនៅតែសាទរចំពោះគោលគំនិតសំខាន់ៗ

របស់ទស្សនទានខាងលើនេះ។ យ៉ាងណាមិញ ដូចដែលក្នុងខណៈពេល ធ្វើបទបង្ហាញក្នុងមហាសន្និបាតបក្សកុំម្មុយនីស្តលើកទី២៧ យើងពិនិត្យ ឃើញថា អគ្គលេខាធិការមជ្ឈិមបក្សនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា គឺលោក ហេង សំរិន បានអះអាងថា «យើងគាំទ្រចំពោះការទាមទារទាំងឡាយ ណារបស់ប្រទេសកំពុងអភិវឌ្ឍស្តីអំពីទស្សនៈនៃការបង្កើតគោលនយោបាយ សេដ្ឋកិច្ចអន្តរជាតិបែបថ្មីក្នុងគោលដៅស្វែងរកភាពយុត្តិធម៌ និងស្វែងរក ប្រជាធិបតេយ្យ»។

ចំពោះបញ្ហាភាគច្រើននៃគោលជំហររបស់កម្ពុជាក៏ដូចជាសម្រាប់ បណ្តាប្រទេសដែលកំពុងអភិវឌ្ឍនានាផងដែរ គឺមានលក្ខណៈប្រហាក់-ប្រហែលគ្នា ក៏ប៉ុន្តែអ្វីដែលមានលក្ខណៈផ្ទុយពីគ្នានោះ ស្ថិតនៅលើត្រង់ បញ្ហាសំខាន់មួយថា ប្រទេសកម្ពុជានាសម័យកាលនោះត្រូវបានគេដកហូត សិទ្ធិសេរីភាពក្នុងកិច្ចដំណើរការគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស របស់ខ្លួនតាមរយៈកិច្ចទំនាក់ទំនងការទូតគ្រប់ជ្រុងជ្រោយ( គឺបិទច្រកគ្រប់ ទំនាក់ទំនង)។ បញ្ហាទាំងអស់នេះបណ្តាលមកពីវត្តមានកងទ័ពវៀតណាម នៅក្នុងប្រទេសកម្ពុជាតាំងពីចុងឆ្នាំ១៩៧៨ដែលធ្វើឱ្យកើតមានប្រតិកម្ម ជាអវិជ្ជមានពីសំណាក់អង្គការសហប្រជាជាតិ។ ក្នុងកាលបរិច្ឆេទពីរឆ្នាំ ជាប់ៗគ្នាដែលក្នុងកិច្ចប្រជុំថ្នាក់កំពូលរបស់អង្គការសហប្រជាជាតិ បានធ្វើ ការសម្រេចបោះឆ្នោតគាំទ្រឱ្យមានការរក្សាជាបន្តទៀតនូវអាសនៈរបស់មេ ដឹកនាំនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ( រដ្ឋាភិបាលរបស់ប៉ុល ពត)ក្នុង អង្គការសហប្រជាជាតិ និងបន្តឱ្យមានការហ៊ុមពទ្ធ័សេដ្ឋកិច្ចប្រឆាំងទៅនឹង រដ្ឋាភិបាលភ្នំពេញ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជា នៅតែបន្តការអត់ធ្មត់របស់ខ្លួន និងរក្សាការទ្រទ្រង់នូវទំនាក់ទំនងល្អជាមួយ នឹងស្ថាប័នជំនាញទាំងឡាយក្នុងក្របខ័ណ្ឌអង្គការ UNICEF UNESCO FAO កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ អង្គការកម្មវិធីស្បៀងអាហារ ពិភពលោក អង្គការសុខភាពពិភពលោក និងលេខាធិការដ្ឋានជាន់ខ្ពស់

របស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនជាដើម។ល។

## ២.២.៣ ការរីកចំណាងទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្លុកសង្គមនិយម

ក្នុងនិទ្ទាការនេះដែរ បើយើងវិភាគអំពីមធ្យោបាយនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស ជាការចាំបាច់ យើងគប្បីពិចារណាផងដែរទៅលើបញ្ហានានាស្តីអំពីភាពផ្តាច់មុខរបស់រដ្ឋលើទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស។ យ៉ាងណាមិញ នៅឆ្នាំ១៩៧៩ បន្ទាប់ពីបានស្តារឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំរដ្ឋជុំវិញការងារពាណិជ្ជកម្មក្រៅប្រទេសនៅកម្ពុជារួចមក យើងពិនិត្យឃើញថា សេចក្តីសម្រេចរបស់រដ្ឋាភិបាលសម័យនោះបានផ្តោតជាសំខាន់លើភាពផ្តាច់មុខរបស់រដ្ឋលើគ្រប់ទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស។ ក៏ប៉ុន្តែ ក្នុងលក្ខខណ្ឌដែលវិស័យសេដ្ឋកិច្ច ត្រូវបានគេបិទច្រកពីសំណាក់ប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍភាគច្រើនក្នុងប្លុកមូលធននិយម ហើយបានធ្វើឱ្យប្រទេសកម្ពុជាជួបប្រទះនូវវិបត្តិរូបិយប័ណ្ណបរទេសយ៉ាងស្រួចស្រាវដែលតម្រូវឱ្យរដ្ឋាភិបាលរួសរាន់បង្វិចិត្តលុបចោលគោលការណ៍ផ្តាច់មុខរបស់រដ្ឋលើវិស័យពាណិជ្ជកម្មក្រៅប្រទេស។ នៅខណៈនោះដែរ ក្រុមហ៊ុនឯកជនជាច្រើនក៏ដូចជាពួកពាណិជ្ជករនានាត្រូវបានរដ្ឋាភិបាលផ្តល់សិទ្ធិស្របច្បាប់ដូចគ្នានឹងអង្គការសេដ្ឋកិច្ចពាណិជ្ជកម្មក្រៅប្រទេសរបស់រដ្ឋ ដើម្បីបំពេញប្រតិបត្តិការនាំចេញ-នាំចូលជាមួយនឹងក្រុមហ៊ុនជាដៃគូនៃបណ្តាប្រទេសមូលធននិយម។ ពួកពាណិជ្ជករក្នុងស្រុកជាច្រើនបានបង្កើតជាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងបណ្តាក្រុមហ៊ុនទាំងឡាយនៅប្រទេសថៃ សិង្ហបុរី ហុងកុង និងតៃវ៉ាន់។ ប៉ុន្តែ ចំពោះដំណើរការវិស័យពាណិជ្ជកម្មក្រៅប្រទេសជាមួយនឹងក្រុមហ៊ុននៅបណ្តាប្រទេសអឺរ៉ុបខាងកើត និងសហភាពសូវៀត ក៏ដូចជាជាមួយប្រទេសឥណ្ឌូចិនទាំងពីរ(គឺវៀតណាម និងឡាវ) បានធ្វើឡើងតាមរយៈអង្គការរដ្ឋតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ការរក្សាអភ័យឯកសិទ្ធិនៃប្រព័ន្ធផ្តាច់មុខ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចំពោះវិស័យសេដ្ឋកិច្ចក្រៅប្រទេសជាមួយនឹងបណ្ដាប្រទេសសង្គមនិយមនានានៅសម័យនោះ ពុំមានអនាគតវែងឆ្ងាយនោះឡើយ ទីបំផុតរដ្ឋាភិបាលត្រូវតែបង្ខំចិត្តដកខ្លួនចេញពីគោលការណ៍នេះ ដោយកែលម្អឥរិយាបថទំនាក់ទំនងរបស់ខ្លួនចំពោះប្រទេសទាំងអស់នោះឡើងវិញ។

ជាមួយនឹងដំណោះស្រាយខាងលើនេះ នៅឆ្នាំ១៩៨៨ ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃរដ្ឋកម្ពុជាបានធ្វើវិសោធនកម្មលើសេចក្ដីសម្រេចមួយចំនួនស្ដីអំពីបម្លាស់ប្ដូរបទបញ្ញត្តិទាក់ទងនឹងភាពផ្ដាច់មុខរបស់រដ្ឋលើវិស័យសេដ្ឋកិច្ចក្រៅប្រទេស ជាពិសេស ជាមួយសហភាពសូវៀត ប្រទេសឡាវ វៀតណាម និងបណ្ដាប្រទេសនានានៅអឺរ៉ុបខាងកើត។ ចាប់តាំងពីខណៈនោះមក ស្ថាប័នរដ្ឋាភិបាលបានដើរតួនាទីជាអ្នកសម្របសម្រួល និងអ្នកគ្រប់គ្រងទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស ហើយសហគ្រាសឯកជនគ្រប់ប្រភេទ និងស្ថាប័នពាណិជ្ជកម្មរបស់រដ្ឋមួយចំនួន មានសិទ្ធិដូចគ្នាក្នុងការនាំចេញទំនិញទៅកាន់ទីផ្សារក្រៅប្រទេស។ វិធានការខាងលើនេះបានបង្កលក្ខណៈឱ្យមានការបង្វិលដើមទុនលើវិស័យពាណិជ្ជកម្មក្រៅប្រទេសក្នុងល្បឿនកើនឡើងយ៉ាងឆាប់រហ័សដូចជានៅចន្លោះឆ្នាំ១៩៨៨-១៩៩០ ទំហំពាណិជ្ជកម្មបានកើនឡើងរហូតដល់១៧,១៤% ក៏ប៉ុន្តែតាមកំណត់ត្រា ឬរបាយការណ៍របស់ក្រសួងផែនការបានអះអាងថា ទំនិញនាំចូលជាច្រើនគឺជាប្រភេទទំនិញដែលទទួលបាននូវប្រាក់ចំណេញអតិបរមា និងលក់ដាច់រហ័ស តែពុំមែនជាប្រភេទទំនិញដែលមានលក្ខណៈចាំបាច់សម្រាប់យកមកធ្វើជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិនោះទេ។ ម្យ៉ាងទៀត កិច្ចព្រមព្រៀងលើពិធីការស្ដីពីការផ្លាស់ប្ដូរទំនិញរវាងប្រទេសមួយចំនួនមិនត្រូវបានយកមកអនុវត្តឡើយ ដោយសារតែក្រុមហ៊ុនជាច្រើនបានផ្ដល់អាទិភាព ឬយកចិត្តទុកដាក់តែទៅលើការលក់ទំនិញទាំងឡាយណាស្របទៅតាមគំនិតយល់ឃើញរបស់ខ្លួន។ អាស្រ័យហេតុនេះ ការធ្វើសកម្មភាពសេដ្ឋកិច្ចជាមួយនឹងទីផ្សារក្រៅស្រុកបានដំណើរការឡើងដោយបញ្ច្រាសទិស ឬផ្ទុយគ្នាទាំង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រុងជាមួយនឹងគោលការណ៍គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រដ្ឋលើវិស័យពាណិជ្ជកម្មក្រៅប្រទេស។

ផ្សេងពីបញ្ហាទាំងអស់ខាងលើនេះ យើងបានពិនិត្យឃើញទៀតថា បន្ទាប់ពីបានបង្កើតរដ្ឋកម្ពុជានៅខែមករា ឆ្នាំ១៩៧៩រួចមក ការអភិវឌ្ឍលើកិច្ចការងារសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច-ពាណិជ្ជកម្មជាមួយនឹងបណ្ដាប្រទេសនៅឥណ្ឌូចិន សហភាពសូវៀត ក៏ដូចជាប្រទេសមួយចំនួននៅអឺរ៉ុបខាងកើត បានក្លាយជាវិស័យអាទិភាពបំផុតចំពោះគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់ប្រទេសកម្ពុជា។ លើសពីនេះទៀត ចាប់តាំងពីឆ្នាំ ១៩៧៩-១៩៨៧ ប្រទេសកម្ពុជាបានផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងពិសេសជាមួយនឹងប្រទេសវៀតណាម និងប្រទេសឡាវ។ ទំនាក់ទំនងដែលបានបង្កើតឡើង គឺមិនត្រឹមតែស្ថិតនៅលើការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានព្យាយាមបង្កើតជារចនាសម្ព័ន្ធអង្គការអន្តរជាតិនៃប្រទេសទាំងបីទៀតផង ដើម្បីរក្សាតុល្យភាពលើគ្រប់វិស័យជាមួយនឹងបណ្ដាប្រទេសក្នុងសហគមន៍អាស៊ានដែលបានបង្កើតឡើងនាឆ្នាំ១៩៦៧។ ក្នុងស្ថានភាពនេះ សម្រាប់ប្រទេសទាំងបីនៅឥណ្ឌូចិនបានរៀបចំជាគណៈកម្មការសំខាន់ៗជាច្រើន រួមមានគណៈកម្មការសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច គណៈកម្មការសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ-បច្ចេកទេស និងគណៈកម្មការសហប្រតិបត្តិការលើវិស័យវប្បធម៌ជាដើម។ ចំពោះគណៈកម្មការទាំងនេះបានតាក់តែងផែនការសកម្មភាពឡើងសម្រាប់បំពេញកម្មវិធីសហប្រតិបត្តិការរយៈពេលខ្លី និងរយៈពេលវែងផងដែរនៃកិច្ចសហប្រតិបត្តិការ។ រីឯយន្តការសម្របសម្រួលនៃផែនការសេដ្ឋកិច្ចជាតិក៏បានដាក់ឱ្យដំណើរការស្របតាមទិសដៅនៃកម្មវិធីសហប្រតិបត្តិការដែលបានប្រជុំពិភាក្សាគ្នា និងបានអនុម័តដោយគណៈកម្មការចម្រុះនាពេលកន្លងមក។ ជាងនេះទៀត ទាក់ទងនឹងទិសដៅសំខាន់ៗចំនួន៥ចំណុច សម្រាប់ដាក់ឱ្យដំណើរការមានខ្លឹមសារដូចខាងក្រោម ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១. ត្រូវធ្វើយ៉ាងណា ដើម្បីពង្រីកឱ្យបានឆាប់រហ័សនូវផលិតកម្មទំនិញជាស្បៀងអាហារ សម្រាប់ស្ថិរភាពនីយកម្មជីវភាពប្រជាជន និងការបង្កើតជាវត្ថុធាតុដើមបម្រុងចំពោះវិស័យឧស្សាហកម្ម។

២. ត្រូវជំរុញល្បឿននៃការនាំចេញ ជំរុញការស្តាបនាពល់លក្ខខណ្ឌអំណោយផល សម្រាប់រក្សាតុល្យភាពរវាងការនាំចេញ និងការនាំចូល ព្រមទាំងពង្រីកការសន្សំ។

៣. ត្រូវពង្រីកប្រភពថាមពលបង្កើតលក្ខខណ្ឌប្រកបសម្រាប់ផលិតកម្មទំនិញចាំបាច់ និងរុករកវត្ថុធាតុដើមធម្មជាតិបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម។

៤. ត្រូវពង្រីកផ្លូវគមនាគមន៍ ដោយការបង្កលក្ខណៈងាយស្រួលសម្រាប់ប្រទេសឡាវ ក្នុងការប្រើប្រាស់កំពង់ផែសមុទ្ររបស់កម្ពុជា និងវៀតណាម និងការពង្រីកបន្ថែមទៀតនូវការដោះដូរទំនិញក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេសរវាងប្រទេសទាំងបី។

៥. ត្រូវតែដំណើរការឡើងនូវការសិក្សាស្រាវជ្រាវលើវិស័យកិច្ចការវិទ្យាសាស្ត្រ និងធ្វើការសិក្សាអំពីធនធានធម្មជាតិ និងការបណ្តុះបណ្តាលមន្ត្រីសាធារណៈ។

សម្រាប់ការប្រែក្លាយផែនការកម្មវិធីទាំង៥ចំណុចខាងលើនេះឱ្យទៅជាសកម្មភាពជាក់ស្តែង យើងពិនិត្យឃើញថា នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការនៃប្រទេសទាំងបី បានរួមគ្នាអនុម័តលើកម្មវិធីសហប្រតិបត្តិការចំនួន៧ចំណុចបន្ថែមទៀត។ ក៏ប៉ុន្តែ កម្មវិធីបំពេញបន្ថែមទាំងនោះបានស្ថិតនៅលើតែក្រដាសប៉ុណ្ណោះ ហើយការខិតខំប្រឹងប្រែង ឬការព្យាយាមបង្កើតជារចនាសម្ព័ន្ធអន្តរជាតិណាមួយដែលពឹងផ្អែកលើមូលដ្ឋានដ៏ទន់ខ្សោយផ្នែកសម្ភារបច្ចេកទេស និងអាស្រ័យលើភាពអន់ថយខាងកម្លាំងផលិតកម្ម ក៏ដូចជាភាពអសកម្មផ្នែកទំនាក់ទំនងដោះដូរទំនិញ និងមូលធន ព្រមទាំងកង្វះការពិចារណាឱ្យបានដិតដល់លើកត្តាជាប្រវត្តិនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលធ្លាប់មានជាប្រពៃណីកន្លងមក គឺពុំអាចគេចផុតពីភាពបរាជ័យនោះបានឡើយ។ ហើយជាងនេះទៅទៀត ក្នុងកម្មវិធីទាំងអស់នោះទៀតសោតសូម្បីតែការកំណត់ទៅលើកិច្ចការដែលសំខាន់បំផុតជាងគេនោះ ក៏ពុំឃើញបានលើកយកមកអនុម័តទៀតផង ពោលគឺបញ្ហាប្រភពនៃការឧបត្ថម្ភហិរញ្ញប្បទានទៅលើគម្រោងរួម និងប្រភពនៃទុនវិនិយោគជាដើម។

គួរបញ្ជាក់បន្ថែមទៀតដែរថា ក្រៅពីការពង្រឹងទំនាក់ទំនងពិសេសជាមួយប្រទេសវៀតណាម និងឡាវលើគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេស យើងពិនិត្យឃើញថា ប្រទេសកម្ពុជាយើងក៏បានពិចារណាល្អិត-ល្អន់ផងដែរទៅដល់ទំនាក់ទំនងជាយុទ្ធសាស្ត្រជុំវិញគោលនយោបាយនេះជាពិសេស ជាមួយសហភាពសូវៀត និងប្រទេសសង្គមនិយមភាគខាងកើតនៃទ្វីបអឺរ៉ុបផងដែរ។ ជាក់ស្តែង ខ្លឹមសារនៃទំនាក់ទំនងជាមិត្តភាពរវាងបណ្តាប្រទេសទាំងនោះត្រូវបានលើកឡើងដោយលោក ហេង សំរិន នៅក្នុងសុន្ទរកថានៃមហាសន្និបាតបក្សលើកទី៥នៃបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលមានខ្លឹមសារជាអាទិ៍ថា «កិច្ចសហប្រតិបត្តិការលើគ្រប់ជ្រុងជ្រោយជាមួយនឹងប្រទេសសង្គមនិយមជាបងប្អូន ជាពិសេស សហភាពសូវៀតបានក្លាយជាកត្តាដ៏សំខាន់បំផុតនៃកិច្ចសហប្រតិបត្តិការរបស់ប្រទេសកម្ពុជា»។ ហេតុដូចនេះហើយបានជា ក្រោយឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៨៧ យើងឃើញថា ប្រទេសកម្ពុជាតែងតែបានវាយតម្លៃខ្ពស់លើកិច្ចការងារសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស ក៏ដូចជាលើវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្មជាមួយនឹងសហភាពសូវៀត និងបណ្តាប្រទេសអឺរ៉ុបខាងកើត។ ក៏ប៉ុន្តែ ដោយសារតែមានការវិវត្តលក្ខខណ្ឌចាំបាច់មួយចំនួន ទាំងផ្នែកខាងក្នុងប្រទេស និងក្រៅប្រទេសបានតម្រូវឱ្យប្រទេសកម្ពុជាយើងសម្រេចពិនិត្យទិសដៅសំខាន់ៗនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់ខ្លួនឡើងវិញ។

នៅក្នុងខែសីហា ឆ្នាំ១៩៨៧ យើងសង្កេតឃើញថា គោលនយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាត្រូវបានកែលម្អឡើងវិញ។ នៅខណៈនោះដែរ រដ្ឋាភិបាលរបស់លោក ហ៊ុន សែន ក៏បានធ្វើសេចក្តីប្រកាសអំពីមាគ៌ានយោបាយដែលប្រទេសកម្ពុជាគប្បីជ្រើសរើស និងធ្វើដំណើរបន្តទៀតដោយបានចាប់ផ្តើមពិនិត្យឡើងវិញនូវបណ្តាទិសដៅដែលជាទស្សនទាននានា សម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងវិស័យនយោបាយសង្គមរបស់ប្រទេសកម្ពុជា។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើសេចក្តីថ្លែងការមួយថា «ការធ្វើបដិវត្តន៍របស់កម្ពុជាកំពុងស្ថិតលើដំណាក់កាលមួយទៀតនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជន» មានន័យថា ថ្នាក់ដឹកនាំប្រទេសកម្ពុជាបានយល់ច្បាស់អំពីសភាពមិនស្ថិតស្ថេរចំពោះទស្សនទានដែលបានអនុវត្តកន្លងមក និងបានសម្រេចចិត្តស្វែងរកទស្សនទានថ្មីៗទៀតមកជំនួសវិញ។ ការពិនិត្យឡើងវិញចំពោះទស្សនទាន និងគោល-បំណងជាអាទិភាពណាមួយនៃគោលបំណងនយោបាយសេដ្ឋកិច្ចជាក់-ស្តែងត្រូវតែកំណត់ដោយលក្ខខណ្ឌនៃកត្តាចាំបាច់របស់វា។ ជាការពិតណាស់ការធ្វើអន្តរកាលនីយកម្មតែមួយជ្រុងទៅរកប្រទេសសង្គមនិយម គឺពុំប៉ិនប្រសប់ដល់ការជួយដោះស្រាយបានទាន់ពេលវេលាចំពោះបញ្ហាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានឡើយ។ រីឯរោងចក្រសហគ្រាសឧស្សាហកម្មភាគច្រើនដែលបានស្តាបនាឡើងក្នុងទសវត្សរ៍ទី៦០ បានប្រើប្រាស់គ្រឿងបរិក្ខារ និងគ្រឿងបន្លាស់ពីបណ្តាប្រទេសលោកខាងលិច ហើយមានតែរោងចក្រសហគ្រាសមួយចំនួនប៉ុណ្ណោះបានសាងសង់ឡើងដោយប្រើប្រាស់ជំនួយបច្ចេកទេសពីប្រទេសយូហ្គោស្លាវី ចិន និងសាធារណរដ្ឋឆេកូស្លូវ៉ាគី ប៉ុន្តែសម័យរដ្ឋកម្ពុជា ក្រៅពីប្រទេសឆេកូស្លូវ៉ាគី កម្ពុជាពុំធ្លាប់មានទំនាក់ទំនងពាណិជ្ជកម្មជាផ្លូវការនោះឡើយ។ ហេតុផលនេះហើយទើបរោងចក្រឧស្សា-ហកម្មជាច្រើននៅសម័យនោះមិនត្រូវបានជួសជុល និងដាក់ឱ្យដំណើរការឡើងវិញដោយសារបញ្ហាកង្វះខាតគ្រឿងបន្លាស់គ្រប់ប្រភេទ។

ម្យ៉ាងទៀត កិច្ចសហប្រតិបត្តិការជាមួយសហភាពសូវៀត និងបណ្តា

ប្រទេសអឺរ៉ុបខាងកើត បានឈានដល់ដំណាក់កាលមួយដែលមានបញ្ហាយ៉ាងដំណំ ជាពិសេសពាក់ព័ន្ធនឹងបញ្ហាអតុល្យភាពជញ្ជីងពាណិជ្ជកម្ម ដែលធ្វើឱ្យប្រទេសកម្ពុជាយើងជួបប្រទះនូវកំណើនប្រាក់បំណុលគួរឱ្យព្រួយបារម្ភលើវិស័យពាណិជ្ជកម្មក្រៅប្រទេស។ បញ្ហាបំណុលច្រើនពាក់ព័ន្ធនឹងការនាំចូល ដូចជាវត្ថុធាតុដើម ប្រេងឥន្ធនៈ វត្ថុធាតុដើមផលិតកម្ម ទំនិញជាឱសថ និងទំនិញប្រើប្រាស់ទូទៅដែលបានគ្របបណ្តប់រហូតដល់ជាង៧០%នៃទំហំបំណុលសរុប។ ក្រៅពីនោះ បញ្ហាបំណុលផ្សេងៗទៀតច្រើនពាក់ព័ន្ធទៅនឹងការនាំចូលរថយន្ត និងគ្រឿងបន្លាស់ដែលមានទំហំប្រមាណជា៣០%។ ចំពោះលក្ខខណ្ឌនៃការទូទាត់វិញដែលកន្លងមកសម្រាប់ការទិញរថយន្ត និងគ្រឿងបន្លាស់ បានទូទាត់ជាលក្ខណៈឥណទានរូបិយ-ប័ណ្ណរូប្លិ៍។ ម្យ៉ាងទៀត ការនាំចូលទំនិញមកក្នុងទីផ្សារប្រទេសកម្ពុជាមិនទទួលបានការចាប់អារម្មណ៍ក្នុងការផ្គត់ផ្គង់នោះឡើយ ព្រោះច្រើនតែនាំចូលទំនិញដែលមានគុណភាពទាប ជួនកាលបាននាំចូលទំនិញជាគ្រឿងបរិក្ខារចាស់ៗ(ទំនិញជជុះ) ពោលគឺបាននាំចូលមកសុទ្ធសឹងតែជាផលិតផលហួសសម័យ។ ក្រៅពីនេះទៀត បន្ទាប់ពីបានកើតមានព្រឹត្តិការណ៍ជាអវិជ្ជមាននៅប្រទេសអឺរ៉ុបខាងកើត និងការចាប់ផ្តើមកើតមានវិបត្តិសេដ្ឋកិច្ច-សង្គមយ៉ាងធ្ងន់ធ្ងររបស់សហភាពសូវៀត យើងសង្កេតឃើញថា ប្រទេសទាំងនោះបានធ្វើការយកចិត្តទុកដាក់តែទៅលើបញ្ហាផ្ទៃក្នុងរបស់ខ្លួនតែប៉ុណ្ណោះ និងបានងាកទៅរកការពង្រីកទំនាក់ទំនងតែជាមួយបណ្តាប្រទេសមូលធននិយមវិញ រីឯកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្រីក្រមានលក្ខណៈព្រងើយកន្តើយ។ ជាក់ស្តែង ចំពោះកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗដូចជាវិស័យថាមពល វិស័យអប់រំ និងសុខាភិបាលសាធារណៈជាដើមបានធ្លាក់ចុះយ៉ាងខ្លាំងក្លា(ស្ទើរតែបានផ្តាច់ទំនាក់ទំនង)។

ក្រៅពីបញ្ហាខាងលើនេះ ចំពោះទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសនៅតំបន់ចិនក៏ត្រូវបានយកមកពិនិត្យសាជាថ្មី។ នៅដំណាក់កាលនោះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយសារតែការផ្ទុះឡើងនូវបញ្ហាវិបត្តិសេដ្ឋកិច្ចក្នុងប្រទេសនៅឥណ្ឌូចិន បានញាំងឱ្យដំណើរការខាងលើនេះរឹងរឹតតែមានល្បឿនលឿនទៅមុខៗ។ ដោយឡែកចំពោះការសាកល្បងស្ថាបនារចនាសម្ព័ន្ធសេដ្ឋកិច្ចជាអន្តរជាតិជាមួយគ្នាកន្លងមក ក្នុងកម្រិតរីកលូតលាស់ទាបលើគ្រប់វិស័យ ក៏ពុំបាននាំមកនូវលទ្ធផលដែលសមតាមបំណងដែរ។ នៅឆ្នាំ១៩៨៨ ប្រទេសទាំងបីនៅឥណ្ឌូចិនក៏បានដកខ្លួនចេញពីអ្វីដែលហៅថា «ទំនាក់ទំនងពិសេស» រៀងៗខ្លួនដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងវិទ្យាសាស្ត្របច្ចេកទេស។ នៅក្នុងឆ្នាំដដែលនេះដែរ នៅកម្ពុជាក៏បានសម្រេចចិត្តរំលាយគណៈកម្មការទទួលបន្ទុកកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងវិទ្យាសាស្ត្របច្ចេកទេសជាមួយប្រទេសវៀតណាម និងឡាវផងដែរ។

សារៈសំខាន់ជុំវិញការពិនិត្យឡើងវិញនៃគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា គឺជាយុទ្ធវិធីដ៏ល្អមួយរបស់ខ្លួនតាមរយៈនៃការប្រើប្រាស់វិស័យពាណិជ្ជកម្មក្រៅប្រទេសជាអាទិភាពឆ្ពោះទៅរកការទាក់ទាញមូលធនបរទេស ការផ្ទេរចូលបច្ចេកវិទ្យា ទំនាក់ទំនងគ្នាលើវិស័យពាណិជ្ជកម្ម និងការដកស្រង់បទពិសោធន៍គ្រប់គ្រងល្អៗបែបលោកខាងលិច ដើម្បីនាំចូលមកក្នុងប្រទេសកម្ពុជា។ គោលនយោបាយពាណិជ្ជកម្មក្រៅប្រទេសរបស់រដ្ឋាភិបាលនាសម័យនោះមិនបានបង្កប់ដោយចរិតលក្ខណៈក្នុងទ្រង់ទ្រាយមនោគមវិជ្ជាណាមួយនោះទេ ក៏ប៉ុន្តែ បានបង្កប់ទៅដោយចរិតលក្ខណៈជាទស្សនៈផលប្រយោជន៍សេដ្ឋកិច្ចជាចម្បង។ ដោយឡែក ការពង្រីកទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសជាមួយនឹងប្រទេសអាស៊ាន ជាពិសេសប្រទេសថៃ ក៏ដូចជាជាមួយបណ្តាប្រទេសឧស្សាហកម្មថ្មីនៅតំបន់អាស៊ី (សិង្ហបុរី ហុងកុង តៃវ៉ាន់ និងកូរ៉េខាងត្បូង) និងប្រទេសមូលធននិយមជាច្រើនទៀតបានស្ថិតនៅលើចំណុចកំពូលនៃការយកចិត្តទុកដាក់នៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា សម្រាប់យុគសម័យនោះ។ ព្រោះថា នៅក្នុងបណ្តាប្រទេសខាងលើនេះបានប្រមូលផ្តុំ(សន្សំ)

មូលធនលើសពីការប្រើប្រាស់ដែលអាចបង្វែរចេញមកកម្ពុជាបានយ៉ាងរហ័ស ក្នុងខណៈដែលប្រទេសកម្ពុជាអាចបង្កើតបរិយាកាសសមស្របសម្រាប់ការវិនិយោគបរទេស។ រដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា ការពង្រីកខ្សែបណ្ដាញទំនាក់ទំនងជាមួយនឹងបណ្ដាប្រទេសទាំងអស់ខាងលើនេះ គឺជាគោលដៅនយោបាយសេដ្ឋកិច្ចជាតិដែលត្រូវតែសម្របសម្រួល។ ជាងនេះទៀត ប្រទេសថៃត្រូវបានគេចាត់ទុកថា ជាដៃគូដ៏មានសារៈសំខាន់បំផុតរបស់កម្ពុជាក្នុងការសម្របសម្រួលផ្នែកទំនាស់នយោបាយ ព្រោះនៅតំបន់ព្រំដែនខ្មែរ-ថៃនាសម័យនោះ បានបង្កើតមូលដ្ឋានជំរំជនភៀសខ្លួន និងមូលដ្ឋានទ័ពប្រឆាំងនឹងរដ្ឋាភិបាលភ្នំពេញ ហេតុនេះហើយ រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់បំផុត និងចង់ធ្វើឱ្យមានប្រក្រតីភាពនីយកម្មនៃទំនាក់ទំនងជាមួយរដ្ឋាភិបាលថៃ។ ដូច្នេះ ការពិនិត្យឡើងវិញនូវគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាមានឥរិយាបថត្រូតស៊ីគ្នាជាមួយនឹងការផ្លាស់ប្ដូរទិសដៅសេដ្ឋកិច្ចក្រៅប្រទេសរបស់នាយករដ្ឋមន្ត្រីថៃដែលបានចេញសេចក្ដីប្រកាស និងបង្ហាញអំពីបេះដូងល្អរបស់ខ្លួនក្នុងបំណងចង់ប្រែក្លាយតំបន់ឧបទ្វីបឥណ្ឌូចិនឱ្យរួចចាកផុតពីសមរភូមិ ពីសឹកសង្គ្រាមឱ្យទៅជាទីផ្សារលក់ដូរទំនិញរបស់ថៃ។ គួរបញ្ជាក់ថា នៅសម័យនោះ រដ្ឋាភិបាលកម្ពុជាបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះមូលធនរបស់ថៃក្នុងការជ្រើសរើសដៃគូសេដ្ឋកិច្ចរបស់ខ្លួន។ ចំពោះរយៈពេលពីរឆ្នាំចុងក្រោយរដ្ឋាភិបាលនៃប្រទេសទាំងពីរបានឈានដល់ការបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងថ្នាក់ដឹកនាំនយោបាយ និងយោធារបស់ថៃដែលជានិច្ចកាលបានសម្ដែងឡើងនូវការគាំទ្រផ្នែកអាជីវកម្មជាមួយប្រទេសថៃ។

ការពិនិត្យឡើងវិញលើគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសខាងលើនេះពុំមែនមានន័យថា ប្រទេសកម្ពុជាបានបដិសេធចំពោះការពង្រីកទំនាក់ទំនងសេដ្ឋកិច្ចបន្តទៅទៀតជាមួយសហភាពសូវៀត និងបណ្ដាប្រទេសនៅអឺរ៉ុបខាងកើតនោះទេ ដាក់ស្ដែងប្រទេសកម្ពុជានៅតែបន្តកិច្ចសហ-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រតិបត្តិការលើកិច្ចការស្តារឡើងវិញនូវវិស័យថាមពល កសិដ្ឋានដំណាំកៅស៊ូ និងហេដ្ឋារចនាសម្ព័ន្ធសង្គមជាដើម។ ប៉ុន្តែដោយសារតែស្ថានភាពភូមិសាស្ត្រនយោបាយរបស់ប្រទេសកម្ពុជាបានតាំងនៅចន្លោះប្រទេសសង្គមនិយមវៀតណាម និងប្រទេសមូលធននិយមថៃ ហេតុនេះហើយទើបភូមិសាស្ត្រនយោបាយនេះហាក់ដូចជាមានលក្ខណៈអំណោយផលដល់ការកំណត់យុទ្ធសាស្ត្រនយោបាយសេដ្ឋកិច្ចក្រៅប្រទេសបែបនេះឯង។ ម្យ៉ាងវិញទៀត ការដឹកនាំនយោបាយទាំងឡាយណាដែលធ្វើឱ្យមានតុល្យភាពល្អ វានាំឱ្យយើងអាចបង្កើតជាលក្ខខណ្ឌនយោបាយដ៏សមប្រកបមួយសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

សរុបសេចក្តីមក ការសិក្សាវិភាគអំពីទស្សនទានសេដ្ឋកិច្ចជាអន្តរកាលឆ្ពោះទៅរកសង្គមនិយមបាននាំមកនូវបទពិសោធន៍ និងជួយដល់ការធ្វើកំណែទម្រង់គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសទៅរកមាគ៌ាមួយផ្សេងទៀតពាក់ព័ន្ធនឹងការពង្រីកទំនាក់ទំនងថ្មីជាមួយនឹងបណ្តាប្រទេសអាស៊ាន និងប្រទេសលោកខាងលិចផងដែរ។ ភាពជោគជ័យនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ប្រទេសជាសមាជិកអាស៊ានបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការដឹកនាំរបស់កម្ពុជាដែលក្លាយជាបទពិសោធន៍សម្រាប់ការតាក់តែងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសប្រកបដោយភាពត្រឹមត្រូវ។ ក្នុងស្ថានភាពដែលមានបរិយាកាសល្អ និងរីកលូតលាស់លើនិន្នាការសន្ទនារវាងគ្នានៅក្នុងតំបន់លើកិច្ចការនយោបាយ និងសេដ្ឋកិច្ច ដូច្នេះស្ថានភាពទាំងអស់នេះនាំឱ្យយើងអាចធ្វើការពិភាក្សាគ្នាជុំវិញគំនិតដ៏ទាក់ទាញមួយ ពោលគឺគំនិតស្តីពី«ឧបទ្វីបមាស»។ ទស្សនទានមួយនេះបានកើតមានឡើងតាំពីការចាប់ផ្តើមដំបូងនៃសម័យកាលសង្គ្រាមលោកលើកទី២មកម្ល េះដែលពេលនោះស្តេចសៀមមួយព្រះអង្គបានព្យាយាមបង្កើតកុលសម្ព័ន្ធមួយជាមួយប្រទេសជិតខាងរបស់ខ្លួនដែលក្នុងនោះ មានប្រទេសសហភាពភូមា ប្រទេសឡាវ កម្ពុជា និងវៀតណាម។

ផ្សេងពីទស្សនទានខាងលើនេះទៀត គោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាអាចដំណើរការឡើងបានល្អតាមរយៈជំនួយពីឧបករណ៍ផ្សេងៗគ្នា ក្នុងនោះមានកិច្ចការពន្ធគយ ពន្ធដារ ការត្រួតពិនិត្យលើនយោបាយរូបិយប័ណ្ណ និងកិច្ចការឥណទានដែលយើងនឹងចាប់ផ្ដើមសិក្សាវិភាគបន្តទៅទៀតនៅកថាខណ្ឌខាងក្រោមនេះ។

## ២.៣ ការវិវត្តនៃនយោបាយពាណិជ្ជកម្មក្រៅប្រទេស

តាមការស្រាវជ្រាវបង្ហាញថា ការធ្វើដំណើរឆ្លងកាត់ទៅរកការស្ដាបនាទម្រង់សេដ្ឋកិច្ចណាមួយ បន្ទាប់ពីការដណ្ដើមបានឯករាជ្យជាតិលើវិស័យនយោបាយ ហេតុដូចនេះសម្រាប់ដំណាក់កាលបន្ទាប់ គឺពាក់ព័ន្ធទៅនឹងការកាត់ផ្ដាច់រាល់រចនាសម្ព័ន្ធអាណានិគមផ្សេងៗទៀតលើវិស័យសេដ្ឋកិច្ចជាតិដែលទាមទារឱ្យយើងសិក្សាលើទ្រឹស្ដីជាបទពិសោធន៍បន្ថែមទៀតបានត្រឹមត្រូវ។ ទន្ទឹមនឹងនេះដែរ ចំពោះមធ្យោបាយនៃការជ្រើសរើសរាល់មូលដ្ឋានទស្សនទានរបស់គោលនយោបាយសេដ្ឋកិច្ច ចាំបាច់យើងគប្បីផ្សារភ្ជាប់ជាមួយនឹងស្នាដៃ ឬបទពិសោធន៍សេដ្ឋកិច្ចឱ្យបានប្រាកដប្រជា ដោយពិចារណាទៅលើសារៈសំខាន់នៃសមិទ្ធផលរបស់វាសម្រាប់គោលដៅរយៈពេលវែង ក៏ដូចជាសម្រាប់ដំណោះស្រាយលើបញ្ហាជាច្រើនដែលតែងតែកើតមានឡើងជាប្រចាំក្នុងលក្ខខណ្ឌដែលស្ថានភាពនយោបាយខាងក្នុងនិងខាងក្រៅប្រទេសមានការផ្លាស់ប្ដូរ។

នៅក្នុងដំណាក់ដំបូងនៃដំណើរការឧស្សាហូបនីយកម្មនៅកម្ពុជា (នៅពាក់កណ្ដាលទសវត្សរ៍ទី៥០រហូតដល់ចុងទសវត្សរ៍ទី៦០) យើងពិចារណាឃើញថា មុខងារនៃការនាំចូលបានក្លាយជាគោលដៅរួម ទាំងការការពារឧស្សាហកម្មវ័យក្មេង ទាំងគោលនយោបាយនាំចូលរបស់ប្រទេស។ ម្យ៉ាងទៀត តួនាទីគយ និងរដ្ឋាករក្នុងវិស័យនេះមានឥទ្ធិពលចំពោះតម្លៃទំនិញចូល និងជារបាំងការពារទីផ្សារជាតិដែលមានឥទ្ធិពលដល់ការសន្សំមូល-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធន និងដល់ចង្វាក់អភិវឌ្ឍន៍ និងដាក់កំហិតលើអត្រាប្រាក់ចំណេញរបស់វិស័យសេដ្ឋកិច្ច ក៏ដូចជាអ្នកកំណត់ភាពខុសគ្នាក្នុងលក្ខខណ្ឌផលិតកម្មទាំងក្នុងស្រុក និងអន្តរជាតិផងដែរ។

ការពង្រឹងតួនាទីរបស់រដ្ឋក្នុងទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាបាននាំមកនូវប្រាក់ចំណូលថវិកាជាតិជាលក្ខណៈផលគុណ ប៉ុន្តែក៏បង្កឱ្យមានភាពស្មុគស្មាញកាន់តែខ្លាំងចំពោះឧបករណ៍នៃការត្រួតពិនិត្យលើការបំពេញសំណុំបែបបទលើនីតិវិធីជាច្រើនផងដែរ។ ដោយឡែក ភាពចាំបាច់នៃយន្តការសេដ្ឋកិច្ចក្នុងការប្រើប្រាស់រូបិយប័ណ្ណបរទេស ក៏ដូចជាតួនាទីរបស់វាដែលមានមុខងារក្នុងការសម្របសម្រួលការនាំចូលទំនិញសម្រាប់ការកសាងឧស្សាហកម្មជាតិ អាចធ្វើឱ្យមានផលប៉ះពាល់ចំពោះគោលនយោបាយនាំចូល។ យ៉ាងណាមិញ ដូចដែលអ្នកស្រាវជ្រាវរបស់ភូមាដ៏ល្បីល្បាញម្នាក់ឈ្មោះ H. Myint បានលើកឡើងថា មានទិសដៅជាមូលដ្ឋានចំនួនពីរ(មានហេតុផលសំខាន់ពីរយ៉ាង)ដែលធ្វើឱ្យប្រសើរឡើងដល់ដំណើរការសេដ្ឋកិច្ចក្រៅប្រទេសរបស់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ដូចខាងក្រោមនេះ ៖

១. ត្រូវបំពេញមុខងារនាំចូល សម្រាប់បម្រើឱ្យឧស្សាហូបនីយកម្ម (អភិវឌ្ឍន៍វិស័យឧស្សាហកម្មកែច្នៃ)តាមរយៈការដាក់កំហិតព្រំដែនលើការកែលម្អភាពស្មុគស្មាញរបស់យន្តការទីផ្សារ ដោយប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុ(រូបិយប័ណ្ណ)តាមរយៈការពង្រីកការនាំចេញវត្ថុធាតុដើមរបស់ខ្លួន។

២. អភិវឌ្ឍវិស័យឧស្សាហូបនីយកម្ម តាមរយៈការលើកកម្ពស់ការត្រួតពិនិត្យពីរដ្ឋដោយផ្ទាល់ នៅក្នុងដំណោះស្រាយជាជំហានៗនូវគ្រប់ទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស។

ចំពោះលក្ខណៈសម្បត្តិនៃទស្សនទានខាងលើនេះ មានអត្ថន័យផ្សេងៗគ្នាត្រង់ថា ៖


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ទី១ ៖ អាស្រ័យដោយការជ្រើសរើសម៉ូឌែលមួយណា( ការបោះឆ្នោតយកមួយណា)ដែលយើងចង់បាន។

- ទី២ ៖ អាចត្រលប់ទៅរកយន្តការគ្រប់គ្រងសេដ្ឋកិច្ចបែបរដ្ឋបាលដែលបំពេញបន្ថែមទៅលើដំណើរការបែបប្រពៃណី លើការងារគយ និងរដ្ឋាករ។

ការអនុវត្តបែបនេះ យើងពិនិត្យឃើញថា អាចអនុញ្ញាតឱ្យឧស្សាហកម្មដ៏ក្មេងខ្ចី មានឱកាសចូលរួមបានយ៉ាងទូលំទូលាយក្នុងការបែងចែកពលកម្មអន្តរជាតិ។

## ២.៣.១ ការកំណត់គោលនយោបាយអត្រាពន្ធចម្រុះ

ចំពោះឧបករណ៍ដែលប្រទេសកម្ពុជានិយមប្រើប្រាស់ក្នុងការការពារវិស័យឧស្សាហកម្មដ៏ក្មេងខ្ចីរបស់ខ្លួននាពេលកន្លងមក គឺបានទាក់ទងទៅនឹងវិស័យពន្ធគយ និងរដ្ឋាករដែលបានអនុវត្តដោយកំណត់ជាអត្រាពន្ធគយគិតជាភាគរយធៀបនឹងអត្រាតម្លៃនាំចូល។ ជាងនេះទៀត រចនាសម្ព័ន្ធនៃការការពារឧស្សាហកម្មមានទ្រង់ទ្រាយទៅតាមវិស័យផ្សេងៗគ្នាដែលត្រូវបានជ្រើសរើស ឬកំណត់ដោយរដ្ឋ និងមានការពាក់ព័ន្ធទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ រីឯវិធានការនៃការការពារទាំងនោះដំណើរការឡើងដើម្បីទ្រទ្រង់លើគ្រប់វិស័យដែលបានកំណត់រួច សម្រាប់ការស្ថាបនាផែនការសេដ្ឋកិច្ចជាតិ ពោលគឺដើម្បីបង្កើតលក្ខខណ្ឌប្រកបសម្រាប់សេដ្ឋកិច្ច និងធ្វើយ៉ាងណាឱ្យវិនិយោគិនមានជំនឿជឿជាក់ និងមានការធានាចំពោះពួកគេដែលបានទាមទារ សម្រាប់ជាបច្ច័យក្នុងការអនុម័តលើសេចក្ដីសម្រេចស្ដីពីការវិនិយោគ។ ដូច្នេះហើយ ប្រទេសកម្ពុជាបានធ្វើការការពារជាបឋមលើផលិតកម្មវិស័យស្បៀងអាហារ ផលិតកម្មជី វាយនភណ្ឌ ផលិតផលកញ្ចក់ ព្រមទាំងឧស្សាហកម្មម៉ាស៊ីនអារឈើ។ ទំនិញដែលបានលើកឡើងខាងលើនេះជាប្រភេទទំនិញដែលស្ថិតក្នុងវិស័យជាអាទិភាព ហើយត្រូវ

បានចាត់បញ្ចូលក្នុងការលើកលែងពន្ធនាំចូល ហើយទំនិញមួយចំនួនទទួលបានការអនុគ្រោះជាច្រើន។ ចំពោះអត្រាពន្ធគយនៅកម្ពុជាសម័យនោះមានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង និងបានឈរលើលក្ខណៈវិនិច្ឆ័យ៣យ៉ាងដូចខាងក្រោមនេះ៖

- ទី១ ៖ សម្រាប់ទំនិញនាំចូលពីប្រទេសមូលធននិយមដែលមិនទទួលស្គាល់រដ្ឋកម្ពុជា ហេតុដូច្នេះ ទំនិញប្រភេទនេះត្រូវបានកំណត់អត្រាពន្ធគយជាអតិបរមា។

- ទី២ ៖ សម្រាប់ទំនិញដែលនាំចូលពីបណ្តាប្រទេសសង្គមនិយម និងមានទំនាក់ទំនងល្អជាមួយគ្នាត្រូវបានកំណត់អត្រាពន្ធគយជាអប្បបរមា។

- ទី៣៖ សម្រាប់ប្រភេទទំនិញដែលបាននាំចូលក្នុងប្រទេសកម្ពុជាពុំមែនក្នុងបំណងធ្វើពាណិជ្ជកម្ម( សម្រាប់ការប្រើប្រាស់ជាលក្ខណៈបុគ្គល) ក៏ត្រូវបានកំណត់អត្រាពន្ធគយដូចគ្នាទៅនឹងប្រភេទទី២ដែរ ពោលគឺអប្បបរមា។

ក្នុងបញ្ហានេះដែរ ដោយសារតែវិស័យកសិកម្មនៅកម្ពុជាក្លាយជាវិស័យដែលមានគោលដៅជាអាទិភាពក្នុងគោលនយោបាយសេដ្ឋកិច្ច ហេតុនេះ ទំនិញជាមធ្យោបាយ ឬជាបរិក្ខារផលិតកម្ម ឬក៏ជាវត្ថុធាតុដើមចាំបាច់សម្រាប់ប្រើប្រាស់ក្នុងវិស័យនេះ ត្រូវបានកំណត់អត្រាពន្ធនាំចូលទាបជាងគេបង្អស់ គឺប្រមាណពី៣%ទៅ៨% ហើយចំពោះទំនិញខ្លះទៀតបានកំណត់យកតែ១%ទៅ៥%តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ សម្រាប់ទំនិញដែលប្រើប្រាស់សម្រាប់វិស័យឧស្សាហកម្មផលិតកម្មជាគ្រឿងសំណង់ មធ្យោបាយដឹកជញ្ជូនទំនិញក្នុងវិស័យសុខាភិបាល បរិក្ខារអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកទេស និងផ្សេងៗទៀតត្រូវបានកំណត់អត្រាពន្ធគយក្នុងចន្លោះពី៥%រហូតដល់១៥%។ ជាងនេះទៅទៀត ចំពោះមុខទំនិញចាំបាច់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃដែលមានកង្វះខាតក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការទីផ្សារក្នុងស្រុក ( ទំនិញលក់ដាច់ខ្លាំង) ត្រូវបានកំណត់ពន្ធនាំចូលក្នុងចន្លោះពី១៥%ទៅ

៣០%។ ដោយឡែកចំពោះការនាំចូលទំនិញប្រណីតៗ និងមានគុណភាព ដូចជារថយន្ត ទោចក្រយានយន្ត គ្រឿងអេឡិចត្រូនិច ស្រាទំពាំងបាយជូ បារីល្អៗជាដើម គឺត្រូវបានកំណត់អត្រាពន្ធគយអប្បបរមាពី៣០%ទៅ ៨០% រីឯទំនិញខ្លះទៀតរហូតដល់១០០%។

សម្រាប់យុទ្ធសាស្ត្រទាក់ទាញមូលធនរបស់វិនិយោគិនបរទេសឱ្យចូលមកក្នុងស្រុក ការទាក់ទាញមធ្យោបាយផលិតកម្ម វត្ថុធាតុដើម និងគ្រឿងសម្ភារចាំបាច់ សម្រាប់ការសាងសង់រោងចក្រសហគ្រាសសហកម្ម-សិទ្ធិដែលជាកម្មសិទ្ធិរបស់វិនិយោគិនបរទេសនានា យើងពិនិត្យឃើញថាជាទូទៅ មិនត្រូវបានជាប់ពន្ធគយនោះឡើយ។ ក៏ប៉ុន្តែ គោលនយោបាយគាំពារនិយម(ទំនិញក្នុងស្រុក) បើសិនជាចាប់ផ្តើមអនុវត្តភ្លាមៗ វាអាចប៉ះពាល់ដល់ខ្លឹមសារនៃការរីកលូតលាស់ដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលអាចកើតចេញពីហេតុផលថា ការអនុវត្តគោលនយោបាយលើកទឹក-ចិត្តជាប្រព័ន្ធសម្រាប់ការនាំចូលអាចធ្វើឱ្យមានការធ្លាក់ចុះដល់សមត្ថភាពប្រកួតប្រជែងជាមួយនឹងទីផ្សារខាងក្រៅ(តម្លៃទំនិញម្ចាស់ស្រុកមានតម្លៃថ្លៃជាងទំនិញវិនិយោគិនបរទេសដែលផលិតនៅកម្ពុជា) ទីបំផុត បានធ្វើឱ្យចុះថយនូវការនាំចេញសរុប។

ក្នុងលក្ខខណ្ឌនៃការប្រកួតប្រជែងផ្តាច់មុខចំពោះការនាំចូលវិញ បើយើងប្រើប្រាស់តែវិធានការប្រមូលពន្ធគយក្នុងអត្រាខ្ពស់យ៉ាងណាក៏ដោយ ក៏មិនអាចមានលទ្ធភាពគ្រប់គ្រង ឬទប់ស្កាត់ការហូរចូលទំនិញដែលមានការប្រកួតប្រជែងខ្ពស់ពីបណ្តាប្រទេសអភិវឌ្ឍន៍ក្នុងនិន្នាការមូលធននិយម និងប្រទេសឧស្សាហកម្មថ្មីៗមកក្នុងទីផ្សារប្រទេសកម្ពុជាតាមច្រករបៀងផ្សេងៗបានទេ។ ឧបករណ៍ចាស់ៗនៃនយោបាយគាំពារបែបនេះត្រូវបានថែរក្សានៅក្នុងប្រទេសកម្ពុជា តែក្នុងបំណងប្រមូលពន្ធ និងសម្រាប់ការលើកទឹកចិត្តប្រព័ន្ធពន្ធដារដែលមិនទាន់មានសុក្រឹតភាពក្នុងការងារពន្ធដារ ក៏ដូចជាធ្វើឡើងដើម្បីការបែងចែកលម្អិតលើប្រាក់ចំណូល រវាង

វិស័យសេដ្ឋកិច្ចនានាដែលបម្រើផលប្រយោជន៍ចំពោះវិស័យទាំងឡាយណាដែលចាត់ទុកថា ជាវិស័យអាទិភាពតែប៉ុណ្ណោះ។

បើពិនិត្យមើលទៅលើបទពិសោធន៍ពិភពលោកបង្ហាញថា នៅក្នុងបណ្តាប្រទេសមូលធននិយមដែលមានសេដ្ឋកិច្ចលូតលាស់ ឬកំពុងលូតលាស់ យើងសង្កេតឃើញថា វិធានការសំខាន់ៗនៃគោលនយោបាយគាំពារនិយមត្រូវបានគេប្រើប្រាស់តាមរយៈវិធីសាស្ត្រផ្សេងៗជាច្រើនទៀតដែលហៅថា វិធីសាស្ត្រពុំមែនអត្រាបាំងពន្ធគយដែលវិធានការនេះបានគ្រសោបយកវិសាលភាពការងារធំធេងទាក់ទងនឹងកិច្ចការរដ្ឋបាល ការចំណាយហិរញ្ញវត្ថុ ការកំណត់គោលនយោបាយពាណិជ្ជកម្ម និងផ្សេងៗទៀតដែលវិធានការទាំងនេះបានបង្កការលំបាកក្នុងការនាំចូលទំនិញទៅក្នុងប្រទេសរបស់គេ។ ចំណាត់ប្រភេទនៃវិធានការទាំងនោះសង្ខេបត្រឹមអត្ថន័យវាក្យស័ព្ទមួយគឺ «ការកំហិតមិនពាក់ព័ន្ធអត្រាពន្ធ»ដែលមានចំនួន៥វិធានការសំខាន់ៗសម្រាប់ប្រតិបត្តិការលើវិស័យពាណិជ្ជកម្មក្រៅប្រទេសរបស់រដ្ឋ និងមានខ្លឹមសារដូចខាងក្រោមនេះ ៖

- ទី១ ៖ រដ្ឋត្រូវឧបត្ថម្ភធនក្នុងវិស័យផលិតកម្ម និងវិស័យនាំចេញទំនិញ ឬឧបត្ថម្ភប្រព័ន្ធការប្រមូលទិញទំនិញ និងការធ្វើពាណិជ្ជកម្មរបស់រដ្ឋជាមួយប្រទេសដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចទីផ្សារ។

- ទី២ ៖ រៀបចំលិខិតបទដ្ឋានពន្ធគយសម្រាប់ការនាំចូល និងបែបបទរដ្ឋបាលឱ្យបានច្បាស់លាស់( ដូចជាវិធានការរដ្ឋបាលមិនមែនគយ វិធីសាស្ត្រវាយតម្លៃចំពោះថ្លៃបង់ពន្ធនាំចូលរបស់ទំនិញ លិខិតបទដ្ឋានគយ និងស្លាកកុងស៊ុល ឯកសារបញ្ជូនទំនិញ និងចំណាត់ថ្នាក់ទំនិញជាដើម)។

- ទី៣ ៖ ការបញ្ជាក់អំពីស្តង់ដារ និងលក្ខខណ្ឌនៃការទាមទារផ្សេងៗដែលពាក់ព័ន្ធទៅនឹងផ្នែកសុខាភិបាល និងនិយាមអនាម័យរបស់ទំនិញ ស្តង់ដារបច្ចេកទេស និងសុវត្ថិភាពទំនិញឧស្សាហកម្ម ការទាមទារលើការវេចខ្ចប់ល្អ និងបិទម៉ាកទំនិញ កាលបរិច្ឆេទផលិតផល និងសុពលភាព


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់ការប្រើប្រាស់ជាដើម។

- ទី៤ ៖ ការកំហិតលើបរិមាណចំពោះការនាំចូល ឬនាំចេញរូបិយ-ប័ណ្ណ។

- ទី៥ ៖ ការដាក់កំហិតក្នុងយន្តការតម្កល់បង់ប្រាក់ពន្ធគយដូចជាការតម្កល់ប្រាក់ក្នុងធនាគារ ការប្រមូលពន្ធគយដល់ទីកន្លែង និងការកាត់បន្ថយរបៀបរបបបង់ពន្ធជាដើម។

សរុបមក វិធានការនៃការចូលរួមរបស់រដ្ឋក្នុងគោលនយោបាយគាំពារនិយមដែលពាក់ព័ន្ធទៅនឹងការកំណត់អត្រាពន្ធគយ បានបង្កប់ទៅដោយទ្រង់ទ្រាយជាឧបករណ៍នយោបាយពាណិជ្ជកម្មផង និងជាឧបករណ៍គោល-នយោបាយសេដ្ឋកិច្ចក្នុងប្រទេសផងដែរ។ ក៏ប៉ុន្តែ បើយើងពិនិត្យមើលទៅលើរូបភាពខាងក្រៅនៃវិធានការខាងលើនេះ ទីបំផុតគឺហាក់ដូចជាបានគាំពារទំនិញក្នុងស្រុក(តាមរយៈការបង្កើតបញ្ហាស្មុគស្មាញចំពោះទំនិញនាំចូល)ដែលនាំឱ្យកើតមានតម្រូវការខ្ពស់លើទំនិញផលិតក្នុងស្រុក។ ជាងនេះទៅទៀត វិធីសាស្ត្រខាងលើនេះក្លាយជាជាតុផ្សំនៅក្នុងឧបករណ៍អន្ត-រាគមន៍របស់រដ្ឋក្នុងវិស័យសេដ្ឋកិច្ច។ ប៉ុន្តែ ការដាក់កំហិតយ៉ាងច្រើនសន្ធឹកសន្ធាប់បែបនេះចំពោះបែបបទនៃការនាំចូលទំនិញ វាក៏អាចក្លាយជាវិធានការដ៏តឹងរឹងបំផុតនៃរបាំងមិនមែនពន្ធគយផងដែរដែលអាចដោះស្រាយបានសមស្របក្នុងការនាំចូលទំនិញសម្រាប់ទីផ្សារក្នុងស្រុក ក៏ដូចជាអាចឱ្យយើងកំណត់បានយ៉ាងតឹងរឹងលើបរិមាណនាំចូល(កំណត់កូតានាំចូល) ព្រមទាំងអាចឈានទៅរកដំណោះស្រាយនៃអំណាចពាណិជ្ជកម្មក្រៅប្រទេស(ការកំណត់អាជ្ញាប័ណ្ណនាំចូល)ទៀតផង។ យន្តការខាងលើនេះបានបើកទូលាយដល់លទ្ធភាពនៃការត្រួតពិនិត្យខាងរដ្ឋបាលយ៉ាងសកម្មទៅលើដំណើរការនាំចូលទំនិញ និងទៅលើដំណើរការជ្រើសរើសដៃគូនាំចូលដែលអាចទទួលយកបានទៀតផង។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៣.២ ការបង្កើតរបាំងសេដ្ឋកិច្ច និងនយោបាយគាំពារ

នៅប្រទេសកម្ពុជាយើងនាសម័យកាលនោះ ការកំណត់ចំនួនកូតានាំចូលទំនិញ និងការកំណត់អាជ្ញាប័ណ្ណនាំចូល បានក្លាយជាមធ្យោបាយដ៏ចាំបាច់បំផុត សម្រាប់ការសម្របសម្រួលការនាំចូលដែលជាគោលដៅសេដ្ឋកិច្ចជាមួយនឹងការប្រើប្រាស់រូបិយប័ណ្ណបរទេសផង និងក្នុងគោល-បំណងការពារវិស័យសេដ្ឋកិច្ចដ៏ក្មេងខ្ចីរបស់វិស័យឧស្សាហកម្មជាតិផង។ ទម្រង់នៃការដាក់កំហិតសេដ្ឋកិច្ចត្រូវបានប្រើប្រាស់សម្រាប់ជារបាំងការពារទៅលើវិស័យសេដ្ឋកិច្ចដែលទន់ខ្សោយរបស់ខ្លួន និងធ្វើឱ្យមានស្ថិរភាពនីយកម្មនៃតុល្យភាពវិស័យពាណិជ្ជកម្ម។ ហេតុនេះនៅប្រទេសកម្ពុជាអាជ្ញាប័ណ្ណនាំចូលត្រូវបានផ្តល់ដោយនាយកដ្ឋានទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃក្រសួងពាណិជ្ជកម្ម ហើយមានសុពលភាពចំនួន២ខែប៉ុណ្ណោះ។

វិធីសាស្ត្រផ្សេងៗទៀតដែលគេនិយមប្រើប្រាស់ច្រើនណាស់ដែរជុំវិញគោលនយោបាយគាំពារនិយម សំដៅលើការបង្កើតនូវរបបគ្រប់គ្រងពន្ធគយ និងរដ្ឋាករនៅតាមបណ្តាច្រករបៀងជាប់ព្រំដែនដែលអនុវត្តលើការបង់ពន្ធការនាំចូលទំនិញនៅនឹងប៉ុស្តិ៍ក្នុងការិយាល័យជម្រះបញ្ជីគយតែម្តង។ របាំងបែបនេះមានលក្ខណៈទិសដៅជាការប្រមូលពន្ធគយសុទ្ធសាធ ព្រោះថា បានប្រតិបត្តិក្នុងការប្រមូលពន្ធទូទៅចំពោះទំនិញពីអ្នកជំនួញដោយមិនរើសមុខ។

បទពិសោធន៍ផ្សេងៗទៀតនៃរបាំងពន្ធដែលមានឥរិយាបថបែបហិ-រញ្ញវត្ថុនិយម សំដៅលើការតម្លើងថ្លៃទំនិញនាំចូល(តាមរយៈការតម្លើងអត្រាពន្ធ) ឬបន្ទាបអត្រាប្តូរប្រាក់រូបិយវត្ថុជាតិ ជាប្រាក់រៀល ដែលតែងតែអនុវត្តនៅប្រទេសកម្ពុជា។ នៅរយៈពេលចុងក្រោយ គោលនយោបាយនេះបានប្រើប្រាស់សម្រាប់ធ្វើឱ្យមានស្ថិរភាព និងតុល្យភាពចំណាយទៅរកការកំហិតការនាំចូលទំនិញ។ លទ្ធផលជាអតិបរមានៃការបន្ទាបតម្លៃអត្រាប្តូរប្រាក់រូបិយប័ណ្ណជាតិ(លុយរៀលឡើងថ្លៃ)បានធ្វើឱ្យមានភាពយឺតលើ

កំណើនតម្លៃទំនិញក្នុងប្រទេស ហើយដោយមិនខ្វល់ពីបម្រែបម្រួលតម្លៃសមាមាត្រជាមួយរូបិយប័ណ្ណបរទេសធ្វើបែបនេះបានផ្តល់លទ្ធភាពបញ្ចុះតម្លៃនាំចូលទំនិញ និងតម្លើងថ្លៃនាំចេញ។ ប៉ុន្តែ ការអនុវត្តបែបនេះអាចប្រើប្រាស់បានតែក្នុងថិរវេលាខ្លីៗជាមធ្យមគឺមួយ ឬពីរខែតែប៉ុណ្ណោះ។ បទពិសោធន៍ដ៏មានប្រសិទ្ធភាពក្នុងការដាក់កំហិតរបាំងនាំចូលទំនិញត្រូវបានគេប្រតិបត្តិជាច្រើនផងដែរពាក់ព័ន្ធនឹងកិច្ចដំណើរការបញ្ជិការនៃស្ថានកុងស៊ុល(នីត្យានុកូលភាព) និងការវាយតម្លៃរបស់រដ្ឋបាលគយ និងរដ្ឋាករ។ ចំពោះគុណភាពរបស់ឧបករណ៍ការពារទីផ្សារក្នុងស្រុក និងការផ្តល់រង្វាន់លើកទឹកចិត្តចំពោះការអភិវឌ្ឍឧស្សាហកម្មជាតិ ត្រូវបានគេប្រើប្រាស់វិធីសាស្ត្រតាមរយៈការរួមចំណែករបស់រដ្ឋក្នុងការជាវទំនិញផលិតក្នុងស្រុកយ៉ាងសកម្មផងដែរ។ ប្រភេទផ្សេងៗទៀតនៃរបាំងពន្ធ រួមមានការដាក់កំហិតលើរូបិយប័ណ្ណ ការបង្កកប្រាក់ចំណូល ការកក់ប្រាក់សម្រាប់ការនាំចូល ការជំរុញការនាំចេញ និងផ្តល់ឱកាសជាប្រាក់កម្ចីឥណទានចំពោះក្រុមហ៊ុនក្នុងស្រុក(ក្នុងលក្ខខណ្ឌអត្រាការប្រាក់អនុគ្រោះ) ការដាក់កំហិតបច្ចេកទេសជាដើម-ល-ដែលគោលនយោបាយគាំពារបែបនេះមិនបានអនុវត្តក្នុងប្រទេសកម្ពុជានៅឡើយទេ។

នៅសម័យកាលនោះដែរ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានខិតខំបំពេញការងារយ៉ាងសស្រាក់សស្រាំចំពោះការដោះស្រាយកិច្ចការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់ខ្លួនដែលក្នុងដំណើរការនេះតែងតែពើបប្រទះបញ្ហាដែលជារឿងស្មុគស្មាញយ៉ាងច្រើនលើការកំណត់គោលនយោបាយចំពោះវិស័យនាំចូលដែលជាការចាំបាច់ យើងត្រូវពិចារណាទៅលើកត្តាមួយចំនួនដូចខាងក្រោមនេះ ៖

- ទី១ ៖ ត្រូវដំណើរការឱ្យបានសមស្របទៅតាមធនធានដែលមាន និងសម្របតាមសេចក្តីត្រូវការទំនិញ មានន័យថា គប្បីផ្គត់ផ្គង់ទំនិញនាំចូលឱ្យបានប្រសើរបំផុត ប៉ុន្តែមិនត្រូវមានលក្ខណៈខ្ជះខ្ជាយ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ទី២ ៖ ត្រូវធ្វើចំណាត់ថ្នាក់ទំនិញនាំចូលតាមកម្រិតនៃភាពចាំបាច់ស្របតាមធនធានដែលយើងមាន។

បើពិនិត្យទៅលើកម្រិតនៃភាពចាំបាច់របស់ការនាំចូលទំនិញ យើងអាចបែងចែកទៅតាមចំណាត់ប្រភេទផ្សេងៗគ្នាដូចខាងក្រោមនេះ ៖

- ទី១ ៖ ការនាំចូលទំនិញ សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទូទៅ។

- ទី២ ៖ ការនាំចូលវត្ថុធាតុដើម ប្រេងឥន្ធនៈ ទំនិញពាក់កណ្តាលផលិតសម្រេច និងសារធាតុគីមី សម្រាប់អភិវឌ្ឍន៍វិស័យឧស្សាហកម្មមូលដ្ឋាន។

- ទី៣ ៖ ការនាំចូលគ្រឿងយន្ត និងគ្រឿងបរិក្ខារផលិតកម្មជាលក្ខណៈវិនិយោគមូលធន។

- ទី៤ ៖ ការនាំចូលផលិតផលឧស្សាហកម្មគ្រប់ប្រភេទ សម្រាប់ការប្រើប្រាស់ទូទៅ។

គួរបញ្ជាក់ដែរថា ដើម្បីលើកកម្ពស់ចង្វាក់អភិវឌ្ឍន៍សេដ្ឋកិច្ច យើងពិនិត្យឃើញថា យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតនោះបានស្តែងឡើងតាមរយៈការពង្រីកការនាំចូលគ្រឿងម៉ាស៊ីន និងសម្ភារផលិតកម្មជាច្រើនទៀតដែលចាំបាច់សម្រាប់ការវិនិយោគមូលធន។ ក៏ប៉ុន្តែ រចនាសម្ព័ន្ធទំនិញនាំចូលរបស់កម្ពុជានាសម័យនោះ មានឥរិយាបថផ្ទុយគ្នាពីទ្រឹស្តីខាងលើនេះ។ ដូចជានៅឆ្នាំ១៩៨៨ ទំហំចំណែកមធ្យោបាយផលិតកម្មមានប្រមាណតែ៦,៦១%ប៉ុណ្ណោះ រីឯទំហំទំនិញប្រើប្រាស់ទូទៅវិញ បានគ្របដណ្តប់ដល់ទៅ៩៣,៣៨%នៃចំនួនទំនិញនាំចូលសរុប សម្រាប់អាជីវកម្មនៃស្ថាប័នពាណិជ្ជកម្មក្រៅប្រទេសរបស់រដ្ឋ។ ក្នុងលក្ខខណ្ឌនេះ រចនាសម្ព័ន្ធ និងកំណើនការនាំចូលត្រូវតែកែលម្អឡើងវិញ ព្រោះថា កិច្ចការទាំងនេះបានដើរតួនាទីយ៉ាងសំខាន់បំផុត ចំពោះយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។ ហេតុដូចនេះ ការដែលយើងចេះធ្វើការតាក់តែងផែនការនាំចូលឱ្យបាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រឹមត្រូវ ឬឈ្លាសវៃ វាអាចក្លាយជាកត្តាកំណត់មួយ សម្រាប់ការស្ដារមូលដ្ឋានសេដ្ឋកិច្ចជាតិដែលមានច្រើនវិស័យ និងមានភាពប្រទាក់គ្នា។

ក្រោមជំនួយពីបទពិសោធន៍នានាដែលយើងធ្លាប់បានអនុវត្តនាពេលកន្លងមក តាមរយៈគោលនយោបាយខាងលើនេះធ្វើឱ្យយើងអាចសម្រេចជោគជ័យទៅបានជាបន្តទៀតតាមរយៈការបំពេញផែនការការងារជាមូលដ្ឋានរួមមាន ផ្លាស់ប្ដូររចនាសម្ព័ន្ធនាំចូលឡើងវិញដោយងាកទៅរកការនាំចូលមធ្យោបាយផលិតកម្ម ក៏ដូចជានាំចូលទំនិញសម្រាប់ការវិនិយោគឱ្យមកបម្រើឱ្យវិស័យឧស្សាហកម្មផលិតកម្មមូលដ្ឋាន ទីបំផុតវិធានការទាំងនេះអាចក្លាយជាឧបករណ៍នៃការទាក់ទាញមូលធន ឬសម្រាប់ការបំពេញថវិការដ្ឋថែមទៀតផង។

ចំពោះធនធានរូបិយប័ណ្ណដែលមានកំណត់របស់ប្រទេស តម្រូវឱ្យប្រទេសកម្ពុជាយើងគប្បីបែងចែកយ៉ាងហ្មត់ចត់ និងឈ្លាសវៃបំផុតក្នុងប្រតិបត្តិការពាណិជ្ជកម្មក្រៅប្រទេស។ កន្លងមក រាល់ការចេញអាជ្ញាប័ណ្ណនាំចេញ និងការដាក់កំហិតកូតាពាណិជ្ជកម្មបានធ្វើឱ្យរដ្ឋាភិបាលបានទទួលចំណូលរូបិយប័ណ្ណយ៉ាងច្រើនផងដែរ។ ក៏ប៉ុន្តែ រដ្ឋាភិបាលមានចំណាប់អារម្មណ៍មិនត្រឹមតែទៅលើការសន្សំសំចៃការប្រើប្រាស់រូបិយប័ណ្ណប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចាប់អារម្មណ៍ផងដែរទៅលើការប្រើប្រាស់ធនធានទាំងនោះឱ្យបានចំទិសដៅថែមទៀត។ ម្យ៉ាងទៀត វិធីសាស្ត្រក្នុងការអនុវត្តជាទូទៅលើការសម្របសម្រួលការគ្រប់គ្រងរូបិយប័ណ្ណសំដៅលើការអនុវត្តគោលនយោបាយរូបិយប័ណ្ណចម្រុះ និងទន់ភ្លន់។

ឆ្លើយតបទៅនឹងគោលនយោបាយរូបិយប័ណ្ណបែបនេះ ការនាំចូលទំនិញត្រូវបានបែងចែកជាចំណាត់ប្រភេទទំនិញទៅតាមកម្រិតចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ បញ្ហាទាំងអស់នេះទាក់ទងនឹងការធ្វើចំណាត់ថ្នាក់របស់ទំនិញ( ក្រុមទំនិញ) និងកំណត់តម្លៃលក់រូបិយប័ណ្ណ (ប្ដូរជារូបិយប័ណ្ណ) សម្រាប់ឈ្មួញនាំចូលទៅតាមក្រុមទំនិញ។ បើតាម


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រឹត្យក្រមរូបិយប័ណ្ណសម្រាប់យកទៅទិញទំនិញនាំចូលដែលចាំបាច់សម្រាប់តម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច(ដូចជាមធ្យោបាយផលិតកម្មក្នុងវិស័យកសិកម្មជាដើម...) ទំនិញសម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋទូទៅ(ដូចជាសម្លៀកបំពាក់ ថ្នាំពេទ្យ...) ត្រូវបានលក់ដូរក្នុងអត្រាតម្លៃច្បាស់លាស់(តម្លៃរឹង) ឬក៏បន្ថែមតម្លៃពីលើនេះបន្តិចបន្តួចតែប៉ុណ្ណោះដែលកំណត់ដោយធនាគារកណ្តាល។ ប៉ុន្តែ រូបិយប័ណ្ណដែលប្តូរយកទៅទិញទំនិញនាំចូលប្រភេទផ្សេងៗទៀត(ដូចជាទំនិញប្រណីត ទំនិញលក់ដាច់រហ័សសម្រាប់អ្នកមានជីវភាពខ្ពស់ជាដើម) គឺតម្លៃប្តូររូបិយប័ណ្ណត្រូវតែកំណត់ក្នុងអត្រាអតិបរមា(ប្រាក់រៀលថោក) និងមានការបត់បែនទៅតាមនិន្នាការទីផ្សាររហូតដល់តម្លៃដូចគ្នានឹងតម្លៃដោះដូរក្នុងទីផ្សារសេរី។

ការប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណជាច្រើនសណ្ឋានដូចខាងលើនេះធ្លាប់បានដំណើរការឡើងនៅសម័យកាលចុងទសវត្សរ៍ទី៨០ក្នុងប្រទេសកម្ពុជាដែលគោលនយោបាយរូបិយប័ណ្ណបែបនេះអនុញ្ញាតឱ្យប្រទេសកម្ពុជាយើងសម្រេចបាននូវស្ថិរភាពសេដ្ឋកិច្ចជាកំណត់មួយចំពោះប្រភេទមុខទំនិញនាំចូលចាំបាច់ សម្រាប់ទីផ្សារក្នុងស្រុក។ ហេតុដូចនេះ ទំនិញជាតម្រូវការទីមួយសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបាននាំចូលក្នុងតម្លៃអនុគ្រោះដែលធ្វើឱ្យតម្លៃលក់លើទីផ្សាររបស់រដ្ឋមានតម្លៃថោក ដោយសារតែសហគ្រាសរដ្ឋដែលនាំចូលទំនិញ(ដែលភាគច្រើននាំមកពីបណ្តាប្រទេសសង្គមនិយម)បានចំណាយប្រាក់តិចលើការដោះដូររូបិយប័ណ្ណ(ព្រោះអត្រាប្តូរប្រាក់ពីប្រាក់រៀលទៅជារូបយប័ណ្ណរូប្ល(រូបិយប័ណ្ណសូវៀត) គឺមានតម្លៃសមាមាត្រទាបជាងតម្លៃទីផ្សារ) ប៉ុន្តែសម្រាប់ប្រភេទទំនិញទាំងឡាយណាដែលបាននាំចូលពីប្លុកផ្សេងៗទៀត អត្រាប្តូរប្រាក់មានតម្លៃខ្ពស់។ ដោយហេតុនេះហើយបានជានៅសម័យនោះ សហគ្រាសនាំចូលរបស់រដ្ឋជាច្រើនបានអនុវត្តដោយបំពានទៅលើតួនាទីរបស់ខ្លួន និងយន្តការនាំចូល ដើម្បីបម្រើឱ្យផលប្រយោជន៍បុគ្គល ពីព្រោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយសារតែទំនិញរបស់រដ្ឋអាចលក់បានថោកជាងតម្លៃទីផ្សារសេរី និងមានតម្រូវការខ្ពស់(ផ្គត់ផ្គង់មិនគ្រប់គ្រាន់) បានធ្វើឱ្យពួកគេព្យាយាមដំឡើងថ្លៃទំនិញចាំបាច់ទាំងនោះ ដើម្បីដកហូតយកប្រាក់ចំណេញពីរដ្ឋ ហើយទីបំផុតបាននាំមកនូវអស្ថិរភាពតម្លៃ និងបានធ្វើឱ្យគោលនយោបាយគាំពារនិយមទទួលបាននូវភាពបរាជ័យ និងនាំមកនូវបញ្ហាអតិផរណាយ៉ាងខ្លាំងក្លា។

ចំពោះលក្ខណៈដែលគួរឱ្យកត់សម្គាល់ផ្សេងៗទៀតនៃគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជាសម័យនោះ គឺជាប់ពាក់ព័ន្ធទៅនឹងការតម្រង់ទិសសេដ្ឋកិច្ចជាតិទៅរកការបង្កើតឱ្យមានផលិតផលថ្មីៗទៀត(ច្រើនមុខទំនិញ) និងមានទ្រង់ទ្រាយធំជាងនេះ។ ផ្អែកលើទស្សនៈបែបនេះ ប្រទេសកម្ពុជាបានខិតខំព្យាយាមបញ្ចប់ជាមួយនឹងវិស័យពាណិជ្ជកម្មដែលមានឯកទេសនីយកម្មចង្អៀតដែលនាំចេញទំនិញតែបី ឬបួនមុខប៉ុណ្ណោះ ព្រោះតែភាពមិនឯករាជ្យពីទីផ្សារខាងក្រៅ។ ក្នុងលក្ខណៈដែលមានឯកទេសនីយកម្មដ៏តូចចង្អៀតបែបនេះបានធ្វើឱ្យប្រាក់ចំណូលដែលទទួលបានពីការនាំចេញទំនិញក្នុងស្រុក មានការប្រែប្រួលយ៉ាងខ្លាំង ព្រោះតែការបត់បែននៃទីផ្សារទំនិញនៅលើពិភពលោក ជាពិសេសផលិតផលកសិកម្ម។

ក្រៅពីនេះទៀត តាមបទពិសោធន៍របស់ប្រទេសអាស៊ីបូព៌ា និងអាស៊ីភាគអាគ្នេយ៍បានបង្ហាញថា ភាពជោគជ័យលើការអភិវឌ្ឍវិស័យឧស្សាហកម្មរបស់បណ្តាប្រទេសទាំងនោះអាចក្លាយជាគំរូដ៏ល្អ សម្រាប់ការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ និងគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់រដ្ឋាភិបាលនៃប្រទេសកម្ពុជា។ ការកែលម្អឡើងវិញត្រូវពិនិត្យលើការជំរុញយកចិត្តទុកដាក់ទៅរកការអភិវឌ្ឍផលិតកម្មក្នុងនិន្នាការសម្រាប់ការនាំចេញ(សម្រាប់តម្រង់ទិសនាំចេញ) និងទ្រឹស្តីកត្តាផលិតកម្មរបស់លោក Heckscher Ohlin ដែលបានបង្ហាញអំពីទិសដៅជាចក្ខុវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ហេតុនេះហើយ ចំពោះនិន្នាការដ៏ចាំបាច់មួយក្នុងចំណោមនិន្នាការផ្សេងៗទៀតនារយៈពេលចុងក្រោយនេះ សំដៅលើការបំពេញបន្ថែមទៅលើគោល-

នយោបាយពាណិជ្ជកម្មក្នុងក្របខ័ណ្ឌនៃនិន្នាការអភិវឌ្ឍជំនួសការនាំចូល និងគោលនយោបាយលើកទឹកចិត្តការនាំចេញ។

ហេតុនេះ នៅក្នុងគោលនយោបាយនាំចេញរបស់កម្ពុជា យើងពិនិត្យឃើញថា បានសិក្សាតែទៅលើបណ្តាកត្តាពាក់ព័ន្ធទាំងឡាយណាដែលបានពិចារណាទៅរកភាពជោគជ័យរបស់ខ្លួនតែក្នុងស្ថានភាពមួយដែលនៅមានកម្រិតទាបនៅឡើយ ចំពោះការធ្វើឱ្យមានស្ថិរភាពនីយកម្មផ្នែកតម្លៃ ពិសេសទៅទៀត សម្រាប់គោលនយោបាយរដ្ឋាភិបាល ហាក់ដូចជាបានយកចិត្តទុកដាក់ខ្ពស់បំផុតទៅលើតែការនាំចេញទំនិញកសិកម្មដែលបានចាត់ទុកថា ជាបញ្ហារួមរបស់ជាតិ និងអាចប៉ុនប្រសប់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ក៏ប៉ុន្តែគោលនយោបាយនាំចេញដែលល្អប្រសើរនោះ ពុំមែនផ្តើមចេញពីការចេះត្រួតពិនិត្យការងារ និងការចេះកែតម្រូវការនាំចេញប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តើមចេញពីការប្រើប្រាស់ការវិនិយោគមូលធន និងការធ្វើឱ្យមានផលិតកម្ម។ ដូចជាករណីចំពោះកម្មវិធីនាំចេញត្រូវបានរដ្ឋាភិបាលពិនិត្យមើល និងចាត់ទុកថា ជាធាតុផ្សំដ៏សំខាន់របស់កម្មវិធីស្តារឡើងវិញ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ប្រទេសតាំងពីឆ្នាំ១៩៨៦ដល់ឆ្នាំ១៩៩០។ ជាក់ស្តែងនៅក្នុងកម្មវិធីនេះត្រូវបានស្នើឡើងរហូតដល់ឆ្នាំ១៩៩០ដែលបានកំណត់អំពីសមាមាត្ររវាងផលិតកម្មទំនិញ និងការនាំចេញ ដូចជាករណីការផលិតជ័រកៅស៊ូរក្រែបជាដើម ពោលគឺបើផលិតជ័របាន៥០ពាន់តោន ត្រូវនាំចេញ៤០ពាន់តោន និងអាជីវកម្មព្រៃឈើ បើផលិតបាន៣០០ពាន់ម៉ែត្រត្រីគុណ ត្រូវនាំចេញប្រមាណ២៥០ពាន់ម៉ែត្រត្រីគុណ។

លើសពីនេះទៀត ក្នុងគោលបំណងពង្រីកការនាំចេញរបស់ខ្លួន ប្រទេសកម្ពុជាបានប្រមែប្រមូលវិធានការគ្រប់បែបយ៉ាងរួមមានវិធានការអនុគ្រោះពន្ធ ការឧបត្ថម្ភលើការនាំចេញ ការកំណត់ជាអាទិភាពអាជ្ញាប័ណ្ណសម្រាប់ការនាំចូលវត្ថុធាតុដើម ឬក៏វត្ថុពាក់កណ្តាលផលិតសម្រេច និងបរិក្ខារផលិតកម្ម ការប្រើប្រាស់យន្តការគោលនយោបាយរូបិយប័ណ្ណ ការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អនុគ្រោះចំពោះការវិនិយោគមូលធន ក៏ដូចជាការលើកទឹកចិត្តចំពោះវិធានការទាំងឡាយណាដែលទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវទីផ្សារជាដើម។

តាមការស្រាវជ្រាវបង្ហាញទៀតថា នៅសម័យនោះ ប្រទេសកម្ពុជាក៏បានយកចិត្តទុកដាក់ខ្ពស់ផងដែរទៅលើការបញ្ចុះតម្លៃអត្រាពន្ធនាំចេញស្របតាមលក្ខខណ្ឌដូចគ្នានឹងការនាំចូល( ឧទាហរណ៍ ៖ ការទូទាត់សំណងទៅលើការប្តូររូបិយប័ណ្ណជាប្រយោជន៍នៃការនាំចេញ ការអនុញ្ញាតឱ្យរក្សាប្រាក់ចំណូលពីការនាំចេញ ក្នុងដែសហគ្រាសនីហវ័ណរបស់រដ្ឋ ការធ្វើឱ្យមានស្ថិរភាពតម្លៃទំនិញទៅកាន់ទីផ្សារខាងក្រៅ និងផ្សេងៗទៀត) ពីព្រោះថា ការតម្លើងអត្រាពន្ធនាំចេញចំពោះទំនិញណាមួយ វាបណ្តាលឱ្យថយចុះប្រសិទ្ធភាពនាំចេញរបស់ទំនិញនោះ។ អាស្រ័យហេតុនេះ ក្នុងការតាក់តែងវិធាននៃការលើកទឹកចិត្តការនាំចេញធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ចុះចំណូលពន្ធគយដែលធ្លាប់ទទួលបានពីទំនិញជាប្រពៃណីរបស់ខ្លួន។ ដូច្នេះហើយ សម្រាប់រដ្ឋាភិបាលប្រសើរបំផុតនោះ ត្រូវតែពង្រីកឱ្យបាននូវទំហំប្រាក់ចំណូលរបស់ខ្លួនតាមរយៈការប្រមូលពន្ធសម្រាប់ថវិការដ្ឋ តែពុំមែនពង្រីកចំណូលរូបិយវត្ថុជាតិនោះទេ ហើយត្រូវប្តូរ និងទទួលជារូបិយប័ណ្ណបរទេស។

ទន្ទឹមនឹងនេះ ក្នុងដំណើរការនាំចេញ រដ្ឋាភិបាលបានកំណត់អត្រាពន្ធគយពី៥%ទៅ១០% និងអប្បបរមាប្រមាណពី៣%ទៅ៧%។ បើពិនិត្យលើបទដ្ឋានច្បាប់ស្តីពីការវិនិយោគបរទេសដែលបានអនុម័តដោយរដ្ឋសភានាឆ្នាំ១៩៨៩ បានកំណត់អំពីការអនុគ្រោះពន្ធយ៉ាងទូលំទូលាយទៅលើមាត្រាជាច្រើន។ ដូច្នេះ ការនាំចេញផលិតផលត្រូវបានទទួលការអនុគ្រោះចំពោះប្រភេទពន្ធប្រយោលទាំងអស់ ជាពិសេស ទៅលើប្រាក់ចំណូលពីផលិតផលនាំចេញដែលបានដំណើរការឡើងដោយសហគ្រាសទើបតែបង្កើតថ្មីៗ គឺពួកគេមានសិទ្ធិទទួលបានការអនុគ្រោះពន្ធជាច្រើន ឬ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក៏អាចរំដោះពន្ធទាំងស្រុងទៅលើប្រាក់ចំណេញក្នុងរយៈពេល២ឆ្នាំ ឬអាចបន្តបន្ថែម២ឆ្នាំទៀតក្នុងករណីចាំបាច់។ បើពិនិត្យមើលលើបទពិសោធន៍ជាញឹកញាប់ដើម្បីការពារកិច្ចការអាជីវកម្មរបស់សហគ្រាសរដ្ឋ គេអាចផ្តល់សិទ្ធិលើការប្រើប្រាស់ដោយស្វ័យភាពក្នុងការរក្សាទុកចំណែកខ្លះនៃរូបិយប័ណ្ណដែលគេទទួលបានពីការនាំចេញដែលវិធានការនេះបានក្លាយជាការជួយទ្រទ្រង់(ឧបត្ថម្ភធន)ចំពោះការនាំចេញ។ នៅប្រទេសកម្ពុជាសម័យនោះបានកំណត់ច្បាស់លាស់នូវអត្រាតម្លៃដោះដូរជាផ្លូវការនូវរូបិយវត្ថុជាតិដែលជាប្រាក់រៀល ជាមួយនឹងរូបិយប័ណ្ណបរទេសផ្សេងទៀត និងអាចដោះដូរតាមតម្លៃទីផ្សារសេរីផងដែរ។ ភាពខុសគ្នារវាងតម្លៃរដ្ឋជាមួយនឹងតម្លៃទីផ្សារសេរី អាចខុសគ្នាចន្លោះពី១០%ទៅ១៥%។ ក្រោយពីនោះ នៅចន្លោះឆ្នាំ១៩៨២-១៩៨៩ រដ្ឋាភិបាលដោយខ្លួនឯងបានកំណត់គោលនយោបាយប្រើប្រាស់រូបិយប័ណ្ណក្នុងអត្រាតម្លៃផ្សេងពីគ្នាដែលការទិញដូរដោយអ្នកនាំចេញត្រូវកំណត់ដោយអត្រាតម្លៃជាផ្លូវការមួយប្រភេទ រីឯការទិញដូរដោយអ្នកនាំចូលវិញត្រូវកំណត់ដោយអត្រាតម្លៃពិសេសជាផ្លូវការមួយផ្សេងទៀតអាស្រ័យដោយប្រភេទទំនិញនាំចូល។ សរុបមក សហគ្រាសនាំចូលរបស់រដ្ឋបានទទួលផលចំណេញច្រើន តែក្នុងទំហំភាគផលដែលបានកាន់កាប់រូបិយប័ណ្ណក្នុងដៃរបស់ខ្លួន រីឯទំហំរូបិយប័ណ្ណផ្សេងទៀតរបស់សហគ្រាសដែលនៅសល់ត្រូវបានកំណត់ក្នុងអត្រាតម្លៃខ្ពស់ដែលបម្រើប្រយោជន៍រដ្ឋាភិបាល។

ដើម្បីជាការលើកទឹកចិត្តដល់សហគ្រាសថ្មីៗនៅកម្ពុជាសម័យនោះ រដ្ឋាភិបាលបានអនុវត្តគោលនយោបាយបន្ទាបអត្រាពន្ធគយ ឬក៏រំដោះពន្ធទាំងស្រុង សម្រាប់ការនាំចូលទំនិញជាវត្ថុធាតុដើម គ្រឿងបរិក្ខារឧបទេសចាំបាច់ក្នុងការស្តារ និងការកែលម្អឡើងវិញលើវិស័យផលិតកម្មជាតិ។ វាអាចមានលក្ខណៈផ្សេងទៀតដែរ ដោយគ្រាន់តែអនុគ្រោះពន្ធក្នុងកម្រិតសមរម្យចំពោះការនាំចូលសារធាតុផ្សំរបស់ទំនិញក្នុងគោលនយោបាយ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ណាមួយដើម្បីក្រើនរំឭកសហគ្រាសនាំចេញឱ្យងាកទៅរកការប្រើប្រាស់ធនធានក្នុងស្រុកទាំងស្រុង។ ក្នុងនិន្នាការនេះដែរ សហគ្រាសនាំចេញត្រូវបានរដ្ឋាភិបាលលើកទឹកចិត្តដោយកំណត់ជូននូវការអនុគ្រោះចំពោះតម្លៃនៃការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវគមនាគមន៍អយស្ម័យយាន (រថភ្លើង) ប្រើប្រាស់ឡានកុងទីន័ររបស់រដ្ឋ សម្រាប់ការដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែសមុទ្រ ដោយការអនុគ្រោះទាំងនោះមានទំហំប្រមាណពី៥% ទៅ៧%នៃតម្លៃដឹកជញ្ជូនគោល។ ម្ល៉ងម្ល៉ាល ការអនុគ្រោះទាំងឡាយ គឺមិនទាន់គ្រប់គ្រាន់ទេ ដើម្បីញ៉ាំងឱ្យសហគ្រាសនាំចេញមានការចាប់អារម្មណ៍ ពីព្រោះទាំងបរិមាណទំនិញក៏ដូចជាទាំងតម្លៃទំនិញក្នុងស្រុក គឺហាក់នៅមានអត្រាតម្លៃខ្ពស់ និងទំហំទីផ្សារមានសភាពតូចង្អៀតដែលធ្វើឱ្យសហ-គ្រាសពិបាកនឹងទទួលប្រាក់ចំណេញ។ ជាញឹកញាប់ បានកើតមានឡើងនូវបញ្ហាអតិផរណា(លុយរៀលចុះថោក) រីឯតម្លៃទំនិញបានកើនឡើងយ៉ាងឆាប់រហ័សដែលស្ទើរតែធ្វើការកែលម្អច្បាប់នាំចេញមិនទាន់។

បើយើងវិភាគលើបទពិសោធន៍ផ្សេងៗទៀតបានបង្ហាញថា ការផ្តល់ជូនការអនុគ្រោះពន្ធច្រើនពេកសម្រាប់សហគ្រាសតែងតែនាំមកនូវភាពស្តុកស្តម្ភដល់អ្នកនាំចេញ រីឯរដ្ឋាភិបាលវិញពុំទទួលបានជោគជ័យទេ សម្រាប់ការទទួលបានចំណូលថវិកា។ ជាតុពិត បើសិនជាសហគ្រាសនាំចេញទទួលបានការអនុគ្រោះគ្រប់យ៉ាង ទីបំផុតទំហំរូបិយវត្ថុជាតិទទួលបានច្រើនជាងពីសហគ្រាសដែលធ្វើអាជីវកម្មក្នុងស្រុកដោយសារតែសហ-គ្រាសនាំចេញមានលទ្ធភាពលក់ទំនិញរបស់ខ្លួនក្នុងតម្លៃទាបជាងតម្លៃទីផ្សារពិភពលោក។ ជាងនេះទៅទៀត ពួកគេនឹងឆ្លៀតឱកាសប្រើប្រាស់ច្បាប់អនុគ្រោះទាំងនេះ ដើម្បីនាំចេញឱ្យបានជាអតិបរមាដែលធ្វើឱ្យគេទទួលបានប្រាក់ចំណេញច្រើនជាងការលក់ក្នុងស្រុក។ ផ្ទុយទៅវិញ ជាលទ្ធផលធ្វើឱ្យការនាំចេញផលិតផលមានការកើនឡើងយ៉ាងគំហុក ក៏ប៉ុន្តែ ទំហំរូបិយ-ប័ណ្ណដែលគេទទួលបានមកវិញ មិនសមស្របឡើយ(ព្រោះលក់បានថោក)


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលក្នុងបញ្ហានេះ សហគ្រាសនាំចេញមិនខ្វល់ខ្វាយនោះឡើយ ខណៈដែលពួកគេកំពុងទទួលបានការលើកទឹកចិត្តពីរដ្ឋាភិបាល។

នារយៈពេលចុងក្រោយ នៅប្រទេសកម្ពុជានាសម័យនោះបានខិតខំពង្រឹងជំហររបស់ខ្លួនក្នុងប្រព័ន្ធនៃចរន្តនាំចេញទំនិញរបស់ក្រុមហ៊ុនឯកជនក្នុងស្រុកដែលបានជះឥទ្ធិពលដល់កំណើនមូលធនជាតិ( ដោយសារការគាំទ្រពីរដ្ឋ និងការលួតលាស់ទំនាក់ទំនងដោះដូរទំនិញ) ក៏ដូចជាការកើនឡើងតួនាទីរបស់មូលធនក្នុងវិស័យពាណិជ្ជកម្មនាំចេញ។ ម្យ៉ាងទៀតការវិនិយោគក្នុងប្រតិបត្តិការនាំចេញនេះ បើយើងវិភាគជារួម មិនបានទាមទារលើការចំណាយមូលធនច្រើនដូចវិស័យផលិតកម្មនោះទេ ព្រោះការស្រង់ដើមរបស់វិស័យផលិតកម្មត្រូវការពេលវេលាច្រើនឆ្នាំ។ នៅសម័យនោះដែរ ការចូលរួមក្នុងទីផ្សារក្រៅប្រទេសបានបង្កើតឱកាសសម្រាប់ការបង្វិលមូលធនយ៉ាងសកម្ម និងរស់រវើកទៀតផងដោយសារតែដំណើរការគម្រោងការអាជីវកម្មទុច្ចរិតផ្សេងៗ( ការលាងលុយកខ្វក់)។ ការធ្វើសេដ្ឋកិច្ចក្រៅប្រទេសក្នុងវិស័យពាណិជ្ជកម្មនាំចេញរបស់ឈ្មួញឯកជន គឺពួកគេនេះហើយដែលបានដើរតួជាឈ្មួញកណ្តាលរវាងទីផ្សារក្នុងស្រុក និងក្រុមហ៊ុនបរទេស ហើយគ្រាន់តែចន្លោះឆ្នាំ១៩៨៩-១៩៩០ ក្នុងប្រទេសកម្ពុជាបានចុះបញ្ជីក្រុមហ៊ុនប្រមាណ១០ក្រុមហ៊ុននាំចេញ-នាំចូលឯកជន។ ម្យ៉ាងទៀតការស្តាបនាវិស័យសេដ្ឋកិច្ចថ្មីនេះក៏ដោយសារតែការទទួលបាននូវការអនុគ្រោះបែបគាំពារនិយម និងការអនុវត្តរបស់រដ្ឋាភិបាលនូវគោលនយោបាយជំរុញការនាំចេញដែលគោលនយោបាលនេះផ្តោះទៅរកការពង្រីកការនាំចេញ។

ដោយឡែក ដើម្បីគេចវេសពីការបង់ពន្ធនាំចេញ ជាមួយនឹងការប្រើប្រាស់គោលនយោបាយអូសទាញរូបិយប័ណ្ណបរទេសផងនោះ យើងពិនិត្យឃើញថា ឈ្មួញឯកជនទាំងនោះបានអនុវត្តយ៉ាងទូលាយនូវការនាំចូលទំនិញខុសច្បាប់( ការរត់ពន្ធគយ)ដោយប្រើប្រាស់ភាពទន់ខ្សោយ

របស់អង្គភាពគយ និងរដ្ឋាករ។

នៅសម័យកាលនោះដែរ កំណើនការនាំចេញភាគច្រើនអាស្រ័យលើការប្រកួតប្រជែងឈ្នះរបស់ទំនិញនៅលើទីផ្សារអន្តរជាតិ និងអាស្រ័យដោយការយល់ដឹងអំពីទីផ្សារ ព្រមទាំងការសិក្សាច្បាស់លាស់អំពីបម្លាស់ប្តូរយ៉ាងឆាប់រហ័សនៃតម្រូវការទំនិញផងដែរ។ ហេតុនេះហើយ រដ្ឋាភិបាលតែងតែលើកទឹកចិត្តដល់អ្នកផលិតក្នុងស្រុកដែលបានចំណាយធនធានរបស់ខ្លួនយ៉ាងច្រើន ដើម្បីកែលម្អគុណភាពផលិតផល និងការសិក្សាទីផ្សារ។

## ២.៣.៣ ការកំណត់នយោបាយរូបិយប័ណ្ណ និងឥណទាន

ជាទូទៅ នៅលើទីផ្សារពិភពលោក តែងតែមានការតស៊ូប្រកួតប្រជែងគ្នាយ៉ាងស្រួចស្រាវ មិនត្រឹមតែលើបញ្ហាតម្លៃ និងគុណភាពប៉ុណ្ណោះទេ ប៉ុន្តែពាក់ព័ន្ធផងដែរដល់រយៈពេលដែលត្រូវទូទាត់ ព្រោះថា អ្នកកក់ទិញតែងតែសុំចរចាទាមទារការចុះកិច្ចព្រមព្រៀងដោយពន្យារពេលដើម្បីទូទាត់ថ្លៃទំនិញ រីឯអ្នកលក់វិញ គឺចង់បានលក្ខខណ្ឌផ្ទុយគ្នា។ ហេតុនេះ ដើម្បីធានាដល់ការប្រកួតប្រជែងឈ្នះនៅលើទីផ្សារអន្តរជាតិ រដ្ឋាភិបាលត្រូវតែហ៊ានលះបង់ធនធានយ៉ាងច្រើន និងផ្តល់ជាឥណទានចំពោះការនាំចេញទំនិញរបស់ខ្លួនដែលយុទ្ធសាស្ត្របែបនេះបានក្លាយជាផែនការកម្មវិធីដ៏ស្មុគស្មាញពាក់ព័ន្ធទៅនឹងកង្វះខាតមធ្យោបាយធនធានហិរញ្ញវត្ថុ។ ម្យ៉ាងទៀត ប្រភពឥណទានដ៏សំខាន់បំផុត សម្រាប់វិស័យពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជានាសម័យនោះ គឺធនាគារជាតិនៃកម្ពុជា ប៉ុន្តែអ្វីដែលគួរឱ្យសង្វេគបំផុតនោះ ចំពោះប្រភពឥណទានសម្រាប់សហគ្រាសនាំចេញយើងពិនិត្យឃើញថា រហូតដល់ចុងទសវត្សរ៍ទី៨០ មិនទាន់បានបោះពុម្ពនៅឡើយ។

ចំពោះធាតុផ្សំនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសដ៏សំខាន់មួយក្នុងចំណោមធាតុផ្សំដទៃទៀតនោះ គឺសំដៅលើការវិនិយោគរបស់

រដ្ឋាភិបាលដែលមានរយៈពេលវែង។ នៅពេលដែលមានកំណើនអតិផរណា ឬទំនិញឡើងថ្លៃ ហេតុនេះ ការអូសបន្លាយពេលវេលាលើការវិនិយោគរយៈពេលវែងរបស់រដ្ឋត្រូវតែកែលម្អឡើងវិញជាការចាំបាច់ ព្រោះថាការធ្វើអាជីវកម្មនៃសហគ្រាសរដ្ឋ បើយើងពិនិត្យមើលជាទម្ងាប់ តែងតែដំណើរការដោយគ្មានប្រសិទ្ធភាពសេដ្ឋកិច្ចដែលមិនត្រឹមតែបាត់បង់ប្រាក់ចំណេញពីការវិនិយោគរបស់រដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំមកនូវការលំបាកជាច្រើនទៀត ជុំវិញបញ្ហានៃការឧបត្ថម្ភដល់សហគ្រាសទាំងអស់នោះទៀតផង តាមរយៈការប្រើប្រាស់កញ្ចប់ថវិការបស់រដ្ឋាភិបាល។

ជាងនេះទៀត ទាក់ទងទៅនឹងការរីករាលដាលនៃបញ្ហាការពង្រីកខ្ទង់ចំណាយលើកិច្ចដំណើរការគម្រោងសហគ្រាសរដ្ឋតាមរយៈអ្នករត់ការក្រោមតុ ព្រមទាំងការធ្វើពាណិជ្ជកម្មដោយគ្មានប្រសិទ្ធភាព និងខុសពេលវេលារបស់សហគ្រាសរដ្ឋ យើងសិក្សាឃើញថា ធនធានដែលបានចំណាយលើគោលដៅខាងលើនេះ ពុំមានផលិតភាពនោះទេ ហើយបញ្ហានេះកាន់តែចូលជ្រៅទៅក្នុងផលវិបាកនៃកង្វះខាតហិរញ្ញវត្ថុ និងអតិផរណា។ ហើយការចំណាយទៅលើកិច្ចការគ្រប់គ្រងរដ្ឋបាលច្រើនពេកបានធ្វើឱ្យមានការធ្លាក់ចុះផលិតភាពផលិតកម្មដែលបញ្ហាទាំងនេះ កើតចេញពីភាពមិនចាំបាច់ក្នុងការចំណាយជាអត្តនោម័តលើកំណើនសកម្មភាពមិនមែនសេដ្ឋកិច្ច បញ្ហាការិយាល័យធិបតេយ្យ ការពង្រីកក្បាលម៉ាស៊ីនរដ្ឋបាល និងគណបក្ស ជាពិសេស បញ្ហាកង្វះខាតខាងវិន័យផ្នែកហិរញ្ញវត្ថុ។ យ៉ាងណាមិញ នៅឆ្នាំ១៩៨៩ ទំហំនៃការចំណាយលើផ្នែករដ្ឋបាល និងកិច្ចការគណបក្សបានកើនដល់៨,៣២%នៃចំណាយសរុបដែលស្មើនឹង១,៧៨ពាន់លានរៀល។ ជាងនេះទៅទៀត ការចំណាយភាគច្រើនទៅលើវិស័យយោធា និងការសាងសង់អគារទំនើបៗដែលការចំណាយបែបនេះ បានក្លាយជាមូលហេតុ ឬជាបច្ច័យនៃការកើនឡើងខ្ពស់នូវអតិផរណា និងធ្វើឱ្យមានឱនភាពថវិការដ្ឋនៅកម្ពុជានាសម័យកាលនោះ។ ដូចជានៅឆ្នាំ១៩៨៩


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រដ្ឋាភិបាលបានចំណាយលើកិច្ចការនៃវិស័យយោធា និងសំណង់អគាររបស់រដ្ឋរហូតដល់ទៅ២៦,៩%ដែលស្មើនឹង៥,៧៦ពាន់លានរៀល។

ចំពោះការពង្រីកឥណទានរបស់ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីជាអ្នកកំណត់យ៉ាងសំខាន់មួយក្នុងការស្តារឡើងវិញនូវអតិផរណា។ យ៉ាងណាមិញ គ្រាន់តែចន្លោះឆ្នាំ១៩៨១-១៩៨៤ រដ្ឋាភិបាលបានផ្តល់ប្រាក់ឥណទានចំនួន៩,១២ពាន់លានរៀលដែលក្នុងនោះ ឥណទានរយៈពេលខ្លីមានចំនួនរហូតដល់៩៨,៧%។ ទំហំឥណទានភាគច្រើនបានផ្តល់ឱ្យទៅវិស័យពាណិជ្ជកម្ម( ៧៤,៧១%)ដែលប្រាក់ឥណទានទាំងនោះមានចំនួនរហូតដល់១០ដងច្រើនជាងទំហំតម្លៃផលិតផលសរុបរបស់វិស័យឧស្សាហកម្មប្រចាំឆ្នាំទៅទៀត។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក្តី ចាប់ពីឆ្នាំ១៩៧៩-១៩៩០ ទំហំសាច់ប្រាក់ឥណទានដែលបានផ្តល់ដោយធនាគារជាតិមានចំនួនតិចជាងទំហំឱនភាពថវិការដ្ឋនោះទេ។ សម្រាប់រយៈពេលចុងក្រោយចង្វាក់អតិផរណាបានកើនឡើងយ៉ាងគំហុករហូតដល់២៥០%ក្នុងមួយឆ្នាំ។ ហេតុនេះហើយ ការសិក្សាលើបញ្ហាអតិផរណា និងកត្តាបង្កឱ្យកើតមានអតិផរណាផ្សេងៗទៀតបានក្លាយជាបញ្ហាបច្ចុប្បន្នភាពរបស់រដ្ឋកម្ពុជានាសម័យកាលនោះ។

សរុបមក ការអនុវត្តគោលនយោបាយលើបញ្ហាឱនភាពហិរញ្ញវត្ថុរបស់រដ្ឋបាននាំមកនូវកំណើនសាច់ប្រាក់ទ្រង់ទ្រាយធំនៅលើទីផ្សារលឿនជាងកំណើនផ្គត់ផ្គង់ទំនិញ និងសេវាកម្មទៅទៀតដែលបរិយាកាសបែបនេះបានបំពានទៅលើអត្រាសមាមាត្រគ្នារវាងរូបិយវត្ថុជាតិជាមួយនឹងការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម មានន័យថា ធ្វើឱ្យចុះខ្សោយនូវអំណាចទិញរបស់ប្រាក់រៀល។ ហើយដូចដែលយើងបានដឹងហើយថា អំណាចទិញរបស់រូបិយវត្ថុត្រូវមានទំនាក់ទំនងគ្នាជាមួយឯកតាទំនិញ និងសេវាកម្មដែលជាអ្នកកំណត់អត្រាតម្លៃដោះដូរ ឬជាខ្នាតណាមួយរបស់រូបិយវត្ថុធៀបនឹងទំនិញ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូច្នេះ បើវិភាគទៅលើគោលនយោបាយរូបិយវត្ថុរបស់រដ្ឋាភិបាល យើងពិនិត្យឃើញថា ហាក់ដូចជាមានអនុគមន៍ជាប្រចាំជាមួយនឹងការវិភាគលើយន្តការនៃការកំណត់តម្លៃប្រាក់រៀលដែលជាកត្តាជះឥទ្ធិពលទៅលើការកំណត់វិធានការរបស់រដ្ឋាភិបាលទៅរកស្ថិរភាពនីយកម្មតម្លៃប្រាក់រៀល។ នៅប្រទេសកម្ពុជា ត្រូវបានកំណត់តម្លៃប្តូរប្រាក់រៀលជាច្រើនសណ្ឋានដូចខាងក្រោមនេះ ៖

- ទី១ ៖ តម្លៃដោះដូរផ្លូវការ

- ទី២ ៖ តម្លៃនាំចេញ-នាំចូលជារូបិយប័ណ្ណរបស់ប្រជាពលរដ្ឋ សម្រាប់ទំនាក់ទំនងសេដ្ឋកិច្ចនៅក្រៅប្រទេស។

- ទី៣ ៖ តម្លៃដោះដូរក្នុងទីផ្សារសេរី។

ហេតុនេះ សម្រាប់ប្រភេទទី១ និងទី២ជាតម្លៃដែលបានកំណត់រួចជាស្រេចដោយធនាគារជាតិនៃកម្ពុជាដែលមានតម្លៃទាបជាងតម្លៃទីផ្សារសេរីបន្តិចបន្តួច។ ភាពខុសគ្នារវាងតម្លៃផ្លូវការរបស់រដ្ឋជាមួយនឹងតម្លៃទីផ្សារសេរីបានបន្ថយលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការប្រមូលទិញរូបិយប័ណ្ណបរទេសដែលរដ្ឋកំពុងតែបានការខ្វះខាត។ សម្រាប់ដំណាក់កាលចុងក្រោយតម្លៃដោះដូរជាប្រាក់រៀលរបស់រដ្ឋមានកម្រិតទាបជាងតម្លៃទីផ្សារសេរីរហូតដល់១០%ទៅ១៥%ឯណោះ។ គួររំឭកដែរថា ការខាតបង់នៃគោលនយោ-បាយនេះធ្វើឱ្យធនាគារជាតិបានតម្រង់ទិសឡើងវិញទៅរកអត្រាតម្លៃទីផ្សារសេរីក្នុងការអនុវត្តគោលនយោបាយដោះដូររូបិយប័ណ្ណរបស់ខ្លួនដែលបានយកចិត្តទុកដាក់ខ្ពស់លើយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីរក្សាតម្លៃប្រាក់រៀល។ ទាក់ទងទៅនឹងកិច្ចការទាំងនេះ រដ្ឋាភិបាលបានកំណត់ជាបណ្តោះអាសន្ននូវកត្តានានាដែលជាអ្នកកំណត់អត្រាតម្លៃប្តូរប្រាក់រៀល សម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង។ សម្រាប់យុទ្ធសាស្ត្ររយៈពេលខ្លីដែលជះឥទ្ធិពលទៅលើអត្រាកំណើនរូបិយប័ណ្ណ ហើយពាក់ព័ន្ធទៅនឹងផលិតភាពពលកម្ម និងចង្វាក់លូតលាស់នៃផ.ស.ស(GDP)នៅក្នុងប្រទេស ពីព្រោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តែកម្រិតផលិតភាពពលកម្មទាបក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម គឺជាបច្ច័យជាអវិជ្ជមានទៅលើវិស័យនាំចេញទំនិញទៅលើការប្រកួតប្រជែង និងអំណាចទិញរបស់រូបិយវត្ថុដែលតាមរយៈបញ្ហាទាំងនេះមានឥទ្ធិពលដល់អត្រាតម្លៃប្តូររូបិយវត្ថុ(ប្រាក់រៀល)។ អត្រាចង្វាក់កំណើនផ.ស.សប្រចាំឆ្នាំនៅកម្ពុជា មានប្រមាណជា២%ទៅ៣%ប៉ុណ្ណោះ រីឯអត្រាកំណើនបរិមាណសាច់ប្រាក់(ជាប្រាក់រៀល)វិញ ក្នុងចរន្តទីផ្សារមានរហូតដល់២០០%ទៅ២៥០%ឯណោះ។ ហេតុនេះ តម្លៃប្រាក់រៀលបានចុះថោក(លុយហើម) សម្រាប់ផែនការរយៈពេលវែង។ ចំពោះយុទ្ធសាស្ត្ររយៈពេលមធ្យម គឺពាក់ព័ន្ធទៅនឹងស្ថានភាពតុល្យភាពចំណាយរបស់ប្រទេសចំពោះប្រតិបត្តិការចរន្ត និងចង្វាក់កំណើនតម្លៃទំនិញ។ ទន្ទឹមនឹងនេះដែរ ចំពោះការវិភាគលើតុល្យភាពចំណាយនៅកម្ពុជាសម័យនោះមានការលំបាកជាខ្លាំង ដោយសារតែកត្តាអវត្តមានទិន្នន័យស្ថិតិសមស្របដែលបណ្តាលមកពីបញ្ហាសេវារដ្ឋាភិបាលផ្នែកកិច្ចការស្ថិតិនៅមានសភាពទន់ខ្សោយ។ ហេតុដូចនេះហើយ ការសិក្សាវិភាគរបស់យើងបានពិនិត្យតែទៅលើស្ថានភាពនៃតុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់សហគ្រាសពាណិជ្ជកម្មរដ្ឋតែប៉ុណ្ណោះ (នៅសម័យនោះប្រទេសកម្ពុជាពុំបានចុះបញ្ជីស្ថិតិទៅលើប្រតិបត្តិការអាជីវកម្មរបស់ឈ្មួញឯកជននោះទេ)។ ជាក់ស្តែង សម្រាប់ឆ្នាំ១៩៨០-១៩៨៩ តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាមានចរិតលក្ខណៈក្នុងស្ថានភាពអសកម្មរ៉ាំរ៉ៃដែលក្នុងចន្លោះឆ្នាំខាងលើនេះ ឱនភាពវិស័យពាណិជ្ជកម្មអន្តរជាតិមានចំនួនរហូតដល់៥១០លានរៀល ដូចដែលមានបង្ហាញក្នុងតារាងខាងក្រោមនេះ។


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## តារាងលេខ៩
## តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់សហគ្រាសពាណិជ្ជកម្មក្រៅប្រទេស នៃរដ្ឋកម្ពុជានាឆ្នាំ១៩៨០-១៩៨៧ (គិតជាពាន់លានរៀល)

| ឆ្នាំ | ការនាំចេញ | ការនាំចូល | ឱនភាពពាណិជ្ជកម្ម | ទំនាក់ទំនងការនាំចេញ និងការនាំចូល |
|---|---|---|---|---|
| ១៩៨០ | ១. ០០៦ | ១. ៣៣០ | -៣២៤ | ៧៥,៦% |
| ១៩៨១ | ១០. ២០៦ | ៤៤. ៩៨០ | -៣៤. ៧០២ | ២២,៧% |
| ១៩៨២ | ៤. ៣២៧ | ៤៨. ៨៧០ | -៤៤. ៤៤៣ | ៨,៨% |
| ១៩៨៣ | ៩. ១៩៦ | ៧៣. ៨៤២ | -៦៤. ៦៤៨ | ១២,៤% |
| ១៩៨៤ | ១២. ៧២៧ | ៩១. ៩៦៣ | -៧៩. ២៣៦ | ១៣,៨% |
| ១៩៨៥ | ១៧. ៧២៦ | ៩៦. ២៣៧ | -៧៨. ៥១១ | ១៨.៤% |
| ១៩៨៦ | ២៥. ៣០៣ | ១១៤. ៤០២ | -៨៩. ០៩៩ | ២២.១% |
| ១៩៨៧ | ២៧. ១៤៤ | ១៤៦. ៦៦៤ | -១១៩. ៥២០ | ១៨.៥% |

**ប្រភព ៖ ស្ថិតិក្រសួងផែនការឆ្នាំ១៩៧៩-១៩៨៩, ភ្នំពេញ, ឆ្នាំ១៩៨៩, ទំព័រ៥៦-៥៧**

*តាមតារាងខាងលើបង្ហាញថា ឱនភាពពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសនាសម័យកាលនោះ មានស្ថានភាពធ្ងន់ធ្ងរណាស់ដូចជានៅឆ្នាំ១៩៨២ ការនាំចេញមានទំហំតែ៨,៨%ប៉ុណ្ណោះធៀបទៅនឹងការនាំចូលទំនិញ ហើយបើគិតជាមធ្យមនៅចន្លោះឆ្នាំ១៩៨១-១៩៨៧ ផលធៀបរវាងទំនាក់ទំនងការនាំចេញ-ការនាំចូល ទទួលបានតែ១៦,៦%តែប៉ុណ្ណោះ។ ចំពោះឱនភាពពាណិជ្ជកម្មខាងលើនេះត្រូវបានសង្គ្រោះដោយឥណទានរបស់ប្រទេសជាដៃគូពាណិជ្ជកម្មរបស់ខ្លួន ជាពិសេសប្រទេសសហភាពសូវៀត។ ម្យ៉ាងវិញទៀត ពួកពាណិជ្ជកររឯកជនក៏បានរួមចំណែកជួយសង្គ្រោះចំពោះឱនភាពពាណិជ្ជកម្មក្រៅប្រទេសដោយប្រយោលផងដែរ តាមរយៈការផ្ទេរដុំមាស និងរូបិយប័ណ្ណបម្រុងពីបរទេសចូលក្នុងស្រុក។ ក្នុងលក្ខណៈតុល្យភាពពាណិជ្ជកម្មដោយប្រយោលបែបនេះបានធ្វើឱ្យមាន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្រូវការរូបិយប័ណ្ណ និងសាច់មាសនៅក្នុងប្រទេសដែលទីបំផុតបាននាំមកនូវការធ្លាក់ចុះតម្លៃប្រាក់រៀលជាប្រចាំ។

គួររំឭកដែរថា នៅប្រទេសកម្ពុជានាសម័យនោះបានអនុវត្តគោលការណ៍ភ្ញោះទៅលើការកំណត់តម្លៃទំនិញនៅលើទីផ្សារ ពោលគឺរដ្ឋាភិបាលបានដើរតួនាទីជាអ្នកកំណត់អត្រាតម្លៃលក់ និងតម្លៃទិញ សម្រាប់តែទំនិញរបស់រដ្ឋប៉ុណ្ណោះដែលបានដាក់ឱ្យចរាចរនៅលើទីផ្សារ ក៏ប៉ុន្តែ សម្រាប់បរិមាណតម្លៃទំនិញយ៉ាងច្រើនសន្ធឹកសន្ធាប់របស់វិស័យឯកជនវិញ គឺបានកំណត់ដោយច្បាប់សេដ្ឋកិច្ចទីផ្សារ(ច្បាប់ផ្គត់ផ្គង់ និងតម្រូវការ)ដែលបាននឹងកំពុងចរាចរលើទីផ្សារក្នុងស្រុក ហើយមានវិសាលភាពគ្របដណ្តប់រហូតដល់ទៅ៨៥%នៃបរិមាណទំនិញសរុប។ ហេតុដូចនេះ តម្លៃលក់រាយរបស់វិស័យឯកជនបានសម្តែងចេញនូវឥទ្ធិពលយ៉ាងធំធេងទៅលើកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនាសម័យនោះ ព្រោះថា ទំនិញប្រើប្រាស់ស្ទើរតែទាំងអស់ទៅហើយដែលបានដាក់តាំង និងលក់នៅលើទីផ្សារត្រូវបានគេនាំចូលពីប្រទេសថៃ សិង្ហបុរី ហុងកុង និងផ្សេងៗទៀតដែលបច្ច័យទាំងនេះបានធ្វើឱ្យអត្រាតម្លៃទំនិញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅរកខ្នាតតម្លៃជាសាច់មាស ឬជារូបិយប័ណ្ណដុល្លារអាមេរិក និងរូបិយប័ណ្ណបាត(រូបិយប័ណ្ណថៃ)ដែលបានប្រើប្រាស់ជាមធ្យោបាយដោះដូរទំនិញយ៉ាងសកម្មក្នុងប្រទេសកម្ពុជា។

ចំពោះផែនការរយៈពេលខ្លីវិញ ច្រើនពាក់ព័ន្ធទៅនឹងកត្តាចិត្តសាស្ត្រ កត្តាសង្គ្រាម និងកត្តានយោបាយដែលជះឥទ្ធិពលទៅលើទីផ្សារ។ ក្នុងលក្ខខណ្ឌដែលប្រទេសមានសង្គ្រាមស៊ីវិល ហេតុនេះ រចនាសម្ព័ន្ធទីផ្សាររូបិយប័ណ្ណរបស់ប្រទេសបានផ្តេកផ្តួលយ៉ាងខ្លាំងទៅតាមស្ថានភាពនយោបាយ និងសង្គ្រាមដែលបាននិងកំពុងតែកើតមាននៅឡើយ។ ភាពសកម្មនិយមរបស់កងទ័ពព្រៃដែលបានធ្វើសកម្មភាពយ៉ាងខ្លាំងក្លាប្រឆាំងទៅនឹងរដ្ឋាភិបាលភ្នំពេញ បានបង្កផលប៉ះពាល់ និងធ្វើឱ្យតម្លៃប្រាក់រៀលធ្លាក់ចុះ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យ៉ាងគំហុក។ ក៏ប៉ុន្តែ កត្តាសំខាន់ជាងគេបំផុតនៃផែនការយុទ្ធសាស្ត្ររយៈពេលខ្លី គឺការធ្វើជំនួញរូបិយប័ណ្ណ និងការធ្វើអន្តរាគមន៍របស់រដ្ឋទៅលើទីផ្សាររូបិយប័ណ្ណដែលបានអនុវត្តរួចមកហើយនៅសម័យគ្រានោះ ហើយធ្វើឱ្យទីផ្សារនេះមានការរីកលូតលាស់ក្នុងសភាពទន់ខ្សោយបំផុត។ នៅប្រទេសកម្ពុជា ពុំទាន់មានទីផ្សារភាគហ៊ុនដែលជួញដូររូបិយប័ណ្ណ ឬធនាគារពាណិជ្ជកម្មនៅឡើយទេ ក៏ប៉ុន្តែនៅក្នុងទីផ្សារងងឹត និងទីផ្សារសេរីវិញត្រូវបានដំណើរការលើមុខងារជួញដូររូបិយប័ណ្ណ និងលោហៈមានតម្លៃយ៉ាងសកម្មដែលធ្វើឡើងតាមរយៈខ្សែបណ្ដាញរបស់ឈ្មួញឯកជន។ ពួកឈ្មួញទាំងអស់នោះបានធ្វើសកម្មភាពដោយឡែកៗពីគ្នា ប៉ុន្តែពួកគេបានរក្សាទំនាក់ទំនងព័ត៌មានជាមួយគ្នាយ៉ាងខ្ជាប់ខ្ជួន ហើយទីផ្សាររូបិយប័ណ្ណដែលល្បីល្បាញបំផុតនោះ គឺទីផ្សារលក់ដុំអូឡាំពិកនៅទីក្រុងភ្នំពេញដែលជារៀងរាល់ថ្ងៃបានបំពេញប្រតិបត្តិការក្នុងទំហំសាច់ប្រាក់រហូតដល់រាប់សែនដុល្លារអាមេរិក។ ទីផ្សារអូឡាំពិកនេះហើយដែលនៅសម័យនោះ បានដើរតួនាទីជាអ្នកកំណត់យន្តការតម្លៃទីផ្សារសេរីរបស់ប្រទេស ទាំងទីផ្សាររូបិយ-ប័ណ្ណ ទីផ្សារសាច់មាស ក៏ដូចជាទីផ្សារស្ទើរគ្រប់ប្រភេទទំនិញទាំងអស់ថែមទៀតផង។

ឧបករណ៍ដ៏សំខាន់បំផុតនៃគោលនយោបាយរូបិយប័ណ្ណរបស់កម្ពុជាត្រូវបានគេអនុវត្តដើម្បីអន្តរាគមន៍ទៅលើតម្លៃរូបិយប័ណ្ណដែលយន្តការនេះបានក្លាយជាឧបករណ៍អន្តរាគមន៍ជាផ្លូវការលើវិស័យរូបិយប័ណ្ណ។ ស្របជាមួយគ្នានេះ យើងពិនិត្យឃើញថា សាច់មាស និងរូបិយប័ណ្ណដុល្លារអាមេរិកបានដើរតួនាទីចម្បងបំផុតក្នុងប្រព័ន្ធរូបិយប័ណ្ណរបស់សេដ្ឋកិច្ចកម្ពុជា ហើយការធ្វើអន្តរាគមន៍របស់រដ្ឋ គឺត្រូវបានដាក់ចេញដោយធនាគារជាតិក្នុងទីផ្សារសេរីលើប្រតិបត្តិការនៃការទិញ-លក់រូបិយវត្ថុ( ប្រាក់រៀល) ជាមួយនឹងដុំមាស ឬក៏ជាមួយរូបិយប័ណ្ណអាមេរិក។ ចំពោះយន្តការអន្តរា-គមន៍របស់រដ្ឋ បានក្លាយជាមធ្យោបាយគាំពារនិយមជាផ្លូវការ ហើយដើម្បី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធ្វើឱ្យមានស្ថិរភាពនីយកម្មតម្លៃប្រាក់រៀល រដ្ឋបានកំណត់យកវិធីសាស្ត្រអន្តរាគមន៍តាមរយៈរូបិយប័ណ្ណដាប្រាក់ដុល្លារអាមេរិកមកធ្វើជាឧបករណ៍ (ការកំណត់អត្រាសមាមាត្រ)។ ក៏ប៉ុន្តែ នៅក្នុងប្រតិបត្តិការនៃយន្តការខាងលើនេះបានទាមទារឱ្យយើងរក្សាបរិមាណរូបិយប័ណ្ណបរទេសគ្រប់គ្រាន់ និងសាច់មាសក្នុងបរិមាណដ៏ច្រើន ទើបអាចដំណើរការគោលនយោបាយទៅបាន។ ហេតុនេះហើយ បានជានៅដំណាក់កាលចុងក្រោយ រដ្ឋាភិបាលបានអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់បំផុតតាមរយៈការដាក់ចេញនូវនីតិវិធីច្បាប់រដ្ឋបាលទៅលើការធ្វើអាជីវកម្មរូបិយវត្ថុនៅក្នុងទីផ្សារសេរីដែលកំពុងចរាចរយ៉ាងមមាញឹកក្នុងទំហំសាច់ប្រាក់ដ៏ធំធេង។ ជាក់ស្តែង នៅក្នុងខណៈពេលដែលតម្លៃប្រាក់រៀលបានធ្លាក់ចុះ យើងពិនិត្យឃើញថា រដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជារបស់ខ្លួនឱ្យស្ថាប័នដាកម្លាំងសមត្ថកិច្ចធ្វើការចាប់ខ្លួនពួកអាជីករធំៗមួយចំនួនដែលបានអនុវត្តបំពានទៅលើបទបញ្ញត្តិគោលនយោបាយរូបិយវត្ថុរបស់រដ្ឋ និងបានធ្វើឱ្យទីផ្សារមានសភាពច្របូកច្របល់ ហើយក្នុងស្ថានភាពនេះ រដ្ឋាភិបាលសម័យនោះថែមទាំងបានលើកទឹកចិត្ត និងបំពាក់ជាគ្រឿងឥស្សរិយយស(មេដាយ)ដល់ពួកមន្ត្រីនគរបាលទាំងឡាយណាដែលបានអនុវត្តការកិច្ចប្រកបដោយភាពជោគជ័យថែមទៀតផង។ វិធីសាស្ត្រនេះបានធ្វើឱ្យតម្លៃប្រាក់រៀលចាប់ផ្តើមទទួលបានស្ថិរភាពថ្លៃឡើងវិញ ប៉ុន្តែវិធានការបែបនេះអាចអនុវត្តបានជោគជ័យចំពោះតែផែនការរយៈពេលខ្លីប៉ុណ្ណោះ ហើយកល្បិចមួយនេះមិនអាចធ្វើការពារាំងដល់ការការពារតម្លៃប្រាក់រៀលបានជាអមតៈនោះទេ។ ដូច្នេះហើយ ការប្រតិបត្តិវិធីសាស្ត្រគាំពារបែបរដ្ឋបាលបញ្ជានិយម ឬក៏ការអនុវត្តជាយន្តការសេដ្ឋកិច្ចប្រភេទណាមួយដែលពុំមានមូលដ្ឋានស្រាវជ្រាវត្រឹមត្រូវសម្រាប់ការទ្រទ្រង់តម្លៃប្រាក់រៀល ហេតុនេះ យើងមិនគប្បីអនុវត្តនោះទេ។

ផ្សេងពីនេះទៀត តាមបទពិសោធន៍ជាក់ស្តែងបានបង្ហាញថា អត្រាតម្លៃរូបិយប័ណ្ណគឺជាឧបករណ៍ដ៏សំខាន់បំផុតនៃគោលនយោបាយរូបិយ-


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប័ណ្ណ និងសេដ្ឋកិច្ចក្រៅប្រទេស ព្រោះវាជាឧបករណ៍មួយក្នុងចំណោមវិធី-សាស្ត្រផ្សេងៗទៀតដែលបានញ៉ាំងឱ្យការនាំចេញទំនិញអាចសម្រេចទៅបានប្រកបដោយភាពជោគជ័យ ហើយក៏ជាឧបករណ៍ដែលអាចទ្រទ្រង់ដល់ល្បឿនចង្វាក់កំណើននៃកានាំចូលផងដែរដែលទីបំផុតបានធ្វើឱ្យកើតមានលំនឹង ឬតុល្យភាពជញ្ជីងពាណិជ្ជកម្ម។ ប៉ុន្តែ ដោយសារនៅក្នុងប្រទេសកំពុងតែកើតមានបញ្ហាអតិផរណាដែលធ្វើឱ្យអត្រាតម្លៃរូបិយវត្ថុជាតិ (ជាប្រាក់រៀល)ធ្លាក់ចុះជារឿយៗក្នុងមួយឆ្នាំៗ និងសេដ្ឋកិច្ចកម្ពុជាមានការរីកលូតលាស់យឺតយ៉ាវ ហើយធនធានដែលបម្រើឱ្យមានការនាំចេញក្នុងទ្រង់ទ្រាយធំនោះ សម្រាប់ករណីភាគច្រើន គឺនៅមានកម្រិតនៅឡើយ។ ម្យ៉ាងទៀត ប្រសិនបើយើងបន្ទាបអត្រាតម្លៃប្រាក់រៀល និងដាស់តឿនដល់ពួកពាណិជ្ជករ ដើម្បីជំរុញការនាំចេញក្នុងទ្រង់ទ្រាយធំ ហេតុនេះធ្វើឱ្យស្ថានភាពទីផ្សារក្នុងស្រុកមានភាពចលាចលយ៉ាងខ្លាំងក្លា ហើយអត្រាតម្លៃទំនិញនឹងស្ទុះងើបឡើងវិញយ៉ាងលឿនដែលបណ្តាលឱ្យកើតមានបញ្ហាលំហូរត្រលប់ក្រោយវិញចេញពីគណនីនាំចេញ។ លើសពីនេះទៅទៀត សេដ្ឋកិច្ចកម្ពុជាក៏ដូចជាសេដ្ឋកិច្ចនៃបណ្តាប្រទេសតតិយលោកផ្សេងៗទៀតដែរ គឺមានការប្រែប្រួលតិចតួចណាស់ និងនៅក្នុងដំណាក់កាលនៃការអនុវត្តវិធានការខាងលើនេះ យើងពិនិត្យឃើញថា ការបើកច្រកទ្វារសម្រាប់សហគ្រាសនាំចេញអាចដំណើរការទៅបាន លុះត្រាតែក្នុងលក្ខខណ្ឌមួយដែលពាក់ព័ន្ធទៅនឹងការបន្ទាបតម្លៃប្រាក់រៀលតែប៉ុណ្ណោះ ហើយដែលធ្វើឱ្យធនធានមូលធនថ្មីៗមិនអាចបង្វិលឱ្យទាន់ចូលក្នុងវិស័យនាំចេញក្នុងទ្រង់ទ្រាយធំបាននោះទេ។ ចំពោះបញ្ហានេះដែរ ពុំមែនមានន័យថា គ្រប់ឈ្មួញនាំចេញទាំងអស់សុខចិត្តចូលរួមធ្វើអាជីវកម្មពាណិជ្ជកម្មក្រៅប្រទេសដោយគ្មានបទពិសោធន៍រកស៊ីពីអតីតកាល ក៏ដូចជាគ្មានបទ-ពិសោធន៍ចាត់ចែងការងារ ការគ្រប់គ្រងបុគ្គលិក និងខ្សែបណ្តាញពាណិជ្ជ-កម្មនោះឡើយ បើទោះជាពួកគេមានដើមទុនគ្រប់គ្រាន់ក៏ដោយ ពីព្រោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ថា ការសម្រេចចិត្តវិនិយោគលើវិស័យសេដ្ឋកិច្ចនីមួយៗសុទ្ធតែអាស្រ័យលើ មូលដ្ឋានបទពិសោធន៍ច្បាស់លាស់។ ហេតុនេះហើយលទ្ធផលបន្ទាបតម្លៃ ប្រាក់រៀលជាផ្លូវការ គឺមានផលប៉ះពាល់ជាកំហិត និងមានឥទ្ធិពលជា អវិជ្ជមានទៅលើសេដ្ឋកិច្ច និងសហគ្រាសនាំចេញ។ គួរបញ្ជាក់បន្ថែមទៀត ដែរថា មូលហេតុដ៏សំខាន់មួយទៀតដែលបានធ្វើឱ្យរដ្ឋាភិបាលកំណត់ លក្ខខណ្ឌឱ្យមានការដាក់កំហិតបែបនេះ ដោយសារតែភាពមិនឯកភាពជ្យ ទាំងស្រុងរបស់ប្រទេសកម្ពុជាលើបញ្ហាការនាំចូលទំនិញពីក្រៅប្រទេស យ៉ាងច្រើនសន្ធឹកសន្ធាប់ដែលមិនអាចខ្វះបាន។ ហើយបន្ទាប់ពីបានអនុវត្ត គោលនយោបាយបន្ទាបអត្រាតម្លៃរូបិយវត្ថុជាតិផ្លូវការក្នុងគោលបំណង ចំណាយលើការនាំចូលទំនិញ ជាការចាំបាច់សម្រាប់១ឯកតារូបិយប័ណ្ណ ត្រូវទទួលបានរូបិយវត្ថុជាតិ(ប្រាក់រៀល)ច្រើនជាងមុនៗ។ ដូច្នេះ ការនាំចូល ទំនិញត្រូវបានចាប់ផ្ដើមមានតម្លៃ ហើយជាលទ្ធផល តម្លៃទំនិញនាំចូល សម្រាប់ការដោះដូរក្នុងទីផ្សារ មានការរីកចម្រើនជាបណ្ដើរៗ ហើយមាន ការកើនឡើងតម្លៃគ្រប់ទំនិញទាំងអស់(ទាំងទំនិញផលិតក្នុងស្រុក)។ វិធី-សាស្ត្របែបនេះមានន័យថា សហគ្រាសនាំចេញត្រូវតែទទួលបានប្រាក់ ចំណេញបន្ថែមតាមរយៈការអនុវត្តគោលនយោបាយបន្ទាបអត្រាតម្លៃរូបិយ វត្ថុដែលធ្វើឱ្យមានការឡើងថ្លៃទំនិញ។ នៅប្រទេសកម្ពុជា ប្រហែលជា៩០% នៃផលិតផលដែលបានលក់ដូរក្នុងទីផ្សារ គឺជាប្រភេទទំនិញដែលបាន នាំចូលពីបរទេស ទាំងទំនិញផលិតសម្រេច និងទំនិញពាក់កណ្ដាលផលិត សម្រេច។ ហេតុនេះហើយ ការលើកទឹកចិត្តការនាំចេញបានក្លាយជា ឧបករណ៍ដ៏សំខាន់ និងមានសកម្មភាពយូរអង្វែង និងវែងឆ្ងាយ ក៏ប៉ុន្តែ គោលនយោបាយបន្ទាបតម្លៃរូបិយវត្ថុជាតិជារឿយៗបែបនេះ ក៏ពុំបានក្លាយ ជាមធ្យោបាយដ៏ល្អ សម្រាប់ជំរុញឱ្យមានការនាំចេញដែលមានប្រសិទ្ធភាព ខ្លាំងក្លានោះទេ ផ្ទុយទៅវិញយុទ្ធសាស្ត្របែបនេះ វាបានបង្កលក្ខណៈឱ្យ មានការឡើងថ្លៃទំនិញ និងការហូរចូលត្រលប់មកវិញនូវទំនិញដែលត្រូវ

ផលិតសម្រាប់ការនាំចេញ។

## ២.៤ គោលនយោបាយលើវិស័យទំនាក់ទំនងមូលធនបរទេស

នៅក្នុងទសវត្សរ៍ទី៥០ និង៦០ មូលធនបរទេសនៅកម្ពុជាបានសម្តែងឥទ្ធិពលយ៉ាងធំធេងចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជា ជាពិសេស មូលធនរបស់ប្រទេសបារាំងដែលទទួលបានលំដាប់ចម្បងជាងគេក្នុងសេដ្ឋកិច្ចរបស់ប្រទេស។ នៅឆ្នាំ១៩៦២ ទំហំមូលធនសរុបត្រូវបានវាយតម្លៃប្រហែលជា ៣៧ពាន់លានហ្វ្រង់ដែលក្នុងនោះ៣០ពាន់លានហ្វ្រង់( ជាង៨០%) បានវិនិយោគលើដំណាំកសិ-ឧស្សាហកម្មកសិដ្ឋានចម្ការកៅស៊ូដែលជាផលិត-ផលសម្រាប់បម្រើឱ្យការនាំចេញ។ រីឯមូលធនបរទេសក្នុងលំដាប់លេខពីរនោះ គឺមូលធនរបស់ជប៉ុនដែលបានវិនិយោគក្នុងសេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមនឹងនេះដែរ ក៏មានការចូលរួមផងដែរពីមូលធនសហរដ្ឋអាមេរិក អង់គ្លេស អាល្លឺម៉ង់ សិង្ហបុរី ឥណ្ឌា និងហុងកុង។ មូលធនបរទេសទាំងអស់បានចូលរួមវិនិយោគក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនចម្រុះគ្នា ដោយបាននាំចូលបរិក្ខារផលិតកម្មគ្រប់ប្រភេទ និងប្រើប្រាស់បុគ្គលិកដែលមានជំនាញត្រឹមត្រូវ។ បរិមាណសរុបនៃការវិនិយោគបរទេសនៅដើមទសវត្សទី៧០ត្រូវបានវាយតម្លៃថាប្រមាណជា៥០លានហ្វ្រង់។

បន្ទាប់ពីបានចូលកាន់កាប់អំណាចរបស់ពួកខ្មែរក្រហមនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ យើងសង្កេតឃើញថា សហគ្រាសបរទេស ឧស្សាហកម្មទាំងអស់ រួមទាំងក្រុមហ៊ុនពាណិជ្ជកម្មបរទេសផ្សេងៗទៀតត្រូវបានបម្លែងឱ្យទៅជាសហគ្រាសជាតិដោយគ្មានច្បាប់ទទួលបានសំណងបន្តិចសោះឡើយ។ ក៏ប៉ុន្តែបន្ទាប់ពីបានផ្តួលរំលំរបបប៉ុល ពតរួចមក មូលធនបរទេសក៏មិនទាន់បានអនុញ្ញាតឱ្យមានការវិនិយោគឡើងវិញក្នុងសេដ្ឋកិច្ចកម្ពុជានោះឡើយ។ បន្ទាប់ពីការបង្កើតរបបដឹកនាំថ្មីអស់រយៈកាល១០ឆ្នាំរួចមក រដ្ឋាភិបាលបានចាប់ផ្តើមស្វែងយល់ថា ដើម្បីរក្សាអំណាចរបស់ខ្លួន រដ្ឋជា

ចាំបាច់ត្រូវរៀនធ្វើសេចក្តីសម្រេចវិធានការនានាជាបន្ទាន់ក្នុងវិស័យសេដ្ឋកិច្ច ដែលបាន និងកំពុងស្ថិតនៅក្នុងស្ថានភាពវិបត្តិសេដ្ឋកិច្ច។ និយាយរួម នៅក្នុងប្រទេសកំពុងមានបញ្ហាអតិផរណាស្រួចស្រាវ ហើយកំណើនផលិតកម្មមានល្បឿនយឺតយ៉ាវដែលនៅក្នុងស្ថានភាពបែបនេះ ទាមទារឱ្យមានការពិនិត្យឡើងវិញដល់ឫសគល់ជុំវិញទំនាក់ទំនងទៅកាន់ការប្រើប្រាស់មូលធនបរទេស និងបង្កើតឱ្យមានក្រុមសាជីវកម្មពហុជាតិ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩ ក្នុងមហាសន្និបាតថ្នាក់ជាតិនៅកម្ពុជាបានអនុម័តបទបញ្ញត្តិច្បាប់ស្តីពីការវិនិយោគបរទេសដែលសេចក្តីសម្រេចនេះបានក្លាយជាចំណុចចាប់ផ្តើមនៃរបត់ថ្មីរបស់គោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា។ ខ្លឹមសារនៃអង្គច្បាប់ខាងលើនេះបានកំណត់អំពីកិច្ចស្វាគមន៍ និងការលើកទឹកចិត្តចំពោះសកម្មភាពវិនិយោគមូលធនបរទេស ក្រុមហ៊ុន និងអ្នកវិនិយោគទាំងឡាយណាដែលមានបំណងចង់មកបណ្តាក់ទុនវិនិយោគក្នុងប្រទេសកម្ពុជា។ ជាងនេះទៀត រដ្ឋាភិបាលក៏បានពិចារណា និងវាយតម្លៃខ្ពស់អំពីសារៈសំខាន់នៃក្រុមហ៊ុនសាជីវកម្មពហុជាតិដែលអាចក្លាយជាភ្នាក់ងារបែបទំនើបនីយកម្មនៃសេដ្ឋកិច្ចរបស់កម្ពុជា ហើយតាមរយៈសកម្មភាពរបស់ពួកគេពាក់ព័ន្ធនឹងការនាំចូលទំនិញ ក៏ដូចជាការផ្តល់ឥណទានជាមូលធនបរទេស ធ្វើឱ្យប្រទេសកម្ពុជាអាចលូនចូលទៅក្នុងប្រព័ន្ធនៃការបែងចែកពលកម្មអន្តរជាតិ ជាពិសេស ក្លាយជាដើមចមគន្លឹះដ៏ពិសិដ្ឋក្នុងចលនាជំរុញល្បឿនការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន។

នៅសម័យនោះដែរ នៅប្រទេសកម្ពុជាបានចាប់ផ្តើមផ្លាស់ប្តូរទិន្នាការឆ្ពោះទៅរកការធ្វើកំណែទម្រង់ជីវិតសេដ្ឋកិច្ច និងមានសភាពទន់ទោរទៅរកការចុះខ្សោយនៃឥទ្ធិពលរបស់រដ្ឋក្នុងការចាត់ចែងសេដ្ឋកិច្ចបែបរដ្ឋបាលបញ្ជាដែលជំនួសដោយការដឹកនាំបែបសេដ្ឋកិច្ចទីផ្សារវិញ ហើយជាជំហានៗបានកាត់បន្ថយការធ្វើអាជីវកម្មរបស់សហគ្រាសរដ្ឋ និងចាប់ផ្តើមដំណើរការគោលនយោបាយឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ។ ហេតុដូចនេះ


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទំនាក់ទំនងនយោបាយសេដ្ឋកិច្ចបានបង្កភាពងាយស្រួលដល់ទំនាក់ទំនងផ្ទាល់មុខជាអន្តរជាតិដែលបានប្រឹងប្រែងស្វែងរកច្រកចេញដ៏សមស្របក្នុងការធ្វើទំនាក់ទំនងគ្នាជាមួយក្រុមហ៊ុនសាជីវកម្មពហុជាតិ និងបានស្តែងចេញអំពីកម្រិតចំណាប់អារម្មណ៍របស់រដ្ឋចំពោះការទាក់ទាញមូលធនបរទេសឱ្យចូលមកបណ្តាក់ទុនក្នុងសេដ្ឋកិច្ចកម្ពុជាយើង។

បម្លាស់ប្តូរគោលនយោបាយរបស់រដ្ឋក្នុងទំនាក់ទំនងខាងលើនេះក៏បានក្លាយជាលក្ខខណ្ឌផងដែរទៅលើបញ្ហានានាដែលមិនអាចដោះស្រាយបានកន្លងមកនូវផែនការយុទ្ធសាស្រ្ត(ដូចជាបញ្ហាកំណើនសេដ្ឋកិច្ចរយៈពេលវែង បញ្ហាគោលនយោបាយវិទ្យាសាស្រ្តបច្ចេកទេស និងការពង្រឹងសក្តានុពលសេដ្ឋកិច្ចជាតិជាដើម។ល។)ដែលបានប្រើប្រាស់វិធីចាស់តាមរយៈមាគ៌ាពង្រឹងការគ្រប់គ្រងបែបរដ្ឋបាលបញ្ជាក្នុងសេដ្ឋកិច្ចជាតិដែលធ្វើឱ្យសេដ្ឋកិច្ចបានធ្លាក់ចូលក្នុងស្ថានភាពវិបត្តិ។ តាមបទពិសោធន៍ ការដកខ្លួនចេញពីការអនុវត្តបែបប្រពៃណីនូវគោលនយោបាយចាស់ដោយចាប់យកគោលនយោបាយថ្មីដែលសមស្របជាងមុន ជាមួយនឹងក្រុមហ៊ុនសាជីវ-កម្មពហុជាតិ គឺតែងតែកើតមានបញ្ហាទំនាស់ដោយមិនអាចគេចផុតបានរវាងភាពមិនចុះសម្រុងនឹងគ្នាលើបញ្ហាផលប្រយោជន៍របស់ក្រុមហ៊ុនសាជីវកម្មពហុជាតិជាមួយនឹងប្រទេសដែលភ្ជាប់ទំនាក់ទំនងជាមួយគ្នា។ ជាញឹកញាប់ ការតស៊ូលើផ្នែកនយោបាយ ឬក៏មនោគមវិជ្ជាទាមទារការស្វែងយល់ច្បាស់លាស់អំពីផលប្រយោជន៍រយៈពេលវែងរបស់ប្រទេស និងតួនាទីដ៏ធំធេងរបស់វាដែលបានដំណើរការជុំវិញកិច្ចការសហប្រតិបត្តិការជាមួយសហគ្រាសផ្ទាល់មុខអន្តរជាតិទាំងនោះ។ ទំនាក់ទំនងគ្នាទៅកាន់ការប្រើប្រាស់មូលធនបរទេសក៏ដូចជាក្រុមហ៊ុនសាជីវកម្មពហុជាតិ កាន់តែបានក្លាយជាលក្ខខណ្ឌអំណោយផលផ្នែកបច្ចេកទេសសេដ្ឋកិច្ចច្រើនជាងទស្សនៈនយោបាយ។

តាមការស្រាវជ្រាវបង្ហាញថា ទស្សនវិជ្ជាថ្មីនៃគោលនយោបាយ

សេដ្ឋកិច្ចគឺជាកត្តាដ៏សំខាន់មួយដែលបង្កលក្ខណៈដល់ការវាយដណ្ដើម ឬអូសទាញយកក្រុមហ៊ុនសាជីវកម្មពហុជាតិក្នុងគោលជំហរផ្ដាច់មុខឱ្យចូលមកបម្រើឱ្យវិស័យនេះ ឬវិស័យណាមួយនៃសេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែយន្តការនេះវាអាចជាការបិទទ្វារទីផ្សារក្នុងស្រុកពីពិភពលោកខាងក្រៅ និងបាត់បង់ឱកាសនៃការការពារវិស័យឧស្សាហកម្មជាតិ និងអាជីវកម្មក្នុងស្រុក។ ការតស៊ូប្រឆាំងនឹងបាតុភូតជាអវិជ្ជមានទាំងអស់នេះទាមទារការប្រឹងប្រែងយ៉ាងខ្លាំងក្នុងការសម្របសម្រួលពីសំណាក់រដ្ឋាភិបាលដែលមានមុខងារយ៉ាងប៉ិនប្រសប់ក្នុងការបើកទ្វារទីផ្សារក្នុងស្រុកទៅរកការប្រកួតប្រជែងជាអន្តរជាតិ និងការបង្កើតឱ្យមានប្រភពផ្សេងៗនូវការវិនិយោគបរទេស ក៏ដូចជាញ៉ាំងឱ្យមានទំនាក់ទំនងគ្នាខ្ពស់រវាងសាខានៃក្រុមហ៊ុនសាជីវកម្មពហុជាតិផងដែរ។

ច្បាប់ស្ដីពីការវិនិយោគបរទេសដែលបានអនុម័តដោយមហាសន្និបាតថ្នាក់ជាតិនៅខែកក្កដា ឆ្នាំ១៩៨៩ បានអនុញ្ញាតឱ្យមានការបើកជាក្រុមហ៊ុនបរទេស ការរួបរួមពីពាណិជ្ជករបរទេស និងជនភៀសខ្លួនខ្មែរដែលរស់នៅតាមព្រំដែនឱ្យចូលមកកម្ពុជាដោយសេរីមកចូលរួមកសាងសេដ្ឋកិច្ចកម្ពុជា។ រដ្ឋាភិបាលបានប្ដេជ្ញាខ្ពស់ក្នុងការបំពេញកិច្ចសន្យារបស់ខ្លួនដោយមិនប្រកាន់យកទស្សនៈជាតិសាសន៍និយម និងមិនអនុវត្តការគ្រប់គ្រងបែបរដ្ឋបាលបញ្ជាចំពោះក្រុមហ៊ុននានាដែលជាកម្មសិទ្ធិក្រុមហ៊ុនបរទេស ឬក៏ដាក់កំហិតណាមួយផ្នែកផ្លូវច្បាប់ចំពោះម្ចាស់សហគ្រាស ក្នុងការតាមដានត្រួតពិនិត្យ ឬការគ្រប់គ្រងដល់ពួកគេ។ ខ្លឹមសារបទដ្ឋានច្បាប់ថ្មីនេះបានកំណត់ទម្រង់នៃកិច្ចសហប្រតិបត្តិការជាបីសណ្ឋានជាមួយនឹងក្រុមហ៊ុនបរទេសដូចខាងក្រោមនេះ ៖

១. ការបង្កើតជាសហគ្រាសសហកម្មសិទ្ធិ (ចម្រុះ)

២. ការបង្កើតជាសហគ្រាសដោយប្រើប្រាស់មូលធនបរទេសសុទ្ធ

៣. កិច្ចសហប្រត្តិបត្តិការដោយឈរលើគោលការកិច្ចព្រមព្រៀង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្លឹមសារអត្ថច្បាប់ថ្មីនេះបានចែងផងដែរអំពីទំហំភាគហ៊ុនអប្បបរមារបស់ដៃគូបរទេសដែលមានចំនួនមិនតិចជាង៣០%នៃចំនួនដែលត្រូវវិនិយោគសរុប ប៉ុន្តែគេអាចពង្រីកទំហំភាគហ៊ុនបន្ថែមដោយគ្មានកំហិតណាមួយ។ ពួកពាណិជ្ជករបរទេសត្រូវបានទទួលសិទ្ធិក្នុងការរៀបចំក្បាលម៉ាស៊ីនគ្រប់គ្រងសហគ្រាសរបស់ខ្លួន ឬក៏អញ្ជើញអ្នកជំនាញបរទេស ឬអ្នកបច្ចេកទេសឱ្យចូលមកជួយរៀបចំចាត់ចែងអាជីវកម្មរបស់ខ្លួន។ ក្រៅពីនោះ ច្បាប់ក៏បានចែងអំពីទម្រង់នៃការវិនិយោគដូចជាការវិនិយោគជារូបិយប័ណ្ណសុទ្ធ ឬក៏ជាសម្ភារផលិតកម្ម។ ដៃគូបរទេសត្រូវតែប្រើប្រាស់សាច់ប្រាក់ជារូបិយប័ណ្ណដុល្លារ និងប្រើប្រាស់គ្រឿងបរិក្ខារផលិតកម្ម គ្រឿងសំណង់ ស៊ីម៉ងត៍ និងផ្សេងៗទៀតដោយធ្វើការនាំចូលតាមរយៈច្បាប់ជាអជ្ញាប័ណ្ណ និងបង់ពន្ធប៉ាតង់ត្រឹមត្រូវ។

ទាក់ទងទៅនឹងអាទិភាពចំពោះវិស័យសេដ្ឋកិច្ច ទំហំវិនិយោគ និងចំនួននាំចេញត្រូវបានទទួលការអនុគ្រោះពន្ធយ៉ាងច្រើន ឬក៏លើកលែងពន្ធទាំងស្រុងក្នុងចិរវេលាពីរឆ្នាំ រហូតដល់សហគ្រាសចាប់ផ្តើមទទួលបានប្រាក់ចំណេញជាក់ស្តែង។ ក្នុងករណីពិសេសខ្លះទៀត រយៈពេលអនុគ្រោះពន្ធអាចបន្ថែមពីរឆ្នាំបន្តទៀត។ លើសពីនេះទៀត សហគ្រាសត្រូវតែចំណាយបន្ថែមទៅលើអ្វីដែលកំណត់ដោយច្បាប់ ពោលគឺ ទៅលើការប្រើប្រាស់ដីធ្លីប្រើប្រាស់ទឹក ដែនសមុទ្រ និងការប្រើប្រាស់ធនធានធម្មជាតិ សម្រាប់ការកែច្នៃផ្សេងៗ។ គួរបញ្ជាក់បន្ថែមថា វិនិយោគិនបរទេសអាចបណ្តាក់ទុនវិនិយោគរបស់ខ្លួនលើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ដែលគេមានបំណង។ ដៃគូវិនិយោគិនបរទេសមានសិទ្ធិពេញលេញក្នុងការផ្ទេរភាគផលប្រាក់ចំណេញរបស់ខ្លួនទៅក្រៅប្រទេសដោយត្រូវជាប់ពន្ធប្រាក់ចំណេញតែពី៥%ទៅ១០%ប៉ុណ្ណោះ ចំពោះវិស័យដែលទទួលបានការអនុគ្រោះ( ដោយអន្ទើ ឬទាំងស្រុង)។ គណនីខ្ទង់រំលស់ និងឥណទានអាចផ្ទេរចេញបានដោយគ្មានការបង់ពន្ធ។ ដៃគូបរទេសមានសិទ្ធិផងដែរនូវការនាំចេញទៅ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រៅប្រទេសនៃធនធានទ្រព្យសម្បត្តិរបស់សហគ្រាសផលិតកម្មដែលខ្លួនបានប្រើប្រាស់ក្រោយពេលដែលសហគ្រាសនោះត្រូវបានបិទទ្វារ( បញ្ឈប់)។ រីឯបុគ្គលិកបរទេសក៏អាចផ្ទេរប្រាក់បៀវត្សរបស់ខ្លួនទៅក្រៅប្រទេសដោយគ្មានការបង់ពន្ធ ក្រោយពេលគេបានបង់ពន្ធលើប្រាក់ចំណូលរួចរាល់ស្រប តាមច្បាប់របស់ប្រទេសកម្ពុជា។

ដូច្នេះ រដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ឱ្យមានការប្រើប្រាស់ជាអតិបរមានូវមូលធនបរទេស សម្រាប់ការជំរុញល្បឿនការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែបញ្ហាខ្វះចន្លោះស្ថិតនៅត្រង់ថា ការបើកចំហជើងមេឃតែលើកិច្ចការផ្តល់សិទ្ធិប្រើប្រាស់មូលធនបរទេស តែរដ្ឋាភិបាលហាក់ដូចជាមិនទាន់ទទួលស្គាល់អំពីភាពចាំបាច់នៃគោលនយោបាយវិមជ្ឈការលើវិស័យប្រព័ន្ធធនាគារ និងការអនុញ្ញាតឱ្យមានធនាគារពាណិជ្ជកម្មឯកជន។ ហេតុនេះហើយ បើវិភាគលើបញ្ហានេះ គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិ-បាលលើវិស័យទាក់ទាញវិនិយោគបរទេសមានលក្ខណៈពាក់កណ្តាលថ្ងៃតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលដូចជាបានប្រឹងប្រែងជាអតិបរមាលើការបង្កើតលក្ខខណ្ឌប្រកប សម្រាប់វិនិយោគិនបរទេស ផ្ទុយទៅវិញរដ្ឋាភិបាលបែជាបំបិទសិទ្ធិចំពោះលទ្ធភាពជាសក្តានុពលរបស់ខ្លួនលើការទាក់ទាញមធ្យោបាយទាំងនោះ គឺមានន័យថា នៅក្នុងប្រទេសពុំបានអនុ-ញ្ញាតឱ្យមានការបង្កើតទាំងធនាគារពាណិជ្ជកម្មជាតិ និងទាំងធនាគារបរទេស។

នៅសម័យកាលនោះ ទំហំសាច់ប្រាក់វិនិយោគបរទេសនៅកម្ពុជាមានបរិមាណធំធេងដូចជានៅឆ្នាំ១៩៩០ បើតាមការសិក្សាវាយតម្លៃពីប្រភពផ្សេងៗគ្នា ទំហំនេះមានរហូតដល់៣០ទៅ៣៥លានដុល្លារអាមេរិកដែលក្នុងនោះ ទំហំចំណែករបស់ប្រទេសជប៉ុនមានប្រហែល៧%នៃការវិនិយោគបរទេសសរុប។ ក្រុមហ៊ុនបរទេសនានាបានទទួលរងគ្រោះ ហើយខាងភាគីកម្ពុជាវិញត្រូវតែចូលរួមជារូបិយវត្ថុជាតិ( ប្រាក់រៀល) ហើយក្នុង

ទម្រង់ជាសម្ភារផលិតកម្មវិញអាចចូលរួមជាធនធានធម្មជាតិ សម្ភារសំណង់ក្នុងស្រុក ផ្ដល់សិទ្ធិប្រើប្រាស់ដីធ្លី ប្រើប្រាស់ទឹក ធនធានសមុទ្រ អគាររោងចក្រ គ្រឿងម៉ាស៊ីន បរិក្ខារផលិតកម្ម ពូជដំណាំ(ឬសត្វ)សេវាកម្មសំខាន់ៗ និងបច្ចេកវិទ្យា។

ចំពោះការនាំចូលគ្រឿងម៉ាស៊ីន បរិក្ខារផលិតកម្ម សម្ភារសំណង់ និងវត្ថុធាតុផ្សេងៗទៀតដែលចាំបាច់សម្រាប់ការបង្កើតសហគ្រាសសហកម្មសិទ្ធិ គឺត្រូវបានរដ្ឋាភិបាលលើកលែងតែពន្ធនាំចូលទាំងស្រុង។ ជាមួយគ្នានេះ ការនាំចូលវត្ថុធាតុដើម គ្រឿងសម្ភារចាំបាច់នានា ក្នុងទិសដៅបម្រើឱ្យការផលិតទំនិញសម្រាប់ការនាំចេញ ក៏ត្រូវបានរដ្ឋាភិបាលលើកលែងពន្ធនាំចូលផងដែរ។ ដោយឡែក ចំពោះការនាំចូលវត្ថុធាតុដើម ឬសម្ភារបរិក្ខារផ្សេងៗក្នុងទិសដៅសម្រាប់ការផលិតទំនិញ ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក រដ្ឋាភិបាលអាចកំណត់យកពន្ធនាំចូលក្នុងអត្រាអប្បបរមា ឬក៏អាចលើកលែងពន្ធទាំងស្រុងទៅលើលក្ខណៈពិសេសណាមួយ។

ពាក់ពន្ធនឹងគោលការណ៍គណនាផ្នែកសេដ្ឋកិច្ចរបស់សហគ្រាសសហកម្មសិទ្ធិ(ចម្រុះ)ផ្នែកខ្លះ ត្រូវបានអនុញ្ញាតឱ្យដៃគូបរទេសកំណត់ដោយខ្លួនឯង ហើយចំណែកខ្លះទៀត ត្រូវបានកំណត់ដោយបទដ្ឋានច្បាប់។ ដូចជាការកំណត់អត្រារំលស់ថ្លៃដើមរបស់គ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្មត្រូវបានកំណត់ដោយដៃគូបរទេសខ្លួនឯង ឬក៏ពាក់ព័ន្ធនឹងការបង្កើតជាខ្ទង់បម្រុងតាមរយៈការដកហូតចំនួន៥%ពីប្រាក់ចំណេញមករក្សាទុករហូតដល់ខ្ទង់នេះកើនដល់២៥%នៃថ្លៃដើមវិនិយោគ។ រីឯការបង្កើតខ្ទង់ចំណាយផ្សេងៗទៀតត្រូវបានអនុវត្តតាមបទបញ្ជានៃបទដ្ឋានគតិយុត្តិរបស់សហគ្រាសចម្រុះ។ ជាមួយគ្នានេះ គណនីធានារ៉ាប់រងសង្គមក៏ត្រូវចាប់ផ្ដើមបង្កើតឡើងដែរស្របទៅតាមច្បាប់ការងារនៃប្រទេសកម្ពុជា។

ចំពោះការប្រឹងប្រែងរបស់រដ្ឋលើការទាក់ទាញមូលធនបរទេសសម្រាប់កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនក្នុងស្រុក យើងឃើញថា

រដ្ឋាភិបាលក៏បានសន្យា( ដោយយោងលើច្បាប់)បន្ថែមទៀតក្នុងការផ្តល់ភាពអនុគ្រោះយ៉ាងខ្លាំងចំពោះវិនិយោគិនបរទេសពាក់ព័ន្ធទៅនឹងប្រភេទពន្ធពីរប្រភេទ គឺពន្ធលើប្រាក់បង្វិល និងពន្ធលើប្រាក់ចំណេញ។ សម្រាប់គោលដៅជំរុញការនាំចេញមិនត្រូវបានយកពន្ធលើប្រាក់បង្វិលចំពោះប្រភេទទំនិញទាំងឡាយដែលមានមុខងារសម្រាប់តែការនាំចេញ ហើយអត្រាកំណត់ពន្ធលើប្រាក់ចំណេញវិញ គឺមានទំហំតែ១៥%ទៅ២៥% ប៉ុណ្ណោះដោយអាស្រ័យលើអាទិភាពនៃវិស័យផ្សេងៗគ្នា។ ដោយឡែក ការកំណត់ពន្ធលើប្រាក់ចំណេញសម្រាប់វិស័យកែច្នៃធនធានធម្មជាតិ គឺមានអត្រាពន្ធខ្ពស់ជាងទំហំខាងលើនេះ។

នៅក្នុងការបណ្តាក់ទុនវិនិយោគលើវិស័យថ្មីៗនៃសេដ្ឋកិច្ចកម្ពុជា ដោយសារតែកង្វះទំនុកចិត្តលើស្ថិរភាពនយោបាយនៅក្នុងប្រទេស យើងឃើញថា បរិយាកាសនៃការវិនិយោគបរទេសនៅសម័យនោះមិនទាន់អំណោយផល សម្រាប់អ្នកវិនិយោគបរទេសនោះឡើយដែលភាពស្មុគស្មាញទាំងអស់នោះរួមមាន ៖

- បញ្ហាអស្ថិរភាពផ្នែកនយោបាយ
- ភាពមិនហ្នឹងនរនៃរូបិយវត្ថុជាតិ
- តុល្យភាពជញ្ជីងពាណិជ្ជកម្ម មានលក្ខណៈឱនភាពរ៉ាំរ៉ៃ
- ការិយាល័យធិបតេយ្យក្បាលម៉ាស៊ីនដឹកនាំរដ្ឋ មានកម្រិតខ្ពស់
- ចង្វាក់កំណើនសេដ្ឋកិច្ច មានកម្រិតទាប
- បទដ្ឋានច្បាប់ និងគតិយុត្តិមិនទាន់មានភាពសុក្រឹតដែលអាចទុកចិត្តបាន
- ស្ថាប័នទូរគមនាគមន៍ និងដឹកជញ្ជូនមានភាពអន់ថយ
- អវត្តមានចំពោះលទ្ធភាពទទួលបានប្រាក់ឥណទានទាំងរយៈពេលខ្លី និងវែង។

បើយើងធ្វើការបូកសរុបអត្ថន័យទាំងស្រុងនៅក្នុងជំពូកនេះ ធ្វើឱ្យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យើងអាចវាយតម្លៃដោយឥតសង្ស័យបានថា រដ្ឋាភិបាលកម្ពុជាសម័យនោះបានចាត់ទុកថា ការដោះស្រាយបញ្ហាសេដ្ឋកិច្ចសម្រាប់រយៈពេលខ្លី និងវែងតាមរយៈរូបភាពគោលនយោបាយប្រពលកម្មការអភិវឌ្ឍសេដ្ឋកិច្ចដោយឈរលើមូលដ្ឋានគ្រឹះនៃការប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាថ្មី និងផ្អែកលើលទ្ធភាពរបស់ខ្លួន គឺបានរៀបចំលក្ខខណ្ឌសម្រាប់ការបង្កើតឱ្យមានផលិតផលថ្មីៗជាច្រើននៃសេដ្ឋកិច្ចចំពោះអនាគតកាលថែមទាំងធ្វើការអូសទាញមធ្យោបាយផលិតកម្ម សម្រាប់ស្ថិរភាពនីយកម្មសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ-រូបិយវត្ថុ សម្រាប់ប្រទេសជាតិ។ ក៏ប៉ុន្តែ គោលនយោបាយទាកទាញមូលធនបរទេសខណៈនោះពុំទាន់បានផ្តល់បច្ច័យជាវិជ្ជមាននោះទេ ដោយសារតែបញ្ហាទំនាស់ផ្ទៃកនយោបាយរវាងបួកទាំងបួន(រដ្ឋាភិបាលហ៊ុន សែន ភាគីខាងសម្តេច នរោត្តម សីហនុ, សឺន សាន និងក្រុមខ្មែរក្រហម) និងមូលហេតុផ្សេងៗទៀត។

ដូច្នេះបន្ទាប់ពីបានសិក្សាស្រាវជ្រាវលើជំពូក២រួចមក យើងអាចធ្វើសេចក្តីសន្និដ្ឋានបានដូចខាងក្រោមនេះ ៖

- នៅប្រទេសកម្ពុជាបានដំណើរការពិនិត្យឡើងវិញលើយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចដោយចេញពីទស្សនទិន្នាការសង្គមនិយម(សេដ្ឋកិច្ចផែន-ការ)ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរី។ ការធ្វើកំណែទម្រង់ជាអាទិភាពនៃគោលនយោបាយសេដ្ឋកិច្ចក្នុងប្រទេស បានកំណត់យកទស្សនវិស័យគោល-នយោបាយសេដ្ឋកិច្ចដែលពុំមានការអភិវឌ្ឍ(ការធ្វើការប្រមូលផ្តុំក្នុងផលិតកម្មដោយបង្ខំ ភាពដាច់ខាតនិយមលើតួនាទីរដ្ឋក្នុងសេដ្ឋកិច្ច កម្មសិទ្ធិសង្គមលើមធ្យោបាយផលិតកម្ម និងយន្តការសេដ្ឋកិច្ចបញ្ជា) និងជាងនេះទៀតបង្កឱ្យមានភាពចាំបាច់ដល់ការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចជុំវិញការដឹកនាំនយោបាយរបស់រដ្ឋាភិបាលទៅរកការឯកភាពជាតិ។

- ជាផ្លែផ្កានៃការធ្វើសេរីភាវូបនីយកម្មលើដំណើរជីវិតសេដ្ឋកិច្ចក្នុងស្រុក យើងឃើញថា រដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់បំផុតលើគោល-

នយោបាយសេដ្ឋកិច្ចក្រៅប្រទេសទៅក្នុងប្រព័ន្ធជាអាទិភាពនៃការកែតម្រូវសេដ្ឋកិច្ចរបស់រដ្ឋ។ អាចបញ្ជាក់បន្ថែមថា ការដកខ្លួនចេញពីការបង្កើតកិច្ចសហប្រតិបត្តិការនៃបក្សសម្ព័ន្ធបង្រួបបង្រួមនៃឥណ្ឌូចិនឆ្ពោះទៅរកការពង្រីកឥទ្ធិពល ឬទំនាក់ទំនងសេដ្ឋកិច្ចជាមួយពិភពខាងក្រៅ ជាពិសេសជាមួយប្រទេសថៃបានផ្ដល់ជាមូលដ្ឋានគ្រឹះមួយដល់ការចាប់ផ្ដើមទំនាក់-ទំនងជាមួយថៃ។ លំហូរចូលមូលធនបរទេសមកក្នុងប្រទេសកម្ពុជា និងបច្ចេកវិទ្យាដែលកន្លងមក រូបភាពបែបនេះត្រូវបានគេចាត់ទុកថា ជាបាតុភូតអាណានិគមនិយមបែបថ្មី និងភាពមិនឯករាជ្យផ្នែកបច្ចេកវិទ្យាពីប្រទេសចក្រពត្តិនិយម ប៉ុន្ដែ ក្រោយមកត្រូវបានគេទទួលស្គាល់ថា ជាកត្តាគន្លឹះដែលធ្វើឱ្យមានកំណើនសេដ្ឋកិច្ចទៅវិញ។

- ដូច្នេះ សេរីភាវូបនីយកម្មសេដ្ឋកិច្ចបាននាំទៅរកការលើកកម្ពស់តួនាទីនៃការធ្វើទំនាក់ទំនងគ្នាផ្នែកសេដ្ឋកិច្ចក្រៅប្រទេសជាមួយបណ្ដាប្រទេសជាច្រើននៅលើពិភពលោកដែលជាមូលដ្ឋានគ្រឹះ សម្រាប់ឱ្យយើងឈានទៅរកការសិក្សាវិភាគដល់កំពូលខាងមុខទៀត។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៣
# ទិសដៅចម្បងនៃទំនាក់ទំនងសេដ្ឋកិច្ច
# ក្រៅប្រទេសនៃកម្ពុជា

## ៣.១ ទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាជាមួយស.ស.ស.ស និងជាមួយប្រទេសអឺរ៉ុបខាងកើត

*នៅក្នុងពិភពលោកយើងនេះ ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗពុំអាចកាត់ផ្ដាច់បានពីការចូលរួមក្នុងការដោះដូរជាសកលនូវទ្រព្យសម្ភារ ឬទំនិញ និងវត្ថុមានតម្លៃនានាដែលជាការបង្ហាញនូវទំនាក់ទំនងដែលផ្សារភ្ជាប់គ្នាទៅវិញទៅមករវាងរដ្ឋ និងរដ្ឋ។ ម្យ៉ាងវិញទៀត ទោះបីជាប្រទេសនោះមានទំហំតូច ឬធំយ៉ាងណាក៏ដោយ ក៏ប៉ុន្តែ កម្រិតនៃការអភិវឌ្ឍវិស័យសេដ្ឋកិច្ចរបស់គេអាចទទួលបានផលប្រយោជន៍ពីការចូលរួមក្នុងបំណែងចែកពលកម្មអន្តរជាតិ។ ក្នុងន័យនេះដែរ សម្រាប់ប្រទេសកម្ពុជាយើងដែលជាប្រទេសពឹងផ្អែកលើវិស័យកសិកម្ម ហើយបាននិងកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការចាប់ផ្ដើមការអភិវឌ្ឍវិស័យឧស្សាហូបនីយកម្មនោះ ហេតុដូចនេះ យើងកាន់តែមានតម្រូវការថែមទៀតក្នុងការចូលរួមយ៉ាងសកម្មក្នុងចរន្តសេដ្ឋកិច្ចសកល។*

*ស្របតាមជំហាននៃការស្ដារសេដ្ឋកិច្ចជាតិរបស់ខ្លួន ប្រទេសកម្ពុជានាទសវត្សរ៍ទី៨០បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាដល់ការពង្រីកកិច្ចសហការសេដ្ឋកិច្ចក្រៅប្រទេសជាមួយបណ្ដាប្រទេសក្នុងសកលលោកដែលក្នុងនោះរួមមានសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត( ស.ស.ស.ស)*

និងប្រទេសនៅប៉ែកអឺរ៉ុបខាងកើតផងដែរ។

ដោយឡែក អន្តរាគមន៍នៃកងទ័ពវៀតណាមនៅចុងឆ្នាំ១៩៧៨មកក្នុងប្រទេសកម្ពុជាបានធ្វើឱ្យបញ្ចប់របបប្រល័យពូជសាសន៍ ប៉ុល ពត ហើយក៏បានបង្កើតរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននេះឡើងដែរ។ ក្នុងស្ថានភាពបែបនេះ យើងពិនិត្យឃើញថា បានធ្វើឱ្យប្រទេសមូលធននិយមនានា និងប្រទេសកំពុងអភិវឌ្ឍជាច្រើននៅលើពិភពលោកមានប្រតិកម្មជាអវិជ្ជមានចំពោះការបង្កើតរដ្ឋាភិបាលថ្មីដែលបានទ្រទ្រង់ដោយកងទ័ពវៀតណាមនៅកម្ពុជា។ ពួកគេថែមទាំងបានសម្រេចចិត្តដាក់ទណ្ឌកម្មសេដ្ឋកិច្ចដល់ប្រទេសកម្ពុជាយើងដែលជាការដាក់សម្ពាធខាងសេដ្ឋកិច្ច និងនយោបាយផងដែរ។

ក្នុងលក្ខខណ្ឌនៃការហ៊ុមព័ទ្ធសេដ្ឋកិច្ចប្រឆាំងនឹងប្រទេសកម្ពុជាដោយបណ្ដាប្រទេសមូលធននិយម កម្ពុជាបានកំណត់ទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រទេសរបស់ខ្លួន និងបានពង្រឹងកិច្ចសហការសេដ្ឋកិច្ចលើគ្រប់វិស័យជាមួយបណ្ដាប្រទេសសង្គមនិយមទាំងឡាយនាសម័យកាលនោះ។ ហេតុដូចនេះ ការអភិវឌ្ឍ និងការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្រៅប្រទេសជាមួយនឹងប្រទេសទាំងអស់នោះគឺជាអាទិភាពដ៏សំខាន់របស់រដ្ឋាភិបាល។ យ៉ាងណាមិញ ក្នុងសេចក្ដីថ្លែងការណ៍របស់គណៈកម្មការមជ្ឈិមបក្សនៃបក្សប្រជាជនបដិវត្តន៍កម្ពុជានៅក្នុងមហាសន្និបាតដែលបានប្រារព្ធឡើងនាឆ្នាំ១៩៨៥ សមមិត្ត ហេង សំរិន បានធ្វើសេចក្ដីថ្លែងការមួយថា ៖ «កិច្ចសហប្រតិបត្តិការជាមួយសហភាពសូវៀត និងបណ្ដាប្រទេសសង្គមនិយមដទៃទៀត គឺជាការធានាដ៏សំខាន់បំផុតដល់ការស្ដារឡើងវិញ និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសយើង»។[១] នៅក្នុងន័យនេះ ប្រទេសកម្ពុជាបានប្រើប្រាស់ប្រាក់កម្ចីពីសហភាពសូវៀត និងពីបណ្ដាប្រទេសនៅអឺរ៉ុប

---

[១] មហាសន្និបាតបក្សទូទាំងប្រទេសលើកទី៥ ភ្នំពេញ ១៩៨៥ ទំព័រ.៤០

ខាងកើត ដើម្បីទិញគ្រឿងយន្តឧស្សាហកម្ម សម្រាប់រោងចក្រអគ្គិសនី គ្រឿងបរិក្ខារ សម្រាប់ការស្តារឡើងវិញនូវរោងចក្រសហគ្រាស និងសម្រាប់ការទិញត្រាក់ទ័រ និងបរិក្ខារកសិកម្ម ផលិតផលតេលសិលា(ផលិតផលប្រេង) និងវត្ថុធាតុចាំបាច់ផ្សេងៗទៀត។ ចំពោះការផ្តល់ឥណទានតាមរូបភាពកម្ចីរយៈពេលវែងបានអនុញ្ញាតឱ្យប្រទេសកម្ពុជាយើងអាចប្រើប្រាស់ធនធានបន្ថែម សម្រាប់ការពង្រីងសក្តានុពលផលិតកម្មរបស់ប្រទេស។ ក៏ប៉ុន្តែ ស្ថានភាពភូមិសាស្ត្រនៃប្រទេសបានធ្វើឱ្យយើងជួបប្រទះភាពលំបាកក្នុងការអភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្មក្រៅប្រទេសជាមួយនឹងប្រទេសអឺរ៉ុបខាងកើត។ ដូច្នេះហើយ ទំនិញមួយចំនួនតម្រូវឱ្យប្រទេសកម្ពុជាត្រូវធ្វើពាណិជ្ជកម្មជាមួយប្រទេសនៅតំបន់អាស៊ីដែលជាអ្នកជិតខាងរបស់ខ្លួនទើបទទួលផលចំណេញបានច្រើនជាង។

ក៏ប៉ុន្តែ ទិសដៅនៃការអភិវឌ្ឍកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយនឹងបណ្តាប្រទេសសង្គមនិយមនាសម័យកាលនោះ គឺមិនគ្រាន់តែជាផលវិបាកម៉្យាងដែលកើតចេញពីទណ្ឌកម្មសេដ្ឋកិច្ចរបស់បស្ចិមប្រទេសប៉ុណ្ណោះទេ ប៉ុន្តែ វាជាចំណែកដ៏សំខាន់មួយនៃនិន្នាការនយោបាយដែលមានទំនោរទៅរកលទ្ធិសង្គមនិយម តាមរយៈការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មលើគ្រប់វិស័យជាមួយបណ្តាប្រទេសសង្គមនិយមទាំងឡាយ ហើយក៏ជាកិច្ចការយ៉ាងសំខាន់ផងដែរដល់ការចូលរួមចំណែករបស់កម្ពុជាទៅក្នុងចលនាបំណែងចែកពលកម្មលើវិស័យមូលធនអន្តរជាតិ។ ជាងនេះទៀត នៅក្នុងឯកសារនយោបាយរបស់បក្ស និងរដ្ឋាភិបាល អ្នកដឹកនាំកម្ពុជាតែងតែប្រកាសអំពីគោលជំហរមិនកែប្រែក្នុងការប្រកាន់យក «មាគ៌ាសង្គមនិយម»។ ហេតុនេះហើយ សម្រាយបញ្ជាក់ខាងលើនេះបង្ហាញផែនការជាយុទ្ធសាស្ត្ររយៈពេលវែងដែលត្រូវបានកំណត់អំពីនិន្នាការជុំវិញទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាជាមួយនឹងបណ្តាប្រទេសសង្គមនិយមនានានៅសម័យកាលនោះ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះការវិវឌ្ឍលើកិច្ចសហប្រតិបត្តិការរវាងសហភាពសូវៀតជាមួយនឹងប្រទេសកម្ពុជាយើង គឺត្រូវបានផ្អែកលើមូលដ្ឋានកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ដ៏រឹងមាំ។ ក្នុងនោះដែរ ដូចជានៅឆ្នាំ១៩៨០ យើងពិនិត្យឃើញថា ប្រទេសទាំងពីរបានត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីការផ្គត់ផ្គង់ទំនិញពីប្រទេសសហភាពសូវៀតមកកាន់ប្រទេសកម្ពុជា កិច្ចព្រមព្រៀងស្តីអំពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស និងពិធីសារស្តីអំពីការចាត់តាំងតំណាងពាណិជ្ជកម្មរបស់ស.ស.ស.សនៅកម្ពុជា ព្រមទាំងកិច្ចព្រមព្រៀងស្តីអំពីការផ្តល់ជំនួយបឋមផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស សម្រាប់ការស្តារឡើងវិញនូវគ្រប់វិស័យសេដ្ឋកិច្ចជាតិ និងដើម្បីធ្វើឱ្យមានដំណើរការលើកិច្ចការទាំងអស់។ កិច្ចព្រមព្រៀងពាណិជ្ជកម្មបានកំណត់ផងដែរនូវគោលការណ៍សេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសទាំងពីរដែលភាគីទាំងពីរត្រូវតែផ្តល់ឱ្យគ្នាទៅវិញទៅមកនូវប្រព័ន្ធអនុគ្រោះគ្រប់បែបយ៉ាងដែលទាក់ទងទៅនឹងវិស័យពាណិជ្ជកម្ម ក៏ដូចជាទំនាក់ទំនងផ្នែកសេដ្ឋកិច្ចផ្សេងៗទៀត ព្រមទាំងការដឹកជញ្ជូនតាមកប៉ាល់ វិធីកំណត់តម្លៃលើទំនិញដែលបានផ្គត់ផ្គង់ ការទូទាត់សាច់ប្រាក់ និងដំណោះស្រាយជម្លោះជាដើម។ ម្យ៉ាងវិញទៀត ភាគីទាំងពីរជាការចាំបាច់ត្រូវតែប្រើឱ្យអស់ពីលទ្ធភាពរបស់ខ្លួនសំដៅអភិវឌ្ឍទំនាក់ទំនងវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្មរបស់ខ្លួន។ ជាក់ស្តែងនៅក្នុងឆ្នាំ១៩៨៣ ជាលើកទីមួយក្នុងប្រវត្តិសាស្ត្រ យើងឃើញថា ទំនាក់-ទំនងសេដ្ឋកិច្ចរវាងប្រទេសសូវៀតជាមួយប្រទេសកម្ពុជាដែលមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីកិច្ចការពាណិជ្ជកម្ម និងការទូទាត់ប្រាក់សម្រាប់ឆ្នាំ១៩៨៣ដល់ឆ្នាំ១៩៨៥។ កិច្ចព្រមព្រៀងនេះត្រូវបានបំពេញបន្ថែមជារៀងរាល់ឆ្នាំ ដោយពិធីសារស្តីអំពីពាណិជ្ជកម្ម និងការទូទាត់សាច់-ប្រាក់។ បន្ទាប់ពីអស់សុពលភាពនៃកិច្ចព្រមព្រៀងដូចដែលបានរៀបរាប់ខាងលើនេះ នៅឆ្នាំ១៩៨៥ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាបន្តទៀតស្តីអំពីការផ្លាស់ប្តូរទំនិញ និងការទូទាត់សាច់ប្រាក់ សម្រាប់ឆ្នាំ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៩៨៦ដល់ឆ្នាំ១៩៩០ដែលបានកំណត់ទិសដៅជាបន្តបន្ទាប់ ជុំវិញចំណង ពាណិជ្ជកម្មរវាងស.ស.ស.ស និងរដ្ឋកម្ពុជានាសម័យកាលនោះ។

**តារាងលេខ១០**

**សក្ដានុពលពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាជាមួយបណ្ដាប្រទេស អឺរ៉ុបខាងកើត និងស.ស.ស.ស ចន្លោះឆ្នាំ១៩៨២ដល់១៩៨៩**

| ប្រទេស | ១៩៨២ | | ១៩៨៧ | | ១៩៨៩ | |
|---|---|---|---|---|---|---|
| | ពាន់រូប្ល | % | ពាន់រូប្ល | % | ពាន់រូប្ល | % |
| ស.ស.ស.ស | ៥៥៧០០ | ៩៣,៩៩ | ១២២៤០០ | ៩៥,៥១ | ១៤២៧៩១ | ៩១,៣២ |
| ឆេកូស្លូវ៉ាគី | ១៥៨២ | ២,៥៧ | ១៩៩៦ | ១,៥៥ | ៤០៣២ | ២,៥៧ |
| ប៊ុលហ្គារី | ១២៦០ | ២,១២ | ១២៩៨ | ១,០១ | ៣០៧៣ | ១,៩៦ |
| ហុងគ្រី | ៣៦៣ | ០,៦១ | ១២៩០ | ១,០០ | ១៨៥១ | ១,១៨ |
| ប៉ូឡូញ | ៤១០ | ០,៧១ | ១១៧៥ | ០,៩១ | ៤៦០០ | ២,៩៤ |
| **សរុប** | **៥៩២៦១** | **១០០** | **១២៨១៥៩** | **១០០** | **១៥៦៣៤៧** | **១០០** |

**ដកស្រង់ពី ៖ របាយការណ៍ក្រសួងពាណិជ្ជកម្មចំពោះក្រុមប្រឹក្សារដ្ឋមន្ត្រី, ភ្នំពេញ១៩៨៨**

គួរបញ្ជាក់ដែរថា ទម្រង់គោលនៃទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេស រវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសស.ស.ស.ស និងបណ្ដាប្រទេសអឺរ៉ុប ខាងកើត គឺមានការពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មក្រៅប្រទេស។ ជាងនេះ ទៀត ទំហំបម្លាស់ប្ដូរទំនិញក្រៅប្រទេសជាមួយនឹងប្រទេសទាំងអស់នោះ មានការកើនឡើងលើសពី២ដងទៅទៀតនៅចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៩ ដែលមានទំហំរហូតដល់ទៅ១៥៦,៣៤លានរូប្ល។ ក៏ប៉ុន្តែ កំណើនដ៏ឆាប់រហ័ស នេះបានកើតឡើងដោយសារតែកំណើននៃបម្លាស់ប្ដូរទំនិញជាមួយនឹង ប្រទេសស.ស.ស.សដែលមានទំហំប្រមាណជា៩១,៣២%ដល់៩៥,៥%  ធៀបទៅនឹងបម្លាស់ប្ដូរទំនិញជាមួយបណ្ដាក្រុមប្រទេសទាំងនេះ។ តាមរយៈ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្លឹមសារនេះ យើងពិនិត្យឃើញថា ស.ស.ស.សគឺជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតក្នុងចំណោមប្រទេសទាំងអស់ខាងលើនេះ។ ហើយបន្ទាប់ពីស.ស.ស.សក៏មានប្រទេសជាបន្តបន្ទាប់ទៀត គឺប៉ូឡូញ ឆេកូស្លូវ៉ាគី ប៊ុលហ្គារី និងហុងគ្រីផងដែរ។

ចំពោះចំណាត់ថ្នាក់លេខមួយផ្នែកទំនិញនាំចូលពីស.ស.ស.សមកកាន់ប្រទេសកម្ពុជាយើង គឺគ្រឿងម៉ាស៊ីន និងបរិក្ខារផ្សេងៗទៀត។ ក្នុងឆ្នាំ១៩៨០ ការនាំចូលទំនិញពីស.ស.ស.សស្ទើរតែទាំងអស់ គឺជាគ្រឿងម៉ាស៊ីនបរិក្ខារនានា និងមធ្យោបាយដឹកជញ្ជូន។ នៅឆ្នាំបន្តបន្ទាប់ទៀត ក៏មានការកើនឡើងផងដែរនូវវិស័យដទៃៗទៀត។ ដូចជានៅឆ្នាំ១៩៨៩ វិស័យទាំងនោះបានកើនឡើងដល់៤៧,៧%នៃទំហំនាំចូលសរុបដែលមានតម្លៃជាទឹកប្រាក់ប្រមាណជា៦១,៣លានរូប្លិ៍។ ការនាំចូលនេះបានគ្របដណ្តប់រហូតដល់ទៅប្រមាណ៦០%នៃតម្រូវការក្នុងស្រុក។ ហើយដោយសារតែការផ្គត់ផ្គង់ទំនិញឧស្សាហកម្មពីសហភាពសូវៀត បានធ្វើឱ្យរោងចក្រ និងសហគ្រាសជាច្រើននៅកម្ពុជាដែលកន្លងមកធ្លាប់បានបំផ្លិចបំផ្លាញដោយរបបប៉ុល ពតត្រូវបានស្តារឱ្យដំណើរការឡើងវិញ។ ម្យ៉ាងទៀត ការផ្គត់ផ្គង់នេះបានបង្កលក្ខណៈដល់ការស្តារវិស័យហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយ៉ាងឆាប់រហ័សក្នុងនោះមានកំពង់ផែសមុទ្រនៅក្រុងកំពង់-សោម កំពង់ផែថ្មទន្លេបួនមុខនៅក្រុងភ្នំពេញ ផ្លូវអាកាសយានយាន និងផ្លូវថ្នល់ផងដែរ។ យើងគួរកត់សម្គាល់ផងដែរអំពីតួនាទីនៃការផ្គត់ផ្គង់ទំនិញពីស.ស.ស.សក្នុងការស្តារ និងអភិវឌ្ឍវិស័យឧស្សាហកម្មថាមពលក្នុងប្រទេសកម្ពុជា។

ចំណាត់ថ្នាក់ទីពីរបានទៅលើវិស័យនាំចូលប្រេងឥន្ធនៈដែលផ្តោតទៅលើប្រេង និងផលិតផលតេលសិលា(ផលិតផលប្រេងកាត)ដែលមានការកើនឡើងដល់ទៅពីរដងក្នុងឆ្នាំ១៩៨៩ធៀបនឹងឆ្នាំ១៩៨១ ពោលគឺក្នុងទំហំរហូតដល់ទៅ៣១,២លានរូប្លិ៍ មានន័យថា ២៤,៣១%នៃទំហំទំនិញនាំចូលសរុបពីប្រទេសស.ស.ស.សក្នុងឆ្នាំនោះដែរ។ ការនាំចូលប្រេង និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលិតផលតេលសិលាពីប្រទេសស.ស.ស.ស គឺបានគ្របដណ្ដប់ស្ទើរតែ ៩៥%នៃតម្រូវការទំនិញដ៏ចាំបាច់ទាំងអស់នេះ។ ហើយមកដល់ឆ្នាំ១៩៩០ យើងឃើញថា ស.ស.ស.សបានផ្គត់ផ្គង់ទំនិញដល់ប្រទេសកម្ពុជាប្រមាណ ២០០លានតោន ជាប្រេងឥន្ធនៈ និងផលិតផលតេលសិលាដែលបំពេញ ដល់តម្រូវការក្នុងស្រុក មិនត្រឹមតែនៅក្នុងវិស័យសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ក៏ប៉ុន្ដែ សម្រាប់បំពេញតម្រូវការក្នុងវិស័យយោធាថែមទៀតផង ពោលគឺ ក្នុងនោះមានតែ៤០%ទៅ៥០% ឬប្រមាណជា៧០ទៅ៨០ពាន់តោននៃ ផលិតផលតេលសិលាដែលសម្រាប់ការបម្រើដល់វិស័យស៊ីវិល។ ក្នុងស្ថានភាព នៃការបញ្ចប់សកម្មភាពលើវិស័យយោធានៅក្នុងប្រទេសយើង ទើបអាច បង្វែរធនធានទាំងអស់នេះ សម្រាប់ការអភិវឌ្ឍដល់វិស័យសេដ្ឋកិច្ចទៅបាន។

**តារាងលេខ១១**

**រចនាសម្ព័ន្ធនៃការនាំចូលទំនិញពីស.ស.ស.សមកកាន់កម្ពុជា(គិតជា%)**

| ឈ្មោះមុខទំនិញ | ១៩៨០ | ១៩៨៥ | ១៩៨៩ |
|---|---|---|---|
| ១. គ្រឿងចក្រ បរិក្ខារ និងយានយន្ត | ៩៣,៦២ | ៣៦,៧០ | ៤៧,៧១ |
| ក) បរិក្ខារថាមពល | | | ៤,៦៨ |
| ខ) បរិក្ខារសម្រាប់ឧស្សាហកម្មគីមី | | ២,២១ | ១,៣៨ |
| គ) បរិក្ខារ និងគ្រឿងចក្រគមនាគមន៍ និងសំណង់ផ្លូវ | | ១,៦៧ | ២,៩៩ |
| ឃ) គ្រឿងយន្តកសិកម្ម និងរុក្ខផលិតកម្ម | | | |
| ង) គ្រឿងយន្តជាពសាស្ត្រ និងវារីវប្បកម្ម | ៣,៨១ | ០,៣២ | ១,៦៧ |
| ច) រថយន្តដឹកទំនិញ(គ្រឿង) | | ១០,៣៦ | ៧,៦៤ |
| ឆ) រថយន្តដឹកអ្នកដំណើរ(គ្រឿង) | | ០,១៧ | ០,៦៣ |
| ជ) បច្ចេកវិទ្យាអាកាសចរណ៍ | | | ៨,២៧ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | |
|---|---|---|---|
| ២) ផលិតផលតេលសិលា និងប្រេងឥន្ធនៈសំយោគរាវ | | ៣២,៣៩ | ២៤,៣១ |
| ៣) ផលិតផលវាយនភណ្ឌពោមសត្វ(ពាន់តោន) | | ២,៥១ | ១,១៤ |
| ៤) គ្រុណាត់អំបោះ | | ៣,៨៤ | ៣,៤៧ |
| ៥) បេសអំបោះ | | ២,៦៨ | ១,៩៩ |
| ៦) ទំនិញជាឱសថ | | ២,៤៣ | ១,១៣ |
| **សរុប** | **១០០** | **១០០** | **១០០** |

**ប្រភព ៖ សៀវភៅកម្រងស្ថិតិ ៖ ពាណិជ្ជកម្មក្រៅប្រទេសស.ស.ស.ស ចន្លោះឆ្នាំ១៩៨៦ដល់ ១៩៨៧, ទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសស.ស.ស.ស ចន្លោះឆ្នាំ១៩៨៨ ដល់១៩៨៩**

តារាងខាងលើបង្ហាញថា ទំហំនៃការផ្គត់ផ្គង់ប្រេងឥន្ធនៈពីស.ស.ស.ស ទៅកាន់ប្រទេសកម្ពុជាមាននិន្នាការថយចុះ។ រហូតដល់ឆ្នាំ១៩៩១ យើងអាចកត់សម្គាល់បានថា ការថយចុះចំពោះការផ្គត់ផ្គង់ប្រេងឥន្ធនៈមកកាន់ប្រទេសកម្ពុជា គឺមានប្រមាណជា១៥០ពាន់តោន។ ហើយការផ្គត់ផ្គង់មួយចំណែកត្រូវបានបង់តាមតម្លៃរូបិយប័ណ្ណនៃទីផ្សារសេរី ហើយមួយចំណែកទៀតជាការដោះដូរទំនិញតាមកិច្ចព្រមព្រៀង(ដូរជាមួយការផ្គត់ផ្គង់កៅស៊ូធម្មជាតិ)។

ក្រៅពីនេះទៀត កំណើននៃការនាំចូលទំនិញពីស.ស.ស.សក្នុងទសវត្សរ៍ទី៨០បានកើតឡើងដោយសារតែកំណើននៃការផ្គត់ផ្គង់គ្រឿងចក្រ គ្រឿងបរិក្ខារផ្សេងៗ យានយន្ត និងផលិតផលតេលសិលា ហើយក៏ដោយសារតែការពង្រីកចំនួនមុខទំនិញដទៃទៀតផងដែរ(រួមមាន ៖ បរិក្ខារថាមពល បច្ចេកវិទ្យាអាកាសចរណ៍ គ្រឿងយន្តកសិកម្ម និងវត្ថុផលិតកម្មជាដើម)។

## ៣.១.១ អតុល្យភាពពាណិជ្ជកម្ម និងវិធានការកាត់បន្ថយអតុល្យភាព

ចំពោះទំនាក់ទំនងលើវិស័យពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសកម្ពុជានាសម័យកាលនោះ ជាមួយនឹងប្រទេសស.ស.ស.ស បានដំណើរ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការឡើងពោរពេញទៅដោយអតុល្យភាពយ៉ាងខ្លាំង។ ព្រោះថា ការនាំចេញទំនិញនានាទៅកាន់ស.ស.ស.សបានគ្របដណ្តប់ប្រមាណតែ១០%ទៅ១២% នៃទំហំទំនិញនាំចូលសរុបតែប៉ុណ្ណោះ។ ទោះបីជាទំហំនៃការនាំចេញទៅកាន់ស.ស.ស.សបានកើនឡើងរហូតដល់ទៅ៨ដងធៀបទៅនឹងឆ្នាំ១៩៨០ក៏ដោយ ប៉ុន្តែក្នុងឆ្នាំ១៩៨៨ វាមានទំហំត្រឹមតែ១៣,១លានរូប្លិ៍តែប៉ុណ្ណោះ។ ម្យ៉ាងទៀត រចនាសម្ព័ន្ធមុខទំនិញនាំចេញទាំងនោះមានតិចតួចបំផុតដែលផ្អែកជាសំខាន់តែទៅលើកៅស៊ូធម្មជាតិដែលស្មើនឹង៨០%ទៅ៩០%នៃការនាំចេញសរុបប្រចាំឆ្នាំ។ ហើយក្នុងបរិមាណដ៏តិចតួចណាស់ដែលកម្ពុជាបាននាំចេញទៅកាន់ស.ស.ស.សនូវផលិតផលកប្បាស ថ្នាំជក់ ម្រេច ពោត ផលិតផលឈើតំបន់ត្រូពិកដែលមានតម្លៃ និងផលិតផលកសិកម្មផ្សេងៗទៀត។

ក្នុងចន្លោះឆ្នាំ១៩៨១ដល់១៩៨៩ បម្លាស់ប្តូរទំនិញរវាងកម្ពុជាជាមួយនឹងស.ស.ស.សបានកើនឡើងប្រមាណ២,២៨ដង ប៉ុន្តែកំណើនទាំងនេះ គឺកើតឡើងដោយសារតែកំណើននៃការផ្គត់ផ្គង់ពីភាគីស.ស.ស.ស រីឯចំណែកពីភាគីកម្ពុជាវិញ គឺមានតែ៦%ពីការនាំចេញពីកម្ពុជាទៅកាន់ស.ស.ស.ស។ អតុល្យភាពទាំងអស់នេះត្រូវបានបំពេញដោយឥណទាន(កម្ចី)ពាណិជ្ជកម្មដែលក្នុងដំណាក់កាលនោះ យើងពិនិត្យឃើញថា បំណុលរបស់ប្រទេសកម្ពុជាតាមរយៈឥណទានពាណិជ្ជកម្មមានចំនួនរហូតដល់៧៩២,៣លានរូប្លិ៍។ ហេតុនេះ ដោយសារការជំពាក់មានសភាពរ៉ាំរ៉ៃ ហើយការប្រាក់ក៏កាន់តែមានចំនួនកើនឡើងដែលបានធ្វើឱ្យកើតមានឧបសគ្គដ៏ធំធេង សម្រាប់អនាគតនៃការពង្រីកទំនាក់ទំនងវិស័យពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ ការលុបបំបាត់អតុល្យភាពវិស័យពាណិជ្ជកម្មនេះអាចធ្វើទៅបានលុះត្រាតែយើងមានលទ្ធភាពពង្រីកមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចកម្ពុជា និងការធ្វើពិពិធកម្មការនាំចេញ។ ជាងនេះទៀត ដោយសារតែតម្លៃកម្លាំងពលកម្មទាបនៅកម្ពុជា បានទាក់ទាញការផ្គត់ផ្គង់ផលិតផលវាយនភណ្ឌដែលជាផលិតផលសម្រេចដោយផ្ទួចផ្តើមមកវិញពីប្រទេសថៃ និងពីបណ្តាប្រទេស

អាស៊ីដទៃទៀតដូចជាក្រណាត់ និងសម្ភារផ្សេងៗទៀត។

**តារាងលេខ១២**

**ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ប្រទេស ស.ស.ស.ស**

| | ១៩៨២ | | ១៩៨៥ | | ១៩៨៩ | |
|---|---|---|---|---|---|---|
| | តម្លៃគិតជាពាន់រូប្លិ៍ | % | តម្លៃគិតជាពាន់រូប្លិ៍ | % | តម្លៃគិតជាពាន់រូប្លិ៍ | % |
| ១. កៅស៊ូធម្មជាតិ | ២៣៣៤ | ១០០ | ៨៥៥២ | ៩៣,៩៧ | ៩៨៤៣ | ៨០,០២ |
| ២. សម្ភារសំណង់ធ្វើពីឈើ និងថ្ម | | | | | ១៤៣៧ | ១១,៦៨ |
| ៣. ពោត | ២៣៣៤ | ១០០ | ៩១០០ | ១០០ | ១២៣០០ | ១០០ |

**ប្រភព ៖ សៀវភៅកម្រងស្ថិតិ ៖ ទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសស.ស.ស.ស ចន្លោះឆ្នាំ១៩៨២ដល់១៩៨៩**

មានវិធីសាស្ត្រមួយទៀតក្នុងការលុបបំបាត់អតុល្យភាពជញ្ជីងពាណិជ្ជកម្មនេះ គឺការកាត់បន្ថយបរិមាណនាំចូលទំនិញពីប្រទេសស.ស.ស.ស ជាពិសេសទំនិញដែលខ្វះខាតនៅស.ស.ស.សដូចជាក្រណាត់ ផលិតផលឱសថ វត្ថុប្រើប្រាស់ជាដើម។ ដោយហេតុថា ទំនិញទាំងអស់នោះ យើងអាចប៉ះប៉ូវបានដោយនាំចូលពីប្រទេសជិតខាងដូចជាប្រទេសថៃ សិង្ហបុរី និងប្រទេសផ្សេងៗទៀត។ លើសពីនេះទៅទៀតចំពោះការចំណាយលើការដឹកជញ្ជូនក៏មានចំនួនតិចជាងច្រើនដងផងដែរ។ ហើយបញ្ហាតុល្យភាពរវាងការនាំចេញទំនិញ និងការនាំចូលអាចកើតឡើងបានដោយសារការអនុវត្តគោលនយោបាយសំចៃការនាំចូលក៏អាចថាបាន។

ដើម្បីកាត់បន្ថយកំណើននៃបំណុលរបស់កម្ពុជា យើងឃើញថា នៅខែវិច្ឆិកា ឆ្នាំ១៩៨៩ ក្នុងជំនួបមួយនៃគណៈកម្មការអន្តររដ្ឋាភិបាលនៃប្រទេសទាំងពីរដែលទទួលបន្ទុកផ្នែកសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងសហប្រតិបត្តិការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានជួបប្រជុំគ្នា និងបានចេញជាសេចក្តីសម្រេចមួយស្តីអំពីការផ្លាស់ប្តូរទំនិញ តុល្យការ និងការដោះដូរទំនិញរវាងប្រទេសទាំងពីរក្នុងទិសដៅបង្កើនការយកចិត្តទុកដាក់ខ្ពស់របស់ភាគីទាំងសងខាង ដើម្បីបង្កើនបម្លាស់ប្តូរទំនិញ និងបង្កើនគុណភាពទំនិញដែលត្រូវផ្គត់ផ្គង់ ដែលតាមទស្សនៈរបស់យើង ចំពោះបញ្ហានេះ គប្បីកំណត់តម្លៃដោះដូរគ្នាឱ្យបានសមរម្យដោយប្តូរពីការគិតជារូបិយប័ណ្ណរូបូសុទ្ធទៅជារូបិយប័ណ្ណដែលអាចចាយវាយបានលើទីផ្សារសេរី(ដុល្លារអាមេរិក)ដែលក្នុងបញ្ហានេះដែរ តាមពិសោធន៍បានបង្ហាញថា ចំពោះការទូទាត់ជាលុយរូបូសុទ្ធ ភាគីទាំងអស់បានផ្គត់ផ្គង់ឱ្យគ្នានូវទំនិញដែលមានគុណភាពទាប ឬទំនិញនានាដែលនៅសល់ចាស់ៗ(បាតឃ្លាំង)។

ដោយឡែក ចំពោះការទាក់ទាញឱកាសក្នុងការបង្កលទ្ធភាពដល់ការបង្កើតឡើងនៅកម្ពុជាលើវិស័យផលិតកម្មដោយប្រើប្រាស់ពលកម្មក្នុងស្រុកសម្រាប់ឧស្សាហកម្ម ដើម្បីផលិតនូវផលិតផលសម្រេច សំដៅផ្គត់ផ្គង់ទីផ្សារ ស.ស.ស.ស គឺជាកិច្ចការដ៏ចាំបាច់។ ចលករសំខាន់ក្នុងការពង្រីកសហគ្រាសបែបនេះគឺជាលទ្ធភាពក្នុងការកាត់បន្ថយការចំណាយផលិតកម្មតាមរយៈការប្រើប្រាស់កម្លាំងពលកម្ម និងសម្ភារដែលមានតម្លៃទាប។ ជាពិសេសគឺជាទស្សនៈវិស័យមួយក្នុងការកសាងវិស័យបច្ចេកវិទ្យាដែលមិនស្មុគស្មាញពោលគឺវិស័យឧស្សាហកម្មកាត់ដេរនេះតែម្តង។

ទស្សនវិស័យមួយទៀតក្នុងការកាត់បន្ថយការផ្គត់ផ្គង់ទំនិញពីស.ស.ស.ស វាអាចផ្សារភ្ជាប់ទៅនឹងការបញ្ចប់នូវសកម្មភាពសង្គ្រាមស៊ីវិល និងការសម្របសម្រួលផ្ទៃក្នុងរវាងខ្មែរ និងខ្មែរលើបញ្ហានយោបាយនៅកម្ពុជា។ មូលហេតុចម្បង ដោយសារការផ្គត់ផ្គង់ទំនិញជាច្រើននាពេលកន្លងមកនេះ (ដូចជាផលិតផលតេលសិលា និងទំនិញផ្សេងៗទៀត) ភាគច្រើនគឺសំដៅលើការទ្រទ្រង់តែជុំវិញបញ្ហាសង្គ្រាមស៊ីវិលតែប៉ុណ្ណោះ។

មកដល់បច្ចុប្បន្ននេះ ការធ្វើទំនាក់ទំនងវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្ម


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រវាងស.ស.ស.សជាមួយនឹងប្រទេសកម្ពុជាគឺបានស្ថិតនៅលើដំណាក់កាលនៃរបត់ថ្មីមួយទៀត។ ហើយជាមួយនឹងការឈានចូលទៅកាន់ទំនាក់ទំនងថ្មីនេះ បែបទីផ្សារសេរីរបស់ប្រទេសទាំងពីរ យើងឃើញថា ទំនាក់ទំនងវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្មនៃប្រទេសទាំងពីរត្រូវតែឈរលើមូលដ្ឋានមួយប្រកបទៅដោយសមភាព និងការឯកភាពគ្នា ដោយទទួលបានផលចំណេញទាំងសងខាង។ ជាងនេះទៀត ចំពោះការវិវឌ្ឍទៅមុខឥតឈប់ឈរនៃទំនាក់ទំនងវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសទាំងពីរ គឺវាពិតជាអាស្រ័យយ៉ាងខ្លាំងទៅនឹងបញ្ហាដែលថា តើបញ្ហាបំណុលនឹងត្រូវដោះស្រាយបែបណា។ ជាមួយនឹងការឈានទៅរកតុល្យភាពក្នុងពេលដ៏ខ្លី ត្រូវមានការកាត់បន្ថយទំហំពាណិជ្ជកម្មរវាងស.ស.ស.សជាមួយនឹងប្រទេសកម្ពុជា ដោយហេតុថា ប្រទេសកម្ពុជាពុំមានលទ្ធភាពធំដុំនោះទេ ក្នុងការបង្កើនសក្តានុពលនាំចេញទំនិញរបស់ខ្លួនក្រោមមូលហេតុសេដ្ឋកិច្ចខ្ទេចខ្ទាំ។ នៅសម័យកាលនោះ គេសង្កេតឃើញមានការដកចេញពីកិច្ចសហប្រតិបត្តិការលំដាប់ម៉ាក្រូសេដ្ឋកិច្ច។ ហើយការផ្លាស់ប្តូរទំនាក់ទំនងវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងស.ស.ស.សជាមួយនឹងប្រទេសកម្ពុជាយើងបានឈានទៅរកលំដាប់មីក្រូវិញម្តង ដោយបានបំផុសក្នុងរបៀបវារៈនូវសំណួរថ្មីៗជាច្រើន។ បញ្ហាដែលសំខាន់ជាងគេនោះគឺ អត្រាតម្លៃ និងការទូទាត់រូបិយប័ណ្ណ។ ទាក់ទងទៅនឹងបញ្ហាតម្លៃទំនិញ ជាគោលការណ៍ ប្រហែលជាត្រូវកំណត់តាមតម្លៃទីផ្សារអន្តរជាតិ ឬមួយក៏តាមតម្លៃដែលព្រមព្រៀងគ្នា។ ហើយទាក់ទងទៅនឹងការគណនាសាឡើងវិញនូវអត្រាប្តូរប្រាក់នោះ គឺត្រូវបានពិនិត្យមើលសាជាថ្មីទៀតនូវអត្រាប្តូរប្រាក់រវាងប្រាក់រូប្លសុទ្ធជាមួយនឹងប្រាក់ដុល្លារសុទ្ធ។ ម្យ៉ាងទៀត ជាមួយការគណនាជាប្រាក់សុទ្ធនេះផងដែរ ក៏អាចកំណត់ដោយធៀបទៅនឹងរូបិយប័ណ្ណរឹងមាំដូចជាដុល្លារ។ លើសពីនេះទៀត ក៏អាចមានការចរចាគ្នាបន្ថែមទៀត ស្របតាមអត្រាតម្លៃជារូបិយ-ប័ណ្ណដែលបានប្តូរតាមទីផ្សារសេរីផងដែរ។

ក្រៅពីនិន្នាការខាងលើ កម្ពុជាក៏បានបង្កើនទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅអឺរ៉ុបខាងកើតដូចជាប្រទេស ប៊ុលហ្គារី ហុងគ្រី ប៉ូឡូញ ឆេកូស្លូវ៉ាគីផងដែរ។ ចំពោះកិច្ចសហការរវាងរដ្ឋាភិបាលកម្ពុជាជាមួយនឹងប្រទេសប៊ុលហ្គារី គឺបានចាប់ផ្តើមឡើងភ្លាមៗ ក្រោយពេលដែលរបបប៉ុល ពត ត្រូវបានដួលរលំនៅឆ្នាំ១៩៧៩។ ចំពោះតួនាទីដ៏សំខាន់ក្នុងប្រព័ន្ធទំនាក់ទំនងវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសទាំងពីរ គឺពាក់ព័ន្ធទៅនឹងវិស័យពាណិជ្ជកម្មក្រៅប្រទេសដែលបានកើតមានមិនត្រឹមតែកិច្ចប្រតិបត្តិការបែបទិញ-លក់ប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងមានទិសដៅចំពោះកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចផ្សេងៗទៀតផង។ ពាណិជ្ជកម្មក្រៅប្រទេសជាមួយនឹងប្រទេសទាំងអស់នោះ ជាញឹកញាប់ បានផ្សារភ្ជាប់ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានរយៈពេលប្រាំឆ្នាំ។ ជាឧទាហរណ៍ ប្រទេសកម្ពុជានៅសម័យនោះបានចុះហត្ថ-លេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការទូទាត់សាច់ប្រាក់ជាមួយសហ-ព័ន្ធសាធារណរដ្ឋឆេកូស្លូវ៉ាគីនៅខែវិច្ឆិកា ឆ្នាំ១៩៨០ ជាមួយប្រទេសប៊ុលហ្គារី និងហុងគ្រីនៅឆ្នាំ១៩៨១ ហើយជាមួយនឹងប្រទេសប៉ូឡូញនៅខែមីនា ឆ្នាំ១៩៨២។ កិច្ចព្រមព្រៀងទាំងនោះត្រូវបានបំពេញបន្ថែមដោយពិធីសារប្រចាំឆ្នាំស្តីអំពីពាណិជ្ជកម្ម និងការទូទាត់ប្រាក់។ កិច្ចព្រមព្រៀងបានបង្ហាញលក្ខណៈងាយស្រួលដល់ភាគីទាំងសងខាងនូវគោលការណ៍អនុគ្រោះយ៉ាងប្រសើរដែលភាគីទាំងសងខាងត្រូវមានតួនាទីបង្កើនបម្លាស់ប្តូរទំនិញ និងការពង្រីកការនាំចេញរបស់ខ្លួន។ ហើយក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងលើនេះក៏បានបង្កើតឱ្យមានជាគណៈកម្មការអន្តររដ្ឋាភិបាលផ្នែកពាណិជ្ជ-កម្ម និងសហប្រតិបត្តិការវិទ្យាសាស្ត្រ-បច្ចេកទេសដែលមានតួនាទីកំណត់ទិសដៅ និងផែនការលើកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសទាំងនោះដោយបានធ្វើការកត់សម្គាល់អំពីកិច្ចសហប្រតិបត្តិការរយៈពេលវែងរវាងភាគីទាំងអស់ដែលត្រូវតែចាត់វិធានការឱ្យបានម៉ឺងម៉ាត់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងធ្វើយ៉ាងណាឱ្យមានលក្ខណៈសមស្របជាមួយនឹងទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសរបស់ខ្លួន។

ក្នុងទំនាក់ទំនងវិស័យពាណិជ្ជកម្មនេះ ភាគីទាំងអស់ត្រូវតែគោរពគោលការណ៍តុល្យភាព។ ជាងនេះទៀត កិច្ចព្រមព្រៀងក៏បានពិនិត្យផងដែរនូវវិធីសាស្ត្រនៃការទូទាត់សាច់ប្រាក់ដោយប្រើប្រាស់ប្រាក់រូប្លសុទ្ធ តាមរយៈធនាគារពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសនីមួយៗ។ នៅសម័យនោះ គេបានព្រមព្រៀងជាមួយគ្នាផងដែរនូវគោលការណ៍កំណត់តម្លៃដែលតាមរយៈនោះ តម្លៃគឺត្រូវបានកំណត់ជាប្រាក់រូប្លសុទ្ធ យោងតាមតម្លៃទីផ្សារពិភពលោកដោយគិតជាលុយរូប្លតាមអត្រាធនាគារសហប្រតិបត្តិការប្រទេសអឺរ៉ុបខាងកើត គិតក្នុងថ្ងៃដែលបានចុះកិច្ចព្រមព្រៀង។ នៅទីអវសាន ភាគីទាំងអស់ត្រូវតែបង្ហាញនូវឆន្ទៈដោយប្រកាន់ខ្ជាប់នូវទំនាក់ទំនងលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងវិស័យវិទ្យាសាស្ត្របច្ចេកទេសស្របតាមផលប្រយោជន៍រៀងៗខ្លួន។

យោងតាមកិច្ចព្រមព្រៀងខាងលើនេះ យើងពិនិត្យឃើញថា ក្នុងឆ្នាំ១៩៨២ដល់ឆ្នាំ១៩៨៣ បម្លាស់ប្តូរទំនិញរវាងកម្ពុជាជាមួយនឹងបណ្តាប្រទេសអឺរ៉ុបខាងកើត បានកើនឡើងជាមធ្យមគឺ១,២៦ដង ក្នុងនោះ ជាមួយប្រទេសហុងគ្រី ៣,៣៥ដង ជាមួយប៊ុលហ្គារី ១,៥៥ដង ជាមួយឆេកូស្លូវ៉ាគី ៥ដង និងជាមួយប្រទេសប៉ូឡូញ ប្រមាណ ៤,៧ដង។

ក្នុងដំណាក់កាលឆ្នាំ១៩៨៨ ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ប្រទេសអឺរ៉ុបខាងកើតទាំងបួន(ប្រទេសហុងគ្រី ប៊ុលហ្គារី ឆេកូស្លូវ៉ាគី និងប្រទេសប៉ូឡូញ) មានទំហំប្រមាណជា២,៥លានរូប្ល។ ចំពោះចំណាត់ថ្នាក់លេខ១បានទៅលើប្រទេសឆេកូស្លូវ៉ាគី(៣៨,៨៦%) ចំណាត់ថ្នាក់លេខ២គឺប៊ុលហ្គារី(២៤,៦៧%) ទី៣ ប្រទេសហុងគ្រី(២៤,១១%) និងចុងក្រោយគឺប្រទេសប៉ូឡូញ(១២,៣៦%)។

រចនាសម្ព័ន្ធនៃការនាំចេញរបស់រដ្ឋកម្ពុជានាសម័យកាលនោះទៅ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាន់ប្រទេសអឺរ៉ុបខាងកើតមានភាពស្រដៀងគ្នា។ ជាក់ស្ដែងប្រទេសកម្ពុជាបាននាំចេញទៅកាន់ប្រទេសទាំងនោះនូវផលិតផលកៅស៊ូធម្មជាតិ ថ្នាំជក់ពោត លូ សណ្ដែកសៀង ម្រេច និងឈើមានតម្លៃ។

**តារាងលេខ១៣**

**ការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសអឺរ៉ុបខាងកើត(គិតជា%)**

| **ប្រទេស** | **១៩៨២** | | **១៩៨៥** | | **១៩៨៨** | |
|---|---|---|---|---|---|---|
| | **ពាន់រូប្ល** | **%** | **ពាន់រូប្ល** | **%** | **ពាន់រូប្ល** | **%** |
| ឆេកូស្លូវ៉ាគី | ៨០០ | ៤១,៥៣ | ៤១៦ | ២៣,៤៤ | ៩៧៥ | ៣៨,៨៦ |
| ប៊ុលហ្គារី | ៦០៧ | ៣១,៥១ | ៨៩១ | ៣៨,២៤ | ៦១៩ | ២៤,៦៧ |
| ហុងគ្រី | ១៨១ | ៩,៣៩ | ៦៩៨ | ២៩,៩៥ | ៦០៥ | ២៤,១១ |
| ប៉ូឡូញ | ៣៣៨ | ១៧,៥៧ | ៣២៥ | ៨,៣៧ | ៣១០ | ១២,៣៦ |
| **សរុប** | **១៩២៦** | **១០០,០** | **២៣៣០** | **១០០,០** | **២៣០៩** | **១០០,០** |

**ដកស្រង់ពី ៖ របាយការណ៍ក្រសួងពាណិជ្ជកម្មផ្ញើទៅក្រុមប្រឹក្សារដ្ឋមន្ត្រី, ភ្នំពេញ ឆ្នាំ១៩៨៨**

ដោយឡែក ចំពោះបរិមាណទំនិញនាំចូលមកប្រទេសកម្ពុជាពីបណ្ដាប្រទេសអឺរ៉ុបខាងកើតទាំងបួន ក្នុងឆ្នាំ១៩៨៨ គឺមានទំហំ១,៩លានរូប្លដែលក្នុងនោះ ពីប្រទេសឆេកូស្លូវ៉ាគីមាន៣២,៦៥% ប្រទេសប៊ុលហ្គារី៣០,៧៦% ប្រទេសហុងគ្រី៣០,៦១% និងប្រទេសប៉ូឡូញ៦,០៧% ធៀបទៅនឹងការនាំចូលសរុបពីបណ្ដាប្រទេសទាំងអស់នោះ។ រីឯរចនាសម្ព័ន្ធមុខទំនិញនៃការនាំចូលវិញ មានសភាពប្លែកៗពីគ្នា។ ករណីប្រទេសឆេកូ-ស្លូវ៉ាគី គឺបាននាំចូលមកកម្ពុជានូវវត្ថុធាតុដើមសម្រាប់ផលិតឱសថ បរិក្ខារសម្រាប់បសុ-វប្បកម្មជាឱសថ ក្រណាត់ បរិក្ខារសម្រាប់បម្រើឱ្យវិស័យគមនាគមន៍ គ្រឿងបន្លាស់ និងម៉ាស៊ីនសម្រាប់ឧស្សាហកម្មផលិតទោចក្រយាន រថយន្តដឹកទំនិញ ត្រាក់ទ័រ កៅស៊ូសំយោគ សារធាតុផ្សំគីមី បរិក្ខារប្រើប្រាស់ក្នុងវិស័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឧស្សាហកម្មវាយនភណ្ឌ ម៉ាស៊ីនទួរប៊ីនជាដើម។ល។ ចំណែកឯប្រទេសប៊ុលហ្គារីវិញបានផ្គត់ផ្គង់បរិក្ខារអគ្គិសនី ត្រាក់ទ័រ និងគ្រឿងបន្លាស់ ផលិតផលគីមី ក្រណាត់ អំបោះ និងខ្សែន ព្រមទាំងផលិតផលជាថ្នាំពេទ្យ។ ប្រទេសហុងគ្រីបានផ្គត់ផ្គង់បរិក្ខារអគ្គិសនី ក្រណាត់ ឱសថ និងឧបករណ៍គីមីសម្រាប់ផលិតកៅស៊ូធម្មជាតិ ហើយប្រទេសប៉ូឡូញវិញបានផ្គត់ផ្គង់ម៉ាស៊ីនម៉ាស៊ូត បរិក្ខារមន្ទីរពិសោធន៍ កៅស៊ូសំយោគ ថ្នាំលាប និងក្រណាត់។

## តារាងលេខ១៤
## ការនាំចូលមកប្រទេសកម្ពុជាពីបណ្ដាប្រទេសនៅអឺរ៉ុបខាងកើត

| ប្រទេស | ១៩៨២ | | ១៩៨៥ | | ១៩៨៨ | |
|---|---|---|---|---|---|---|
| | ពាន់រូប្ល | % | ពាន់រូប្ល | % | ពាន់រូប្ល | % |
| ឆេកូស្លូវ៉ាគី | ៧២៨ | ៤៥,៩៣ | ១៤៦៨ | ៣៧,៦៤ | ៦៥១ | ៣៨,៨៦ |
| ប៊ុលហ្គារី | ៦៥៣ | ៤១,១៩ | ១៣៦៧ | ៣៤,៥៨ | ៦១៥ | ២៤,៦៧ |
| ហុងគ្រី | ១៨២ | ១១,៥៨ | ៨៦០ | ២១,៧៥ | ៦១៣ | ២៤,១១ |
| ប៉ូឡូញ | ២២ | ១,៤ | ២៣៨ | ៦,០៣ | ១២០ | ១២,៣៦ |
| **សរុប** | **១៥៨៥** | **១០០,០** | **៣៩៥៣** | **១០០,០** | **១៩៩៩** | **១០០,០** |

**ដកស្រង់ពី ៖ របាយការណ៍ក្រសួងពាណិជ្ជកម្មផ្ញើទៅក្រុមប្រឹក្សារដ្ឋមន្ត្រី, ភ្នំពេញ ឆ្នាំ១៩៨៨**

ក៏ប៉ុន្តែ ពាក់ព័ន្ធទៅនឹងទំនាក់ទំនងវិស័យសេដ្ឋកិច្ចក្រៅប្រទេសរវាងប្រទេសកម្ពុជាជាមួយនឹងបណ្ដាប្រទេសទាំងអស់ខាងលើនេះ ចេះតែមានការធ្លាក់ចុះជាបន្តបន្ទាប់យោងតាមរបត់នៃទំនោរទៅរកការដួលរលំរបស់លិទ្ធិកុម្មុយនីស្តនិយម និងការទទួលជ័យជម្នះរបស់គណបក្សប្រឆាំងក្នុងការបោះឆ្នោតសកល ក៏ដូចជាបញ្ហាវិបត្តិសេដ្ឋកិច្ចមួយចំនួនដែលបណ្ដាប្រទេសទាំងអស់នោះបានជួបប្រទះ។ ជាក់ស្ដែង មូលហេតុសំខាន់ៗមានដូចតទៅនេះ ទីមួយ ៖ បើទោះបីជាស្ថានភាពវិស័យពាណិជ្ជកម្មក្រៅប្រទេស


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថិតលើគោលការណ៍តុល្យភាពក៏ដោយ ក៏ប្រសិទ្ធភាពរបស់វាមិនខ្ពស់នោះទេដោយសារតែមូលហេតុថា ការដឹកជញ្ជូនមានសភាពយឺតយ៉ាវ ហើយគុណភាពទំនិញដែលបានផ្គត់ផ្គង់នៅមានកម្រិតទាប។ ទីពីរ ៖ ការប្តូរទម្រង់ពាណិជ្ជកម្មជាមួយប្រទេសទាំងនោះ ដោយការទូទាត់ជារូបិយប័ណ្ណសេរីវិញ(ប្រាក់ដុល្លារ)។ ទីបី ៖ ប្រទេសនៅអឺរ៉ុបខាងកើតបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យនយោបាយសេដ្ឋកិច្ចក្នុងប្រទេសរបស់ខ្លួន។ ដូច្នេះហើយ ការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ចជាមួយបណ្តាប្រទេសទាំងអស់នោះ អាស្រ័យនឹងការទូទាត់ជារូបិយប័ណ្ណសេរី និងការពិនិត្យអត្រាតម្លៃសាឡើងវិញ។

ចំពោះទម្រង់មួយទៀតនៃយន្តការពាណិជ្ជកម្មក្រៅប្រទេសរវាងប្រទេសកម្ពុជា និងប្រទេសអឺរ៉ុបខាងកើត សំដៅលើកិច្ចសហប្រតិបត្តិការបែបទូទាត់ដែលការប្រើប្រាស់ទម្រង់បែបនេះ បាននាំមកនូវកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសទាំងនោះ និងផ្អែកតាមគោលការណ៍រយៈពេលវែង ហើយបង្កឱ្យមានប្រសិទ្ធភាពចំពោះកិច្ចសហប្រតិបត្តិការទៀតផង។ ពីព្រោះថា កិច្ចព្រមព្រៀងបែបនេះបានធ្វើឡើងជាច្រើនលើកច្រើនសារមកហើយ ចាប់តាំងពីពេលដែលលបើកឱ្យមានទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយសហភាពសូវៀត ក៏ដូចជាមួយបណ្តាប្រទេសដទៃទៀត។

ម្យ៉ាងវិញទៀត កិច្ចសហប្រតិបត្តិការបែបទូទាត់នេះ គឺជាទម្រង់ដ៏ស្មុគស្មាញមួយដែលកំណត់ឱ្យភាគីកម្ពុជាទទួលបានប្រាក់កម្ចីសម្រាប់ការទិញគ្រឿងម៉ាស៊ីន និងគ្រឿងបរិក្ខារ សម្រាប់បង្កើតសក្តានុពលសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យឧស្សាហកម្មរបស់រដ្ឋាភិបាលកម្ពុជា ហើយដែលការបង់រំលស់បំណុលទាំងនោះត្រូវពឹងផ្អែកលើផលិតផលនៃសហគ្រាសនោះ ឬមួយផលិតផលសហគ្រាសដទៃទៀត ស្របតាមការព្រមព្រៀងរវាងភាគីទាំងពីរ។

ដូច្នេះ ទម្រង់នៃកិច្ចសហប្រតិបត្តិការបែបនេះបានផ្តល់អត្ថប្រយោជន៍


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យ៉ាងច្រើន ទីមួយ ៖ សហប្រតិបត្តិការឥណទានតាមរយៈការផ្តល់ឥណទានដល់រដ្ឋកម្ពុជា និងការបង់រំលស់បំណុល។ ទីពីរ ៖ ការនាំចូលម៉ាស៊ីនសម្ភារបរិក្ខារ និងគ្រឿងចក្រមកកាន់រដ្ឋកម្ពុជា។ ទីបី ៖ កិច្ចសហប្រតិបត្តិការបច្ចេកវិទ្យា និងវិទ្យាសាស្ត្រដោយផ្តល់ជាសេវាកម្ម កិច្ចការងារស្រាវជ្រាវការបង្កើតជាគម្រោងនានា និងការបង្ហាត់បង្រៀនអ្នកបច្ចេកទេសជាដើម។ ទីបួន ៖ ការនាំចេញផលិតផលពីរដ្ឋកម្ពុជាទៅកាន់ប្រទេសម្ចាស់បំណុល។ ម្យ៉ាងទៀត កិច្ចព្រមព្រៀងពីការរំលស់ភាគច្រើន បានផ្តោតទៅលើកិច្ចសហប្រតិបត្តិការផ្នែកផលិតកម្មកៅស៊ូ និងដំណាំកប្បាស។ ហើយទម្រង់នៃកិច្ចសហប្រតិបត្តិការបែបនេះបានកំណត់វត្ថុធាតុដើមជាក់លាក់ដែលបានប្រើប្រាស់ក្នុងការផលិត និងការដាំដុះជាកម្មសិទ្ធិរបស់រដ្ឋកម្ពុជាដែលទទួលខុសត្រូវរៀបចំការងារ។

ជាឧទាហរណ៍នៅខែកញ្ញា ឆ្នាំ១៩៨៣ មានការចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការបែបទូទាត់រវាងរដ្ឋកម្ពុជាជាមួយនឹងប្រទេស ស.ស.ស.ស ស្តីអំពីការដាំដុះដំណាំកៅស៊ូលើទំហំផ្ទៃដីប្រមាណ២០ពាន់ហិកតា។ ម្យ៉ាងទៀត ក្នុងកិច្ចព្រមព្រៀងនេះ ភាគីសហភាពសូវៀតយល់ព្រមផ្គត់ផ្គង់ទំនិញជាទឹកប្រាក់កម្ចីចំនួន៥០លានរូប្ល[២] តាមកិច្ចព្រមព្រៀងនេះ ភាគីស.ស.ស.ស មានភារកិច្ចផ្គត់ផ្គង់ម៉ាស៊ីន និងគ្រឿងសម្ភារផ្សេងៗ ផ្តើមចេញតាំងពីឡានដឹកទំនិញ និងសម្ភារសំណង់ទៅកាន់រដ្ឋកម្ពុជា និងការធានាអំពីការចំណាយលើសេវាបេសកកម្មរបស់អ្នកបច្ចេកទេស ហើយនឹងការធានាអំពីការផ្គត់ផ្គង់នូវបច្ចេកវិទ្យាដែលពុំមានការផលិតនៅស.ស.ស.ស ហើយត្រូវបានជាវទិញពីប្រទេសទីបីថែមទៀតផង។ ជាមួយគ្នានោះដែរ កន្លងមកនៅខែកុម្ភៈ ឆ្នាំ១៩៨៣ រដ្ឋកម្ពុជា និងស.ស.ស.សបានចុះកិច្ចព្រមព្រៀងស្តីអំពីការស្តារឡើងវិញនូវដំណាំកប្បាសតាមការទូទាត់ទៅលើផ្ទៃដីទំហំ

[២] របាយការណ៍ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចវិទ្យាសាស្ត្រជាមួយសហភាពសូវៀត, ភ្នំពេញ ១៩៨៤ ទំព័រ ៩



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រមាណជា៦ពាន់ហិកតា និងការសាងសង់ស្ថានីយពិសោធន៍លើផ្ទៃដីប្រមាណជា៨០ពាន់ហិកតាថែមទៀតផង។[៣]

លក្ខណៈពិសេសនៃកិច្ចសហប្រតិបត្តិការបែបទូទាត់លើការអភិវឌ្ឍដំណាំកៅស៊ូ ត្រូវបានកំណត់ក្នុងប្រតិបត្តិការពិសេសមួយនៃដំណើរការផលិតកម្មកៅស៊ូធម្មជាតិ។ ដូចដែលយើងធ្លាប់បានដឹងរួចមកហើយនៅក្នុងដំណើរការប្រមូលផលរបស់កសិដ្ឋានដំណាំចម្ការកៅស៊ូ គេតែងតែចៀរយកជ័រកៅស៊ូរាវ(ជ័រដែលចេញពីដើមកៅស៊ូមានអាយុពី៧ដល់៤០ឆ្នាំ) ហើយផលដែលបានមកត្រូវឆ្លងកាត់ការកែច្នៃម្តងទៀតនៅក្នុងរោងចក្រកៅស៊ូជប់នាខេត្តកំពង់ចាម និងនៅរោងចក្រឫស្សីកែវនៅភ្នំពេញ។ ជាទូទៅ ផលិតផលជ័រកៅស៊ូ គេអាចកែច្នៃជាច្រើនបែបយ៉ាងដូចជាធ្វើជាសន្ទឹកកៅស៊ូជាម្សៅកៅស៊ូជាដើម។ ដូចនេះ ក្នុងការកិច្ចរបស់រដ្ឋកម្ពុជាត្រូវមានការរៀបចំការងារគ្រប់គ្រងជាច្រើនបែបផែននៅក្នុងចម្ការដំណាំ រួមទាំងការប្រមូលទឹកជ័រ ការដឹកជញ្ជូន និងការកែច្នៃជ័រនៅក្នុងរោងចក្រក៏ដូចជាការផ្គត់ផ្គង់កៅស៊ូធម្មជាតិទៅកាន់ប្រទេសស.ស.ស.ស។ ចំពោះការទូទាត់សាច់ប្រាក់វិញ(ការបង់រំលស់បំណុល) ត្រូវបានធ្វើឡើងដោយអាស្រ័យលើការទទួលបានទិន្នផលពីជ័រកៅស៊ូធម្មជាតិ។ មានន័យថា ការបង់រំលោះបំណុល គឺមានទម្រង់ដែលត្រូវបានគណនាជាសាច់ប្រាក់ មិនមែនជាទំនិញនោះទេ។ ហើយចំណែកឯតម្លៃនៃការផ្គត់ផ្គង់ជ័រកៅស៊ូទៀតសោតបានប្រើប្រាស់ជាមូលនិធិសម្រាប់ការទូទាត់ក្នុងទម្រង់ជារូបិយប័ណ្ណ ដើម្បីការបង់រំលស់ប្រាក់បំណុល។

ទម្រង់បែបនេះធ្វើឱ្យភាគីទាំងសងខាងទទួលបានផលប្រយោជន៍ទាំងអស់គ្នាដែលសម្រាប់ប្រទេសកម្ពុជាគឺយើងអាចបង្កើនការនាំចេញរបស់ខ្លួន ការស្តារឡើងវិញនូវដំណាំកៅស៊ូ ដំណាំថ្នាំជក់ និងកប្បាស ក៏ដូចជា

---

[៣] របាយការណ៍ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចវិទ្យាសាស្ត្រជាមួយសហភាពសូវៀត, ភ្នំពេញ ១៩៨២ ទំព័រ ៩



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការផ្គត់ផ្គង់ដល់ការអភិវឌ្ឍវិស័យកសិកម្ម ព្រមទាំងគ្រឿងយន្តកសិកម្ម និងបរិក្ខារផ្សេងៗទៀត។ ផ្ទុយទៅវិញ សម្រាប់ដៃគូរបស់យើងវិញអាចទទួលបានផលប្រយោជន៍តាមរយៈការបង្កើនទូវការនាំចេញគ្រឿងយន្តកសិកម្ម ដែលការដោះដូរមិនអាចទទួលបានជារូបិយប័ណ្ណសុទ្ធនោះទេ គឺទទួលបានជាវត្ថុធាតុដើមដែលដៃគូរបស់ខ្លួនអាចនាំចេញក្នុងអត្រាតម្លៃជារូបិយប័ណ្ណបរទេស។

## ៣.១.២ កិច្ចសហប្រតិបត្តិការវិស័យបច្ចេកទេស និងវិទ្យាសាស្ត្រ

លើសពីនេះទៀត ចំពោះកិច្ចសហប្រតិបត្តិការលើវិស័យបច្ចេកទេសវិទ្យាសាស្ត្ររវាងរដ្ឋកម្ពុជាជាមួយនឹងប្រទេសអឺរ៉ុបខាងកើត គឺមានលក្ខណៈនិងមានមូលដ្ឋានជាយុទ្ធសាស្ត្រជាក់លាក់សម្រាប់រយៈពេលយូរអង្វែង និងមានយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នាក្នុងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមក៏ដូចជាកិច្ចការបច្ចេកទេសវិទ្យាសាស្ត្រ និងការងារក្នុងវិស័យវប្បធម៌ផងដែរ។ ការបង្កើនតួនាទីដែលពាក់ព័ន្ធទៅនឹងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេស និងក្នុងទិសដៅនៃការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចដើម្បីការអភិវឌ្ឍប្រទេសជាការចាំបាច់ ត្រូវតែប្រើប្រាស់ឱ្យអស់ពីលទ្ធភាព និងអត្ថប្រយោជន៍របស់ខ្លួនអំពីបំណែងចែកពលកម្មអន្តរជាតិ សម្រាប់ដោះស្រាយបញ្ហាភាពអន់ថយ និងការកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចឱ្យមានភាពជឿនលឿន។ ពិសេសទៅទៀត កិច្ចសហប្រតិបត្តិការលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេស គឺជាកត្តាដ៏ចម្បងមួយនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋកម្ពុជាជាមួយនឹងប្រទេសអឺរ៉ុបខាងកើតក្នុងគោលបំណងប្រើប្រាស់យ៉ាងទូលំទូលាយនូវលទ្ធផលវិទ្យាសាស្ត្របច្ចេកទេស សម្រាប់ការកសាងវិស័យសេដ្ឋកិច្ច និងការបង្កើនប្រសិទ្ធភាពផលិតកម្ម។ ម្យ៉ាងទៀត វាក៏មានឥទ្ធិពលយ៉ាងខ្លាំងក្លាផងដែរលើដំណោះស្រាយរាល់បញ្ហាសេដ្ឋកិច្ច និងសង្គមទៀតផង។ ដូចដែលបានអះអាងដោយសេដ្ឋវិទូសូវៀតឈ្មោះ ល.ហ្ស. ហ្សេរីន ដែលបានលើកឡើង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថា «កិច្ចសហប្រតិបត្តិការបច្ចេកទេសវិទ្យាសាស្ត្ររវាងប្រទេសមួយជាមួយនឹងប្រទេសមួយទៀតដែលមានកម្រិតអភិវឌ្ឍន៍ខុសគ្នា ជាប្រភេទស្មុគស្មាញដែលមានការរួមផ្សំជាច្រើនពីកត្តាវិទ្យាសាស្ត្រ-បច្ចេកទេស កត្តាសេដ្ឋកិច្ច និងសង្គមដែលមានអំពើលើប្រជាជាតិ(រដ្ឋដែលជាភាគី) ព្រមទាំងទៅលើពិភពលោកផងដែរ។ ភាពស្មុគស្មាញនៃដំណើរការនេះទាមទារនូវការរៀបចំរយៈពេលយូរអំពីគំនិតស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិដោយរក្សាផលប្រយោជន៍រវាងភាគីទាំងអស់ និងតម្រូវការពិសេសនៃប្រទេសដែលមានវឌ្ឍនការទាប»។[៦]

កិច្ចសហប្រតិបត្តិការបែបនេះទាមទារលក្ខខណ្ឌជាច្រើន ទីមួយ ៖ គឺការកសាងមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រដែលជាអ្នកសម្របសម្រួលដ៏សំខាន់ផ្នែកប្រព័ន្ធស្រាវជ្រាវវិទ្យាសាស្ត្រដែលមានតួនាទីជាអ្នកកំណត់ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ស្របទៅតាមទិសដៅដែលអាចប្រើប្រាស់នៅក្នុងលក្ខខណ្ឌនៃប្រទេសនោះ។ ឧទាហរណ៍ ការជ្រើសរើសពូជដំណាំផ្សេងៗតម្រូវឱ្យអនុវត្តស្របតាមលក្ខខណ្ឌធម្មជាតិនៃប្រទេសនោះ ការសិក្សាអំពីដីសម្រាប់ការដាំដុះក្នុងប្រទេស ការដកស្រង់ពិសោធន៍ល្អៗពីប្រទេសដទៃ និងការជ្រើសយកវិធីសាស្ត្រដែលសមប្រកបជាដើម។ ទីពីរ ៖ ការកសាងទំនាក់ទំនងរវាងស្ថាប័នដែលមានសមត្ថភាពណែនាំ និងការដាក់បញ្ចូលលទ្ធផលដែលទទួលបានយ៉ាងឆាប់រហ័សទៅក្នុងវិស័យសេដ្ឋកិច្ច។ ហើយក្នុងនាមជាមជ្ឈមណ្ឌលស្រាវជ្រាវការអភិវឌ្ឍ ត្រូវតែប្រមូលផ្តុំគ្នាក្នុងចំណោមវិទ្យាស្ថានសំខាន់ៗ និងមន្ទីរពិសោធន៍ជាច្រើនដែលមានទំនាក់-ទំនងជិតស្និទ្ធជាមួយនឹងគ្នា។

ចំពោះលក្ខខណ្ឌចាំបាច់ដើម្បីប្រសិទ្ធភាពនៃការអនុវត្ត យើងឃើញថា កិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស គឺជាការសម្រេច

---

[៦] Зевин Л.З. Страны СЭВ и развивающиеся страны 80-х гг. М. Наука, 1985.- С. 107



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យបាននូវប្រព័ន្ធហ្វឹកហ្វឺនដល់សាធារណជន ដើម្បីត្រៀមកសាងអ្នកបច្ចេកទេសកម្រិតខ្ពស់ កសាងបុគ្គលិកវិទ្យាសាស្ត្រ និងអ្នកប្រាជ្ញ រហូតឈានទៅដល់ការបង្កើតឡើងនូវបណ្ឌិត្យសភាវិទ្យាសាស្ត្រថ្នាក់ជាតិដែលជាខួរក្បាលនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងមជ្ឈមណ្ឌលព័ត៌មានផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា។

ក្នុងន័យខាងលើនេះ សម្រាប់វិស័យផ្នែកកសិប្រពលវប្បកម្មដែលមានកិច្ចព្រមព្រៀងរវាងរដ្ឋកម្ពុជាជាមួយនឹងប្រទេសស.ស.ស.សក្នុងការស្ថាបនាស្ថានីយសម្រាប់ជ្រើសរើសពូជស្រូវ និងដំណាំផ្សេងៗទៀតនៅទួលសំរោង (ខេត្តបាត់ដំបង) គឺជាទ្រង់ទ្រាយមួយដែលត្រូវបានអនុវត្តដោយប្រាក់កម្ចី។ ស្ថានីយនេះបានបង្កើតឡើងដោយមានកិច្ចសហការជាមួយអ្នកបច្ចេកទេសសូវៀត។ យ៉ាងណាមិញ នៅក្នុងឆ្នាំ១៩៨៤ ការពិសោធក្នុងវិស័យកសិកម្មគឺត្រូវបានដំណើរការឡើងលើផ្ទៃដីប្រមាណជា២០០ហិកតាដោយបានប្រើ-ប្រាស់គ្រឿងចក្រក្នុងការដាំដុះដំណាំស្រូវ។[៥] ហើយកន្លងមក ក្នុងឆ្នាំ១៩៨០ រវាងស.ស.ស.សជាមួយនឹងរដ្ឋកម្ពុជា ក៏បានចុះកិច្ចព្រមព្រៀងរួចរាល់ដែរស្តីអំពីការស្រាវជ្រាវបាតសមុទ្រ។ កិច្ចការនេះបានអនុញ្ញាតឱ្យមានការសិក្សាស៊ីជម្រៅផងដែរអំពីធនធានធម្មជាតិសមុទ្រ និងធនធានតំបន់ឆ្នេរ។

ក្រៅពីនេះទៀត មានកិច្ចព្រមព្រៀងរវាងរដ្ឋកម្ពុជាជាមួយនឹងសាធា-រណរដ្ឋហុងគ្រីស្តីអំពីការស្ថាបនាមន្ទីរពិសោធន៍ដំណាំពោតលើទំហំផ្ទៃដីចំនួន៥០ហិកតា។[៦] កត្តាចម្បងក្នុងកិច្ចការនេះគឺអ្នកបច្ចេកទេសដែលត្រូវមកជួយយើង គេបានចែករំលែកចំណេះដឹងនានា និងបទពិសោធន៍ល្អៗព្រមទាំងបង្ហាត់បង្រៀនដល់កសិករខ្មែរឱ្យចេះបន្សាំនឹងបច្ចេកវិទ្យាថ្មីៗ។

ក្នុងវង្វង់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្របច្ចេកវិទ្យា គេបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការកសាងសមត្ថភាពអ្នកវិទ្យាសាស្ត្របច្ចេក-

[៥] របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការជាមួយសូវៀត ភ្នំពេញ១៩៨៤ ទំព័រ២

[៦] របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការជាមួយហុងគ្រី, ភ្នំពេញ ១៩៨៤ ទំព័រ២



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទេស ព្រោះថា រដ្ឋកម្ពុជានៅសម័យនោះបាន និងកំពុងត្រូវការអ្នកបច្ចេក-ទេសដែលមានសមត្ថភាពខ្ពស់ជាច្រើននាក់ និងជាច្រើនជំនាញផងដែរ ដែលពោរពេញដោយការហ្វឹកហ្វឺនក្នុងកម្រិតខ្ពស់ ជាពិសេស អាចចាប់យក និងប្រើប្រាស់បច្ចេកវិទ្យា និងតិចនិកសម័យថ្មី មានការយល់ដឹងអំពីវិធីសាស្ត្ររៀបចំផលិតកម្មសម័យទំនើប ក៏ដូចជាការគ្រប់គ្រងការងារកសិកម្ម។ ជាងនេះទៀត និរន្តរភាពនៃការកសាងប្រព័ន្ធអប់រំដែលទំនើប និងការកសាងអ្នកបច្ចេកទេសដែលមានសមត្ថភាពខ្ពស់គឺជាកត្តាដ៏សំខាន់បំផុតមួយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច អភិវឌ្ឍវិទ្យាសាស្ត្របច្ចេកវិទ្យា និងការអភិវឌ្ឍវប្បធម៌របស់ប្រទេស។ ព្រោះតែហេតុផលនេះហើយ ទើបរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាលអ្នកបច្ចេកទេស និងរៀបចំកន្លែងបំពេញការងាររបស់ពួកគេ។ ជាក់ស្តែង នៅសម័យកាលនោះ រដ្ឋាភិបាលបានស្ថាបនាមជ្ឈមណ្ឌលហាត់ការវិជ្ជាជីវៈ វិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់ វិទ្យាស្ថានកសិកម្ម និងសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាល័យមួយចំនួនទៀត។ ជំនួយនៅក្នុងវិស័យទាំងអស់នេះបានទទួលភាគច្រើនមកពីប្រទេសអឺរ៉ុបខាងកើត ជាពិសេស ជំនួយពីប្រទេសស.ស.ស.ស។ សកម្មភាពទាំងអស់នេះបាននាំមកនូវប្រសិទ្ធភាពចំពោះសេដ្ឋកិច្ច និងផលចំណេញយ៉ាងខ្លាំងក្លា។ ហើយវាក៏បាននាំមកនូវការកសាងប្រព័ន្ធអប់រំដែលទំនើប ការបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេស ផ្តល់លទ្ធភាពឱ្យយើងបង្កើតបានដោយខ្លួនឯងនូវអ្នកបច្ចេកទេសកម្រិតមធ្យម និងឧត្តមជាច្រើនជំនាញទៀតផង។

ចាប់តាំងពីទសវត្សរ៍ទី៦០មកម៉្លេះ យើងពិនិត្យឃើញថា ជំនួយក្នុងការបណ្តុះបណ្តាលអ្នកបច្ចេកទេសត្រូវបានជួយដោយប្រទេសស.ស.ស.ស។ ដូចជាក្នុងឆ្នាំ១៩៦២ ស.ស.ស.សបានសាងសង់ និងប្រគល់ជូនប្រជាជនកម្ពុជានូវវិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់ដែលក្នុងនោះ មានមហាវិទ្យាល័យ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួន៩ ហើយមាននិស្សិតប្រមាណជាងមួយពាន់នាក់កំពុងសិក្សា។[៧] វិទ្យាស្ថានបានបណ្តុះបណ្តាលអ្នកបច្ចេកទេស សម្រាប់វិស័យឧស្សាហកម្ម កសិកម្ម និងវិស័យសំណង់។ ក្នុងអំឡុងពេលដែលប្រជាជនកម្ពុជាបាន ទទួលអំណាចរបស់ខ្លួនមកវិញ វិទ្យាស្ថានទាំងអស់នេះក៏ត្រូវបានស្តារឡើង វិញផងដែរ និងបានចាប់ផ្តើមដំណើរការលើការងារបណ្តុះបណ្តាលដល់ និស្សិតចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៨១រហូតមក។ ក្នុងវិទ្យាស្ថានក៏មាន បង្រៀនថ្នាក់ត្រៀមបម្រុង ដែលនៅទីនោះ និស្សិតបានសិក្សាជាភាសារុស្សី និងមានមហាវិទ្យាល័យ៥ទៀត គឺមហាវិទ្យាល័យដែលបណ្តុះបណ្តាល វិស្វករសំណង់ វិស្វករធារាសាស្ត្រ វិស្វករអគ្គិសនី វិស្វកររ៉ែ(ភូគព្ភសាស្ត្រ) និងវិស្វករគីមីជាដើម។ ការអប់រំត្រូវបានដឹកនាំបង្រៀនដោយសាស្ត្រាចារ្យ របស់ប្រទេសសូវៀត។ ក្នុងឆ្នាំ១៩៩០ សាស្ត្រាចារ្យមួយចំនួនត្រូវបានជំនួស ដោយសាស្ត្រាចារ្យខ្មែរ។ ក្នុងឆ្នាំ១៩៨៦ ក្នុងវិទ្យាស្ថាន មាននិស្សិតខ្មែរ កំពុងសិក្សាចំនួន៨៣២នាក់ មានសាស្ត្រាចារ្យសូវៀត៨៣នាក់ សាស្ត្រាចារ្យ ខ្មែរ១២៤នាក់ ដោយរាប់ទាំងអ្នកជំនួយការ និងបុគ្គលិកផងដែរ។[៨]

ក្នុងឆ្នាំ១៩៨៥ វិទ្យាស្ថានកសិកម្មភ្នំពេញត្រូវបានស្តារឡើងវិញរួច រាល់ដោយមាន៤មហាវិទ្យាល័យគឺ មហាវិទ្យាល័យកសិកម្មគីមី បសុវប្ប-កម្ម រុក្ខវប្បកម្ម និងគ្រឿងយន្តកសិកម្ម។ ការសិក្សាបានប្រព្រឹត្តទៅជាភាសា រុស្សីដែលមានសាស្ត្រាចារ្យសូវៀត និងសាស្ត្រាចារ្យខ្មែរយើងជាអ្នកបណ្តុះ-បណ្តាល។

## ៣.១.៣ កិច្ចសហប្រតិបត្តិការឥណទាន និងបញ្ហាបំណុលក្រៅប្រទេស

ក្នុងវង្វង់កិច្ចសហប្រតិបត្តិការផ្នែកឥណទាន នៅថ្ងៃ១៤ វិច្ឆិកា ឆ្នាំ ១៩៨០ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងសាធារណរដ្ឋប្រជា

---

[៧] Кампучия. Справочник. М. : Наука, 1985. – С. 142

[៨] កម្រងស្ថិតិក្រសួងអប់រំ ភ្នំពេញ ១៩៨៦ ទំព័រ ១៩



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានទិតកម្ពុជាជាមួយនឹងស.ស.ស.ស ក្នុងការផ្ដល់ប្រាក់កម្ចីក្នុងទំហំ៥,៥លានរូប្លិ៍ ដើម្បីស្ដារមជ្ឈមណ្ឌលវិជ្ជាជីវៈ«ទឹកថ្លា»។[៩] ក្នុងខែកុម្ភៈ ឆ្នាំ១៩៨១ មានការចាប់ផ្ដើមដំណើរការមជ្ឈមណ្ឌលវិជ្ជាជីវៈខាងលើនេះដែលជាមជ្ឈមណ្ឌលវិជ្ជាជីវៈបច្ចេកទេសធំជាងគេបំផុតក្នុងប្រទេសកម្ពុជា ហើយបានកសាងកម្លាំងកម្មករជំនាញចំនួន១៤មុខវិជ្ជា។ រវាងឆ្នាំ១៩៨១ដល់ឆ្នាំ១៩៨៦ នៅទីនេះ បានបណ្ដុះបណ្ដាលកម្មករជំនាញចំនួន៦៥១នាក់។[១០] ក្នុងមជ្ឈមណ្ឌលបានបង្រៀនដោយសាស្ត្រាចារ្យសូវៀត១០នាក់ និងខ្មែរ៨៩នាក់។[១១]

ជំនួយបន្ថែមលើការបណ្ដុះបណ្ដាលអ្នកបច្ចេកទេសក្នុងប្រទេស គឺនៅសម័យនោះ ក៏មានការទៅសិក្សានៅស.ស.ស.ស និងប្រទេសអឺរ៉ុបខាងកើតផងដែរ។ ក្នុងឆ្នាំ១៩៩០ និស្សិតកម្ពុជាប្រមាណជាង២ពាន់នាក់បានចាកចេញទៅបន្តការសិក្សានៅគ្រឹះស្ថានអប់រំកម្រិតមធ្យម និងកម្រិតឧត្ដមសិក្សានៅប្រទេសស.ស.ស.ស ប៊ុលហ្គារី ហុងគ្រី និងសាធារណរដ្ឋឆេកូស្លូវ៉ាគី។ សហភាពសូវៀតបានផ្ដល់ជំនួយច្រើនជាងគេដល់រដ្ឋកម្ពុជាលើវិស័យកសាងអ្នកបច្ចេកទេស។ ជាក់ស្ដែង មាននិស្សិតខ្មែរជាង៦០% ដែលបានបញ្ចប់ការសិក្សានៅបរទេសនាសម័យនោះ គឺបានរៀនសូត្រនៅស.ស.ស.ស។

កត្តាដែលសំខាន់បំផុតនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់កម្ពុជាជាមួយនឹងបណ្ដាប្រទេសអឺរ៉ុបខាងកើត គឺច្រើនជាប់ពាក់ព័ន្ធនឹងសហប្រតិបត្តិការបែបកម្ចី។ ជាទូទៅ រដ្ឋកម្ពុជាមានទំនាក់ទំនងកម្ចីជាមួយស.ស.ស.ស ប៊ុលហ្គារី និងសហព័ន្ធសាធារណរដ្ឋឆេកូស្លូវ៉ាគីដែលមួយផ្នែកធំនៃទំនាក់ទំនងនេះបានចងភ្ជាប់ទៅនឹងកិច្ចសហប្រតិបត្តិការលើផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា សហប្រតិបត្តិការលើការទូទាត់ និងជំនួយបច្ចេកទេស

---

[៩] របាយការណ៍ស្ដីពីកិច្ចសហប្រតិបត្តិការជាមួយសូវៀត ភ្នំពេញ ១៩៨៤ ទំព័រ១៩

[១០] កម្រងស្ថិតិក្រសួងអប់រំ ទំព័រ២១

[១១] កម្រងស្ថិតិក្រសួងអប់រំ ទំព័រ២២

ដល់រដ្ឋកម្ពុជាពីប្រទេសអឺរ៉ុបខាងកើត។ ទម្រង់ឥណទានរបស់ប្រទេសទាំងនោះ មានទម្រង់ជាកម្ចីរបស់រដ្ឋាភិបាល។ ហើយកិច្ចព្រមព្រៀងផ្លូវច្បាប់ទាំងអស់ជាកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលដែលជាប្រភេទកម្ចីរយៈពេលវែង និងបំពេញបន្ថែមដោយកិច្ចសន្យារវាងធនាគារដែលព្រមព្រៀងពីរបៀបរបបនៃការទូទាត់ របៀបគិតការប្រាក់ និងបង់ប្រាក់ អំពីរយៈពេលដែលត្រូវបំពេញ និងការសងរំលស់បំណុលជាដើម។ កម្ចីឥណទានទាំងនេះមានលក្ខណៈជាផលិតកម្មដែលមានគោលដៅច្បាស់លាស់ ហើយមានបំណងចម្បងក្នុងការកសាងវិស័យឧស្សាហកម្ម ថាមពល កសិកម្ម សំណង់ និងវិស័យសេដ្ឋកិច្ចសំខាន់ៗផ្សេងៗទៀត។ រួមជាមួយកម្ចីទាំងអស់នោះ ក៏មានគោលបំណងជំរុញដល់ការអភិវឌ្ឍស្ថាប័នវិទ្យាសាស្ត្ររបស់ប្រទេសផងដែរ។

ចំណែកឯឥណទានដែលមានទ្រង់ទ្រាយជាទម្រង់ទំនិញវិញ ក៏មានតួនាទីយ៉ាងសំខាន់ណាស់ដែរ ក្នុងទំនាក់ទំនងកម្ចីរបស់កម្ពុជាជាមួយនឹងប្រទេសអឺរ៉ុបខាងកើត។

តាមរយៈបទពិសោធន៍បានបង្ហាញថា កិច្ចសហប្រតិបត្តិការផ្នែកឥណទានបានធ្វើឱ្យមានផលប្រយោជន៍ដូចគ្នាដល់ប្រទេសដែលជាអ្នកខ្ចីប្រាក់ និងអ្នកឱ្យគេខ្ចី។ កម្ចីឥណទានប្រភេទនេះអនុញ្ញាតឱ្យប្រទេសអឺរ៉ុបខាងកើតបង្កើនការនាំចេញគ្រឿងចក្រ និងបរិក្ខារទំនិញនាំចេញសម្រាប់ការប្រើប្រាស់ទូទៅ និងទំនិញដើម្បីបំពេញតម្រូវការផ្នែកវត្ថុធាតុដើមរបស់ប្រទេសកូនបំណុល។ កិច្ចសហប្រតិបត្តិការឥណទានក៏បានក្លាយជាមូលដ្ឋានគ្រឹះដល់ការអភិវឌ្ឍទំនាក់ទំនងលើកិច្ចសហប្រតិបត្តិការតាមទម្រង់ដទៃទៀតផងដែរ។

តាមទំហំនៃប្រាក់ឥណទានដែលបានផ្តល់ឱ្យប្រទេសកម្ពុជានាពេលកន្លងមក តាមរយៈកិច្ចសហប្រតិបត្តិការឥណទាន យើងឃើញថា តំណែងទីមួយបានទៅលើស.ស.ស.ស។ បន្ទាប់មកគឺសហព័ន្ធសាធារណរដ្ឋឆេកូស្លូវ៉ាគី ប្រទេសហុងគ្រី និងប៊ុលហ្គារី។ ក្នុងចន្លោះឆ្នាំ១៩៨០ដល់១៩៨៧



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស.ស.ស.សបានផ្តល់កម្ចីដល់កម្ពុជាជាទឹកប្រាក់១,១១ពាន់លានរូប្លិ៍។ ក៏ប៉ុន្តែមានតែប្រមាណជា២២,៥១% ឬស្មើនឹង២៩២,៨៧លានរូប្លិ៍ដែលបានប្រើប្រាស់ដោយផ្ទាល់សម្រាប់ភាគីកម្ពុជា។[១២] ក្នុងនោះគឺ៧០,៥៧លានរូប្លិ៍ប្រើប្រាស់ដើម្បីការស្តារសេដ្ឋកិច្ច ១៩,៧៨លានរូប្លិ៍សម្រាប់ការស្តារចម្ការកៅស៊ូ ១០,២២លានរូប្លិ៍សម្រាប់ការស្តារសហគ្រាសសំណង់ ៥,៩លានរូប្លិ៍សម្រាប់ស្តារចម្ការកប្បាស និង៣,១៧លានរូប្លិ៍សម្រាប់ការស្តារប្រព័ន្ធវិស័យអប់រំជាតិ។ បើតាមកិច្ចព្រមព្រៀងក្នុងឆ្នាំ១៩៨៦ដល់ឆ្នាំ១៩៩០ ស.ស.ស.សបានផ្តល់ប្រាក់ឥណទានដល់ប្រទេសកម្ពុជានូវទំហំទឹកប្រាក់ប្រមាណ៩៥លានរូប្លិ៍ សម្រាប់ការទ្រទ្រង់ស្ថានីយជ្រើសពូជស្រូវ ការកំណត់ធនធានមច្ឆាទឹកសាប និងទឹកប្រៃ ការផ្គត់ផ្គង់គ្រឿងចក្រសម្រាប់ផលិត-កម្មបំបែកថ្ម ការស្តារប្រព័ន្ធអគ្គិសនីនៅភ្នំពេញ កំពង់សោម បាត់ដំបង និងសៀមរាប ការស្ថាបនារោងជាងជួសជុលត្រាក់ទ័រ ឡានដឹកទំនិញ និងគ្រឿងយន្តកសិកម្ម បរិក្ខារសម្រាប់ការផារព្រលានយន្តហោះភ្នំពេញ និងព្រលានយន្តហោះបីផ្សេងទៀត ការពង្រីករោងចក្រអគ្គិសនីទីបួន និងការជួសជុលកំពង់ផែកំពង់សោម។ល។[១៣]

ដោយឡែក មកដល់ឆ្នាំ១៩៨៧ សហព័ន្ធសាធារណរដ្ឋឆេកូស្លូវ៉ាគីបានធ្វើការផ្តល់ឥណទានដល់កម្ពុជាជាទំហំទឹកប្រាក់៦,១៧លានរូប្លិ៍ដែលមានការប្រាក់២%ក្នុងមួយឆ្នាំ ក្នុងនោះ២លានរូប្លិ៍ សម្រាប់ការស្តាឡើងវិញនូវវិស័យគមនាគមន៍ និង២លានរូប្លិ៍ទៀត គឺជាកម្ចីពាណិជ្ជកម្ម សម្រាប់ការទូទាត់អតុល្យភាពជញ្ជីងពាណិជ្ជកម្មក្រៅប្រទេស។ ក្រៅពីនេះទៀតសហព័ន្ធសាធារណរដ្ឋឆេកូស្លូវ៉ាគីក៏បានផ្តល់ឥណទានជាទំនិញចំនួនប្រមាណ២លានរូប្លិ៍ សម្រាប់ការស្តាររោងចក្រកៅស៊ូកង់ឡាននៅតាខ្មៅ និង២លានរូប្លិ៍ទៀត សម្រាប់ការស្តាររោងចក្រវាយនភណ្ឌ។[១៤]

---

[១២] របាយការណ៍ធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា, ១៩៨៨

[១៣] របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការជាមួយសូវៀត

[១៤] របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការជាមួយឆេកូស្លូវ៉ាគី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាមួយគ្នានេះដែរ មកដល់ឆ្នាំ១៩៨៧ ប្រទេសកម្ពុជាយើងបានទទួលប្រាក់កម្ចីឥណទានពីសាធារណរដ្ឋហុងគ្រីដែលមានទំហំទឹកប្រាក់ប្រមាណចំនួន៤៤៦,៥៦ពាន់រូប្លូ សម្រាប់ការសាងសង់ស្ថានីយជ្រើសពូជពោត និងការស្តារសេដ្ឋកិច្ចឡើងវិញ ហើយទទួលបានពីសាធារណរដ្ឋប៊ុលហ្គារីចំនួន២៩៧,៦ពាន់រូប្លូ សម្រាប់ការអភិវឌ្ឍវិស័យព្រៃឈើ។[១៥]

ចំពោះផលវិបាកនៃកិច្ចសហប្រតិបត្តិការឥណទានទាំងនោះ គឺពាក់ព័ន្ធទៅនឹងបញ្ហាបំណុលក្រៅប្រទេស។ ម៉្យាងវិញទៀត ប្រាក់បំណុលទាំងនោះមិនមែនជាបញ្ហាចោទប៉ុន្មានទេ បើសិនជាប្រាក់ឥណទានទាំងអស់នោះបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ហើយប្រសិនជាវាអាចជួយដល់កំណើនសេដ្ឋកិច្ច។ ប៉ុន្តែជាក់ស្តែង ប្រាក់បំណុលគឺពុំបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនោះឡើយ ចំណែកឯទំនិញដែលជាកម្ចីបែបឥណទាននោះទៀតសោត ជាញឹកញាប់ គឺមានគុណភាពអន់បំផុត។ មកដល់ឆ្នាំ១៩៩០ បំណុលសរុបរបស់ប្រទេសកម្ពុជាជាមួយបរទេសមានប្រមាណជា៧៥០លានរូប្លូ។ ក្នុងនោះ៩៥%ដែលមានតម្លៃជាទឹកប្រាក់៧១៤,៨លានរូប្លូ គឺជាបំណុលរបស់សហភាពសូវៀត ហើយបើគិតមកដល់ត្រឹមថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៨៩(បំណុលដើមគឺមាន៧១៤,៥លានរូប្លូ)។

លើសពីនេះទៀត បញ្ហាបំណុលក្រៅប្រទេសរបស់កម្ពុជាបានក្លាយជាឧបសគ្គមួយយ៉ាងធំធេង សម្រាប់ការពង្រីកទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរវាងកម្ពុជាជាមួយនឹងប្រទេសស.ស.ស.ស ព្រមទាំងជាមួយបណ្តាប្រទេសនៅអឺរ៉ុបខាងកើត ហើយទាមទារឱ្យមានជាដំណោះស្រាយសមស្របណាមួយដែលផ្តល់ជាផលប្រយោជន៍ដល់កូនបំណុល និងម្ចាស់បំណុល។ ចំពោះបញ្ហានេះដែរ យើងអាចផ្តល់ជាដំណោះស្រាយលើបញ្ហាបំណុលក្រៅប្រទេសតាមរយៈវិធីសាស្ត្រដោយធ្វើការបំប្លែងប្រាក់បំណុលឱ្យទៅ

---

[១៥] របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការជាមួយប៊ុលហ្គារី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាការវិនិយោគវិញ មានន័យថា ការចូលរួមរបស់ប្រទេសដែលជាម្ចាស់បំណុលទៅក្នុងវិស័យឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ក៏ដូចជាការបំប្លែងបំណុលឱ្យទៅជាភាគហ៊ុននៃសហគ្រាសរដ្ឋ ការបង្កើតសហគ្រាសសហកម្មសិទ្ធិដែលក្នុងនោះ ភាគហ៊ុនរបស់ប្រទេសម្ចាស់បំណុលត្រូវបានគិតជាផ្នែកមួយនៃប្រាក់បំណុលរបស់កម្ពុជា។ ជាងនេះទៀត មួយចំណែកនៃប្រាក់បំណុលអាចលក់ដោយរដ្ឋទៅឱ្យប្រទេសម្ចាស់បំណុល តាមរយៈស្ថាប័ន ឬសហគ្រាសឯកជននៃប្រទេសទីបីដែលមានបំណងចង់បង្កើតផលិតកម្ម ឬកែច្នៃធនធានរ៉ែ និងត្បូងថ្មនៅប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត ចំពោះចក្ខុវិស័យនៃផែនការនេះអាចពាក់ព័ន្ធទៅនឹងការបង្កើតសហគ្រាសផលិតគ្រឿងសង្ហារិម សម្រាប់ការនាំចេញទៅប្រទេសលោកខាងលិចទៀតផង។

ដូច្នេះ យើងអាចបូកសរុបខ្លះៗអំពីកិច្ចសហប្រតិបត្តិការឥណទានរវាងប្រទេសកម្ពុជា យើងជាមួយនឹងប្រទេសស.ស.ស.សក៏ដូចជាជាមួយនឹងបណ្តាប្រទេសអឺរ៉ុបខាងកើតផងដែរ។ ពោលគឺបរិមាណប្រាក់ឥណទានទាំងអស់ដែលបានផ្តល់ដោយប្រទេសទាំងនោះចំពោះប្រទេសកម្ពុជា គឺបានប្រើប្រាស់ក្នុងគោលបំណងស្តារឡើងវិញនូវរោងចក្រសហគ្រាសឧស្សាហកម្ម ស្តារឡើងវិញនូវរចនាសម្ព័ន្ធផលិតកម្មនិងសង្គម វិស័យកសិកម្ម និងការកាត់បន្ថយអតុល្យភាពជញ្ជីងពាណិជ្ជកម្ម។ ក៏ប៉ុន្តែ កិច្ចសហប្រតិបត្តិការលើវិស័យឥណទានក៏អាចមានចំណុចអវិជ្ជមានរបស់ខ្លួនផងដែរ។ ព្រោះថា ទំនិញ ឬគ្រឿងចក្រ និងបរិក្ខារនានាដែលបានផ្គត់ផ្គង់ជាកម្ចីបែបឥណទាននោះ ជាទូទៅ ពុំស្របទៅតាមស្តង់ដារអន្តរជាតិនោះឡើយ។ ហើយម្ចាស់បំណុលតែងតែផ្គត់ផ្គង់ទំនិញ ឬជាសម្ភារ ក៏ដូចជាបរិក្ខារទាំងឡាយណាដែលពួកគេមិនអាចលក់ដាច់ក្នុងទីផ្សារសេរី។ ជាងនេះទៅទៀត ប្រទេសដែលជាម្ចាស់បំណុល ពុំសូវបានយកចិត្តទុកដាក់ផ្តល់បច្ចេកវិទ្យាថ្មី ឬបទពិសោធន៍ល្អៗ និងរបៀបប្រើប្រាស់(Know-how)ឱ្យបានត្រឹមត្រូវនោះឡើយ។ ហេតុដូចនេះហើយ ទើបក្នុងពេលបច្ចុប្បន្ន គេបានឱ្យតម្លៃខ្ពស់

ទៅលើការវិនិយោគដោយត្រង់នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស។

### ៣.២ ស្ថានភាព និងចក្ខុវិស័យជុំវិញការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសជាមួយប្រទេសតតិយលោក និងប្រទេសមូលធននិយមលូតលាស់

ចាប់តាំងពីថ្ងៃចាប់ផ្តើមដំបូងនៃការកកើតឡើងរបស់រដ្ឋកម្ពុជា យើងពិនិត្យឃើញថា រដ្ឋយើងមានគោលបំណងពង្រីកនូវទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មរបស់ខ្លួនជាមួយនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ក៏ប៉ុន្តែ វាហាក់ដូចជាជួបប្រទះការលំបាកគ្រប់បែបយ៉ាង ដោយសារតែបញ្ហាពាក់ព័ន្ធទៅនឹងការមិនទទួលស្គាល់រដ្ឋាភិបាលថ្មីនេះនៅឯអ.ស.បដែលមានសមា-ជិកភាគច្រើនជាប្រទេសមូលធននិយម និងប្រទេសកំពុងអភិវឌ្ឍ។ នៅខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានប្រកាសពីការត្រៀមខ្លួនរួចជាស្រេចដើម្បីចូលរួមក្នុងគណៈកម្មការប្រើប្រាស់ធនធានទន្លេមេគង្គ។ ក៏ប៉ុន្តែ សំណើនេះក៏ត្រូវបានបដិសេធដោយប្រទេសថៃឡង់ដ៍ និងប្រទេសមូលធននិយមរីកចម្រើនដទៃទៀត។ ក្រោយមក នៅថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៧៩ លោកហេង សំរិន ក៏បានផ្ញើសារទៅឱ្យនាយករដ្ឋមន្ត្រីថៃដែលនៅក្នុងខ្លឹមសារនោះបានរៀបរាប់អំពីគោលជំហររបស់កម្ពុជាពាក់ព័ន្ធនឹងកិច្ចការនយោបាយក្នុងសុច្ឆន្ទៈនៃការចងមិត្តភាព សហប្រតិបត្តិការ និងមិនចូលបក្សសម្ព័ន្ធជាមួយនឹងប្រទេសថៃឡង់ដ៍ក៏ដូចជាប្រទេសដែលជាសមាជិកអាស៊ានដទៃទៀត។ ប៉ុន្តែ ប្រទេសដែលជាមាជិកអាស៊ាននៅតែប្រកាន់យកគោលជំហរអមិត្តជាមួយនឹងរដ្ឋាភិបាលថ្មីនៃប្រទេសកម្ពុជាដដែល។ ម្យ៉ាងទៀត ក្នុងប្រទេសដែលជាសមាជិកសមាគមអាស៊ានទាំងអស់នោះ គេហៅរដ្ឋាភិបាលកម្ពុជាថា ជា«កូនដីងនៃពួកឈ្លានពានវៀតណាម»។ ប្រទេសសមាជិកអាស៊ានរួមនឹងប្រទេសមូលធនរីកចម្រើនបានចូលរួមយ៉ាងសកម្មក្នុងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចដល់ប្រទេសកម្ពុជា។ ដូចនេះ ទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មជាផ្លូវការជាមួយប្រទេសសមាជិកអាស៊ានដាក់ស្តែងគឺគ្មាន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នោះទេ។

ក៏ប៉ុន្តែ ប្រទេសថៃឡង់ដ៍ និងសិង្ហបុរី គឺបានប្រកាន់យកគោលជំហរមុខពីរ។ ក្នុងផលប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួន ប្រទេសទាំងពីរនេះបានពង្រីកការអភិវឌ្ឍពាណិជ្ជកម្មរហូតដល់លំដាប់ក្រុមហ៊ុនឯកជន។ ហើយបម្លាស់ប្តូរទំនិញជាមួយនឹងប្រទេសថៃឡង់ដ៍ គឺមានការរីកលូតលាស់យ៉ាងផុសផុល។ ជាក់ស្តែង ក្នុងឆ្នាំ១៩៩០ បម្លាស់ប្តូរទំនិញជាមួយនឹងប្រទេសនេះមានទំហំប្រហែលជា១០លានបាត( ៣៩១ពាន់ដុល្លា)ក្នុងរយៈពេលមួយខែៗ ដោយគិតទាំងទំនិញរត់ពន្ធគយ មានន័យថា ៤,៦៩លានដុល្លារក្នុងមួយឆ្នាំៗ។[១៦] បើតាមការវាយតម្លៃរបស់យើង តួលេខនេះអាចកើនឡើងចំនួន២ដងធៀបនឹងឆ្នាំ១៩៨៥។ សម្រាប់ការនាំចេញទំនិញរបស់កម្ពុជាវិញ គឺមានតម្លៃប្រហែលជាមួយភាគប្រាំនៃទំហំបម្លាស់ប្តូរទំនិញសរុប។ ចំណែកឯភាគីប្រទេសថៃបាននាំចេញទំនិញជាច្រើនប្រភេទ ចូលមកក្នុងប្រទេសកម្ពុជា ផ្តើមចេញពីម្ហូបអាហារគ្រប់មុខ គ្រឿងទេស រហូតដល់យានជំនិះ។ រីឯខាងភាគីកម្ពុជាវិញក៏បាននាំចេញទៅប្រទេសថៃវិញនូវផលិតផលឈើប្រណីត ត្បូងថ្មមានតម្លៃ ត្រីងៀត ត្រីឆ្អើរ គ្រឿងសង្ហារិមធ្វើពីឫស្សីនិងស្លាន់ ជ័រកៅស៊ូ ព្រមទាំងវត្ថុបុរាណផងដែរ។ គួរបញ្ជាក់ដែរថា ការវិភាគអំពីទំនាក់ទំនងវិស័យពាណិជ្ជកម្មក្រៅប្រទេសទាំងអស់នេះមានសភាពស្មុគស្មាញបំផុត ដោយសារតែមូលហេតុកង្វះទិន្នន័យស្ថិតិក្នុងស្រុក។

ចំពោះស្ថានភាពពាណិជ្ជកម្មខាងលើនេះ មានការផ្លាស់ប្តូរយ៉ាងគំហុកក្នុងអំឡុងឆ្នាំចុងក្រោយដែលអាចពន្យល់បានថា ស្ថានភាពបែបនេះបណ្តាលមកពីមូលហេតុនៃការកើនឡើងនៃចរន្តដំណោះស្រាយលើបញ្ហានយោបាយកម្ពុជា និងចក្ខុវិស័យថ្មីនៃការព្រមព្រៀងគ្នាក៏ដូចជាការផ្លាស់ប្តូរ

១៦ FEER, 1.03. 1990. P. 37.


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឥរិយាបថរបស់រដ្ឋាភិបាល ហ៊ុន សែន ក្រោយពីបានធ្វើកំណែទម្រង់គោល-នយោបាយដឹកនាំប្រទេសរបស់រដ្ឋាភិបាល និងគណបក្សជាមួយនឹងនយោបាយបើកចំហរដោយសេរីលើវិស័យពាណិជ្ជកម្មក្រៅប្រទេសផ្ដោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ស្របជាមួយគ្នានេះ ការចូលកាន់កាប់អំណាចនៃរដ្ឋាភិបាលថ្មីរបស់ប្រទេសថៃ ក្រោមការដឹកនាំរបស់លោក ឆាត់ឆៃ ឈុនហាវ៉ាន់ ក៏បានធ្វើឱ្យប្រទេសថៃងាកមកពិនិត្យមើលលើកិច្ចការនយោ-បាយក្រៅប្រទេសរបស់ខ្លួនជាមួយនឹងកម្ពុជាសាឡើងវិញ។ ម្យ៉ាងទៀត អាស្រ័យដោយផលប្រយោជន៍ពាណិជ្ជកម្មរបស់ថៃ ធ្វើឱ្យរដ្ឋាភិបាលលោក ឆាត់ឆៃ ឈុនហាវ៉ាន់ បានប្រកាន់យកគោលនយោបាយ«កែប្រែឥណ្ឌូចិនពីទីលានប្រយុទ្ធទៅជាទីផ្សារ»។ និន្នាការនេះបានធ្វើឱ្យវិនិយោគិនថៃចាប់ផ្ដើមចូលមកយកផលរ៉ែត្បូងថ្មមានតម្លៃ ផលព្រៃឈើ និងធ្វើទំនើបកម្មសហ-គ្រាសឧស្សាហកម្ម។ ក្រៅពីនោះ ក៏មានការបង្កើតជាកិច្ចព្រមព្រៀងជាមួយគ្នាស្ដីអំពីការស្ដាបនាស្ថានអាកាសរវាងក្រុងបាងកក និងខេត្តសៀមរាប ព្រមទាំងការស្ដារឡើងវិញនូវផ្លូវដែករវាងអារញ្ញប្រាថេត(ថៃឡង់ដ៍)ដល់ខេត្តបាត់ដំបង(កម្ពុជា) និងការតភ្ជាប់គ្នារហូតដល់ភ្នំពេញ គឺមានផ្លូវអាចទាក់ទងគ្នាដល់ទន្លេមេគង្គ និងអាចធ្វើដំណើរទៅដល់ប្រទេសវៀតណាមបាន។[១៧]

ប៉ុន្តែការលូតលាស់ទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្មរវាងរដ្ឋាភិបាលកម្ពុជា និងប្រទេសថៃ បានកាត់ផ្ដាច់ទៅវិញក្រោយពីរដ្ឋប្រហារថ្ងៃ ២៣ កុម្ភៈ ឆ្នាំ១៩៩១ដែលបានទម្លាក់រដ្ឋាភិបាល ឆាត់ឆៃ ឈុនហាវ៉ាន់។ ព្រោះថាអំណាចនៅប្រទេសថៃបានធ្លាក់ទៅក្នុងកណ្ដាប់ដៃយោធាដែលបានប្រកាសថា ក្នុងពេលឆាប់ៗខាងមុខនេះ ការទូតថៃនឹងវិលត្រលប់ទៅរកការអភិរក្សនិយមជាប្រពៃណី...។ រដ្ឋមន្ត្រីការបរទេសថៃ គឺលោក អ. សារ៉ាស៊ីន បាន

[១៧] TACC. 10.08.1989.

ថ្លៃងថា «បាងកកនឹងមិនមានបំណងចង់ធ្វើទំនាក់ទំនងជាមួយក្រុងភ្នំពេញឡើយ ក្នុងទម្រង់ដែលអាចឱ្យយើងយល់បានថា ជាការពុំទទួលស្គាល់រដ្ឋាភិបាលកម្ពុជានោះទេ»។[១៨] ចាប់ផ្ដើមពីចុងខែកុម្ភៈ ឆ្នាំ១៩៩១ យើងសង្កេតឃើញថា កើតមានទំនោរនៃការកាត់បន្ថយទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ការសម្រេចផែនការរបស់រដ្ឋាភិបាល ឆាត់ឆៃ ឈុនហាវ៉ាន់ ដែលត្រូវបានគេទម្លាក់ចេញពីដំណែងក្នុងការបើកការិយាល័យទំនាក់ទំនងពាណិជ្ជកម្មនៅភ្នំពេញ ត្រូវបានគេលើកពេលរហូតដល់«ការបញ្ចប់ជម្លោះនៅកម្ពុជា»។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅតែជាទីផ្សារទំនិញដ៏សំខាន់របស់ប្រទេសថៃឡង់ដ៍។ ហេតុដូច្នេះហើយ ទើបក្រុមអ្នកជំនួញថៃឡង់ដ៍ នៅតែខិតខំប្រឹងប្រែងសាកល្បងឥតឈប់ឈរលើការតភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងប្រទេសកម្ពុជាយើង តែទោះជាយ៉ាងក៏ដោយ ប្រក្រតីភាពនៃទំនាក់ទំនងរវាងប្រទេសទាំងពីរអាចកើតមានឡើងទៅបានលុះត្រាតែបន្ទាប់ពីបញ្ហារបស់កម្ពុជាត្រូវបានដោះស្រាយចប់សព្វគ្រប់។

ដោយឡែក កំណើនទំហំពាណិជ្ជកម្មជាមួយនឹងប្រទេសសិង្ហបុរីវិញ ដែលមានចរិតលក្ខណៈខុសប្លែកពីសមាជិកនៃបណ្ដាប្រទេសដែលជារដ្ឋសមាជិកអាស៊ានដទៃទៀត ត្រង់ចំណុចថា ប្រទេសនេះបានប្រឆាំងទៅនឹងរដ្ឋាភិបាល ហ៊ុន សែន ក៏ប៉ុន្តែបានធ្វើជំនួញយ៉ាងសកម្មជាមួយនឹងប្រទេសកម្ពុជា ក្នុងលំដាប់ក្រុមហ៊ុនឯកជន។ នៅប្រទេសកម្ពុជានាសម័យនោះបាននាំចូលយានយន្ត ម៉ូតូ គ្រឿងប្រដាប់ប្រើប្រាស់ផ្សេងៗ និងបរិក្ខារអគ្គិសនីជាច្រើនទៀតពីប្រទេសសិង្ហបុរី។ លើសពីនេះទៅទៀត ក៏មានការចរចាគ្នាដើម្បីស្វែងរកការបង្កើតជាផ្លូវហោះហើររវាងប្រទេសទាំងពីរផងដែរ។

ផ្ទុយទៅវិញ ទោះបីជាមានបម្រែបម្រួលជាវិជ្ជមានលើវិស័យពាណិជ្ជកម្មក្រៅប្រទេសយ៉ាងណាក៏ដោយ ក៏ទំហំនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

---

[១៨] Материалы управления стран Тихого океана и Юго-Восточной Азии МИД СССР. 18 марта 1991 г.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសអាស៊ាននៅមានទំហំតូចនៅឡើយ។ ហេតុនេះហើយទើបស្ថានភាពសេដ្ឋកិច្ចពាណិជ្ជកម្មក្រៅប្រទេសជាមួយនឹងបណ្តាប្រទេសទាំងអស់ខាងលើនេះពុំអាចចាត់ទុកថា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានោះបានឡើយ ព្រោះដោយសារតែបញ្ហាទំនាស់មនោគមវិជ្ជាផ្នែកនយោបាយ និងបញ្ហាផលិតកម្មទាប ក៏ដូចជាការនាំចេញមានកម្រិតតិចតួចនៅឡើយរបស់កម្ពុជា។

ជាងនេះទៀត ចំពោះការពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសក្នុងតំបន់អាស៊ានជាមួយនឹងប្រទេសនានាក្នុងតំបន់ ក៏ដូចជាជាមួយប្រទេសលោកខាងលិច បានបង្ហាញឱ្យឃើញនូវការពិនិត្យឡើងវិញរបស់ប្រទេសកម្ពុជាអំពីការប្រកាន់យកនិន្នាការមនោគមវិជ្ជា និងនយោបាយពាណិជ្ជកម្មក្រៅប្រទេសរបស់រដ្ឋាភិបាលដោយតម្រូវឱ្យយើងព្យាយាមជាបន្តទៀតក្នុងការបោះបង់ចោលនូវរបបនយោបាយប្រឈមមុខដាក់គ្នានាសម័យសង្គ្រាមត្រជាក់ដែលនៅពេលនោះ បានឱ្យតម្លៃខ្ពស់តែទៅលើកិច្ចការមនោគមវិជ្ជា និងការប្រកាន់យកនិន្នាការនយោបាយនៃប្លុករៀងៗខ្លួន។

ក្រៅពីប្រទេសថៃឡង់ដ៍ និងប្រទេសសិង្ហបុរី យើងសង្កេតឃើញថាប្រទេសកម្ពុជាមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មជាមួយនឹងប្រទេសឥណ្ឌាហុងកុង និងតៃវ៉ាន់ផងដែរ។ ក៏ប៉ុន្តែ ទំហំពាណិជ្ជកម្មមានទ្រង់ទ្រាយតូចបើប្រៀបធៀបទៅនឹងទំហំទំនាក់ទំនងពាណិជ្ជកម្មក្រៅប្រទេសទាំងមូល។ នៅសម័យនោះ ប្រទេសកម្ពុជាបាននាំចេញផលិតផលកសិកម្មមួយចំនួនទៅកាន់ប្រទេសទាំងអស់ខាងលើនេះ ហើយបាននាំចូលគ្រឿងរបស់របរប្រើប្រាស់ផ្សេងៗ គ្រឿងបរិក្ខារអគ្គិសនីនិងអេឡិកត្រូនិក និងសម្ភារសំណង់មកវិញ។ ក៏ប៉ុន្តែ ដោយសារតែការគ្រប់គ្រងរបស់រដ្ឋមានលក្ខណៈទន់ខ្សោយបានធ្វើឱ្យទិន្នន័យស្ថិតិលម្អិតស្តីអំពីស្ថានភាពរបស់វិស័យពាណិជ្ជកម្មក្រៅប្រទេសជាមួយបណ្តាប្រទេសទាំងអស់ខាងលើនេះពុំមានឡើយ។

ជាងនេះទៀត ចំពោះស្ថានភាពនៃទំនាក់ទំនងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាជាមួយនឹងប្រទេសអភិវឌ្ឍសេដ្ឋកិច្ចក្នុងនិន្នាការមូលធននិយមវិញ យើងសង្កេតឃើញថា នៅក្នុងទសវត្សរ៍ទី៨០ហាក់ដូចជាមានស្ថានភាពផ្ទាស់ភ្ជាររវាងកំណើន និងតំហយ។ លើសពីនេះទៀត ទោះបីជាមានរបាំងសេដ្ឋកិច្ចទៅលើប្រទេសកម្ពុជាពីសំណាក់បណ្ដាប្រទេសលោកខាងលិចយ៉ាងណាក៏ដោយ ក៏ទំនាក់ទំនងវិស័យពាណិជ្ជកម្មជាមួយប្រទេសមូលធនទាំងនោះនៅតែមានការរីកលូតលាស់ទៅមុខជាលំដាប់។ ហើយអ្នកជំនួញនៃប្រទេសខាងលើនេះកាន់តែសម្លឹងឃើញអំពីសារៈសំខាន់នៃការភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសកម្ពុជាយើង។ ជាក់ស្ដែង ចាប់តាំងពីឆ្នាំ១៩៨០ សមាគមពាណិជ្ជកម្មជប៉ុន-កម្ពុជាបានប្រកាសថា គេបានព្រមព្រៀងជាមួយប្រទេសកម្ពុជាក្នុងការដោះដូរទំនិញជាទ្វេភាគី។ ស្របតាមការពង្រឹងបានជាបណ្ដើរៗលើវិស័យសេដ្ឋកិច្ចក្នុងប្រទេស និងលទ្ធភាពនាំចេញធំជាងមុនដែលកាលពីកន្លងមកមានកម្រិតទាបនោះ បានធ្វើឱ្យទំនាក់ទំនងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាជាមួយនឹងបណ្ដាប្រទេសមូលធននិយមមានការរីកចម្រើនជាហូរហែ។ ប៉ុន្តែ រហូតមកដល់រយៈពេលចុងក្រោយនេះ ទំនាក់ទំនងវិស័យពាណិជ្ជកម្មជាមួយនឹងប្រទេសទាំងអស់នេះក៏នៅតែមានកម្រិតទាបនៅឡើយ។ ហើយម្យ៉ាងទៀតប្រទេសកម្ពុជាបានផ្សារភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មតែក្នុងលំដាប់ក្រុមហ៊ុនឯកជនជាមួយប្រទេសតែពីរប៉ុណ្ណោះ គឺប្រទេសជប៉ុន និងប្រទេសបារាំង។

ហេតុដូច្នេះហើយ បានជាយើងតែងតែលើកឡើងមកពីខាងដើមថា គេបានដាក់រដ្ឋកម្ពុជាឱ្យស្ថិតនៅជារដ្ឋឯកោផ្នែកនយោបាយ និងសេដ្ឋកិច្ចដ៏យូរអង្វែងពីសំណាក់ប្រទេសមូលធននិយមដែលបញ្ហាទាំងអស់នេះបានក្លាយជាឧបសគ្គដ៏ធំបំផុតដល់ការអភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសកម្ពុជាជាមួយនឹងបណ្ដាប្រទេសលោកខាងលិច និងប្រទេសតតិយលោក។ ចំពោះការបង្កើតតំបន់សេដ្ឋកិច្ចទីផ្សារសេរីនៅកម្ពុជា នាឆ្នាំចុង

ក្រោយនេះ(១៩៩០) បានធ្វើឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់ក្រុមហ៊ុនជាច្រើននៅបស្ចិមប្រទេស និងប្រទេសតតិយលោកផងដែរដែលធ្លាប់មានការធ្វើទំនាក់ទំនងជាមួយនឹងស្ថាប័នពាណិជ្ជកម្មរបស់រដ្ឋ។ ជាងនេះទៅទៀត ទំហំពាណិជ្ជកម្មជាមួយនឹងក្រុមហ៊ុនទាំងនេះមានការកើនឡើងទ្វេដងក្នុងរយៈកាលនៃឆ្នាំចុងក្រោយដែលមានតម្លៃគិតជាទឹកប្រាក់ប្រមាណ១៣,៤លានដុល្លារអាមេរិក។[១៩] នៅសម័យនោះដែរ ប្រទេសកម្ពុជាយើងបាននាំចេញទំនិញកសិកម្មមួយចំនួនទៅកាន់បណ្ដាប្រទេសទាំងអស់នោះ ដូចជាកៅស៊ូធម្មជាតិ និងកសិផលផ្សេងៗទៀត ហើយក៏បាននាំចូលមកវិញនូវវត្ថុធាតុដើម សម្រាប់បម្រើឱ្យវិស័យឧស្សាហកម្មផលិតកម្មជាគ្រឿងបន្លាស់និងបរិក្ខារ និងសម្ភារប្រើប្រាស់ទូទៅ។ មានក្រុមហ៊ុនជាច្រើនដែលមកពីប្រទេសជប៉ុន និងប្រទេសបារាំងដែលបានសម្ដែងនូវបំណងចង់ចូលរួមក្នុងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ជាពិសេសនៅក្នុងវិស័យផលិតកម្មកៅស៊ូ ការកែច្នៃឈើប្រណីត ការផលិតចំណីអាហារ ធនធានជលផលសមុទ្រ ការរុករករ៉ែ និងវិស័យវប្បធម៌ជាដើម។

ការរីកធំធាត់លើទំនាក់ទំនងសេដ្ឋកិច្ចរបស់រដ្ឋាភិបាលជាមួយនឹងបណ្ដាប្រទេសមូលធននិយមនាពេលកន្លងមកទទួលបានលទ្ធផលគួរជាទីមោទនៈ។ ហើយក្នុងចំណោមបណ្ដាប្រទេសទាំងអស់នោះ យើងពិនិត្យឃើញថា ប្រទេសជប៉ុន និងអូស្ត្រាលីបានត្រៀមខ្លួនជានិច្ចជុំវិញការ«ពង្រីកខ្សែចំណងសេដ្ឋកិច្ច»ក្នុងខណៈពេលដែលប្រទេសកម្ពុជាយើង បាននិងកំពុងមានការផ្សះផ្សាជាតិផ្នែកនយោបាយ។ ម្យ៉ាងទៀត ក្នុងគោលបំណងដើម្បីបង្កើនការរួមចំណែកផ្នែកនយោបាយក្រៅប្រទេសរបស់ខ្លួន រដ្ឋាភិបាលជប៉ុនបានសម្រេចផ្ដល់ជាជំនួយជាទឹកប្រាក់ជាសរុបប្រមាណ២ ០០០លានដុល្លារអាមេរិកដល់ដំណើរការនៃការស្ដារឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេស

[១៩] កម្រងស្ថិតក្រសួងផែនការ ឆ្នាំ១៩៧៩-១៩៨៩ ភ្នំពេញ ១៩៨៩


fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្ពុជា។ ចំណែកឯប្រទេសអូស្ត្រាលីវិញ ក៏បានរួមចំណែកផ្នែកហិរញ្ញវត្ថុជាច្រើនលានដុល្លារផងដែរក្នុងកិច្ចដំណើរការនេះ។ អ្នកការទូតរបស់ជប៉ុនមានគោលបំណងចង់បង្កើតឡើងនូវបរិយាកាសដ៏ប្រសើរមួយ សម្រាប់ការជ្រៀតចូលរបស់ក្រុមហ៊ុនជប៉ុនទៅក្នុងសេដ្ឋកិច្ចកម្ពុជា ដូចនេះ ពុំមែនជាការចៃដន្យនោះទេដែលប្រទេសកម្ពុជាបានធ្វើឱ្យក្រុមហ៊ុនជប៉ុនជាច្រើនមានសកម្មភាពយ៉ាងខ្លាំងក្លាជាមួយនឹងគោលបំណងបណ្ដាក់ទុនវិនិយោគ។

ហេតុដូចនេះ ការអនុវត្តគោលនយោបាយបើកចំហរលើវិស័យសេដ្ឋកិច្ចក្រៅប្រទេសបាននាំមកនូវការពង្រឹងស្ថានភាពនយោបាយក្រៅប្រទេសរបស់រដ្ឋកម្ពុជាលើឆាកអន្តរជាតិ និងការបង្កើនទំនុកចិត្តទៅលើរដ្ឋាភិបាលសម័យនោះ។ នៅខែសីហា ឆ្នាំ១៩៩០ រដ្ឋាភិបាល របស់សហរដ្ឋអាមេរិកក៏បានចេញសេចក្ដីប្រកាសចំពោះការត្រៀមជាស្រេចក្នុងការចរចាជាមួយនឹងរដ្ឋាភិបាល ហ៊ុន សែន និងការផ្ដល់ជំនួយសេដ្ឋកិច្ច។

នៅដើមឆ្នាំ១៩៨៩ មានក្រុមហ៊ុនបរទេសជាច្រើនបានមកចុះហត្ថលេខាលើកិច្ចសន្យាសាងសង់រោងចក្រសម្រាប់វិស័យជាច្រើន។ ក្រុមហ៊ុនជប៉ុនឈ្មោះ អូកាដា ឡូហ្គីនកូ បានសាងសង់រោងចក្រអារឈើដែលមានតម្លៃសាច់ប្រាក់ដល់ទៅ២៤លានយ៉េន(១៩៣,៥៥ពាន់ដុល្លារ)។ ផលិតភាពរោងចក្រអាចផលិតបានប្រមាណ៣,៥ពាន់ម៉ែត្រគូបក្នុងមួយខែ។ ហើយមានគម្រោងនាំចេញរហូតដល់១ ០០០លានយ៉េនក្នុងមួយឆ្នាំ។[២០] ផ្សេងពីនេះទៀតក៏មានអណិកជនខ្មែរដែលទៅរស់នៅបរទេសក៏បានកមចុះកិច្ចសន្យាស្ដីអំពីការស្ដារឡើងវិញនូវវិស័យសណ្ឋាគារលំដាប់ផ្កាយខ្ពស់«កាំបូឌីយ៉ាណា»ក្នុងទំហំទឹកប្រាក់ចំនួន១០លានដុល្លារ។[២១] នៅសម័យកាលនោះថ្នាក់ដឹកនាំរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មដែលជាទូទៅ រដ្ឋាភិបាលមានបំណង

[២០] SPK. 25.05.1989.

[២១] Ibid.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រីតបន្តឹងចំណងសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មជាមួយបណ្ដារដ្ឋមូលធននិយម និងប្រទេសតតិយលោក ជាពិសេសជាមួយប្រទេសទាំងឡាយក្នុងតំបន់។

ចក្ខុវិស័យក្នុងការពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងកម្ពុជាជាមួយនឹងប្រទេសមូលធនរីកចម្រើន ក៏ដូចជាប្រទេសតតិយ-លោក ជាប់ទាក់ទងទៅនឹងល្បឿននៃការដោះស្រាយលើបញ្ហាជម្លោះផ្នែកនយោបាយនៅក្នុងប្រទេសកម្ពុជាយើង។ បើយើងសង្កេតតាមដានជុំវិញការវិវត្តនៃព្រឹត្តិការណ៍នយោបាយនៅដំណាក់កាលចុងក្រោយនេះ យើងឃើញថា ជម្លោះដ៏រ៉ាំរ៉ៃដែលបានអូសបន្លាយជាយូរមកហើយនោះនឹងត្រូវបានដោះស្រាយឱ្យបានចប់សព្វគ្រប់នាដំណាក់កាលឆាប់ៗនេះ។ ជាក់ស្ដែងក្នុងខែសីហា ឆ្នាំ១៩៩០ នៅទីក្រុងញូវយ៉ក មានកិច្ចប្រជុំនៃសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលំដាប់អនុរដ្ឋ-មន្ត្រីការបរទេសដែលបានសម្រេច និងអនុម័តលើកិច្ចព្រមព្រៀងស្ដីអំពីដំណោះស្រាយបញ្ហានៅកម្ពុជា។ តាមគោលការណ៍នៃកិច្ចព្រមព្រៀងនេះប្រជាជនកម្ពុជានឹងត្រូវបានផ្ដល់សិទ្ធិក្នុងការជ្រើសរើសអនាគតនៃមាគ៌ានយោបាយរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ផែនការខាងលើនេះបែងចែកជា៥ដំណាក់កាលគឺដំណាក់កាលអន្តរកាលដែលទាក់ទងនឹងការគ្រប់គ្រងក្នុងចន្លោះពេលមុនការបោះឆ្នោត ការសម្រប-សម្រួលផ្នែកយោធា ការបោះឆ្នោតក្រោមការត្រួតពិនិត្យរបស់អ.ស.ប. ការការពារសិទ្ធិមនុស្ស ការធានាអះអាងអំពីសហគមន៍អន្តរជាតិស្ដីអំពីឯករាជ្យភាព និងអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា។ សមាជិកអចិន្ត្រៃយ៍នៃក្រុម-ប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទាំងប្រាំនឹងរៀបចំបង្កើតជាក្រុមប្រឹក្សាជាតិជាន់ខ្ពស់សម្រាប់កម្ពុជា។ ហើយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាត្រូវតែជាតំណាងនៃឯករាជ្យភាព អធិបតេយ្យភាព និងឯកភាពជាតិពិតប្រាកដរបស់កម្ពុជាព្រមទាំងមានតួនាទីជាតំណាងរបស់ប្រទេសក្នុងកិច្ចការ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បរទេស។ អ្នកតំណាងរបស់ក្រុមប្រឹក្សានេះត្រូវអង្គុយលើកៅអីកម្ពុជានៅ អ.ស.ប។

ក្នុងខែកញ្ញា ឆ្នាំ១៩៩០ ក្នុងកិច្ចប្រជុំវិសាមញ្ញរវាងភាគីទាំងបួននៃក្រុមប្រឹក្សានេះបានអនុម័តយល់ព្រមលើឯកសារដែលបានរៀបចំឡើងដោយសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទាំងប្រាំ ហើយបានចាត់ទុកជាគោលការណ៍សម្រាប់ការដោះស្រាយជម្លោះនៅកម្ពុជា ដោយទទួលភារកិច្ចក្នុងការអនុវត្តលើដំណោះស្រាយនយោបាយស្របតាមស្មារតីនៃកិច្ចព្រមព្រៀងអន្តរជាតិនៅទីក្រុងប៉ារីសស្តីពីកម្ពុជា។ នៅក្នុងជំនួបនោះដែរ ក៏មានការព្រមព្រៀងគ្នារវាងភាគីកម្ពុជាទាំងអស់អំពីសមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលមានសមាសភាពចំនួន៦រូបជាតំណាងរដ្ឋកម្ពុជា និង៦រូបទៀតមកពីក្រុមបក្សប្រឆាំង។

ពិតណាស់ថា នៅពេលដែលដំណើរការដោះស្រាយបញ្ហាកម្ពុជាបានខិតជិតមកដល់ទីបញ្ចប់ ក្រុមអ្នកជំនួញនៅប្រទេសអាស៊ានក៏បានចាប់ផ្តើមពិភាក្សាអំពីកម្ពុជា។ ពួកក្រុមអ្នកនយោបាយ និងអ្នកជំនួញនៅប្រទេសថៃបានចាប់ផ្តើមពិភាក្សាគ្នាអំពីគោលការណ៍«សុវណ្ណភូមិ»ដែលក្នុងកិច្ចពិភាក្សានេះ មានការចូលរួមពីប្រទេសថៃ វៀតណាម ឡាវ កម្ពុជា និងមីយ៉ាន់ម៉ា។ ពួកគេបានយល់ថា ប្រទេសថៃត្រូវតែធ្វើជាអ្នកនាំមុខគេក្នុងការបង្រួបបង្រួមនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ លើសពីនេះទៅទៀត រដ្ឋាភិបាលរបស់លោក ឆាត់ឆៃ ឈុនហាវ៉ាន់ ថៃមទាំងបានបង្កើតជាគម្រោងការដើម្បីប្រើប្រាស់ទំនាក់ទំនងជាមួយកម្ពុជាក្នុងទិសដៅអភិវឌ្ឍន៍តំបន់ត្រីក្រប៉ែកឦសាននៃប្រទេសទៀតផង។[២២]

ចំណែកឯក្រុមអ្នកជំនួញក្នុងចំណោមបណ្តាប្រទេសអាស៊ានវិញ យល់ថា យោងទៅតាមស្ថានការណ៍នយោបាយដែលបានកើតមាននៅ

---

២២ TACC. 24.02.1989.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជា ហេតុដូចនេះ ក្រោយពីបានដោះស្រាយបញ្ហានយោបាយបានចប់សព្វគ្រប់ ប្រទេសកម្ពុជាអាចតភ្ជាប់ខ្លួនទៅនឹងប្រទេសក្នុងចំណោមប្រទេសនៃអនុតំបន់របស់ខ្លួនបាន ហើយកិច្ចសហប្រតិបត្តិការ អាចកើតមានឡើងដើម្បីការស្តារ និងការអភិវឌ្ឍកំណើនសេដ្ឋកិច្ចឱ្យឡើងទៅដល់កម្រិតណាមួយ។ ជាងនេះទៀត ពួកគេយល់ថា បើប្រទេសកម្ពុជាយើងពុំអាចដោះស្រាយបញ្ហាទាំងអស់នេះបានដោយខ្លួនឯងនោះទេ ហេតុនេះ ពួកគេក៏មិនអាចសង្ឃឹមបានដែរលើការបណ្តាក់ទុនវិនិយោគ និងបច្ចេកវិទ្យាពីក្រុមប្រទេសអាស៊ាន ព្រោះថា ប្រទេសទាំងអស់នោះបច្ចុប្បន្នក៏បាននឹងកំពុងតែដោះស្រាយបញ្ហាបង្កើនចំណូល និងស្វែងរកការវិនិយោគហិរញ្ញវត្ថុពីក្រៅប្រទេសដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសអាស៊ានក៏នៅតែយកចិត្តទុកដាក់ជាខ្លាំងចំពោះការអភិវឌ្ឍទំនាក់ទំនងជាមួយនឹងកម្ពុជាក្នុងកម្រិតមួយដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួន ពោលគឺការពង្រីកទីផ្សារនាំចេញទំនិញតាមរយៈការបង្កើនការគាំពារ ហើយពន្យឺតល្បឿនផលិតកម្មក្នុងប្រទេសមូលធនរីកចម្រើន។

ជំហានដ៏សំខាន់មួយក្នុងការពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជាជាមួយនឹងអាស៊ាន គឺការហ្វឹកហ្វឺនអ្នកបច្ចេកទេសជាតិក្នុងស្ថាប័នអប់រំនៃប្រទេសសមាជិកអាស៊ាន។ ការបណ្តុះបណ្តាលជំនាញនានាតាមផ្នែកជាច្រើន ជាពិសេស ក្នុងផ្នែកកសិកម្មផលិតកម្ម មានអាទិភាពធំធេងជាងគេនៅកម្ពុជា បើធៀបទៅនឹងបណ្តាប្រទេសជឿនលឿន ដោយហេតុថា មិនចាំបាច់បង្វឹក ឬបន្សាំអ្នកបច្ចេកទេសទាំងនោះច្រើនទេ ព្រោះតែលក្ខខណ្ឌដែលមានលក្ខណៈដូចគ្នា ឬប្រហែលគ្នាក្នុងប្រទេសជិតខាងយើង។ លើសពីនោះទៅទៀត សឹងតែគ្រប់ប្រទេសដែលជាសមាជិកអាស៊ានធ្លាប់បានឆ្លងកាត់ដំណាក់កាលនៃការអភិវឌ្ឍប្រហាក់ប្រហែលគ្នាដូចដែលយើងកំពុងតែអនុវត្តនៅក្នុងប្រទេសកម្ពុជាដែរ។ ហេតុដូច្នេះហើយ យើងសង្កេតឃើញថា បទពិសោធន៍ដ៏មានតម្លៃជាច្រើនផ្នែកកសិកម្មក្នុងបណ្តា


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសទាំងអស់ខាងលើនោះអាចយកមកប្រើប្រាស់ជាបទពិសោធន៍បាន សម្រាប់ប្រទេសកម្ពុជាយើងផងដែរ។

ផលប្រយោជន៍ដ៏ធំមួយទៀត គឺការរៀបចំជាកម្មវិធីទាក់ទាញវិនិយោគិនពីបរទេសឱ្យមកកាន់ប្រទេសកម្ពុជា និងប្រទេសជាសមាជិកអាស៊ាន។ ក្នុងផែនការនេះដែរ ប្រទេសដែលជាសមាជិក មានបទពិសោធន៍យ៉ាងបរិបូណ៌ដែលក្នុងបញ្ហានេះ ក្រុមអ្នកជំនួញអាស៊ានយល់ថា ទិសដៅដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតំបន់នាទសវត្សរ៍៩០ គឺត្រូវធ្វើយ៉ាងណាដើម្បីប្រែក្លាយប្រទេសអាស៊ានឱ្យក្លាយទៅជាមជ្ឈមណ្ឌលវិនិយោគ។ ក្នុងនិន្នាការនេះដែរ គេបានអំពាវនាវឱ្យមានការប្រើប្រាស់ឱ្យអស់ពីលទ្ធភាពក្នុងការស្តារសេដ្ឋកិច្ចប្រទេសក្នុងឥណ្ឌូចិន។[២៣] ជាងនេះទៀត ប្រទេសសិង្ហបុរីដែលជាសមាជិកមួយក្នុងចំណោមសមាជិកអាស៊ានដទៃទៀត ធ្លាប់មានកិត្តិសព្ទល្បីល្បាញ និងជាមជ្ឈមណ្ឌលហិរញ្ញវត្ថុ និងធនាគារ ហើយក៏ធ្លាប់បានដើរតួយ៉ាងសំខាន់ក្នុងការស្តារសេដ្ឋកិច្ចកម្ពុជានាពេលកន្លងមក។

ក្នុងដំណាក់កាលចុងក្រោយនេះ ក្រៅពីគំនិតដែលថា «កែប្រែឥណ្ឌូចិនពីទីលានប្រយុទ្ធឱ្យទៅជាទីផ្សារទំនិញ»នោះក្នុងចំណោមអ្នកនយោបាយ និងអ្នកជំនួញនៃប្រទេសអាស៊ីអាគ្នេយ៍ ក៏មានការពិភាក្សាយ៉ាងផុសផុលផងដែរអំពីសំណួរដែលមិនមានលក្ខណៈបច្ចុប្បន្នភាព ហើយគ្រាន់តែជាទ្រឹស្តីស្តីអំពីការចូលរួមក្នុងពេលអនាគតរបស់កម្ពុជាទៅក្នុងអាស៊ាន។

យើងអាចពោលបានថា ទស្សនទានក្នុងការពង្រីកសេដ្ឋកិច្ចអាស៊ានពុំមែនទើបតែកើតមានឡើងនាពេលនេះនោះទេ ប៉ុន្តែលទ្ធភាពជាទ្រឹស្តី គឺបានកើតមានឡើងក្នុងសេចក្តីថ្លែងការណ៍រួមនៅទីក្រុងបាងកកតាំងពីឆ្នាំ១៩៦៧មកម្ល៉េះ ដែលបានចង្អុលបង្ហាញថា សមាគមបានបើកចំហសម្រាប់ការចូលរួមពីគ្រប់ប្រទេសទាំងអស់ក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលអាចគោរព

---

[២៣] TACC. 30.03.1990.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានតាមគោលបំណង និងគោលការណ៍ខាងលើនេះ។[២៤]

ពាក្យចចាមអារាមស្ដីពីការរំពឹងអំពីការចូលរួមរបស់កម្ពុជា និងប្រទេសដទៃទៀតបានកើតមានឡើងមួយរយៈចុងក្រោយនេះ យោងទៅលើបរិយាកាសនយោបាយក្នុងអនុតំបន់ និងទំនោរដែលផាកទៅរកការរួបរួមគ្នាតាមតំបន់ខាងផ្នែកសេដ្ឋកិច្ច ក៏ដូចជាវិស័យនយោបាយជំនួសឱ្យការប្រទូសរ៉ាយគ្នាផ្នែកមនោគមវិជ្ជា។ ជាក់ស្ដែង នៅសម័យកាលនោះ នៅតាមបណ្ដារដ្ឋធានីនៃប្រទេសអាស៊ាននានា មានការលើកឡើងជាបដាថា ៖ «ឈ្មោះថាអាស៊ានគឺជាសមាគមនៃប្រទេសនៅអាស៊ីអាគ្នេយ៍ និងមិនត្រឹមត្រូវតាមឈ្មោះ និងទីតាំងភូមិសាស្ត្រទេ ដរាបណាសមាគមមិនទទួលយកជាសមាជិករបស់ខ្លួននូវប្រទេសមីយ៉ាន់ម៉ា ឡាវ វៀតណាម និងកម្ពុជា ដែលទោះបីជាពេញចិត្តយើងក្ដី ឬមិនពេញចិត្តក្ដី ប៉ុន្តែប្រទេសទាំងនោះក៏ស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍នោះដែរ»។ ប៉ុន្តែតាមការវាយតម្លៃរបស់អ្នកស្រាវជ្រាវ និងអ្នកជំនួញក្នុងសមាគម គឺពួកគេពុំបានមិនឯកភាពគ្នាទាំងស្រុងអំពីពេលវេលានៃការចូលរួមរបស់ប្រទេសទាំងអស់នេះមកក្នុងសមាជិកអាស៊ាននោះទេ។ម៉្យាងទៀត ការពង្រីកសមាជិកភាពរបស់សមាគម វាអាចនាំមកនូវតុល្យភាពនយោបាយអាស៊ាន ការកសាងសុខដុមនីយកម្មសម្រាប់ការស្ដារពិភពលោក និងសន្តិសុខក្នុងតំបន់។

ក៏ប៉ុន្តែ ការពង្រីកសមាជិកភាពនៃសមាគមអាស៊ានអាចនាំមកនូវអម្រែកហិរញ្ញវត្ថុបន្ថែមទៀតដល់ប្រទេសជាសមាជិកដែលកំពុងតែខ្វល់ខ្វាយអំពីកំណើនសេដ្ឋកិច្ចរបស់ខ្លួនផងដែរនោះ។ ដូចនេះហើយទើបនៅរដ្ឋធានីនៃប្រទេសជាសមាជិកអាស៊ាន មានការយល់ឃើញផ្សេងៗគ្នាជុំវិញបញ្ហានេះ។ ចំពោះប្រទេសកម្ពុជា ការចូលជាសមាជិកអាស៊ាន យើងមានជំនឿមុតមាំថា ពុំអាចដោះស្រាយបញ្ហាសេដ្ឋកិច្ចប្រទេសដោយស្វ័យប្រវត្តបាន

[២៤] The Asian Declaration, August 8, 1967. Bangkok.

នោះទេ ប៉ុន្តែវាអាចជួយយើងក្នុងការបង្កើនកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងបណ្តាប្រទេសជាសមាជិកក្នុងតំបន់ ហើយនឹងបានដល់ការបញ្ជ្រាបសេដ្ឋកិច្ចកម្ពុជាបានឆាប់រហ័សទៅក្នុងចរន្តសេដ្ឋកិច្ចពិភពលោក។ ជាចក្ខុវិស័យ ការចូលរួមរបស់ប្រទេសកម្ពុជាចូលក្នុងសមាជិកនៃប្រទេសអាស៊ានធ្វើឱ្យយើងទទួលបានចំណុចវិជ្ជមានជាច្រើនអន្លើ។ ក្នុងនោះដោយសារតែភូមិសាស្ត្រនៃប្រទេសជាសមាជិកអាស៊ានជាមួយនឹងប្រទេសកម្ពុជា គឺបានស្ថិតក្នុងតំបន់តែមួយ។ ទិសដៅដ៏សំខាន់មួយទៀតនៃកិច្ចសហប្រតិបត្តិការគឺត្រូវតែឈរលើការបង្កើតផលិតកម្មរួមដោយផ្អែកលើការអភិវឌ្ឍធនធានធម្មជាតិ ការកសាងសហគ្រាសចម្រុះក្នុងវិស័យឧស្សាហកម្ម ការអភិវឌ្ឍរួមគ្នា ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំវិធានការនានាសម្រាប់បង្កើនទុនវិនិយោគ បម្លាស់ប្តូរបទពិសោធន៍ និងព័ត៌មាន និងការរៀបចំបណ្តុះបណ្តាលអ្នកបច្ចេកទេសជាដើម។ គោលបំណងចម្បងនៃការចូលជាសមាជិករបស់អាស៊ាន ដើម្បីជំរុញដល់ដំណើរការនៃការអភិវឌ្ឍនៃវិស័យឧស្សាហូបនីយកម្មដោយធ្វើយ៉ាងណាឱ្យក្លាយជាចលករនៃការអភិវឌ្ឍពិតប្រាកដ។

ប៉ុន្តែ ចំពោះលទ្ធភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសអាស៊ាន គឺនៅមានកម្រិតទាបនៅឡើយ ដោយសារតែមូលហេតុពាក់ព័ន្ធនឹងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅមានកម្រិតទាបជាងប្រទេសដទៃទៀតក្នុងសមាគម។

ក្រៅពីបញ្ហាខាងលើនេះ ប្រទេសអាស៊ានក៏ជាអង្គការនយោបាយមួយផងដែរ។ ហើយការចូលរួមរបស់កម្ពុជាក្នុងសមាជិកអាស៊ានអាចកើតឡើងបាន ប្រសិនបើវាមិនប៉ះពាល់ដល់អព្យាក្រឹតភាពរបស់ប្រទេសកម្ពុជាក្រោយពីជម្លោះត្រូវបានដោះស្រាយបញ្ចប់។ លើសពីនេះទៀត ក៏មាននិន្នាការនយោបាយយោធា និងយុទ្ធសាស្ត្ររវាងតុល្យភាពកម្លាំងនៅក្នុងតំបន់នេះ( រវាងប្លុកវៀតណាម និងឡាវ មួយផ្នែក ហើយមួយផ្នែកទៀត


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺជាប្រទេសសមាជិកអាស៊ាន)។ បើយើងពិនិត្យជារួមនៅក្នុងទ្រង់ទ្រាយសកល គឺវាជាមហាអំណាចធំៗដែលឈរនៅពីខាងក្រោយ(ពោលគឺវាង លោកខាងលិចជាមួយនឹងស.ស.ស.ស និងចិន)។ ហេតុនេះហើយ ប្រទេសកម្ពុជាអាចមានជម្រើសបីយ៉ាង គឺកម្ពុជាអព្យាក្រឹត មិនចូលរួមជាមួយអាស៊ាន ប៉ុន្តែបង្កើនទំនាក់ទំនងជិតស្និទ្ធជាមួយនឹងប្រទេសក្នុងសមាគមទាំងផ្នែកសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងវប្បធម៌។ ទីពីរ ការចូលរួមរបស់កម្ពុជាធ្វើឡើងតែក្នុងវង្វង់សេដ្ឋកិច្ចនៃអង្គការអាស៊ាន។ ទីបី រួមបញ្ចូលកម្ពុជាចូលទៅក្នុងប្រទេសទាំងអស់នៅឥណ្ឌូចិន និងទៅក្នុងអាស៊ាន ប៉ុន្តែ ករណីនេះ តិច ឬច្រើន ធ្វើឱ្យកើតមាននូវបញ្ហាមិនឯករាជ្យភាពផ្នែកនយោបាយក្រៅប្រទេស។

ទោះជាយ៉ាងណាក៏ដោយ ក្រោយពេលដែលប្រទេសកម្ពុជាយើងបានដោះស្រាយបញ្ហាជម្លោះរួចរាល់ហើយនោះ ប្រទេសកម្ពុជាត្រូវតែគិតគូរ និងហ៊ានធ្វើសេចក្តីសម្រេចដ៏ត្រឹមត្រូវអំពីការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច-ពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់ ជាពិសេស ជាមួយបណ្តាតំបន់ឧស្សាហកម្មថ្មីៗនៅអាស៊ី រួមមានហុងកុង តៃវ៉ាន់ និងប្រទេសកូរ៉េខាងត្បូង។ ប្រទេសទាំងអស់នេះ យើងពិនិត្យឃើញថា មានលក្ខណៈសម្បត្តិដែលប្រកបដោយធនធានបម្រុង និងបច្ចេកវិទ្យាឈានមុខដែលមានលទ្ធភាពលើការមកបណ្តាក់ទុនវិនិយោគសម្រាប់សេដ្ឋកិច្ចប្រទេសកម្ពុជា។

យើងមានសុទិដ្ឋិនិយមចំពោះស្ថានការណ៍មួយដែលថា ក្រោយពីការសម្រេចបាននូវការសម្របសម្រួលផ្នែកនយោបាយនៅកម្ពុជារួចមក ប្រភពទុនវិនិយោគជាច្រើនអាចនឹងហូរចូលមកសម្រាប់ការស្តារសេដ្ឋកិច្ចប្រទេសកម្ពុជា ជាពិសេសមកពីប្រទេសជប៉ុន អូស្ត្រាលី បារាំង ស.រ.អ និងប្រទេសលោកខាងលិចដទៃទៀត។ នៅក្នុងសន្និសីទអន្តរជាតិមួយស្តីអំពីកម្ពុជាដែលបានប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ១៩៨៩ យើងពិនិត្យឃើញថា ប្រទេសជប៉ុនបានលើកឡើងនូវសំណើជុំវិញការបង្កើតគណៈកម្មការអន្តរជាតិមួយសម្រាប់ពង្រឹងការស្តារសេដ្ឋកិច្ចកម្ពុជា។ ប្រទេសជប៉ុន និង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រទេសលោកខាងលិចនានាបានបង្ហាញវិធីសាស្ត្រផ្សេងៗផ្នែកការទូត និង សេដ្ឋកិច្ចក្នុងការស្តារសុខសន្តិភាពក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ប្រទេសទាំងអស់នោះក៏ពុំព្រមចុះញ៉មជាមួយនឹងប្រទេសថៃ និងសិង្ហបុរី ដែលចាប់ផ្តើមបណ្តាក់ទុនក្នុងសេដ្ឋកិច្ចកម្ពុជារួចទៅហើយនោះដែរ។ ដូចគ្នាដែរ គោលជំហររបស់ភាគីកម្ពុជាទាំងអស់លើបញ្ហានេះក៏មិនសូវខុសគ្នានោះដែរ។ យើងយល់ស្របគ្នាលើទស្សនៈថា គួរបើកចំហឱ្យមានការទទួលយកវិនិយោគទុនបរទេស។ ជាងនេះទៀត ថ្នាក់ដឹកនាំរដ្ឋាភិបាលនៃរដ្ឋកម្ពុជាគឺលោក ហ៊ុន សែន នាសម័យកាលនោះក៏បានថ្លែងនៅក្នុងសន្និសីទទីក្រុងប៉ារីសថា «រដ្ឋាភិបាលរបស់យើងស្វាគមន៍ជានិច្ចចំពោះវិនិយោគិនបរទេសមកពីគ្រប់ទិសទី»។[២៥] អនាគតជាមេដឹកនាំក្រុមបក្សប្រឆាំងរបស់រដ្ឋាភិបាលចម្រុះត្រីភាគីក្រោមបូជនីយកិច្ចដឹកនាំរបស់ព្រះបាទសម្តេច នរោត្តម សីហនុ ក៏បានមានព្រះបន្ទូលថា «ប្រទេសលោកខាងលិច ជាពិសេសបារាំង និងជប៉ុនគួរចូលរួមយ៉ាងសកម្មក្នុងដំណើរការស្តារសេដ្ឋកិច្ចកម្ពុជា»។[២៦]

ស្របជាមួយគ្នានេះដែរ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានដែលបានធ្វើឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩៩០ រដ្ឋមន្ត្រីការបរទេសជប៉ុននាពេលនោះក៏បានពោលអំពីការដែលប្រទេសជប៉ុនគួរគប្បីធ្វើអ្វីមួយតាមដែលខ្លួនអាចធ្វើទៅបាន ដើម្បីជួយដល់ការស្តារឡើងវិញនូវសេដ្ឋកិច្ចកម្ពុជា។[២៧] ធនធានមូលធនជប៉ុនក៏មានទិសដៅស្របតាមបំណងខាងលើនេះដែរ។ ហើយក្រោយពី បានចាក់ឫសគល់យ៉ាងរឹងមាំក្នុងតំបន់អាស៊ីអាគ្នេយ៍រួចពាល់ហើយ អ្នកឧស្សាហកម្មជប៉ុនមានបំណងចង់ផ្ទេរសក្តានុពលឧស្សាហកម្មរបស់ខ្លួនទៅមកកាន់ទីនេះ។ មកដល់ទសវត្សទី៨០ ប្រទេសជប៉ុនធ្លាប់បានអនុវត្តនយោបាយយ៉ាងសកម្មរួចមកហើយ ក្នុងការ

[២៥] ឯកសារសន្និសីទអន្តរជាតិស្តីពីកម្ពុជា. ១៩៩០

[២៦] AFP

[២៧] TACC 12 ИЮЛЯ 1990 Г.

ផ្ទេរវិស័យឧស្សាហកម្មដែលប្រើប្រាស់កម្លាំង និងបច្ចេកវិទ្យាទាបចេញពីប្រទេសរបស់ខ្លួនទៅកាន់ប្រទេសជិតខាង រួចបន្ទាប់មក បានផ្ទេរទៅកាន់ក្រុមប្រទេសឧស្សាហកម្មថ្មីៗមួយចំនួនទៀត។ តាមលក្ខណៈនេះ បំណែងចែកពលកម្មតាមខ្សែឈរ ជាញឹកញាប់ តែងតែមានសភាពថមថយជាងខ្សែដេក ពោលគឺមានន័យថា ការនាំចេញទំនិញជាបរិក្ខារបច្ចេកទេសសម្រាប់សហគ្រាសឧស្សាហកម្មទៅក្រៅប្រទេសដែលបម្រើឱ្យវិស័យផលិតកម្មចាំបាច់មួយចំនួនទើបជាការប្រសើរជាង។ ហើយមុនដំបូង យើងគប្បីអភិវឌ្ឍវិស័យវាយនភណ្ឌ ព្រមទាំងវិស័យឧស្សាហកម្មធុនស្រាលផ្សេងៗទៀត បន្ទាប់មក គប្បីផលិតទំនិញឧស្សាហកម្មជាគ្រឿងអេឡិកត្រូនិក និងគ្រឿងម៉ាស៊ីន។ ដូចនេះ នៅកម្ពុជា មូលធនជប៉ុនក៏អាចប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មខ្នាតទាបធៀបទៅនឹងប្រទេសអាស៊ាន។ ម្យ៉ាងវិញទៀត អាស្រ័យដោយល្បឿននៃកំណើនគុណភាពវិស័យឧស្សាហកម្ម និងមូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្របច្ចេកវិទ្យារបស់កម្ពុជាផ្ទាល់ ប្រទេសនេះអាចមានចក្ខុវិស័យក្នុងដំណើរការផលិតគ្រឿងផ្សំឧស្សាហកម្មផ្សេងៗ និងតម្លើងផ្នែកខ្លះៗនៃឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់( ឧទាហរណ៍ ៖ ផលិតគ្រឿងម៉ាស៊ីន ត្រាក់ទ័រ ម៉ូតូ គ្រឿងយន្តកសិកម្ម និងគ្រឿងអេឡិកត្រូនិកជាដើម) ដោយប្រើប្រាស់ទុនវិនិយោគពីប្រទេសជប៉ុន និងលោកខាងលិច។ ចំណែកឯផលប្រយោជន៍ដ៏ធំធេងសម្រាប់អ្នកវិនិយោគ និងអ្នកផ្តល់ហិរញ្ញវត្ថុក្នុងកាលៈទេសៈដែលរដ្ឋាភិបាលបាន និងកំពុងតែប្រកាន់យកនូវមាគ៌ា«គោលនយោបាយបើកទ្វារចំហ»បែបនេះ គឺអាចទាក់ទាញធនាគារិកជប៉ុនបានយ៉ាងច្រើន។ លើសពីនោះទៀត កន្ទ្រងមកប្រទេសជប៉ុនក៏ជាម្ចាស់បំណុលដ៏ធំជាងគេផងដែរ (៣០០ពាន់លានដុល្លារអាមេរិក)។

នៅសម័យកាលនោះដែរ ឧបសគ្គដ៏ធំមួយដែលសាងភាពលំបាកស្មុគស្មាញបំផុតដល់ការវិនិយោគពីបរទេស គឺពាក់ព័ន្ធទៅនឹងបញ្ហាស្ថានភាពហេដ្ឋារចនាសម្ព័ន្ធដ៏សែនអាក្រក់។ នៅប្រទេសកម្ពុជា ដើម្បីទទួលយកនូវ


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការវិនិយោគប្រកបដោយភាពជោគជ័យ ជាការចាំបាច់ ដំបូងយើងគប្បីធ្វើការស្តារឡើងវិញឱ្យបាននូវផ្លូវថ្នល់ និងស្ពានចម្បងសំខាន់ៗដែលផ្តើមចេញតាំងពីរាជធានីភ្នំពេញរហូតទៅទល់នឹងព្រំដែនថៃ(ដែលតាមតម្លៃប៉ាន់ស្មាន គឺត្រូវចំណាយថវិកាប្រមាណជា២៨លានដុល្លារ)[២៨] ត្រូវពង្រីកវិសាលភាពចំណត ឬស្ថានីយឈប់សំចត សម្រាប់ការដឹកជញ្ជូនតាមផ្លូវអយស្ម័យយាន និងពង្រឹងសមត្ថភាពកំពង់ផែភ្នំពេញ និងក្រុងកំពង់សោមៗ ទាក់ទងទៅនឹងការមកដល់ប្រទេសកម្ពុជានាសម័យកាលនោះនៃកងកម្លាំងរក្សាសន្តិភាពជាអន្តរជាតិ និងបេសកកម្មស៊ីវិលរបស់អ.ស.បក្នុងការឃ្លាំមើល និងការប្រព្រឹត្តទៅនៃការបោះឆ្នោតសកល យើងសង្កេតឃើញថា អង្គការអន្តរជាតិនេះក៏មានបំណងចង់ចូលរួមក្នុងការងារស្តារហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តផងដែរ។ លើសពីនេះទៀត ឯកអគ្គរាជទូតនៃប្រទេសអូស្ត្រាលីនៅទីក្រុងបាងកក គឺលោក រ. បាត្វឺរ ក៏បានថ្លែងដែរថា ប្រទេសអូស្ត្រាលីជានិច្ចកាល បានត្រៀមខ្លួនរួចជាស្រេចក្នុងពេលអនាគត ដើម្បីជួយស្តារឡើងវិញនូវវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តចំពោះប្រទេសកម្ពុជា(ពោលគឺជួយកសាងផ្លូវថ្នល់ ស្ពាន និងខ្សែទូរគមនាគមន៍ជាដើម)ដោយប្រើប្រាស់បទពិសោធន៍ និងចំណេះដឹងរបស់ក្រុមការងារមកពីប្រទេសថៃ។[២៩]

សរុបសេចក្តីមក ចំពោះការសិក្សាស្រាវជ្រាវរបស់យើងនៃជំពូកទីបីនេះ យើងអាចធ្វើជាសេចក្តីសន្និដ្ឋានរួមដូចខាងក្រោមនេះ៖

- នៅសម័យកាលនោះ ចំពោះកិច្ចការទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាមាននិន្នាការទៅរកការកាត់បន្ថយការដោះដូរពាណិជ្ជកម្មជាមួយនឹងស.ស.ស.សក៏ដូចជាជាមួយនឹងបណ្តាប្រទេសអឺរ៉ុបខាងកើត។ ទន្ទឹមនឹងនោះដែរ ក៏មានការស្នើឡើងជុំវិញការបង្កើតជាទម្រង់ថ្មីនៃកិច្ចសហប្រតិបត្តិការដែលក្នុងនោះ គឺចង់ឱ្យមានការបង្កើតជាសហគ្រាសរួម

[២៨] FEER, 23.11.1989. p. 19.

[២៩] TACC. 16.09.1989

គ្នា និងការបណ្ដាក់ទុនដោយផ្ទាល់ផងដែរ។ ជាងនេះទៀត ដំណោះស្រាយបញ្ហាបំណុលរវាងប្រទេសកម្ពុជាយើងជាមួយនឹងបណ្ដាប្រទេសខាងលើនេះ គឺជាចំណុចសំខាន់បំផុតសម្រាប់ការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មក្រៅប្រទេស។

- នៅពេលដែលដំណើរការលើការសម្របសម្រួលបញ្ហានយោបាយកម្ពុជាបានឈានដល់ដំណាក់កាលចប់សព្វគ្រប់ យើងនឹងអាចឃើញថាការផ្លាស់ប្ដូរនៃទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាបានងាកទៅរកប្រទេសរីកចម្រើន និងប្រទេសឧស្សាហកម្មថ្មីៗ ជាពិសេស ងាកទៅរកបណ្ដាប្រទេសក្នុងតំបន់អាស៊ាន។ ការដែលអាចបញ្ចប់ជម្លោះដ៏រ៉ាំរ៉ៃបានបើកចក្ខុវិស័យថ្មីដល់ប្រទេសកម្ពុជាក្នុងការទទួលបានការចាប់អារម្មណ៍អំពីការបណ្ដាក់ទុនវិនិយោគ និងការផ្ទេរបច្ចេកវិទ្យាពីសំណាក់ប្រទេសមូលធននិយម។

# សេចក្តីសន្និដ្ឋានរួម

នៅពាក់កណ្តាលទីពីរនៃទសវត្សរ៍ទី៨០ ក្រោមឥទ្ធិពលនៃទស្សនៈនយោបាយ និងសេដ្ឋកិច្ចថ្មី បានធ្វើឱ្យមានការប្រែប្រួលយ៉ាងខ្លាំងលើគ្រប់វិស័យ រួមមានទាំងនៅបណ្តាប្រទេសអាស៊ី-ប៉ាស៊ីហ្វិក និងទាំងនៅប្រទេសអឺរ៉ុបខាងកើតផងដែរ។ ដោយឡែក នៅប្រទេសកម្ពុជាយើងបានចាប់ផ្តើមមានការផ្លាស់ប្តូរពីនិន្នាការនយោបាយឆ្ពោះទៅរកសង្គមនិយម ដោយប្តូរទិសដៅងាកទៅរកទស្សនៈទានថ្មីដែលឈរលើមូលដ្ឋាននៃការទទួលស្គាល់ការពិត ឬភាពជាក់ស្តែង និងទំនាក់ទំនងគ្នាទៅវិញទៅមក។

ក្នុងបរិយាកាសនេះ ពីសំណាក់អ្នកដឹកនាំបក្ស និងអ្នកដឹកនាំរដ្ឋនៃប្រទេសកម្ពុជាបានទាមទារដំណោះស្រាយបញ្ហាថ្មីៗ និងការរៀបចំតាក់តែងមាគ៌ាគោលនយោបាយថ្មីដែលអាចដោះស្រាយធ្វើយ៉ាងណាឱ្យមានស្ថិរភាពនីយកម្មជុំវិញការសម្របសម្រួលផ្នែកនយោបាយរបស់ខ្លួន ដើម្បីរង់ចាំការដោះស្រាយបញ្ចប់ជម្លោះនយោបាយកម្ពុជាដោយមានការចូលរួមពីសំណាក់សហគមន៍អន្តរជាតិ និងពីសង្គមកម្ពុជាខ្លួនឯង។

ក្រោយពីការរលំរលាយទម្រង់រដ្ឋបាលបង្គាប់បញ្ជា«និន្នាការទៅរកសង្គមនិយម» យើងឃើញថា ការពឹងផ្អែកលើទម្រង់នៃទំនាក់ទំនងទំនិញនឹងការដោះដូរជាមួយសាច់ប្រាក់គឺជាវិធីសាស្ត្រមួយដែលប្រកបដោយប្រសិទ្ធភាព និងជាមធ្យោបាយជាក់ស្តែង សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយតួនាទីប្រកបដោយភាពឯករាជ្យរបស់ប្រព័ន្ធធនាគារដែលមានលក្ខណៈសម្បត្តិសព្វគ្រប់ជំនួសឱ្យការគ្រប់គ្រងបែបប្រមូលផ្តុំ ក៏ដូចជាការទាក់ទាញវិនិយោគទុនបរទេសយ៉ាងទូលំទូលាយ និងការកើនឡើងយ៉ាងខ្លាំងនូវវិស័យឯកជន ព្រមទាំងការធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋមួយចំនួនដែលកំពុងទទួលបានការយកចិត្តទុកដាក់ពីសំណាក់គោល-


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលនាសម័យដែលកំពុងគាំទ្រដល់ដំណើរការផ្សះផ្សារជាតិ ទាំងអស់នេះគឺជាអ្វីៗដែលបានកើតមានឡើងនៅសម័យគ្រានោះ។

ក្រោមឥទ្ធិពលនៃសេរីភាវូបនីយកម្មជីវភាពសេដ្ឋកិច្ច យើងអាចកត់សម្គាល់ផងដែរនូវកំណើនតួនាទីនៃនយោបាយសេដ្ឋកិច្ចក្រៅប្រទេសដែលអ្នកដឹកនាំរដ្ឋាភិបាលប្រទេសកម្ពុជានៅសម័យកាលនោះ បាន និងកំពុងតែគិតគូរយ៉ាងសស្រាក់សស្រាំ រួមជាមួយនឹងដំណើរការនយោបាយយោធាជាយុទ្ធសាស្ត្ររួមផ្សំនឹងនយោបាយសេដ្ឋកិច្ចក្នុងស្រុកផងដែរ។

ប៉ុន្តែ ចំពោះការដួលរលំនៃរបបកុម្មុយនីស្តនិយមនៅបណ្តាប្រទេសអឺរ៉ុបនៅខាងកើតបាននាំមកនូវការភ័យខ្លាចចំពោះការបាត់បង់អំណាចក្នុងចំណោមអ្នកដឹកនាំជាន់ខ្ពស់ក្នុងបក្ស និងរដ្ឋដែលនាំឱ្យកើតមានការប្រេះឆាក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋដែលជាក្រុមអភិរក្សនិយម និងក្រុមកំណែទម្រង់។ ដូចនេះហើយ ទាំងកិច្ចការនយោបាយសេដ្ឋកិច្ចក្នុង និងក្រៅប្រទេសសុទ្ធសឹងតែជាកិច្ចការសម្រុះសម្រួលគ្នារវាងក្រុមអភិរក្សនិយម និងក្រុមកំណែទម្រង់។

នៅសម័យកាលនោះ មានការពិនិត្យ និងស៊ើរើជាច្រើនលើគោលគំនិតនយោបាយសេដ្ឋកិច្ចក្រៅប្រទេសកម្ពុជាឱ្យទៅជាការចូលរួមពេញទំហឹងក្នុងបំណែងចែកពលកម្មអន្តរជាតិ។ ប្រទេសកម្ពុជាក៏បានដកខ្លួនចេញពីគោលការណ៍«ទំនាក់ទំនងពិសេស»ក្នុងសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសវៀតណាម និងឡាវ និងដកចេញពីទម្រង់នៃការបង្កើតឥណ្ឌូចិនតែមួយ។

នយោបាយរូបិយប័ណ្ណនៅមានភាពទន់ខ្សោយដោយមានតែភាពផ្ទុយគ្នារវាងគោលបំណង និងសម្ភារ។ ក្នុងលក្ខខណ្ឌដែលប្រទេសកម្ពុជាបានបន្ទាបតម្លៃរូបិយបណ្ណជាតិជាញឹកញយដែលទង្វើបែបនេះ មិនអាចជួយដល់កំណើននាំចេញនោះទេ តែផ្ទុយទៅវិញ បែរជាបង្កើនអតិផរណាក្នុង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្រុក និងបាននាំមកនូវឥទ្ធិពលអាក្រក់ចំពោះសេដ្ឋកិច្ច និងការនាំចេញទៅវិញ។

រួមជាមួយនយោបាយទាក់ទាញវិនិយោគទុនពីបរទេស ក៏មានការផ្តួចផ្តើមរូបភាពអន្តរជាតូបនីយកម្មផលិតកម្មដែលជាប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក៏ប៉ុន្តែបើពុំមានឱកាស ឬអវត្តមានចំពោះការវិនិយោគក្នុងប្រទេសក៏ពុំទាន់មានសញ្ញាណាមួយដល់ការលើកទឹកចិត្តដល់លំហូរទុនវិនិយោគពីបរទេសនោះដែរ។

នៅប្រទេសកម្ពុជាយើងនាសម័យនោះ ត្រូវបានគេយល់ថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសសហភាពសូវៀត និងប្រទេសអឺរ៉ុបខាងកើត មានឥទ្ធិពលយ៉ាងខ្លាំងក្លាលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជា ក្នុងនោះវិស័យកសិកម្ម ឧស្សាហកម្ម គមនាគមន៍ ទូរគមនាគមន៍ វិស័យអប់រំ និងសុខាភិបាលជាដើម។ល។ ក៏ប៉ុន្តែ ទិសដៅនៃកិច្ចសហប្រតិបត្តិការជាចម្បងនោះបានសំដៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមដែលបាននាំមកនូវកំណើនផលិតកម្មដ៏តិចតួច។

ចំពោះទម្រង់នៃចក្ខុវិស័យជុំវិញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសអឺរ៉ុបខាងកើត(រួមបញ្ចូលទាំងស.ស.ស.សផងនោះ) គឺជាទំនាក់ទំនងពាណិជ្ជកម្មដោយប្រើប្រាស់រូបិយប័ណ្ណសេរី(ជាដុល្លារ) ឬដោយការព្រមព្រៀងដោះដូរណាមួយ។

ផ្សេងពីនេះទៀត បញ្ហាបំណុលដែលមិនអាចដោះស្រាយបាន បាននាំមកនូវនិន្នាការកាត់បន្ថយកិច្ចសហប្រតិបត្តិការរបស់កម្ពុជាជាមួយនឹងប្រទេសស.ស.ស.ស និងបណ្តាប្រទេសអឺរ៉ុបខាងកើត ហើយមានការផ្លាស់ប្តូរកាន់តែខ្លាំងឡើងៗជុំវិញទិសដៅទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជាជាមួយនឹងប្រទេសក្នុងតំបន់ និងបណ្តាប្រទេសលោកខាងលិច។

អនាគតនៃការវិវត្តផ្នែកនយោបាយនៅប្រទេសកម្ពុជាដែលទាក់ទងទៅនឹងដំណើរការ និងការវិវត្តនៅតំបន់អាស៊ីអាគ្នេយ៍ និងជុំវិញការដោះ-

ស្រាយបញ្ហាជម្លោះរបស់កម្ពុជា ព្រមទាំងការរក្សានូវតុល្យភាពកម្លាំងនយោបាយក្នុងចំណោមមេដឹកនាំកម្ពុជា អាចនឹងមានជម្រើសពីរ បន្ទាប់ពីមានដំណោះស្រាយពោលគឺ ៖

ទីមួយ ៖ ព្រឹត្តិការណ៍ដ៏រំជើបរំជួលនៅសហភាពសូវៀត និងការរលំរលាយរបបកុម្មុយនីស្តនៅប៉ែកអឺរ៉ុបខាងកើតបានធ្វើឱ្យមានជំនួបរវាងមេដឹកនាំចិន និងវៀតណាម ដើម្បីរឹតចំណងមិត្តភាពដែលមិនធ្លាប់មានជាយូរណាស់មកហើយ។ ជាងនេះទៀត ដើម្បីជួយស្រោចស្រង់«របបកុម្មុយនីស្តនៅកម្ពុជា» បានធ្វើឱ្យប្រទេសចិន និងវៀតណាមអាចរួបរួមគ្នាម្តងទៀត ដើម្បីដោះស្រាយបញ្ហារបស់កម្ពុជា។ ក្នុងករណីនេះ ក្រុមគូប្រជែងផ្នែកនយោបាយទាំងពីរនៅកម្ពុជា គឺក្រុមអ្នកដែលចូលរួមជាមួយ«ខ្មែរក្រហម» និងក្រុមដែលកាន់អំណាចនៅភ្នំពេញ និងត្រូវបានបង្ខំឱ្យចាប់ដៃគ្នាក្រោមសម្ពាធរបស់គ្រូដឹកនាំរបស់ខ្លួន មានវៀតណាម និងចិន។ ហើយគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជានឹងមានទិសដៅទៅរកប្រទេសតណ្ហចិន និងសាធារណរដ្ឋប្រជាមានិតចិនក្នុងករណីបែបនេះ។

ទីពីរ ៖ នៅតំបន់អាស៊ីអាគ្នេយ៍ នឹងមានការប្រែប្រួលផែនទីនយោបាយដែលទាក់ទងទៅនឹងសម្ព័ន្ធភាពផ្សេងៗក្រោយការដួលរលំរបប ប៉ុល ពតនៅឆ្នាំ១៩៧៩។ បម្លាស់ប្តូរទំនាក់ទំនងសេដ្ឋកិច្ចនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ការចុះខ្សោយឥទ្ធិពលរបស់ប្រទេសចិននៅក្នុងតំបន់ កំណើនហិរញ្ញវត្ថុដ៏ខ្លាំងក្លារបស់ជប៉ុន កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់ប្រទេសឧស្សាហកម្មថ្មីៗនៅអាស៊ី និងបម្រែបម្រួលថ្មីនៃទិសដៅការទូតរបស់សូវៀតដែលទាំងអស់នេះគឺជាយន្តការដែលនាំមកនូវដំណើរការថ្មីៗតទៅទៀត នឹងកើតមានការវិលត្រលប់ទៅរកនយោបាយសេដ្ឋកិច្ចក្រៅប្រទេសជាមួយនឹងប្រទេសក្នុងតំបន់ដែលប្រហែលជាអាចមានសេណារីយ៉ូដូចតទៅ។ ទីមួយ ៖ គឺកម្ពុជាអាចក្លាយជាប្រទេសអព្យាក្រឹតដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងបណ្តាប្រទេសសមាជិកអាស៊ាន។ ទីពីរ ៖ គឺកម្ពុជាអាចចូលរួមតែក្នុង


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កិច្ចការផ្នែកសេដ្ឋកិច្ចជាមួយអង្គការនៃប្រទេសអាស៊ាន និងទីបី ៖ គឺការចូលរួមពេញទំហឹងរបស់កម្ពុជាក្នុងទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន ដោយប្រើប្រាស់គោលការណ៍នយោបាយក្រៅប្រទេសស្របតាមជំហរអព្យាក្រឹតភាពរបស់ខ្លួន។ ការជ្រើសរើសយកតាមមាគ៌ាអភិវឌ្ឍន៍បែបណាមួយនោះ គឺអាស្រ័យទៅនឹងលក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយក្នុងប្រទេស និងក្រៅប្រទេសរបស់ខ្លួន។

# បណ្ឌិត ហង់ជួន ណារ៉ុន

*បណ្ឌិត **ហង់ជួន ណារ៉ុន** បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៥នៃរាជរដ្ឋាភិបាលកម្ពុជា។*

*លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពីវិទ្យាស្ថានធានារ៉ាប់រង(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី(MII) នៅឆ្នាំ២០០៨។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិតសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។*

*លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។*

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្ដាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះ លោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្ដាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ **សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសិទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្ដីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy: Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ«កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព»។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្នាដៃរបស់អ្នកនិពន្ធ

1- Hang Chuon Naron—L'Économie du Cambodge : La lutte pour le développement, Phnom Penh, 2005

2- Hang Chuon Naron—Essais économiques, Phnom Penh, 2007

3- Hang Chuon Naron et Patrick Gilbert-Desvallons—Les finances publiques du Cambodge, Phnom Penh, 2007

4- Hang Chuon Naron—Cambodia: Recent Macroeconomic and Financial Sector Development, Phnom Penh, 2008

5- Hang Chuon Naron—Three Essays on Macroeconomic Management of Cambodia, Phnom Penh, 2008

6- Hang Chuon Naron—Introduction to Insurance, Phnom Penh, 2008

7- ហង់ជួន ណារ៉ុន — ម៉ាក្រូសេដ្ឋកិច្ច ភ្នំពេញ គ្រឹស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ២០០៩

8- Hang Chuon Naron and Patrick Gilbert-Desvallons—Public Finance in Cambodia, Phnom Penh: Preah Vihear Editions, 2009

9- ហង់ជួន ណារ៉ុន និង ហ្ស៊ីលប៊ែ ដឺវ៉ាល់ឡុង — ហិរញ្ញវត្ថុសាធារណៈ ភ្នំពេញ គ្រឹស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ២០០៩

10- ហង់ជួន ណារ៉ុន — ប្រាសាទព្រះវិហារ ភ្នំពេញ គ្រឹស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ២០០៩


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

11- Hang Chuon Naron—Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, Phnom Penh: Preah Vihear Editions, 2009

12- Hang Chuon Naron—L'économie du Cambodge: Nouvelles frontières du développement socio-économique, Phnom Penh: Preah Vihear Editions, 2010

13- Hang Chuon Naron—Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, Phnom Penh: Preah Vihear Editions, 2012

14- *ហង់ជួន ណារ៉ុន — ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និង ថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ២០១៣*

15- *ហង់ជួន ណារ៉ុន — សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត ភ្នំពេញ គ្រឹស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ២០១៥*

16- *ហង់ជួន ណារ៉ុន — កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ភ្នំពេញ គ្រឹស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ២០១៦*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia